


# សេរីភាពខាងការបញ្ចេញមតិនៅកម្ពុជា៖
# ប្រជាធិបតេយ្យថ្លិនភ្នែក

របាយការណ៍ លីកាដូ
ខែធ្នូ ឆ្នាំ២០១០

លីកាដូ
LICADHO

សម្ព័ន្ធខ្មែរជំរឿននិងការពារសិទ្ធិមនុស្ស លីកាដូ
**LICADHO**
Cambodian League for the
Promotion and Defense of Human Rights

# សេរីភាពខាងការបញ្ចេញមតិនៅកម្ពុជា
# ប្រជាធិបតេយ្យផ្តិនភ្នែក

---

របាយការណ៍លីកាដូ
ខែធ្នូ ឆ្នាំ២០១០


សម្ព័ន្ធខ្មែរជំរឿននិងការពារសិទ្ធិមនុស្ស លីកាដូ

**LICADHO**

CAMBODIAN LEAGUE FOR THE PROMOTION
AND DEFENSE OF HUMAN RIGHTS

## សម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស លីកាដូ

លីកាដូ គឺជាអង្គការសិទ្ធិមនុស្សជាតិមួយនៅកម្ពុជា។ ចាប់តាំងពីអង្គការលីកាដូ ត្រូវបានបង្កើតឡើងនៅឆ្នាំ១៩៩២ អង្គការនេះ គឺជាអង្គការស្ថិតនៅជួរមុខគេក្នុងកិច្ចការពារសិទ្ធិមនុស្សនៅកម្ពុជា និងលើកស្ទួយការគោរពសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយតាមរយៈរាជរដ្ឋាភិបាលកម្ពុជា និងស្ថាប័ននានា។ ការកសាងសមិទ្ធិផលរបស់ខ្លួនក្នុងអតីតកាល **លីកាដូ** បានបន្តដើរតួជាអ្នកតស៊ូមតិ សម្រាប់ប្រជាពលរដ្ឋ និងឃ្លាំមើលរដ្ឋាភិបាលតាមរយៈ កម្មវិធីសិទ្ធិមនុស្សនានាពីការិយាល័យកណ្ដាលរបស់ខ្លួននៅភ្នំពេញ និងនៅតាមសាខាទូទាំង១២ ខេត្ត-ក្រុងផ្សេងទៀត។

**អង្គការលីកាដូអនុវត្តសកម្មភាពរបស់ខ្លួនតាមរយៈកម្មវិធីធំៗពីរ:**
**កម្មវិធីឃ្លាំមើល និងការពារសិទ្ធិមនុស្ស:**

- **ឃ្លាំមើលការរំលោភសិទ្ធិមនុស្សដែលប្រព្រឹត្តដោយបុគ្គលរបស់រដ្ឋ លើការរំលោភសិទ្ធិស្ត្រី និងការរំលោភសិទ្ធិកុមារ:** បុគ្គលិកធ្វើការស៊ើបអង្កេតលើករណីរំលោភសិទ្ធិមនុស្ស ដែលប្រព្រឹត្តដោយបុគ្គលរបស់រដ្ឋ ចំពោះការរំលោភបំពានលើស្ត្រី និងកុមារ ហើយជនរងគ្រោះត្រូវបានផ្ដល់សេវាជួយជ្រោមជ្រែងតាមរយៈការធ្វើអន្តរាគមន៍ជាមួយអាជ្ញាធរមូលដ្ឋាន។

- **ការប្រឹក្សាផ្នែកច្បាប់ និងកិច្ចការពារផ្នែកច្បាប់:** ជនរងគ្រោះត្រូវបានផ្ដល់ជូននូវការប្រឹក្សាផ្នែកច្បាប់ ហើយចំពោះករណីសំខាន់ៗ ទទួលបាននូវកិច្ចការពារផ្នែកច្បាប់ ដែលផ្ដល់ជូនដោយក្រុមប្រឹក្សាផ្នែកច្បាប់ និងក្រុមមេធាវីការពារសិទ្ធិមនុស្ស។

- **ការឃ្លាំមើលពន្ធនាគារ:** អ្នកស្រាវជ្រាវពន្ធនាគារធ្វើការឃ្លាំមើលពន្ធនាគារចំនួន១៨ ដើម្បីធ្វើការវាយតម្លៃអំពីស្ថានភាពនៅក្នុងពន្ធនាគារ និងដើម្បីធានាថាពិរុទ្ធជនទទួលបាននូវតំណាងផ្នែកច្បាប់។

- **ជំនួយផ្នែកវេជ្ជសាស្ត្រ:** ក្រុមគ្រូពេទ្យផ្ដល់សេវាវេជ្ជសាស្ត្រដល់អ្នកទោស និងមន្ត្រីពន្ធនាគារចំនួន១២កន្លែង។ បន្ថែមពីលើនេះ ក៏ជួយផ្ដល់សេវាវេជ្ជសាស្ត្រ និងបញ្ជូនជនរងគ្រោះដោយការរំលោភសិទ្ធិមនុស្សទៅកាន់មន្ទីរពេទ្យ។

**កម្មវិធីទំនាក់ទំនង និងការទាក់ទាញមតិគាំទ្រ:**

- **ការហ្វឹកហ្វឺនសហគមន៍ អប់រំ និងការតស៊ូមតិ:** អ្នកហ្វឹកហ្វឺន និងអ្នកតស៊ូមតិធ្វើការអប់រំដល់ សាធារណៈជន អំពីសិទ្ធិស្ត្រី និងសិទ្ធិកុមារ បង្កើតបណ្ដាញការពារនៅតាមមូលដ្ឋាន និងធ្វើការតស៊ូមតិ ដើម្បីឲ្យមានការផ្លាស់ប្ដូរសង្គម និងច្បាប់។

- **ការតស៊ូមតិជាសាធារណៈ និងតាមសហគមន៍:** ករណីរំលោភសិទ្ធិមនុស្សដែលស៊ើបអង្កេតដោយ លីកាដូ ត្រូវបានចងក្រងទុកនៅក្នុងប្រព័ន្ធទិន្នន័យដើម្បីឲ្យមានភាពងាយស្រួលក្នុងការស្វែងរកព័ត៌មាន វិភាគផលិតជារបាយការណ៍ជាប្រចាំ (ការបោះពុម្ពជារបាយការណ៍ និងរបាយការណ៍សោតទស្សន៍)។

**ចំពោះព័ត៌មានបន្ថែមសូមទាក់ទង**

លោកស្រីវេជ្ជបណ្ឌិត ពុង ឈីវកេក ប្រធានអង្គការលីកាដូ
អាសយដ្ឋានៈ អង្គការលីកាដូ (សម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស)
ផ្ទះលេខ ១៦ ផ្លូវលេខ ៩៩ រាជធានីភ្នំពេញ កម្ពុជា
ទូរស័ព្ទៈ (៨៥៥) ២៣ ៧២៧ ១០២/៣៦៤ ៩០១ ទូរសារៈ (៨៥៥) ២៣ ៧២៧ ១០២/២១៧ ៦២៦
អ៊ីម៉ែលៈ contact@licadho-cambodia.org គេហទំព័រ http://www.licadho-cambodia.org/

# មាតិកា


**សេចក្តីផ្តើម ............................................................................ ១**

**១. អំពីរបាយការណ៍នេះ ............................................................................ ៤**

ចំណាត់ប្រភេទករណី ---------------------------------------------------------------------- ៤

**២. ការរំខានដល់ការជួបប្រជុំជាសាធារណៈដោយសន្តិវិធី ............................................................................ ៧**

ករណីសិក្សា ១៖ អ្នកភូមិដីក្រែងធ្វើដំណើរផ្លូវវែងឆ្ងាយ និងលទ្ធផលទទួលបានក្រោយមក ------------------------------ ៧

ការបង្ក្រាបដោយមានការចាត់តាំង: ពីភាពព្រៃផ្សៃទៅការរំលោភសមត្ថកិច្ចធ្ងន់ធ្ងរតាមបែបការិយាធិបតេយ្យ -------- ១១

**៣. ការប្រើប្រាស់ប្រព័ន្ធតុលាការគំរាមកំហែង និងបំបិទមាត់អ្នករិះគន់ ............................................................................ ២៧**

ករណីសិក្សា ១៧៖ លាង សុខជឿន: ការបង្ក្រាបអ្នកនាំសំបុត្រ ---------------------------------------------------------------------- ២៧

ការដាក់ទម្ងន់: តុលាការជាអាវុធអយុត្តិធម៌ ---------------------------------------------------------------------- ៣០

**៤. ការគំរាមកំហែងក្រៅផ្លូវតុលាការ ការវាយប្រហារ និងការសំលាប់ ............................................................................ ៤៤**

ករណីសិក្សា ២៦៖ ពេជ្រ សុភ័ណ: ស្លាប់ព្រោះតែដីធ្លីក្នុងខេត្តបាត់ដំបង ---------------------------------------------------------------------- ៤៤

ការស្លាប់-ចប់ការស៊ើបអង្កេត និងនិទណ្ឌភាព ---------------------------------------------------------------------- ៤៥

**៥. ការគំរាមកំហែងផ្នែកនយោបាយ ............................................................................ ៥២**

ករណីសិក្សា ៣៥៖ ហូ វ៉ាន់ -ញុះញង់អោយប្រជាពលរដ្ឋបាត់បង់ឧត្តមគតិ' ---------------------------------------------------------------------- ៥២

អស់ទីកន្លែងសំរាប់ការធ្វើនយោបាយ ---------------------------------------------------------------------- ៥៥

**៦. ការគំរាមកំហែងផ្នែកការទូត ............................................................................ ៦៦**

ករណីសិក្សា ៤៦: ប្រទេសកម្ពុជា- 'យើងមិនមែនជាបាណាណា រិផាប្លិក [ Banana Republic]' ------------------------- ៦៦

យកនំពីគេមកហូប ដោយមិនអោយលុយគេ ---------------------------------------------------------------------- ៦៧

**៧. ករណីអ្នកសារព័ត៌មានជម្រិតទារប្រាក់ ............................................................................ ៧៣**

ការបង្ក្រាបសកម្មភាពកាប់ឈើខុសច្បាប់ ---------------------------------------------------------------------- ៧៣

បង្ក្រាបអ្នករាយការណ៍ ---------------------------------------------------------------------- ៧៧

**៨. សេចក្តីសន្និដ្ឋាន និងអនុសាសន៍ ............................................................................ ៨៦**

អនុសាសន៍ ---------------------------------------------------------------------- ៨៨

ឧបសម្ព័ន្ធ១៖ បទបញ្ញត្តិ និងច្បាប់ព្រហ្មទណ្ឌ និងនីតិវិធីព្រហ្មទណ្ឌអនុវត្តក្នុងសម័យអន្តរកាល (ច្បាប់ព្រហ្មទណ្ឌ អន្តរកាល) ត្រូវបានប្រើដើម្បីដាក់កម្រិតលើសេរីភាព ក្នុងការបញ្ចេញមតិ ............................................................................ ៨៩

ឧបសម្ព័ន្ធ ២៖ បទបញ្ញត្តិនៃក្រមព្រហ្មទណ្ឌថ្មីដែលអាចត្រូវបានប្រើដើម្បីដាក់កម្រិតលើសេរីភាពក្នុងការបញ្ចេញមតិ...... ៩៥

*ជាតិមួយដែលភ័យខ្លាច ដើម្បីអនុញ្ញាតអោយប្រជាពលរដ្ឋរបស់ខ្លួនវិនិច្ឆ័យការពិត និងការមិនពិតដោយចំហរ និងជាសាធារណៈ គឺជាជាតិមួយដែលភ័យខ្លាចចំពោះប្រជាពលរដ្ឋខ្លួនឯង ។* - ចន អេហ្វ.កេណេឌី

# សេចក្តីផ្តើម

នៅក្នុងតំបន់ដាច់ស្រយាលមួយនៃខេត្តសៀមរាប គឺជាភូមិដែលប្រជាពលរដ្ឋចំនួន ២០០ គ្រួសារបានបាត់បង់ដីធ្លី។ រដ្ឋាភិបាលក្នុងនាមផលប្រយោជន៍អោយឈ្មួញ ដែលមានខ្នងបង្អែកយ៉ាងរឹងមាំមួយបានរឹបអូសយកដីពីប្រជាពលរដ្ឋ។ អ្នកភូមិចំនួន ១២នាក់ ត្រូវបានគេចាប់ដាក់ពន្ធនាគារ ចំពោះការតស៊ូការពារដីធ្លី និងអ្នកភូមិខ្លះទៀត ដោយសារតែចង់ចូលរួមក្នុងសវនាការ។ ក្រុមនគរបាលប្រដាប់ដោយអាវុធស្វ័យប្រវត្តិបានដឹងអំពីផែនការរបស់អ្នកភូមិ ហើយក៏ធ្វើការឡោមព័ទ្ធភូមិ។ អាជ្ញាធរក្រោយមកព្យាយាមចាប់ផ្សឹកព្រះសង្ឃក្នុងពុទ្ធសាសនា ហើយដែលជាអ្នកតស៊ូការពារបុព្វហេតុរបស់អ្នកភូមិ។

នៅខេត្តតាកែវ បុរសបួននាក់ត្រូវបានជាប់ចោទ ដោយគ្មានភស្តុតាងទាក់ទងនឹងការចែកចាយខិតប័ណ្ណនយោបាយរិះគន់ការជាប់ពាក់ព័ន្ធជាប្រវត្តិសាស្ត្ររបស់ប្រទេសវៀតណាម ជាមួយប្រទេស កម្ពុជា។ មន្ត្រីវៀតណាមមកធ្វើទស្សនកិច្ចនៅកម្ពុជា ហើយបានស្នើសុំជាសាធារណៈ ឲ្យរាជរដ្ឋាភិបាលកម្ពុជាបង្ក្រាបសកម្មភាពនានា ដែលរិះគន់ដល់ទំនាក់ទំនងល្អរវាងប្រទេសទាំងពីរ។ បួនសប្តាហ៍ក្រោយមក បុរសបីនាក់ក្នុងចំនោមពួកគេបួននាក់ ត្រូវបានកាត់ទោសអោយជាប់ពន្ធនាគារម្នាក់ៗចំនួន ២ឆ្នាំ និងប្រាក់ពិន័យចំនួន ២លានរៀល។ ចៅក្រមយល់ឃើញថា ការសម្តែងមតិយោបល់ខាងនយោបាយរបស់ពួកគេបណ្តាលអោយកើតកោលាហលដល់ "សន្តិសុខ សាធាណៈ"។

នៅភូមិឆ្ងាយមួយក្នុងខេត្តបាត់ដំបង អ្នកចងក្រងសហគមន៍ម្នាក់ត្រូវបានសំលាប់ ដោយខ្មាន់កាំភ្លើងអាកា៤៧ មិនស្គាល់មុខចំនួនបួននាក់។ បុរសរងគ្រោះ បានរៀបចំសហគមន៍របស់គាត់ដើម្បីរកដំណោះស្រាយចំពោះបញ្ហាទំនាស់ដីធ្លីដែលមានរយៈពេលដ៏យូរមួយពាក់ព័ន្ធជាមួយយោធា។ គាត់ទើបតែត្រលប់មកពីដើរប្រមូលស្នាមមេដៃពីអ្នកភូមិ ពីព្រោះពួកគេមានផែនការដាក់ពាក្យបណ្តឹង។ ជនប្រព្រឹត្តបទឧក្រិដ្ឋក្នុងករណីនេះមិនទាន់ត្រូវបានចាប់ខ្លួននៅឡើយ។

នៅរាជធានីភ្នំពេញ តំណាងរាស្ត្រមកពីគណបក្សជំទាស់ បានរិះគន់ពីលក្ខណៈសម្បត្តិមន្ត្រីយោធាចំនួន ២២រូប។ អភ័យឯកសិទ្ធិសភារបស់គាត់ ត្រូវបានដកហូតយ៉ាងបន្ទាន់ ហើយគាត់ត្រូវបានចោទប្រកាន់ពីបទព្រហ្មទណ្ឌបរិហារកេរ្តិ៍។ អ្នកសារព័ត៌មានពីរនាក់ ដែលចុះផ្សាយបទអត្ថាធិប្បាយនេះ ក្នុងអត្ថបទសារព័ត៌មានរបស់ខ្លួនក៏រងការចោទប្រកាន់ផងដែរ។ តំណាងរាស្ត្ររូបនេះ បានរួចផុតពីការចោទប្រកាន់ ប៉ុន្តែគាត់ស្ទើរតែជាប់ខ្លួននៅក្នុងបណ្តឹងបរិហារកេរ្តិ៍មួយផ្សេងទៀត បន្ទាប់ពីគាត់ រិះគន់អ្នកតំណាងរាស្ត្រជាន់ខ្ពស់ម្នាក់។

ក្នុងដំណើរឆ្ពោះទៅរកការអនុម័តច្បាប់ថ្មី គឺច្បាប់ប្រឆាំងអំពើពុករលួយ ប្រធានរបស់អង្គការសហប្រជាជាតិអំពាវនាវអោយមានដំណើរការប្រកបដោយ "តម្លាភាព"។ រាជរដ្ឋាភិបាលបានឆ្លើយតបវិញ ដោយការគំរាមបណ្តេញប្រធានអង្គការសហប្រជាជាតិរូបនេះចេញពីប្រទេស។ ប៉ុន្មានសប្តាហ៍ក្រោយមក ក្រសួង

ការបរទេសផ្ញើលិខិតគ្រើនរំលឹកទៅគ្រប់បេសកកម្មការទូតទាំងអស់ ដែលក្នុងលិខិតនោះសរសេរថា៖ កុំជ្រៀតជ្រែកចូលក្នុងកិច្ចការផ្ទៃក្នុងរបស់យើង។ "ប្រទេសកម្ពុជា មិនមែនជាបាណាណារិផាប្លិក [BANANA REPUBLIC] ទេ!"។

ចំណែកឯយុទ្ធនាការពាសពេញផ្ទៃប្រទេស និងប្រកបដោយការឃោសនាយ៉ាងខ្លាំងក្លាប្រឆាំងនឹងសកម្មភាពកាប់ឈើខុសច្បាប់ ប្រព្រឹត្តឡើងទន្ទឹមពេលនឹងការចាប់ខ្លួនអ្នកសារព័ត៌មាន យ៉ាងហោចណាស់ក៏១៦នាក់ដែរ។ ពួកគេត្រូវបានចោទប្រកាន់ថា បានព្យាយាមជំរិតទារប្រាក់ពីឈ្មួញឈើ ហើយដែលក្នុងស្ថានភាពខ្លះ ការចោទប្រកាន់ទាំងនោះត្រឹមត្រូវតាមច្បាប់ ប៉ុន្តែការចាប់ខ្លួន និងការនាំយកមកកាត់ទោសនូវឈ្មួញឈើខុសច្បាប់វិញ មានការព្រងើយកន្តើយ។

ស្ថានភាពមិនស៊ីសង្វាក់គ្នាប្រហាក់ប្រហែលគ្នាទាំងនេះ មិនមែនជាឧប្បត្តិហេតុដាច់ដោយឡែកនោះទេ គឺវាមាននៅគ្រប់ទិសទីទាំងអស់ក្នុងប្រទេស។ ក្នុងរយៈពេល ៦ខែ ដែលគ្របដណ្តប់ក្នុងរបាយការណ៍នេះ អង្គការលីកាដូ បានសរសេរចងក្រងករណីចំនួនជិត ៥០ករណី ទាក់ទងនឹងការរំលោភសិទ្ធិបញ្ចេញមតិនៅក្នុងប្រទេសកម្ពុជា។ ករណីទាំងអស់នេះ មានលំនាំដូចគ្នា ហើយភាពដូចគ្នានៃករណីទាំងនេះមិនមែនកើតឡើងដោយចៃដន្យទេ។ លំនាំដូចគ្នាទាំងនេះ ជាសញ្ញាសំគាល់នៃការបង្ក្រាបជាប្រព័ន្ធ។

គោលដៅនៃការបង្ក្រាប គឺមានចាប់ពីក្នុងចំនោមមេដឹកនាំសហគមន៍ដល់តំណាងសហជីព និងអ្នកនយោបាយពីគណបក្សជំទាស់ ហើយមិនតែប៉ុណ្ណោះនរណាដែលហ៊ាននិយាយប្រឆាំងចំពោះផលប្រយោជន៍នៃក្រុមអ្នកកាន់អំណាចត្រូវស្ថិតក្នុងស្ថានភាពគ្រោះថ្នាក់។ ដោយសារតែរាជរដ្ឋាភិបាលមានអំណាចរឹងមាំខ្លាំង រាជរដ្ឋាភិបាលរឹតតែបង្កើនការមិនអត់អោនរបស់ខ្លួនចំពោះមតិរិះគន់ និងប្រធានបទកាន់តែច្រើនឡើងៗ ត្រូវបានហាមឃាត់ ហើយបរិយាកាសសំរាប់មតិជំទាស់កំពុងតែខ្សត់ខ្សោយទៅៗ។ លទ្ធផលនៅទីបំផុត គឺប្រជា-ពលរដ្ឋកម្ពុជាត្រូវបានរារាំងពីការចូលរួមក្នុងប្រជាធិបតេយ្យរបស់ខ្លួនដោយខ្លួនឯង។

វិធីសាស្ត្រនៃការបង្ក្រាបប្រែប្រួល ប៉ុន្តែមិនច្រើនពេកទេ។ របៀបបង្ក្រាបយ៉ាងគ្រោតគ្រាតដូចជា ការគំរាមសំលាប់ ការយាយីលើរាងកាយ និងការបំភិតបំភ័យនៅតែមានជាទូទៅ។ ការតវ៉ាជាសាធារណៈនានាអាចទទួលការឆ្លើយតបបែបឃោរឃៅប្រហាក់ប្រហែលគ្នា។ អ្នកចូលរួមតវ៉ានៅពាសពេញប្រទេសជាញឹកញាប់នៅតែរងការវាយដំ ការឃាត់ដំណើរមិនអោយទៅដល់ទីកន្លែងតវ៉ា រងការប្រឆាំងតបវិញ ឃាត់ខ្លួន និងចាប់យកចេញដោយបង្ខំ។

ប៉ុន្តែភាគច្រើន វិធីសាស្ត្រដែលអាជ្ញាធរចូលចិត្តប្រើបំផុតគឺ របៀបយកច្បាប់មកបិទបាំង ឬប្រើច្បាប់ជាអាវុធ។ ការអនុញ្ញាតសំរាប់បាតុកម្ម ដែលអាជ្ញាធរមិនពេញចិត្ត ត្រូវបានបដិសេធដោយហេតុផលមិនស្មោះត្រង់។ ប្រជាពលរដ្ឋដែលហ៊ាននិយាយពីប្រធានបទមានលក្ខណៈរសើប អាចត្រូវបាននាំយកមកកាត់ទោសចំពោះរឿងអ្វីមួយ ដែលមានចាប់តាំងពីបទបរិហារកេរ្តិ៍ហូតដល់បទប្លន់ ហើយមតិយោបល់ជំទាស់បែបនយោបាយត្រូវបានចាត់ទុកថាជា ការគំរាមកំហែងដល់សន្តិសុខជាតិ។ ទន្ទឹមពេលជាមួយគ្នានេះ តុលាការដែលទទួលឥទ្ធិពលពីផ្នែកប្រតិបត្តិយ៉ាងមុតមាំនឹងធានាថា ជនជាប់ចោទដែលជាគោលដៅនៃការបង្ក្រាប

របស់អាជ្ញាធរមិនមានឱកាសនៅក្នុងដំណើរការសវនាការត្រឹមត្រូវទេ។

សេរីភាពក្នុងការបញ្ចេញមតិ មានការចាំបាច់ណាស់សំរាប់ការប្រព្រឹត្តិទៅដ៏ត្រឹមត្រូវ នៃលទ្ធិប្រជាធិប-តេយ្យ។ សេចក្តីថ្លែងនេះ ប្រហែលជាជាក់ស្តែងដោយមិនចាំបាច់មានភស្តុតាងណាមួយយកមកបញ្ជាក់អះអាង ប៉ុន្តែភាពសមហេតុផលនៃសេចក្តីថ្លែងនេះគឺ ការដឹង និងមើលឃើញពីដំណើរការដដែលៗរបស់វា៖ ប្រជាធិបតេយ្យ គឺអាស្រ័យលើប្រជាពលរដ្ឋគ្រប់គ្រងរដ្ឋរបស់ខ្លួនដោយខ្លួនឯង។ សំរាប់ប្រព័ន្ធប្រជាធិបតេយ្យមួយដំណើរការទៅយ៉ាងត្រឹមត្រូវ វាត្រូវការការចូលរួមពីប្រជាពលរដ្ឋយ៉ាងពេញលេញ និងដោយគ្មានការដាក់កំហិត។

"ការចូលរួម" គឺមិនមែនមានត្រឹមតែជាសកម្មភាពសាមញ្ញនៃការបោះឆ្នោតទេ។ ការដាក់កំហិតលើលំហូរនៃព័ត៌មាន និងមតិយោបល់ដោយសេរី ត្រូវតែមានកំរិតអប្បរមាបំផុតដើម្បីអោយអ្នកបោះឆ្នោតទទួលបានព័ត៌មាន។ អ្នកបោះឆ្នោត ត្រូវតែបានអនុញ្ញាតអោយសំដែងចេញនូវសេចក្តីសង្ឃឹម និងបំណងប្រាថ្នារបស់ខ្លួន ដោយគ្មានការភ័យខ្លាចពីការចោទប្រកាន់តបវិញ ដូច្នេះវានឹងនាំផ្លូវអ្នកតំណាងជាប់ឆ្នោតតាមបែបប្រជាធិបតេយ្យរបស់ខ្លួនក្នុងការធ្វើសេចក្តីសំរេចនានា។ អ្នកបោះឆ្នោត ត្រូវតែមានលទ្ធភាពដើម្បីរិះគន់រៀបចំជួបប្រជុំ ធ្វើដំណើរ ធ្វើញត្តិ និងនៅទីបំផុតមានឥទ្ធិពលលើសេចក្តីសំរេចចិត្តរបស់រដ្ឋាភិបាល ដែលខ្លួនបានបោះឆ្នោតអោយ។

បើគ្មានសិទ្ធិទាំងអស់នេះទេ ការបោះឆ្នោតទៅជាសកម្មភាពបរាជ័យ និងមិនទំនង លើសពីនេះលទ្ធិប្រជាធិបតេយ្យគ្រាន់តែជាពិធីការប្រថាប់ត្រា សំរាប់អាជ្ញាធរដែលត្រួតត្រានយោបាយបោកប្រាស់ប្រជាពលរដ្ឋតែប៉ុណ្ណោះហើយអាចនិយាយម្យ៉ាងទៀតថា គំនិតប្រជាធិបតេយ្យទៅជារឿងថ្មិនភ្នែក។

□□□

# ១. អំពីរបាយការណ៍នេះ

របាយការណ៍នេះចងក្រងករណី ស្តីអំពីស្ថានភាពថ្មីៗនៃសេរីភាពខាងការបញ្ចេញមតិនៅកម្ពុជា[១]។ ជនរងគ្រោះនៃករណីទាំងអស់នេះមកពីគ្រប់ទិសទីក្នុងប្រទេសកម្ពុជា និងពីគ្រប់ជីវភាពសង្គមពួកគេគឺជា អ្នកនយោបាយ បុគ្គលិកអង្គការមិនមែនរដ្ឋាភិបាល សាស្ត្រាចារ្យ អ្នកសារព័ត៌មាន តំណាងសហគមន៍ និងប្រជាពលរដ្ឋសាមញ្ញ។ អ្វីដែលពួកគេមានដូចគ្នានោះគឺអជ្ញាធររដ្ឋាភិបាល បានធ្វើអោយបរាជ័យដល់កិច្ចខិតខំប្រឹងប្រែងអនុវត្តសេរីភាពខាងការបញ្ចេញមតិរបស់ពួកគេ - សិទ្ធិរបស់ពួកគេក្នុង**ការរៀបចំ ជួបប្រជុំ ធ្វើដំណើរ និយាយស្តី ធ្វើញត្តិ និងមានឥទ្ធិពលលើសេចក្តីសំរេចចិត្តនានារបស់រដ្ឋាភិបាល**។

ករណីទាំងអស់នេះទទួលបានក្នុងរយៈពេល ៦ខែ នៃឆ្នាំ២០១០ (ខែមេសា ដល់ ខែកញ្ញា) ជារយៈពេលដែលអង្គការលីកាដូ ធ្វើការពិនិត្យតាមដានយ៉ាងល្អិតល្អន់នូវសារព័ត៌មានជាភាសាខ្មែរ និងភាសាអង់គ្លេស។ ចំនួនភាគច្រើននៃព្រឹត្តិការណ៍ ដែលមានចងក្រងក្នុងរបាយការណ៍នេះ ត្រូវបានផ្សព្វផ្សាយលើសារព័ត៌មាននានាក្នុងកំឡុងពេលនេះ[២]។ ក្រៅពីនេះករណីផ្សេងទៀតគឺ ផ្អែកលើការស៊ើបអង្កេតស្រាវជ្រាវដោយអង្គការលីកាដូផ្ទាល់។

មិនមានអ្វីប្លែកជាពិសេសអំពីរយៈពេល ៦ខែនេះទេ - មិនមានការបោះឆ្នោត ជម្លោះប្រដាប់អាវុធ ឬគ្រោះអាសន្នជាតិទេ។ យើងជឿថា ការផ្តោតតែលើរយៈពេលខ្លីអាចបង្ហាញអោយឃើញពីទំហំបញ្ហានៃសេរីភាពខាងការបញ្ចេញមតិរបស់ប្រទេសកម្ពុជា។ លទ្ធផលទទួលបានពីការងារនេះ មិនមានអ្វីជាការគួរជម្រុញទឹកចិត្តទាល់តែសោះ៖ ត្រឹមតែរយៈពេល ៦ខែ នៃការងារពិនិត្យតាមដាន យើងចងក្រងបាននូវករណីចំនួនជិត ៥០ ដែលនឹងបង្ហាញក្នុងរបាយការណ៍នេះ។

### *ចំណាត់ប្រភេទករណី*

មានការលំបាកដើម្បីដាក់ទៅតាម "ប្រភេទ" អោយបានរៀបរយនៃករណីរំលោភសេរីភាពខាងការបញ្ចេញមតិ។ គំនិតអំពីសេរីភាពខាងការបញ្ចេញមតិរួមមាន សិទ្ធិផ្សេងៗមួយចំនួន -និយាយស្តី ជួបប្រជុំ ធ្វើដំណើរ។ល។ - ដែលតែងតែប្រាស្រ័យគ្នាទៅវិញទៅមក។ ការដាក់ឧប្បត្តិហេតុទៅតាមប្រភេទជនរងគ្រោះក៏អាចជាបញ្ហាដែរ ដែលវាមានហេតុផលដូចគ្នា។ ម្យ៉ាងវិញទៀត ការប្រើវិធីសាមញ្ញទាំងអស់នេះ អាចនាំ

[១] យើងសន្មតថា អ្នកអានមានការយល់ដឹងពីការការពារតាមផ្លូវច្បាប់ជាតិ និងអន្តរជាតិទាក់ទងនឹងសេរីភាពក្នុងការបញ្ចេញមតិនៅកម្ពុជា។ *សូមមើល* ឧទាហរណ៍៖ សេចក្តីប្រកាសជាសាកលស្តីពីសិទ្ធិមនុស្ស (មាត្រា១៣ មាត្រា១៩ និងមាត្រា២០) កាតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (មាត្រា១២ មាត្រា១៩ និងមាត្រា២១) រដ្ឋធម្មនុញ្ញកម្ពុជា (មាត្រា៣៥ មាត្រា៣៧ មាត្រា៤០ មាត្រា៤១ មាត្រា៤២ និងមាត្រា៨០)។ សំរាប់ការពិភាក្សាជាទូទៅបន្ថែមទៀតលើបញ្ហាផ្លូវច្បាប់ជុំវិញសេរីភាពខាងការបញ្ចេញមតិនៅកម្ពុជា *សូមមើល* "កម្ពុជាត្រូវបានបំបិទមាត់៖ លទ្ធិប្រជាធិបតេយ្យស្ថិតក្នុងគ្រោះថ្នាក់? របាយការណ៍ស្តីពីសេរីភាពខាងការបញ្ចេញមតិនៅកម្ពុជា" របាយការណ៍រួមគ្នារបស់បណ្តាអង្គការក្រៅរដ្ឋាភិបាល សម្របសម្រួលដោយមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ខែកញ្ញា ឆ្នាំ២០១០ និងមាននៅគេហទំព័រ: http://www.cchrcambodia.org/English/add_report/reports/joint_report_on_foex.10sept.eng.pdf )

[២] ក្នុងករណីខ្លះ ការរំលោភលើសេរីភាពបញ្ចេញមតិបានកើតឡើងពីដំបូង នៅមុខ ខែមេសា ដល់ ខែកញ្ញា ប៉ុន្តែសារព័ត៌មានចុះផ្សាយពីការអភិវឌ្ឍន៍ជាបន្តនៃករណីក្នុងកំឡុងពេល ៦ខែនេះ-សវនាការ សាលក្រម បណ្តឹងឧទ្ធរណ៍ ការបំភិតបំភ័យជាបន្ត។ល។ ក្នុងករណីទាំងនេះ យើងផ្តល់ប្រវត្តិនៃករណី ក្រៅពីរង្វង់រយៈពេលសរសេរបាយការណ៍ ដើម្បីផ្តល់ព័ត៌មានពីការវិវឌ្ឍន៍ថ្មីៗបំផុត ដែលកើតមានទាំងមុខ និងក្រោយព្រឹត្តិការណ៍។

អោយអ្នកអានមើលវិលងអំពីលំនាំនៃវិធីដែលអាជ្ញាធរប្រើប្រាស់ដើម្បីបង្ក្រាបសកម្មភាពខាងការបញ្ចេញមតិ។

ដោយសារហេតុផលទាំងអស់នេះ យើងបានជ្រើសរើសយកការដាក់តាមប្រភេទនៃករណីទាំងអស់ទៅតាមមធ្យោបាយ ឬគោលដៅដែលប្រើប្រាស់ដោយអាជ្ញាធរ។ យើងជឿជាក់ថា វិធីសាស្ត្រនេះសមរម្យបំផុតសំរាប់បង្ហាញអោយឃើញពីលំនាំនៃការបង្ក្រាបលើសេរីភាពខាងការបញ្ចេញមតិដែលកំពុងតែកើតមាន។

ប្រភេទករណីដែលយើងបានប្រើប្រាស់នៅក្នុង របាយការណ៍នេះមានដូចជា:

- **ការរំខានដល់ការជួបប្រជុំជាសាធារណៈដោយសន្តិវិធី** ដោយគ្មានហេតុផល និងមិនចាំបាច់
- **ការគំរាមកំហែងតាមផ្លូវតុលាការ** ទៅលើបុគ្គលដែលអនុវត្តសិទ្ធិបញ្ចេញមតិ ដែលរួមមាន ការស៊ើបអង្កេត ការចាប់ខ្លួន ការចោទប្រកាន់ ការឃុំខ្លួន និងការកាត់ទោស។
- **ការគំរាមកំហែងក្រៅផ្លូវតុលាការ ការបំភិតបំភ័យ និងការវាយប្រហារលើរាងកាយ** ទៅលើបុគ្គលដែលអនុវត្តសិទ្ធិបញ្ចេញមតិ។
- **ការបំភិតបំភ័យខាងនយោបាយ** (ការគាបសង្កត់គ្រប់ប្រភេទពីរដ្ឋាភិបាលទៅលើបុគ្គលដែលសំដែងមតិខាងនយោបាយ ឬបំពេញតួនាទីនយោបាយ)។
- **ការគំរាមកំហែងខាងការទូត** (ការគំរាមកំហែងសំដៅលើអ្នកតំណាងនៃអង្គការអន្តរជាតិ និងរដ្ឋាភិបាលបរទេសទាក់ទងនឹងអត្ថាធិប្បាយជាសាធារណៈរបស់ពួកគេលើគោលនយោបាយ រាជរដ្ឋាភិបាលកម្ពុជា)។

តាមពិតទៅការរៀបជាប្រភេទបែបនេះ មិនមែនល្អឥតខ្ចោះនោះទេ។ ក្នុងករណីខ្លះ អាជ្ញាធរបានប្រើឧបាយកលច្រើនជាងមួយដើម្បីបំបិទមាត់អ្នករិះគន់។ យើងក៏បានព្យាយាមរៀបដាក់តាមប្រភេទនៃករណីទាំងនេះទៅតាមអំពើរំលោភសិទ្ធិខាងបញ្ចេញមតិដែលលេចធ្លោបំផុត។

នៅទីបំផុតយើងបានពិនិត្យមើល**ប្រភេទទី៦** មួយទៀតគឺ ការកើនឡើងនូវចំនួននៃការចាប់ខ្លួនអ្នកសារព័ត៌មានពីបទចោទប្រកាន់ដោយគ្មានភស្តុតាងថា បានជំរិតទារប្រាក់ពីឈ្មួញឈើ និងអ្នកជំនួញដទៃទៀត។ បើទោះបីជាឧប្បត្តិហេតុទាំងនេះខ្លះ អាចដាក់ចូលទៅក្នុងប្រភេទ "ការគំរាមកំហែងតាមផ្លូវតុលាការ" តែមានហតុផលនាំអោយជឿថា ករណីទាំងនេះគួរតែដាក់ក្នុងក្រុមមួយដោយឡែក។

អង្គការលីកាដូ បានធ្វើការស៊ើបអង្កេតលើករណីមួយចំនួនទាក់ទងនឹងអ្នកសារព័ត៌មានជំរិតទារប្រាក់ - ក្នុងអតីតកាលនិងបច្ចុប្បន្នកាល - ហើយបានសន្និដ្ឋានថា មានអ្នកសារព័ត៌មានខ្វះក្រមសីលធម៌ខ្លះ ពិតជាបានស្វែងរកសំណូកពីឈ្មួញឈើ។ ទោះជាយ៉ាងនេះក្តី ក៏ក្នុងករណីផ្សេងទៀតបានស្តែងអោយឃើញថា អ្នកដែលប្រតិបត្តិការងារសារព័ត៌មានត្រឹមត្រូវតាមច្បាប់ បានរងនូវការចោទប្រកាន់ដោយបំពានផងដែរ។

ដោយមិនគិតអំពីកំហុស ឬភាពគ្មានកំហុសរបស់បុគ្គលអ្នកសារព័ត៌មាន យើងជឿជាក់ថា ពេលវេលានៃការបង្ក្រាបគឺជា ការគួរកត់សំគាល់ណាស់។ ចាប់ផ្តើមក្នុងខែមករា ឆ្នាំ២០១០ រាជរដ្ឋាភិបាលបានចាប់ផ្តើមយុទ្ធនាការប្រឆាំងសកម្មភាពកាប់ឈើខុសច្បាប់ក្នុងទ្រង់ទ្រាយធំមួយ និងប្រកបដោយការផ្សព្វផ្សាយយ៉ាងទូលំទូលាយ។ យុទ្ធនាការនេះ បានប្រមូលឈើដែលរឹបអូសបានចំនួន៣,០០០ម៉ែត្រគូប ប៉ុន្តែមានការចាប់ខ្លួនបុគ្គលសំខាន់ៗ ពាក់ព័ន្ធជាមួយមុខជំនួញនេះតែពីរ ឬបីនាក់ប៉ុណ្ណោះ។ ទន្ទឹមពេលជាមួយគ្នានេះ មានអ្នក

[៦] របាយការណ៍ លីកាដូ

សារព័ត៌មានយ៉ាងហោចណាស់ ១៦នាក់ ដែលបានចុះផ្សាយអំពីបញ្ហានេះ ត្រូវបានចាប់ខ្លួនរវាង ខែមេសា និងខែកញ្ញា ឆ្នាំ២០១០។ ផ្នែកចុងក្រោយនៃរបាយការណ៍នេះ ពិនិត្យមើលករណីប្រភេទនេះមួយចំនួន និង ពិនិត្យមើលលើការ ជាប់ជំពាក់ដែលអាចមានជាមួយនឹងយុទ្ធនាការប្រឆាំងការកាប់ឈើ។

□□□

# ២. ការរំខានដល់ការជួបប្រជុំជាសាធារណៈដោយសន្តិវិធី

### *ករណីសិក្សា ១៖ អ្នកភូមិជីក្រែងធ្វើដំណើរផ្លូវវែងឆ្ងាយ និងលទ្ធផលទទួលបានក្រោយមក*[៣]

អ្នកភូមិជីក្រែង ដែលបានជាប់ពាក់ព័ន្ធនៅក្នុងទំនាស់ដីធ្លីដ៏ក្ដៅគគុកមួយមានសំណូមពរដ៏សាមញ្ញមួយ។ សំណូមពរនោះមាន បន្ទាប់ពីឧប្បត្តិហេតុថ្ងៃទី២២ ខែមីនា ឆ្នាំ២០០៩ ជាពេលដែលកងកំលាំងរបស់រាជរដ្ឋាភិបាលបាន ចូលទៅរឹបអូសយកដីរបស់ពួកគេដើម្បីផលប្រយោជន៍ឈ្មួញឯកជនមួយ។




*ព្រះតេជគុណ លួន សុវ៉ាតប្រើប្រាស់រូបថត និងវីដេអូដើម្បីជាឯកសារផ្សព្វផ្សាយពីការរំលោភសិទ្ធិមនុស្សនៅក្នុងប្រទេសកម្ពុជា*

អ្នកភូមិបាន នាំគ្នាចេញមកធ្វើការតវ៉ា ហើយមានការប្រទាញប្រទង់គ្នា ដែលក្នុងពេលនោះមានអ្នកភូមិបីនាក់ ត្រូវបានកងកំលាំងរាជរដ្ឋាភិបាលបាញ់សំដៅលើ និងអ្នកភូមិ៩នាក់ បន្ថែមទៀតត្រូវបានចាប់ខ្លួន។ អ្នកភូមិទាំងនេះ ត្រូវបានចោទប្រកាន់ ពីបទបង្ករបួសស្នាមលើរាងកាយ និងលួចស្រូវ ជាស្រូវពួកគេបានដាំដុះ ដោយដៃរបស់ខ្លួនផ្ទាល់។ តុលាការខេត្តសៀមរាប បាននិយាយថា ខ្លួននឹងប្រកាសសាលក្រម នៅថ្ងៃទី២៧ ខែតុលា។

អ្នកភូមិចង់ទៅចូលរួមសវនាការ - ឬក៏យ៉ាងហោចណាស់រង់ចាំនៅខាងក្រៅបន្ទប់សវនាការ - គឺជាសិទ្ធិរបស់ពួកគេក្រោមរដ្ឋធម្មនុញ្ញកម្ពុជា[៤]។ ប៉ុន្តែ នៅប្រទេសកម្ពុជាកត្តាទាំងនេះមិនមែនជារឿងសាមញ្ញពេកទេ។

នាពេលរសៀលមុនពេលចេញសាលក្រម មានមន្រ្តីនគរបាលប្រដាប់ដោយអាវុធចំនួនប្រហែលជា ៥០នាក់បានហ៊ុំព័ទ្ធភូមិ និងវត្តអារាមនៃមេដឹកនាំរបស់អ្នកភូមិ ដែលត្រូវបានអាជ្ញាធរឈប់ទទួលស្គាល់ គឺព្រះ

---

[៣] "យើងទាំងអស់គ្នាជាអ្នកការពារសិទ្ធិមនុស្ស" របាយការណ៍អង្គការលីកាដូ ថ្ងៃទី៩ ខែឧសភា ឆ្នាំ២០១០ (មាននៅគេហទំព័រ: http://www.licadho-cambodia. org/articles/20100509/111/index.html)។ ឯកសារផ្ទៃក្នុងអង្គការលីកាដូ។

[៤] សូមមើលរដ្ឋធម្មនុញ្ញកម្ពុជា មាត្រា៤០ (សេរីភាពក្នុងការធ្វើដំណើរ)។ សូមមើលផងដែរ រដ្ឋធម្មនុញ្ញកម្ពុជា មាត្រា៣១ ដែលទទួលស្គាល់សេចក្តីប្រកាសជាសាកលស្តីពីសិទ្ធិមនុស្សមាត្រា១១ (សិទ្ធិចូលរួមក្នុងសវនាការជាសាធារណៈ) និងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយមាត្រា១៤ (ដែលអនុញ្ញាតិអោយបដិសេធសាធារណៈជនពីការចូលរួម"ទាំងស្រុង ឬ ផ្នែកណាមួយនៃសវនាការសម្រាប់ផលប្រយោជន៍នៃទំនៀមទំលាប់សណ្តាប់ធ្នាប់សាធារណៈ ឬសន្តិសុខជាតិ"។ អជ្ញាធរមិនបានផ្តល់សេចក្តីពន្យល់ច្បាស់លាស់ ថាហេតុអ្វីបានជាការមិនអោយមិត្តភ័ក្រ្ត និងក្រុមគ្រួសាររបស់ចុងចោទក្នុងករណីនេះចូលរួមក្នុងសវនាការជាការចាំបាច់។)។

តេជគុណ លួន សុវ៉ាត។ នគរបាលបានច្រកគ្រាប់ចូលអាវុធរបស់ពួកគេសម្តែងអោយ អ្នកភូមិឃើញ។ វាគឺជាសារដ៏ច្បាស់ក្រលែតមួយៈ គឺអ្នកភូមិមិនអាចធ្វើដំណើរទៅកាន់ខេត្តសៀមរាបបានទេ។ នគរបាលបានស្នាក់នៅក្នុងភូមិពេញមួយយប់ដើម្បីអនុវត្តបទបញ្ជា ដោយមាននគរបាលបីនាក់ស្នាក់នៅក្នុងវត្តរបស់ព្រះសង្ឃ លួន សុវ៉ាត។

បន្ទាប់មកមានដំណឹងអាក្រក់ៈ ម្ចាស់រថយន្ត ដែលព្រះសង្ឃសុវាតបានជួលសំរាប់ដឹកអ្នកភូមិបានផ្តល់ដំណឹងមកថា ពួកគេត្រូវបាននគរបាលគំរាមកំហែង ដូច្នេះមិនអាចមកកាន់ភូមិបានទេ។ ព្រះសង្ឃ សុវ៉ាត បានកោះហៅអ្នកភូមិជួបប្រជុំ និងសួរថាតើពួកគេចង់ធ្វើអ្វី។ សហគមន៍បានសំរេចចិត្តថា ពួកគេក្រោកពីព្រលឹម និងធ្វើដំណើរដោយថ្មើរជើង បើទោះបីជាតុលាការមានចំងាយ ៩០គីឡូម៉ែតក៍ដោយដែលជាក់ស្តែង គឺវាមិនអាចធ្វើដំណើរទៅដល់ទេ។

នាព្រលឹមថ្ងៃបន្ទាប់ ព្រះសង្ឃ សុវ៉ាត បានក្រោកឡើងនៅម៉ោង ៤ព្រឹក។ គាត់បានចាកចេញពីវត្តដោយស្ងាត់ៗមិនអោយនគបាលដឹង និងបាននិមន្តទៅក្នុងភូមិ។ គាត់បាននិមន្តពីផ្ទះមួយទៅផ្ទះមួយដើម្បីដាស់គ្រួសារនិមួយៗអោយភ្ញាក់ពីដំណេក រហូតប្រមូលបានគ្នាមួយក្រុមជាង ៥០នាក់ - មានមនុស្សវ័យចាស់ក្មេង និងមានទាំងកុមារ និងស្ត្រីមានផ្ទៃពោះ។ ពួកគេបានចេញដំណើរកាត់តាមវាលស្រែដើម្បីទៅកាន់ផ្លូវជាតិ។

រយៈពេល ២ម៉ោងក្រោយមក នគបាលបានដឹងខ្លួនថា ត្រូវបានអ្នកភូមិបញ្ឆោត ហើយក៏នាំគ្នាធ្វើដំណើរដោយម៉ូតូទៅតាមរកអ្នកភូមិ។ ពួកគេរកឃើញក្រុមអ្នកភូមិចំងាយ ១០គ.ម ជិតដល់ផ្លូវជាតិ។ នគបាល ៦នាក់ដាក់ម៉ូតូរបស់ខ្លួនធ្វើជារបាំងបិទផ្លូវជាបណ្តោះអាសន្នចំងាយប្រហែល ៥០ម៉ែត្រពីខាងមុខក្រុមអ្នកភូមិ។ ព្រះសង្ឃសុវ៉ាត បានបើកកាមេរ៉ាវីដេអូរថតរូបភាព ហើយក្រុមអ្នកភូមិបន្តដំណើរទៅមុខទៀត។

មន្ត្រីនគបាលម្នាក់បានស្រែកឡើងថា "មិនអនុញ្ញាតិអោយអ្នកធ្វើដំណើរទៅមុខទេ"។ នាពេលនោះ ក្រុមអ្នកភូមិស្ថិតនៅចំងាយ ៥០ម៉ែត្រពីក្រុមនគបាល។ ព្រះសង្ឃ សុវ៉ាត បានសួរថា "ព្រោះហេតុអ្វីទៅ? អាត្មាមានសិទ្ធិទៅទីកន្លែងណាដែលអាត្មាចង់ទៅ"។

នាពេលនោះ ព្រះសង្ឃ សុវ៉ាត គង់ទល់មុខគ្នានឹងមន្ត្រីនគបាលដែលមានកំហឹង។ មន្ត្រីនគបាលបានដកយកកាមេរ៉ាវីដេអូរបស់ព្រះសង្ឃសុវ៉ាត។ មន្ត្រីរូបនោះបាននិយាយថា "កុំថតពួកយើង។ "ព្រះសង្ឃសុវ៉ាតបានមានពុទ្ធដីកាតបវិញថា "ថតរូបភាពក៏ជាសិទ្ធិរបស់អាត្មាដែរ។ អាត្មាថតរូបភាពផ្លូវថ្នល់ ហើយបើអស់លោកមិនចង់អោយថតជាប់ទេ សូមចាកចេញពីផ្លូវទៅ"។ ខណៈពេលដែលព្រះសង្ឃសុវ៉ាតជជែកវែកញែកជាមួយនគរបាល ក្រុមអ្នកភូមិបានឆ្លងផុតរបាំងបិទផ្លូវរបស់នគបាល។ ទោះបីជាបានឆ្លងផុតរបាំងបិទផ្លូវមួយនេះក៏ដោយ ប៉ុន្តែនៅមានឧបសគ្គច្រើនថែមទៀត។

នៅលើដងផ្លូវ ព្រះសង្ឃសុវ៉ាតបានហៅរករថយន្តតាក់ស៊ីនៅស្រុកជីក្រែង ប៉ុន្តែពួកគេទាំងអស់មិនហ៊ានមកទេ។ ពួកគេត្រូវបាននគបាលគំរាមកំហែងផងដែរ។ ក្រុមអ្នកភូមិបានបន្តដំណើរដោយថ្មើរជើង។ នគរបាលបានមកតាមដាក់របាំងបិទផ្លូវនៅរៀងរាល់ ១០០មែត្រ ទៅ ២០០ម៉ែត្រ ពីមុខក្រុមអ្នកភូមិ។ ការហៅ

រថយន្តតាមផ្លូវអោយឈប់ដើម្បីធ្វើដំណើរមិនបានផលទេ-អ្នកបើកបររថយន្តទាំងអស់នោះ ត្រូវបានគេព្រមានមិនអោយដឹកក្រុមអ្នកភូមិទាំងនោះទេ។ នៅទីបំផុតមានរថយន្តតាក់ស៊ីមួយ បានឈប់ដឹកអ្នកភូមិមួយចំនួន ប៉ុន្តែធ្វើដំណើរបានចំងាយ ១០០ម៉ែត្រ នគបាលបានបញ្ឈប់រថយន្តនោះ និងឃាត់ខ្លួនអ្នកបើកបរព្រមទាំងដកហូតយកសោររថយន្ត។ ព្រះសង្ឃសុវ៉ាត បានធ្វើអន្តរាគមន៍បញ្ចុះបញ្ចូលនគបាលអោយជឿថាវាជាកំហុសរបស់ព្រះអង្គមិនមែនជាកំហុសរបស់អ្នកបើកបររថយន្តតាក់ស៊ីទេ។ រថយន្តតាក់ស៊ី ត្រូវបានបង្ខំអោយបើកបរត្រលប់ក្រោយវិញតាមទិសដៅដែលខ្លួនបានធ្វើដំណើរមក។

ក្រុមអ្នកភូមិ បានបន្តដំណើរដោយថ្មើរជើង ហើយចំនួនអ្នកធ្វើដំណើរបានថយចុះជាបណ្តើរៗ។ ព្រះសង្ឃ សុវ៉ាត បានស្រែកហៅរថយន្តតាក់ស៊ី និងរថយន្តធំៗបីបួនបន្ថែមទៀត ប៉ុន្តែមិនមានរថយន្តណាឈប់ទេ រហូតទាល់តែក្រុមអ្នកភូមិដើរបាន ២០គីឡូម៉ែត្រ ទើបពួកគេចាប់ផ្តើមមានសំណាងខ្លះ។ អ្នកភូមិបានបំបែកគ្នាជាក្រុមតូចៗ ហើយធ្វើដំណើរតាមតាមរថយន្តបីទៅបួនផ្សេងៗគ្នា។ អ្នកភូមិខ្លះបានទៅដល់ទិសដៅ និងអ្នកខ្លះទៀតត្រូវបានគេអោយត្រលប់ក្រោយវិញ។

ព្រះសង្ឃ សុវ៉ាត ខ្លួនព្រះអង្គ នៅទីបំផុតត្រូវបានបុគ្គលិកអង្គការមិនមែនរដ្ឋាភិបាលមកទទួលយកនៅម៉ោងប្រហែលជា ១០ព្រឹក បន្ទាប់ពីធ្វើដំណើរថ្មើរជើងចំងាយ ៣០គីឡូម៉ែត្រ។ មុនពេលព្រះអង្គទៅដល់តុលាការខេត្ត គឺម៉ោងជិត ១១ព្រឹក។ នាពេលនោះ សាលក្រមប្រកាសបាន ៣ម៉ោងកន្លងមកហើយ: អ្នកភូមិពីរនាក់ត្រូវបានកាត់ទោសពីបទបង្ករបួសស្នាម និងបទប្លន់ ដែលត្រូវជាប់ពន្ធនាគាររយៈពេលមួយឆ្នាំ និងបង់ប្រាក់ពិន័យចំនួន ៧៥០ ដុល្លាសហរដ្ឋអាមេរិក។ អ្នកភូមិ ៧នាក់ ត្រូវបានរួចផុតពីការចោទប្រកាន់របស់តុលាការ ប៉ុន្តែនៅបន្តជាប់ឃុំឃាំងក្នុងពន្ធនាគាររង់ចាំការសំរេចទាក់ទងនឹងបទចោទថ្មី និងបណ្តឹងឧទ្ធរណ៍ពីព្រះរាជអាជ្ញា។

* * *

រយៈពេលនៃឆ្នាំបន្ទាប់ ព្រះសង្ឃសុវ៉ាតបានបន្តធ្វើការងារជាមួយអ្នកភូមិ។ ខណៈដែលញាតិមិត្តពីភូមិរបស់ព្រះអង្គត្រូវគេនាំយកទៅកាត់ទោស ព្រះអង្គបានបន្តរៀបចំប្រមូលផ្តុំអ្នកភូមិនៅខាងក្រៅតុលាការខេត្តសៀមរាប។

នៅថ្ងៃទី២០ ខែសីហា ឆ្នាំ២០១០ ព្រះអង្គបានចូលរួមសវនាការមួយលើកទៀតលើក្រុមមេដឹកនាំសហគមន៍ជីក្រែង។ គាត់បានប្រមូលផ្តុំគ្នាជាមួយសហគមន៍ពីរ និងសហជីពមួយនៅខាងក្រៅតុលាការ ជាទីកន្លែងដែលពួកគេបានបង្ហោះប៉ោងប៉ោង មានភ្ជាប់នូវសារអំពាវនាវអោយមានការដោះលែងអ្នកភូមិជីក្រែង និងផ្តល់យុត្តិធម៌សំរាប់អ្នកភូមិជីក្រែង។

ការប្រមូលផ្តុំគ្នាប្រកបដោយសន្តិវិធី ប៉ុន្តែមានភាពតឹងតែង។ នគបាលបានពង្រាយកំលាំង និងមានការនិយាយគ្នាទុកជាមុនថា អាជ្ញាធរនឹងព្យាយាមចាប់ខ្លួន និងផ្សឹកព្រះសង្ឃសុវ៉ាត ក្នុងថ្ងៃនោះ។ ទោះជាដូច្នេះក្តី ក៏ព្រះអង្គបានបង្ហាញមុខចូលរួមក្នុងការប្រមូលផ្តុំដែរ។

នៅវេលាពាក់កណ្តាលពេលព្រឹក មានព្រះសង្ឃចំនួន ៥០អង្គ បាននិមន្តមកដល់តុលាការដើម្បីប្រឈមមុខនឹងព្រះអង្គ សុវ៉ាត។ មាននគបាល ២០នាក់ផ្សេងទៀតមកដល់ទីនោះដែរ។ ព្រះសង្ឃបានបង្ហាញ

លិខិតមួយច្បាប់ដល់ព្រះសង្ឃសុវ៉ាត។ លិខិតសរសេរចោទប្រកាន់ព្រះអង្គពីការរំលោភសង្ឃប្រកាសលេខ ៩០៣/០៧ ជាសេចក្តីបង្គាប់បញ្ជាឆ្នាំ២០០៧ ហាមប្រាមព្រះសង្ឃ ក្នុងប្រទេសកម្ពុជាពី "ការរៀបចំ ឬចូលរួមក្នុង" បាតុកម្ម ឬកូដកម្ម ដែលប៉ះពាល់ដល់សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ[៥]។

មានបទបញ្ជារសរសេរក្នុងលិខិតនោះផងដែរថាៈ បញ្ឈប់ លួន សុវ៉ាត ពីការចូលរួមក្នុងបាតុកម្មនៅសៀមរាប និងធ្វើការចាប់ខ្លួនគាត់បើមានការរឹងទទឹង។ ព្រះសង្ឃសុវ៉ាត មើលមិនឃើញថា គាត់អាចធ្វើអោយប៉ះពាល់ដល់សន្តិសុខនរណាម្នាក់ ឬ សណ្តាប់ធ្នាប់សាធារណៈយ៉ាងដូចម្តេចទេ ហេតុដូច្នេះហើយគាត់បដិសេធមិនចាកចេញទេ។ អាជ្ញាធរចាប់ផ្តើមចូលមកជិតគាត់។

អ្នកភូមិបាននាំគ្នាព័ទ្ធជុំជិតព្រះសង្ឃ សុវ៉ាត ក្នុងកិច្ចខិតខំដើម្បីធ្វើជារបាំងការពារគាត់ពីការចាប់ខ្លួន។ មធ្យោបាយនេះទទួលបានផល ហើយអាជ្ញាធរសុខចិត្តចុះចាញ់ ដែលបើតាមស្មាន ពីព្រោះពួកគេមិនចង់បង្កអោយកើតមានឧប្បត្តិហេតុនៅទីកន្លែងនោះទេ។ បន្ទាប់ពីការប្រកាសសាលក្រម ព្រះសង្ឃសុវ៉ាតបានចាកចេញជាមួយនឹងរថយន្តអង្គការមិនមែនរដ្ឋាភិបាលមួយ។

ប៉ុន្តែរថយន្តមិនបានទៅមុខឆ្ងាយទេមុនពេល ដែលនគរបាលចរាចរណ៍បានឃាត់អោយឈប់។ បន្ទាប់ពីចរចារគ្នាអស់រយៈពេល ៥នាទី រថយន្តត្រូវបានអនុញ្ញាតិអោយបន្តដំណើរ ប៉ុន្តែត្រូវបានឃាត់អោយឈប់ម្តងទៀតរយៈពេលប៉ុន្មាននាទីក្រោយមក ដែលលើកនេះធ្វើឡើងដោយនគរបាលខេត្ត។ នគរបាលបានបញ្ជារអោយអ្នកបើកបរបើករថយន្តទៅកាន់ទីវត្តមួយ ដែលនៅទីនោះអាជ្ញាធរខាងសាសនាកំពុងតែរង់ចាំជាស្រេច។ នគរបាលបានអមដំណើរព្រះអង្គទៅ។

អ្នកភូមិជីក្រែង បានទទួលដំណឹងអំពីអ្វីដែលកើតឡើងចំពោះព្រះអង្គ ហើយពួកគេបាននាំគ្នាទៅកាន់ទីវត្តនោះ ទៅដល់ចំពេលដែលអាជ្ញាធរសង្ឃបានកំពុងតែមកដល់ទន្ទឹមនឹងរថយន្ត ព្រះសង្ឃសុវ៉ាត។

ប្រធានសង្ឃមួយអង្គប្រញាប់ចូលក្នុងរថយន្ត និងព្យាយាមទាញព្រះសង្ឃ សុវ៉ាត ចេញមកក្រៅ។ អ្នកភូមិបានបំបែកចេញ។ ម្ចាស់រថយន្តបានបិទទ្វាររថយន្ត និងអ្នកភូមិបានព័ទ្ធរថយន្តជិត។ ស្ត្រីវ័យចំណាស់ៗអង្គុយលើផ្លូវដើម្បីរារាំងសង្ឃជាន់ខ្ពស់មិនអោយចូលជិតព្រះអង្គ និងបានអង្វរកព្រះសង្ឃទាំងនោះអោយទុកព្រះសង្ឃ សុវ៉ាត អោយនៅម្នាក់ឯង។ អ្នកភូមិផ្សេងទៀតយំ និងស្រែក ដោយភាពរំជួលចិត្ត។

អ្នកភូមិទទួលបានជោគជ័យចំពោះការដែលពួកគេបង្កឡើង នូវស្ថានភាពទាល់ច្រកមួយនេះ។ ពីរម៉ោងក្រោយមក នគបាលបានបញ្ជារអោយបុគ្គលិកអង្គការមិនមែនរដ្ឋាភិបាលយករថយន្តខ្លួនចេញ។ ព្រះសង្ឃ សុវ៉ាត និងអ្នកភូមិបានរួចខ្លួន និងត្រលប់ទៅជីក្រែងវិញ។

អាជ្ញាធរខាងសាសនាមិនទាន់អនុវត្តបានតាមបទបញ្ជារអោយផ្សឹកព្រះសង្ឃសុវ៉ាតទេ ហើយព្រះអង្គនៅតែបន្តសកម្មភាពរបស់ខ្លួន។ ទោះជាយ៉ាងណាក៏ដោយក៏បទបញ្ជារនេះនឹងនៅតែជាការបំភិតបំភ័យជាបន្តដោយគ្មានកំណត់។

---

[៥] សូមមើល លិខិតបេសកកម្មចេញដោយការិយាល័យធម្មការ និងសាសនាខេត្តសៀមរាប លេខ៩៧/០១០ ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ២០១០

## *ការបង្ក្រាបដោយមានការចាត់តាំង: ពីភាពព្រៃផ្សៃទៅការរំលោភសមត្ថកិច្ចធ្ងន់ធ្ងរតាមបែបការិយាធិបតេយ្យ*

រឿងនៅដីក្រែងបានផ្តល់នូវសេចក្តីសង្ឃឹមព្រាលៗដ៏កំរមួយ។ ថ្វីបើមានកិច្ចខិតខំយ៉ាងច្រើនលើសលប់ពីសំណាក់អាជ្ញាធរយ៉ាងណាក៏ដោយក៏អ្នកភូមិអនុវត្តបានជោគជ័យសិទ្ធិរបស់ខ្លួនក្នុងការធ្វើដំណើរដោយសេរី និងការជួបប្រជុំ។ ពួកគេបានក្រោកឈរឡើងនៅចំពោះមុខនៃឧបាយកលគំរាមកំហែងរបស់អាជ្ញាធរ ហើយព្រះសង្ឃ លួន សុវ៉ាត នៅតែមានភាពសកម្ម។

ប៉ុន្តែការពិពណ៌នារឿងដីក្រែងថា "មានក្តីសង្ឃឹម" ស្តែងអោយឃើញពីសភាពធ្លាក់ចុះឡើងនៃសេរីភាពខាងការបញ្ចេញមតិនៅកម្ពុជា។ អ្នកភូមិបានបាត់បង់ដីធ្លីរបស់ខ្លួន ហើយនគបាលបានបាញ់ប្រហារទៅលើអ្នកភូមិដៃទទេគ្មានអាវុធបីនាក់។ មន្ត្រីទទួលខុសត្រូវរួចផុតពីការចោទប្រកាន់ ខណៈពេលដែលអ្នកភូមិដីក្រែងបានប្រឈមមុខនឹងបទចោទប្រកាន់ព្រហ្មទណ្ឌជាច្រើនក្នុងរយៈពេលជាងមួយឆ្នាំ និងសវនាការផ្សេងៗគ្នាចំនួន ៥លើក។ ក្នុងពេលសរសេររបាយការណ៍នេះ យ៉ាងហោចណាស់មានអ្នកភូមិ ១២នាក់កំពុងជាប់ក្នុងពន្ធនាគារ ឬជាប់ឃុំឃាំងជាបណ្តោះអាសន្នរង់ចាំការកាត់សេចក្តី។ ព្រះសង្ឃសុវ៉ាត អាចនឹងត្រូវគេចាប់ខ្លួនគ្រប់ពេលផងដែរ។

ប៉ុន្តែតាមការជាក់ស្តែង ប្រជាពលរដ្ឋកម្ពុជាមួយចំនួនមានការភ័យខ្លាច ហើយរឹតតែភ័យខ្លាចខ្លាំងឡើងក្នុងការព្យាយាមជួបប្រជុំជាសាធារណៈ។




*តំណាងសហគមន៍ប្រមូលផ្តុំដើម្បីទាមទារសិទ្ធិដីធ្លីនៅក្នុងទីក្រុងភ្នំពេញនៅថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១០*
*កងកំលាំងនគរបាលបានរាំងក្បួនដង្ហែររបស់ពួកគេ។*

អ្នកខ្លះមិនមានលទ្ធភាពចូលរួមប្រជុំទាល់តែសោះ។ វាកាន់តែក្លាយទៅជារឿងធម្មតាទៅៗ ដែលការប្រមូលផ្តុំត្រូវបានអាជ្ញាធរបញ្ឈប់បានមុន។ នៅតំបន់ជនបទ អាជ្ញាធរតែងតែជ្រើសរើសវិធីដ៏សាមញ្ញមួយគឺបដិសេធសិទ្ធិធ្វើដំណើររបស់ប្រជាពលរដ្ឋ។ មានការហ៊ុំព័ទ្ធភូមិ ដាក់របាំងបិទផ្លូវ និងរារាំងប្រជាពលរដ្ឋពីការប្រមូលផ្តុំដោយប្រើកំលាំង។

នៅតាមតំបន់ទីក្រុង មធ្យោបាយដែលអាជ្ញាធរចូលចិត្តប្រើ គឺមិនចេញអោយនូវលិខិតអនុញ្ញាតិ។ ជំរើសរបស់អាជ្ញាធរនូវមធ្យោបាយនេះ គឺច្បាប់ស្តីពីបាតុកម្មដោយសន្តិវិធីឆ្នាំ២០០៩ ដែលតំរូវអោយអ្នករៀបចំបាតុកម្មជូនដំណឹងទៅរដ្ឋាភិបាលលើរាល់ការប្រមូលផ្តុំជាសាធារណៈទាំងអស់[៦]។ ច្បាប់ក៏អនុញ្ញាតិផងដែរដល់មន្ត្រីដើម្បីធ្វើការហាមប្រាមបាតុកម្មដោយសន្តិវិធី ដោយមូលហេតុសន្តិសុខ សុវត្ថិភាព ឬសណ្តាប់ធ្នាប់សាធារណៈ[៧]។

ខណៈដែលសេចក្តីតំរូវនេះ អាចហាក់ដូចជាសមហេតុផលក្នុងស្ថានភាពទូទៅ ជាញឹកញាប់វាត្រូវបានយកមកប្រើដោយបំពាននៅប្រទេសកម្ពុជា ដែលរដ្ឋាភិបាលមានទំនោរលើការមើលឃើញទស្សនៈជំទាស់ខាងនយោបាយថា ជាការគំរាមកំហែងដល់សណ្តាប់ធ្នាប់សាធារណៈ។

ជាឧទាហរណ៍ នៅខែកក្កដា ឆ្នាំ២០១០ មន្ត្រីជាប់ឆ្នោតមកពីគណបក្សជំទាស់ គឺគណបក្សសិទ្ធិមនុស្ស បានព្យាយាមរៀបចំវេទិកាសាធារណៈលើប្រធានបទ "សេរីភាពនៃការបញ្ចេញមតិ" ក្នុងខេត្តតាកែវ។ អាជ្ញាធរបានបិទវេទិកានោះ ពីព្រោះអ្នករៀបចំកម្មវិធីមិនមានបានទទួលការអនុញ្ញាតិត្រឹមត្រូវទេ[៨]។

វាជារឿងធម្មតាផងដែរ ដែលអាជ្ញាធរពន្យាពេលផ្តល់ការអនុញ្ញាតិរហូតដល់ដំណាក់កាលចុងក្រោយ ដែលទំនងជាសង្ឃឹមថានឹងមានមនុស្សចំនួនតិចតួចមកចូលរួម បើសិនជាគ្មានភាពប្រាកដថា ព្រឹត្តិការណ៍នោះនឹងប្រព្រឹត្តធ្វើទៅបាន។ នេះ គឺជាករណីដែលកើតឡើងក្នុងខែកក្កដា ឆ្នាំ២០១០ ជាពេលដែលអាជ្ញាធរបានបដិសេធការអនុញ្ញាតិពីពេលដំបូងមិនអោយសហជីពកម្មករ ធ្វើការតវ៉ាពីរឿងប្រាក់ឈ្នួលក្នុងរាជធានីភ្នំពេញ[៩]។ រាជរដ្ឋាភិបាលបានអះអាងថា ការតវ៉ាអាចគំរាមកំហែងសណ្តាប់ធ្នាប់សាធារណៈ និងបង្កការបំផ្លិចបំផ្លាញទ្រព្យសម្បត្តិ ប៉ុន្តែអ្នករៀបចំប្តេជ្ញាចិត្តថានឹងធ្វើការតវ៉ា។ នៅទីបំផុតបំរាមត្រូវបានលុបចេញវិញនាពេលព្រឹកនៃថ្ងៃកើតព្រឹត្តិការណ៍នោះ ។

ទោះបីជាបានទទួលការយល់ព្រម ក៏ព្រឹត្តិការជាច្រើនរងការជ្រៀតជ្រែករំខានពីនគរបាល ដែលមានបែបផែនជំទាស់នឹងទំហំនៃក្រុមអ្នកតវ៉ា ខ្សែផ្លូវនៃក្បួនធ្វើដំណើរ ឬទីតាំងធ្វើសកម្មភាព។ ជួនកាលមានការចាប់ខ្លួនអ្នកចូលរួមពីបទញុះញង់ ឬធ្វើអោយប៉ះពាល់ដល់សន្តិសុខ - បើទោះបីជាការតវ៉ាមើលទៅហាក់ដូច

[៦] ច្បាប់ស្តីពីបាតុកម្មដោយសន្តិវិធី ឆ្នាំ២០០៩ មាត្រា ៥

[៧] ច្បាប់ដដែល មាត្រា៩

[៨] សូមមើលករណីសិក្សាលេខ៥

[៩] សេចក្តីថ្លែងសារព័ត៌មានរួម អង្គការលីកាដូ ថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១០ និងព័តមានពីវិទ្យុអាស៊ីសេរី ថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០១០

ជាគ្រប់យ៉ាងប្រព្រឹត្តិទៅប្រកបដោយសន្តិវិធី។

ក្នុងករណីអាក្រក់បំផុត នគរបាលប្រើកងកំលាំងបោសសំអាតបាតុករ - ដោយបង្ហាញនូវភាពអត់ធ្មត់តិចតួចក្នុងការប្រព្រឹត្តនេះ ។ ឧទាហរណ៍ ក្នុងខែសីហា មានអ្នកភូមិមួយក្រុមមានគ្នា ៥០នាក់បានធ្វើដំណើរមកពីខេត្តបាត់ដំបង ដើម្បីមកធ្វើបាតុកម្មដោយអង្គុយស្ងៀមស្ងាត់នៅខាងមុខគេហដ្ឋានលោកនាយករដ្ឋមន្ត្រី[១០] ។ អ្នកភូមិបានប្រឈមមុខជាមួយនគរបាល ដែលចាប់បង្ខំពួកគេដាក់ចូលក្នុងរថយន្តក្រុងអោយវិលត្រលប់ទៅផ្ទះរបស់ពួកគេវិញ។ ប៉ុន្តែការយាយីលើអ្នកភូមិមិនបានបញ្ចប់ត្រឹមតែប៉ុណ្ណេះទេ: អ្នករៀបចំបាតុកម្មត្រូវបានចាប់ខ្លួននៅថ្ងៃបន្ទាប់ ហើយបន្ទាប់មកទៀត កងកំលាំងកងរាជអាវុធហត្ថប្រដាប់ដោយអាវុធបានហ៊ុំព័ទ្ធភូមិរបស់ពួកគេដើម្បីរារាំងអ្នកភូមិពីការធ្វើសកម្មភាពបន្តទៀត។

ទោះបីជានគរបាលជាញឹកញាប់ប្រើអំពើហិង្សាទៅលើក្រុមបាតុករក៏ដោយ ក៏ប្រទេសកម្ពុជាមិនដែលនាំមន្ត្រីនគរបាលដែលបានប្រព្រឹត្តិអំពើហិង្សាក្នុងបាតុកម្មយកមកផ្តន្ទាទោសទេ។ នេះ គឺជាការពិតណាស់ចំពោះករណីជាច្រើន - សូម្បីតែដូចជាករណីជីក្រែងក៏ដោយ - ជាករណីដែលមានភស្តុតាងជាវីដេអូបង្ហាញពីមន្ត្រីបានប្រើកាំភ្លើងបាញ់ទៅលើជនស៊ីវិលដែលគ្មានអាវុធ និងដែលមិនមែនជាអ្នកបង្កហេតុ។

□□□

[១០] "ការប្រើកំលាំងហួសហេតុទៅលើអ្នកភូមិដែលប្រមូលផ្តុំគ្នាដោយសន្តិវិធីនៅរាជធានីភ្នំពេញ" សេចក្តីថ្លែងការណ៍ អង្គការលីកាដូ ថ្ងៃទី៨ ខែសីហា ឆ្នាំ ២០១០ (http://www.licadho-cambodia.org/pressrelease.php?perm=225&pagenb=&filter=)។

**ករណីសិក្សាខាងក្រោមនេះផ្តល់ឧទាហរណ៍ច្រើនថែមទៀតអំពីការចូលជ្រៀតជ្រែករបស់ រដ្ឋាភិបាលទៅក្នុងកិច្ចខិតខំប្រឹងប្រែងចូលរួមក្នុងការប្រមូលផ្តុំដោយសន្តិវិធី និងជាសាធារណៈរបស់ប្រជាពលរដ្ឋកម្ពុជា:**

►►►
១ ឧសភា ២០១០
រាជធានីភ្នំពេញ

**ករណីសិក្សា ២**

**នគបាលរារាំងការដាក់បញ្ចាំងភាពយន្តឯកសារស្តីពីលោក ជា វិជ្ជា**[១១]

- ការដាក់បញ្ចាំងភាពយន្តឯកសារមានចំណងជើងថា "តើនរណាសំលាប់លោកជា វិជ្ជា?" នៅខាងក្រៅវត្តលង្កាក្នុងរាជធានីភ្នំពេញ ដោយគណបក្សសម រង្ស៊ី និងសហព័ន្ធសហជីពកម្មករកម្ពុជានៅថ្ងៃទី១ ខែឧសភា ឆ្នាំ២០១០ ត្រូវបានមន្ត្រីនគរបាលបញ្ឈប់។
- ភាពយន្តឯកសារនេះដឹកនាំផលិតដោយលោក ប្រេដលី ខុក ដោយគាត់បានស៊ើបអង្កេតករណីឃាតកម្ម ថ្ងៃទី២២ ខែមករា ឆ្នាំ២០០៤ លើលោកជា វិជ្ជា អតីតប្រធានសហជីពសេរីកម្មករនៃព្រះរាជាណាចក្រកម្ពុជា។ ភាពយន្តឯកសារនេះធ្វើការស៊ើបអង្កេតយ៉ាងស៊ីជម្រៅ បន្ទាប់ពីឃាតកម្មបានកើតឡើង ហើយចង្អុលបង្ហាញថា មន្ត្រីរាជរដ្ឋាភិបាលកម្ពុជាបានជាប់ពាក់ព័ន្ធក្នុងការបិទបាំងឃាតកម្មនេះ និងបានរៀបចំអោយបុរសពីរនាក់ជាអ្នកទទួលរងកំហុសដែលពួកគេមិនបានប្រព្រឹត្ត ហើយពួកគេត្រូវជាប់ពន្ធនាគារចំពោះឧក្រិដ្ឋកម្មនេះ។
- អាជ្ញាធរបានផ្តល់ហេតុផលខុសៗគ្នា និងយ៉ាងចំរូងចំរាសចំពោះការហាមប្រាមការដាក់បញ្ចាំងភាពយន្តឯកសារនេះ។ ពីដំបូងរដ្ឋមន្ត្រីក្រសួងព័ត៌មានលោក ខៀវ កាញារិទ្ធ បានមានប្រសាសន៍ថា រដ្ឋាភិបាលនឹងមិន"ជំទាស់បែបនយោបាយ" ទៅនឹងការដាក់បញ្ចាំងនេះទេ។ ប៉ុន្តែបន្ទាប់មកមន្ត្រីសាលារាជធានីភ្នំពេញ បានទាមទារអោយអ្នករៀបចំកម្មវិធីស្វែងរកការអនុញ្ញាតពី "ក្រសួងពាក់ព័ន្ធ"។ បន្ទាប់មកទៀត អ្នកនាំពាក្យក្រសួងមហាផ្ទៃបាននិយាយថា ភាពយន្តឯកសារនេះត្រូវបាន "នាំចូលមកក្នុងប្រទេសដោយខុសច្បាប់"។ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈថ្លែងថា រាល់ខ្សែភាពយន្តទាំងអស់មុនដាក់បញ្ចាំងត្រូវតែមានការពិនិត្យ និងអនុញ្ញាតពីក្រសួង។ នៅទីបំផុតមិនមានការអនុញ្ញាតត្រូវ បានផ្តល់អោយសំរាប់ការដាក់បញ្ចាំងភាពយន្តនេះទេ។
- តំណាងគណបក្សសម រង្ស៊ី បានប្រកាសនៅថ្ងៃទី៥ ខែឧសភា ឆ្នាំ២០១០ ថាពួកគេនឹងដាក់បញ្ចាំងភាពយន្តឯកសារនេះនៅទីស្នាក់ការគណបក្សរបស់ខ្លួនក្នុងពេលឆាប់ៗខាងមុខ។

[១១] មាស សុខជា "គណបក្សសមរង្ស៊ីដាក់បញ្ចាំងភាពយន្តឯកសារស្តីពីលោក ជា វិជ្ជា" ភ្នំពេញប៉ុស្ត៍ ថ្ងៃទី៥ ខែឧសភា ឆ្នាំ២០១០។ មាស សុខជា "តើនរណាត្រួតពិនិត្យភាពយន្តឯកសារស្តីពីលោកជាវិជ្ជា?" ភ្នំពេញប៉ុស្ត៍ ថ្ងៃទី៧ ខែឧសភា ឆ្នាំ២០១០។ សារព័ត៌មានកោះសន្តិភាព ថ្ងៃទី២ ខែឧសភា ឆ្នាំ២០១០។

►►►
២៤-២៥ ឧសភា
២០១០
ខេត្តស្វាយរៀង

**ករណីសិក្សា ៣**

**នគរបាលបិទផ្លូវរាំងខ្ទប់អ្នកភូមិពីការធ្វើដំណើរទៅចូលរួមស្តាប់សវនាការលើអ្នកតំណាងរបស់ពួកគេនៅតុលាការ**[១២]

- អាជ្ញាធរបានព្យាយាមរារាំងអ្នកភូមិពីរក្រុមមកពីស្រុករមាសហែក ពីការដើរក្បួន ទៅកាន់តុលាការខេត្តស្វាយរៀង។ មានអ្នកភូមិប្រហែលជា ៥០នាក់ធ្វើដំណើរមកដល់តុលាការ ដើម្បីទាមទារអោយដោះលែងមេដឹកនាំសហគមន៍របស់ពួកគេពីការឃុំឃាំងបណ្តោះអាសន្ន។
- អ្នកភូមិទាំងនេះជាប់ពាក់ព័ន្ធក្នុងទំនាស់ដីធ្លី ជាមួយក្រុមហ៊ុនចំការកៅស៊ូពាមជាំងរបស់ អាន ម៉ាឌីគ្រុប តាំងពីឆ្នាំ២០០៧។ មេដឹកនាំសហគមន៍បានជាប់ឃុំឃាំងបន្ទាប់ពីមានទទួលការបំភិតបំភ័យ និងគំរាមកំហែងពីអាជ្ញាធរមូលដ្ឋានច្រើនឆ្នាំមក។
- ក្រុមអ្នកភូមិ ៥០នាក់ដំបូងដឹកនាំដោយព្រះសង្ឃមួយអង្គត្រូវបានកងរាជអាវុធហត្ថបញ្ឈប់នៅលើស្ពានមួយក្នុងស្រុកកំពង់ត្រាច។ អាជ្ញាធរបានបង្ខំព្រះសង្ឃអោយផ្តិតមេដៃលើឯកសារ ដែលសន្យាថា ព្រះអង្គ នឹងបញ្ឈប់ការដឹកនាំក្បួនបាតុកម្មរបៀបនេះជាថ្មីម្តងទៀត។ បន្ទាប់មកក្រុមអ្នកភូមិត្រូវបានអនុញ្ញាតអោយបន្តដំណើរទៅមុខ។
- ក្រោយមកអ្នកភូមិក្រុមទី២ បានចាប់ផ្តើមដើរឆ្ពោះទៅតុលាការ។ ពួកគេត្រូវបានបញ្ឈប់ និងរងការយាយីពីអាជ្ញាធរនៅកន្លែងរបាំងផ្លូវទី២។ នៅទីបំផុតអ្នកភូមិប្រមាណជា ២០០នាក់បានធ្វើដំណើរមកដល់តុលាការ។

►►►
៤ កក្កដា ២០១០
ខេត្តតាកែវ

**ករណីសិក្សា ៥**

**អាជ្ញាធរហាមឃាត់វេទិការបស់គណបក្សសិទ្ធិមនុស្ស**[១៣]

- អាជ្ញាធរនៅស្រុកកោះអណ្តែតក្នុងខេត្តតាកែវ បានហាមឃាត់វេទិកាស្តីពី "សេរីភាពខាងការបញ្ចេញមតិយោបល់" រៀបចំឡើងដោយគណបក្សសិទ្ធិមនុស្សកាលពីថ្ងៃទី៤ ខែកក្កដា ឆ្នាំ២០១០។
- អាជ្ញាធរបានចោទថា វេទិកានេះមិនមានច្បាប់អនុញ្ញាតសមស្របតាមច្បាប់ដើម្បីអាចដំណើរការទៅបានទេ។ គណបក្សសិទ្ធិមនុស្សថ្កោលទោសចំណាត់ការនេះដោយនិយាយថា អាជ្ញាធររារាំងពួកគេពីការអនុវត្តតួនាទីសភាតំណាងរាស្ត្ររបស់ខ្លួន។

[១២] "ករណីសិក្សាអំពីការដាក់កំហិតលើការធ្វើដំណើរ និងជួបប្រជុំរបស់សហគមន៍ក្នុងខេត្តចំនួន៦" របាយការណ៍សង្ខេបអង្គការលីកាដូ ពាក់កណ្តាលឆ្នាំ ២០១០ មេឃ ទិត្ថារ៉ា "អ្នកភូមិខេត្តស្វាយរៀងភ័យខ្លាចការចាប់ខ្លួន" ភ្នំពេញប៉ុស្តិ៍ ថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១០។

[១៣] ព័ត៌មានពីវិទ្យុអាស៊ីសេរី ថ្ងៃទី៤ ខែកក្កដា ឆ្នាំ២០១០។

►►►
១២ មិថុនា ២០១០
រាជធានីភ្នំពេញ និង ខេត្តកំពង់ចាម

**ករណីសិក្សា ៦**

## អាជ្ញាធររាំងផ្លូវទៅកាន់រាជធានីភ្នំពេញរបស់អ្នកភូមិ និងបំបែកបាតុកម្ម[១៤]

- អ្នកភូមិប្រមាណជា ១០០នាក់ បានធ្វើដំណើរទៅកាន់រាជធានីភ្នំពេញដើម្បីទាញការចាប់អារម្មណ៍លើបញ្ហាទំនាស់ដីធ្លី ដែលពួកគេមានជាយូរមកហើយជាមួយមន្ត្រីយោធាក្នុងស្រុកមេមត់ ខេត្តកំពង់ចាម។
- អ្នកភូមិបានរាយការណ៍ប្រាប់អង្គការ លីកាដូថា ពីពេលមុនៗអាជ្ញាធរស្រុករាំងពួកគេមិនអោយធ្វើដំណើរជាក្បួនមកកាន់រាជធានីភ្នំពេញទេ។ ដើម្បីកុំអោយអាជ្ញាធរបានដឹងនៅលើកនេះ ពួកគេបានរៀបចំគ្នាជាក្រុមតូចៗជាច្រើនក្រុម ហើយចេញដំណើរពេលយប់។ ការប្រើវិធីសាស្ត្រនេះនាំអោយអ្នកភូមិ ១០០នាក់បានមកដល់ភ្នំពេញ។ អ្នកភូមិផ្សេងទៀតដែលចេញមកយឺតត្រូវបានអាជ្ញាធរឃាត់ដំណើរពួកគេ។
- រយៈពេលពីរថ្ងៃក្រោយពីការមកដល់រាជធានីភ្នំពេញ អាជ្ញាធរខណ្ឌដូនពេញបានបណ្តេញអ្នកភូមិចេញពីទីកន្លែងតវ៉ា និងបានប្រាប់ទៅពួកគេអោយវិលត្រលប់ទៅលំនៅដ្ឋានវិញ។
- មួយខែមុនពេលមានក្បួនតវ៉ានេះ អាជ្ញាធរបានចាប់ខ្លួនសមាជិកសហគមន៍ពីររូប។ ពួកគេត្រូវបានដោះលែងបន្ទាប់មក គឺក្រោយពីការចុះហត្ថលេខាលើឯកសារដែលពួកគេយល់ព្រមឈប់ទាមទារដីធ្លីរបស់ខ្លួន។

►►►
១៥ មិថុនា ២០១០
រាជធានីភ្នំពេញ

**ករណីសិក្សា ៧**

## នគរបាលរារាំងការតវ៉ារឿងដីធ្លី[១៥]

- តំណាងសហគមន៍ប្រមាណជា ៣៥០នាក់ មកពី២៤ខេត្ត/ក្រុង - រួមមានសហគមន៍ជនជាតិដើមភាគតិច - បានមកប្រមូលផ្តុំគ្នានៅជិតវត្តបុទុមដើម្បីប្រមូលមតិគ្នាតវ៉ាលើសិទ្ធិដីធ្លី។ ការតវ៉ាត្រូវបានរៀបចំឡើង ដោយបណ្តាញកសាងសន្តិភាព (CPN) ជាអង្គការថ្នាក់មូលដ្ឋានមានគោលបំណងទាក់ទាញចំណាប់អារម្មណ៍ទៅលើបញ្ហាទំនាស់ដីធ្លីនានា។
- អ្នកតំណាងភាគច្រើនពាក់ព័ន្ធនៅក្នុងទំនាស់ដីធ្លីជាមួយក្រុមហ៊ុន ដែលទទួលបានដីសម្បទានសេដ្ឋកិច្ចពីរដ្ឋាភិបាល។ មានអ្នកខ្លះ ប្រឈមមុខនឹងការបណ្តេញចេញខណៈដែលអ្នកខ្លះទៀត ត្រូវបានគេរាំងមិនអោយចូលទៅកាន់ទីកន្លែងប្រភពទឹកនានា ជាកន្លែងដែលពួកគេចិញ្ចឹមជីវិតដូចជា ជាអ្នកនេសាទ។ ការប្រមូលផ្តុំគ្នានេះ មានគោលបំណងទាញចំណាប់អារម្មណ៍ទៅ

---

[១៤] "ករណីសិក្សាអំពីការដាក់កំហិតលើការធ្វើដំណើរ និងជួបប្រជុំរបស់សហគមន៍ក្នុងខេត្តចំនួន៦" របាយការណ៍សង្ខេបអង្គការលីកាដូ ពាក់កណ្តាលឆ្នាំ២០១០។

[១៥] "មេដឹកនាំសហគមន៍ប្រមូលផ្តុំគ្នាដើម្បីសិទ្ធិដីធ្លីនៅក្នុងទីក្រុងភ្នំពេញ" អង្គការលីកាដូ ថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១០ (អាចរកមើលបាននៅគេហទំព័រ: http://www.licadho-cambodia.org/articles/20100621/118/index.html)។ សូមមើលផងដែរសារព័ត៌មាន រ៉យតឺ "នាយករដ្ឋមន្ត្រីកម្ពុជាសោកស្តាយចំពោះភាពគ្មានសេចក្តីគោរពរបស់មន្ត្រីអង្គការសហប្រជាជាតិ" ថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១០

លើស្ថានភាពរបស់ពួកគេ និងប្រមូលញត្តិ ដើម្បីយកទៅប្រគល់ជូនលោកនាយករដ្ឋមន្ត្រីហ៊ុន សែន។

- មានអ្នកតំណាងប្រមាណជា ៨០នាក់ មកពីស្រុកមេមត់ ខេត្តកំពង់ចាមជាអ្នកបានមកដល់រាជធានីភ្នំពេញច្រើនថ្ងៃមុន [សូមអានករណីសិក្សា លេខ៦]។
- ក្រុម CPN មានបំណងដើរជាក្បួន ពីវត្តបុទុមឆ្ពោះទៅកាន់គេហដ្ឋានលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ប៉ុន្តែមានកងកំលាំងយោធា និងរាជអាវុធហត្ថប្រមាណជា ២៥នាក់ - ប្រដាប់ដោយដំបងឆក់ របាំងមុខ អាវុធបាញ់បង្ហូរទឹកភ្នែក និងកាំភ្លើងខ្លី - បានខ្ទប់ផ្លូវធ្វើដំណើររបស់ពួកគេ។ មានកំលាំងយោធាប្រដាប់អាវុធ និងនគបាលក្នុងឯកសណ្ឋានស៊ីវិលប្រហែលជា ៥០នាក់ដែលដឹកនាំដោយអភិបាលខណ្ឌលោក សុខ សម្បត្តិ ឈរមើលយ៉ាងប្រយ័ត្នប្រយែងនៅក្បែរទីនោះ។
- ក្នុងអំឡុងពេលជួបប្រជុំគ្នានោះព្រះសង្ឃ លួន សុវ៉ាត [សូមអានករណីសិក្សាលេខ១] បានប្រឈមមុខជាមួយអាជ្ញាធរ ដោយសារតែព្រះអង្គបានថតរូបភាព។ នគបាលបានចោទព្រះអង្គថា ជាសង្ឃក្លែងក្លាយហើយក៏ថតរូបរបស់គាត់។ ជាចុងក្រោយពួកគេបានបញ្ជូនសារមួយចេញមកពីព្រះសង្ឃជាន់ខ្ពស់តំរូវអោយព្រះសង្ឃសុវ៉ាតវិលត្រលប់ទៅកាន់វត្តអារាមរបស់ព្រះអង្គវិញ។ ព្រះសង្ឃ សុវ៉ាត បានជំទាស់នឹងបញ្ហានេះ និងបន្តថតរូបតទៅទៀត។ បន្ទាប់មកអាជ្ញាធរប៉ុនប៉ងធ្វើការចាប់ខ្លួនព្រះអង្គមុនពេល ដែលព្រះអង្គបានចាកចេញពីទីកន្លែងជួបជុំគ្នានោះ។
- តំណាងមកពីការិយាល័យនាយករដ្ឋមន្ត្រី នៅទីបំផុតទទួលយកញត្តិចំនួនបីប្រអប់ និងស្នើសុំអោយតំណាងអ្នកភូមិទាំងអស់វិលត្រលប់ទៅលំនៅដ្ឋានវិញ។
- លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានរិះគន់ក្រុមសិទ្ធិមនុស្ស ដោយហៅពួកគេថាជា "អង្គការស្រមោល" និងបានចោទប្រកាន់ពួកគេថា បានរៀបចំបាតុកម្មនេះ។

►►►
១៣ កក្កដា ២០១០
រាជធានីភ្នំពេញ

**ករណីសិក្សា ៨**

**រដ្ឋាភិបាលដកយកវិញច្បាប់អនុញ្ញាត សំរាប់ការជួបប្រជុំដោយសន្តិវិធី**[១៦]

- ក្រសួងមហាផ្ទៃ បានដកយកច្បាប់អនុញ្ញាតសំរាប់ការប្រមូលផ្តុំរបស់អ្នកជាតិនិយម ដែលគ្រោងធ្វើឡើងដោយក្រុមប្រឹក្សាឃ្លាំមើលកម្ពុជា (CWC) នៅថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ២០១០។ ការជួបប្រជុំគ្នានេះគ្រោងប្រព្រឹត្តិទៅនៅមុខវត្តបុទុមក្នុងរាជធានីភ្នំពេញ។ អ្នកនាំពាក្យក្រសួងមហាផ្ទៃ លោក ខៀវ សុភ័គ្រ បាន

[១៦] គីម យុទ្ធនា "ក្រុមឃ្លាំមើលនឹងបន្តធ្វើការជួបប្រជុំគ្នា" សារព័ត៌មានភ្នំពេញប៉ុស្តិ៍ ថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០១០ គីម យុទ្ធនា និងថេត សម្បត្តិ " នគរបាលបំបែក ក្រុមអ្នកតវ៉ាប្រឆាំងនឹងថៃ" ភ្នំពេញប៉ុស្តិ៍ ថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១០។

ថ្លែងថា ការប្រមូលផ្តុំធ្វើឡើងដើម្បីបរិហារពីការចូលឈ្លានពានរបស់ប្រទេសថៃនៅតំបន់ប្រាសាទព្រះវិហារ ដែលមានទំនាស់នោះមិនមានផ្តល់ផលប្រយោជន៍អ្វីទេ។

- ការជួបប្រជុំគ្នានេះបានប្រព្រឹត្តទៅ ប៉ុន្តែមានទាហាន និងនគបាលចំនួន ១៥០ នាក់ - ចំនួនច្រើនជាងបាតុករ - បង្ខំអោយអ្នកប្រមូលផ្តុំបំបែកជួរ និងចាកចេញពីទីនោះ។
- ពិធីជួបជុំ ត្រូវបានប្តូរទៅប្រារព្ធធ្វើនៅការិយាល័យឯកជនមួយក្នុងខណ្ឌចំការមន ប៉ុន្តែនៅតែស្ថិតក្រោមការឃោមកាមយ៉ាងតឹងតែងពីនគរបាល។

►►► ១២-១៤ កក្កដា ២០១០ រាជធានីភ្នំពេញ

**ករណីសិក្សា ៩**

**យោធិនពិការ ៥នាក់ត្រូវបានចាប់ខ្លួន បន្ទាប់ពីតវ៉ារឿងដីធ្លី**[១៧]

- មានអ្នកតវ៉ាប្រមាណជា ១៦០នាក់ បានប្រមូលផ្តុំគ្នានៅខាងក្រៅផ្ទះវីឡាលោក ហ៊ុន សែន នៅរាជធានីភ្នំពេញដើម្បីទាមទាររាជរដ្ឋាភិបាលអោយធ្វើតាមការសន្យាផ្តល់ដីសម្បទានទំហំ ៤០០០ហិកតាដល់ប្រជាពលរដ្ឋ ៦២០គ្រួសារក្នុងខេត្តក្រចេះ។ ក្រុមគ្រួសារទាំងនេះមានមេគ្រួសារសុទ្ធតែជាយោធិនពិការ។ មន្ត្រីមូលដ្ឋានបាននិយាយក្នុងខែមេសាថា ដីសម្បទាននេះត្រូវបានគេផ្តល់ទៅអោយក្រុមហ៊ុនឯកជនជាជំនួសវិញ។
- តំណាងរាជរដ្ឋាភិបាលបានប្រមូលយកស្នាមមេដៃពីក្រុមអ្នកតវ៉ា ហើយសន្យាដោះស្រាយបញ្ហានេះ និងបានបញ្ចុះបញ្ចូលអោយពួកគេចាកចេញទៅ។ ប៉ុន្តែយោធិន ៥នាក់ត្រូវបានចាប់ខ្លួននៅពេលដែលពួកគេកំពុងតែធ្វើដំណើរទៅកាន់លំនៅដ្ឋានវិញ។
- តំណាងមកពីអង្គការ អាដហុក បាននិយាយថា នគរបាលគំរាមកំហែងអ្នកភូមិអោយបញ្ឈប់ការតវ៉ារបស់ពួកគេ មុនការសំរេចដោះលែងពួកគេ។
- នៅថ្ងៃទី៣០ ខែសីហា មានយោធិនពិការពីរនាក់ត្រូវបានចាប់ខ្លួននៅក្នុងភូមិរបស់ពួកគេក្នុងខេត្តក្រចេះ។ ពួកគេត្រូវបានចោទប្រកាន់ថា "បានគំរាមកំហែងមន្ត្រីអភិរក្សសត្វព្រៃ" ហើយត្រូវបានជាប់ឃុំឃាំងជាបណ្តោះអាសន្នរង់ចាំការស៊ើបអង្កេត។
- ពាក្យបណ្តឹងបានចោទប្រកាន់ដោយគ្មានភស្តុតាងថា បុរសទាំងពីរនាក់គឺជា "មេខ្យល់ និងបានញុះញង់ប្រជាពលរដ្ឋ ៥០០នាក់អោយមកចាប់យកដី"។ បុរសពីរនាក់នេះប្រឈមមុខនឹងការជាប់ពន្ធនាគាររយៈពេល ៥ឆ្នាំ បើសិនជារកឃើញថាមានកំហុស។

---

[១៧] មេឃ ទិត្ថារ៉ា "យោធិនពិការ ៥នាក់ត្រូវបានចាប់ខ្លួនបន្ទាប់ពីបានតវ៉ារឿងដីធ្លី" ភ្នំពេញប៉ុស្ត៍ ថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០១០។ ឆាយ ចាន់ឌីណា "យោធិនពិការត្រូវបានចាប់ខ្លួនក្នុងខេត្តក្រចេះ" ភ្នំពេញប៉ុស្ត៍ ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១០។

►►►
២១ កក្កដា ២០១០
រាជធានីភ្នំពេញ

**ករណីសិក្សា ១០**

## អាជ្ញាធរហាមឃាត់បាតុកម្មដោយសន្តិវិធីរបស់កម្មកររោងចក្រកាត់ដេរ[១៨]

- អាជ្ញាធររាជធានីភ្នំពេញ បដិសេធសំណើររបស់សម្ព័ន្ធសហជីពកម្មករកម្ពុជា (CLC) និងសម្ព័ន្ធសហជីពជាតិកម្ពុជា (CNC) ធ្វើបាតុកម្មនៅខាងមុខវត្តបុទុមនៅថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១០។ នៅថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០១០ អាជ្ញាធររាជធានីភ្នំពេញជាក់ស្តែងបានហាមឃាត់ការប្រមូលផ្តុំដោយផ្អែកលើមូលដ្ឋាន៖ ១) ប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ ២) គំរាមកំហែងសុវត្ថិភាពសាធារណៈ និង ៣) បង្កអោយខូចខាតទ្រព្យសម្បត្តិសាធារណៈ។ ពីរថ្ងៃក្រោយមកក្រសួងមហាផ្ទៃបញ្ជាក់ការគាំទ្រចំពោះការហាមឃាត់នេះ។
- បាតុកម្ម ត្រូវបានរៀបចំឡើងដើម្បីតវ៉ាចំពោះសេចក្តីសំរេចនាពេលថ្មីៗយល់ព្រមតម្លើងប្រាក់ឈ្នួលអប្បរមា ៥ដុល្លារដល់កម្មកររោងចក្រកាត់ដេរជាតម្លៃដែលសមាជិកសហជីពកម្មករអះអាងថា មិនគ្រប់គ្រាន់ទៅនឹងការចំណាយសំរាប់ការរស់នៅដែលមានតម្លៃចេះតែកើនឡើង។
- នៅនាទីចុងក្រោយបំរាមចំពោះបាតុកម្មនេះត្រូវបានលុបចោល។ នៅថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១០ មានកម្មកររវាង ៣,៥០០នាក់ ទៅ ៤,៥០០នាក់ធ្វើបាតុកម្មដោយសន្តិវិធីនៅខាងមុខរដ្ឋសភាជាតិ បើទោះបីជានគរបាលបានដាក់របាំងបិទផ្លូវ និងប្រើយុទ្ធសាស្ត្រផ្សេងៗ ដើម្បីរារាំងបាតុករពីការប្រមូលផ្តុំគ្នាក៏ដោយ។
- មិនមានសេចក្តីរាយការណ៍ពីការខូចខាតទ្រព្យសម្បត្តិ ឬរំខានដល់សណ្តាប់ធ្នាប់សាធារណៈទេ។

[១៨] សេចក្តីថ្លែងការរួម អង្គការលីកាដូ ថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១០។ ព័ត៌មានវិទ្យុអាស៊ីសេរី ថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០១០។

►►►
២៧ កក្កដា ២០១០
រាជធានីភ្នំពេញ

**ករណីសិក្សា ១១**

## នគរបាលវាយដំលើកម្មកររោងចក្រកាត់ដេរ ៩នាក់ក្នុងអំឡុងពេលបាតុកម្ម[១៩]

- យ៉ាងហោចណាស់មានកម្មកររោងចក្រកាត់ដេរភេទស្រី ៩នាក់បានរងរបួស នៅថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១០ នៅពេលដែលនគរបាលវាយដំលើពួកគេ ដោយដំបងឆក់ និងរបាំងមុខ។ មានកំលាំងនគរបាលជាង ១០០នាក់បាន ចូលទៅបំបែកបាតុកម្មដែលរៀបចំឡើងដោយកម្មករ ដែលបានធ្វើកូដកម្ម។
- មានសមាជិកសហជីពកម្មករប្រមាណជា ៣,០០០នាក់ ចូលរួមក្នុងកូដកម្ម ដើម្បីទាមទារអោយតំណាងសហជីព ដែលគេបណ្តេញចេញពីការងារបាន ចូលធ្វើការឡើងវិញ។ នគរបាលប្រដាប់ដោយគ្រឿងបំពាក់ការពារកុប្បកម្ម និងកាំភ្លើងបានចូលមកព្យាយាមបង្ខំស្ត្រីទាំងនោះ អោយវិលត្រលប់ទៅធ្វើការ ងារវិញ។ នគរបាលខិតខំអនុវត្តសេចក្តីបង្គាប់របស់តុលាការអោយបើកផ្លូវ និង បង្ខំស្ត្រីកម្មករអោយចូលធ្វើការងារវិញ។
- រោងចក្រកាត់ដេរគ្រប់គ្រងដោយ PCCS Garments ជាក្រុមហ៊ុនរបស់ប្រទេស ម៉ាឡេស៊ី ដែលផលិតសំលៀកបំពាក់សំរាប់ម៉ាកយីហោល្បីៗជាអន្តរជាតិរួម មាន Gap, Benetton, Adidas និង Puma ។

►►►
៨ សីហា ២០១០
រាជធានីភ្នំពេញ

**ករណីសិក្សា ១២**

## ការប្រើកំលាំងហួសហេតុទៅលើការប្រមូលផ្តុំដោយសន្តិវិធីរបស់អ្នកភូមិក្នុងរាជធានីភ្នំពេញ[២០]

- អ្នកភូមិមកពីខេត្តបាត់ដំបងមួយក្រុមមានគ្នាជិត ៥០នាក់ត្រូវបានបំបែកចេញ ដោយហិង្សានៅជិតផ្ទះវីឡាលោក ហ៊ុន សែន ខណៈពេលដែលពួកគេ ព្យាយាមផ្សព្វផ្សាយអោយគេបានដឹងលឺ អំពីទំនាស់ដីធ្លីមានរយៈពេលយូរ មួយ។
- អ្នកភូមិបានជួបជុំគ្នា ដោយសន្តិវិធីចំងាយ ១០០ម៉ែត្រពីផ្ទះវីឡាលោកនាយក រដ្ឋមន្ត្រី។ ក្រុមនេះរួមមានស្ត្រី កុមារ និងទារក។ ដំណើរនេះរៀបចំឡើងក្នុង គោលបំណងផ្សព្វផ្សាយអោយគេបានដឹងលឺ អំពីទំនាស់ដីធ្លីអស់រយៈពេលជា យូរមួយរវាងអ្នកភូមិ និងអាជ្ញាធរមូលដ្ឋាន ដែលរួមមានទាំងសមាជិកកង យោធពលខេមរភូមិន្ទផង។ ទំនាស់ដីធ្លីនេះពាក់ព័ន្ធជាមួយ ៤០០គ្រួសារក្នុង ឃុំដូនបា ស្រុកគាស់ក្រឡ ខេត្តបាត់ដំបង។
- ក្រុមអ្នកភូមិសំរាកមួយយប់នៅវត្តបុទុម ហើយពួកគេបានដើរទៅគេហដ្ឋាន

---

[១៩] ប្រាក់ ចាន់ថុល "កម្មកររោងចក្រកាត់ដេរកម្ពុជាប៉ះទង្គិចគ្នាជាមួយនគរបាល" រយទ័រ ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១០។ រីឆាដ សៀ " កម្មករភេទស្រីធ្វើការ នៅរោងចក្រកាត់ដេរសំលៀកបំពាក់សំរាប់ Gap និង Adidas ទទួលបានប្រាក់ឈ្នួល ១ដោនក្នុងមួយថ្ងៃដែលធ្វើកូដកម្មត្រូវបានវាយដំដោយនគរបាលបង្ក្រាប កុប្បកម្ម" ដំណឹងប្រចាំថ្ងៃ (UK) ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១០។

[២០] "ការប្រើកំលាំងហួសប្រមាណប្រឆាំងចំពោះជួបប្រជុំដោយសន្តិវិធីរបស់ប្រជាពលរដ្ឋក្នុងរាជធានីភ្នំពេញ" សេចក្តីថ្លែងការណ៍អង្គការលីកាដូ ថ្ងៃទី៨ ខែ សីហា ឆ្នាំ២០១០ មាននៅគេហទំព័រ (http://www.licadho-cambodia.org/pressrelease.php?perm=225&pagenb=&filter=) ។

លោកនាយករដ្ឋមន្ត្រី ដែលនៅទីនោះពួកគេបានប្រឈមមុខដាក់គ្នាជាមួយនគរបាល និងកងរាជអាវុធហត្ថ។ ពេលនោះអ្នកភូមិបាននាំគ្នាអង្គុយដោយស្ងាត់ស្ងៀម។ អ្នកភូមិបានទាមទារអោយអ្នកតំណាងនៃខុទ្ទកាល័យនាយករដ្ឋមន្ត្រីស្តាប់ពីរឿងទុក្ខសោករបស់ពួកគេ និងសុំអោយចេញជាលិខិតមួយច្បាប់ប្រាប់ទៅអជ្ញាធរអោយធ្វើការដោះស្រាយទំនាស់ដីធ្លីនេះ។

- មន្ត្រីរដ្ឋាភិបាល - អមដោយកំលាំងនគរបាល កងរាជអាវុធហត្ថ និងសន្តិសុខមានចំនួនច្រើនឡើងៗ - បានឆ្លើយតបដោយប្រកាសថា អ្នកភូមិគ្មានសិទ្ធិមកប្រមូលផ្តុំគ្នានៅទីសាធារណៈនេះទេ។ ពួកគេទទូចអោយអ្នកភូមិវិលត្រលប់ទៅខេត្តបាត់ដំបងវិញ និងទុកអោយអជ្ញាធរមូលដ្ឋានដោះស្រាយទំនាស់។ ជិតដល់ពេលថ្ងៃត្រង់ មានរថយន្តក្រុងធំៗបានមកដល់ទីកន្លែងអង្គុយផ្តុំគ្នារបស់អ្នកភូមិ។ នៅពេលដែលអ្នកភូមិជំទាស់មិនឡើងជិះរថយន្តក្រុងនគរបាលបានប្រើកំលាំងបង្ខំពួកគេអោយឡើង។

►►► ៩ សីហា ២០១០ ខេត្តបាត់ដំបង

**ករណីសិក្សា ១៣**

### អាជ្ញាធរចាប់ខ្លួនបុរសម្នាក់ទាក់ទងទៅនឹងការតវ៉ារឿងដីធ្លី[២១]

- អាជ្ញាធរខេត្តបាត់ដំបងចាប់ខ្លួនអ្នកតវ៉ារឿងដីធ្លីម្នាក់ ដោយចោទប្រកាន់ពីបទប្លន់ បន្ទាប់ពីគាត់បានវិលត្រលប់មកពីចូលរួមក្នុងបាតុកម្មតវ៉ារឿងដីធ្លីនៅរាជធានីភ្នំពេញ [សូមអានករណីសិក្សាលេខ ១១]។
- អ្នកតវ៉ាឈ្មោះ ង៉ា មុក បានធ្វើដំណើរមករាជធានីភ្នំពេញនាពេលថ្មីៗនេះជាមួយអ្នកភូមិដទៃទៀត ហើយបានឈរតវ៉ានៅពីមុខអាគារគណៈរដ្ឋមន្ត្រី។ ពួកគេចំណាយពេលពីរថ្ងៃនៅ ក្នុងរាជធានីក្នុងកិច្ចខិតខំនាំអោយមានការយកចិត្តទុកដាក់ចំពោះទំនាស់ដីធ្លីនៅស្រុកគាស់ក្រឡ ខេត្តបាត់ដំបង។ គាត់ត្រូវបានគេចាប់ខ្លួននៅពេលដែលគាត់ត្រលប់មកផ្ទះវិញ។
- អ្នកភូមិផ្សេងទៀតបានរាយការណ៍ថា យោធា និងកំលាំងស៊ីវិលបានហ៊ុំព័ទ្ធភូមិរបស់ពួកគេចាប់តាំងពីពេលនោះមក ដើម្បីរារាំងអ្នកណាម្នាក់ដែលចង់ចេញពីភូមិមកធ្វើបាតុកម្ម។

[២១] ព័ត៌មានវិទ្យុអាស៊ីសេរី ថ្ងៃទី១១ ខែសីហា ឆ្នាំ២០១០។

►►►
១៩-២៦ សីហា ២០១០
រាជធានីភ្នំពេញ

**ករណីសិក្សា ១៤**

**អាជ្ញាធរបង្ក្រាបកម្មកររោងចក្រកាត់ដេរ ស៊ុនលី ហ្វុង ដែលធ្វើកូដកម្ម[២២]**

- យ៉ាងហោចណាស់មានកម្មកររោងចក្រកាត់ដេរ ស៊ុនលី ហ្វុងចំនួន ១៦០នាក់ ក្នុងខណ្ឌមានជ័យ រាជធានីភ្នំពេញបានដើរចេញពីការងារនៅថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១០ ក្នុងគោលបំណងទាមទារនូវការធ្វើអោយលក្ខខ័ណ្ឌការងារមានភាពប្រសើរឡើង។
- ក្នុងរយៈពេលបួនថ្ងៃនៃការធ្វើកូដកម្ម និងមុនពេលតុលាការចេញសេចក្តីបង្គាប់ - នគរបាលបានព្រមានអ្នកតវ៉ាថា សន្តិសុខរបស់ពួកគេនឹងមិនត្រូវ "បានធានា"ទេ ប្រសិនបើពួកគេនៅបន្តធ្វើកូដកម្ម។
- កូដកម្មបានបន្តធ្វើដោយរដិបរដុបអស់រយៈពេលមួយសប្តាហ៍ គឺដល់ថ្ងៃទី២៦ ខែសីហា ជាពេលដែលអាជ្ញាធរបានបង្ហាញសេចក្តីបង្គាប់របស់តុលាការដែលប្រកាសថាកូដកម្ម គឺជាកូដកម្មមិនស្របច្បាប់ និងបញ្ជាអោយនយោជិតវិលត្រលប់ចូលធ្វើការវិញ។ សេចក្តីបង្គាប់បានផ្តល់ការអនុញ្ញាតដល់រោងចក្រធ្វើការបណ្តេញចេញពីការងារនូវអ្នករៀបចំសហជីព ដែលទទួលខុសត្រូវចំពោះកូដកម្មនេះ។
- មេដឹកនាំសហជីព ៣នាក់មានឈ្មោះ អៀន ពៅ ឈ្មោះហេង បូរ៉ា និងណុន ចំណាន ក្រោយមកបានប្រឈមមុខនឹងបទព្រហ្មទណ្ឌញុះញង់ និងបំផ្លិចបំផ្លាញទ្រព្យសម្បត្តិឯកជន។ ករណីចោទប្រកាន់ប្រឆាំងនឹងពួកគេទាំងនេះនៅកំពុងតែរង់ចាំការសំរេចពីតុលាការ។

►►►
២៣ សីហា ២០១០
រាជធានីភ្នំពេញ

**ករណីសិក្សា ១៥**

**នគបាលបំបែកការប្រជុំរបស់អ្នករស់នៅភូមិបឹងកក់ដែលប្រឈមនឹងគ្រោះថ្នាក់នៃការបណ្តេញចេញ[២៣]**

- មន្ត្រីនគរបាលរាជធានីប្រមាណជា ២០០នាក់ បានបំបែកការប្រជុំរបស់ អ្នករស់នៅតំបន់បឹងកក់ ដែលបានប្រមូលផ្តុំគ្នាពិភាក្សាលើផលប៉ះពាល់បរិដ្ឋានដោយសារការអភិវឌ្ឍបឹង។
- កិច្ចប្រជុំ បានប្រព្រឹត្តទៅនៅបរិវេណនៃវិទ្យាស្ថានជាតិអប់រំនៅជិតគេហដ្ឋានលោកនាយករដ្ឋមន្ត្រី។ របៀបវារៈនៃកិច្ចប្រជុំរួមមាន ការពិភាក្សាលើការកើនឡើងទឹកជំនន់ដ៏ធ្ងន់ធ្ងរដោយសារភ្លៀងពីដំបូង និងការចាក់ដីបំពេញបឹង។ ក្រុមហ៊ុនអភិវឌ្ឍ Shukaku, Inc.បានចាក់ដីបំពេញបឹង និងចាប់ផ្តើមដំណើរការ

[២២] ទេព និមល "កូដកម្មអំពីការបង់ប្រាក់ឈ្នួលកម្មករកាត់ដេរបន្ត" កាសែតភ្នំពេញប៉ុស្តិ៍ ថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១០។ ទេព និមល "តុលាការបង្គាប់អោយបុគ្គលិក ស៊ុនលី ហ្វុង ត្រលប់ចូលធ្វើការវិញក្នុងរយៈពេល ៤៨ម៉ោង" កាសែតភ្នំពេញប៉ុស្តិ៍ ថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១០។ ឆាយ ចាន់ឌីណា "កោះហៅសាក្សីក្នុងការស៊ើបអង្កេតរឿងកូដកម្ម" កាសែតភ្នំពេញប៉ុស្តិ៍ ថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១០។

[២៣] ព័ត៌មានវិទ្យុអាស៊ីសេរីថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១០ (ការផ្សាយព័ត៌មាននាម៉ោង ៨.៣០នាទីយប់)។ "អ្នករស់នៅភូមិបឹងកក់ត្រូវបានបដិសេធសេរីភាពក្នុងការជួបប្រជុំ" សេចក្តីប្រកាសព័ត៌មាននៃក្រុមការងារពិសេសសិទ្ធិលំនៅដ្ឋានថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១០។ កាសែតភ្នំពេញបុស្តិ៍ថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១០។ យុត សុភក្តិចរិយា "អ្នករស់នៅភូមិបឹងកក់ រាយការណ៍ពីការភ័យខ្លាចចំពោះកលល្បិច" ភ្នំពេញបុស្តិ៍ ថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១០។

ការងារអភិវឌ្ឍន៍លក្ខណៈពាណិជ្ជកម្មលើទំហំដី ១៣៣ហិកតា។ ក្រុមហ៊ុនកំពុងតែព្យាយាមបង្ខំគ្រួសារប្រជាពលរដ្ឋភាគច្រើន ដែលរស់នៅតំបន់នោះអោយផ្លាស់ទីលំនៅ ប៉ុន្តែអ្នករស់នៅតំបន់នេះនិយាយថា ពួកគេមិនត្រូវគេផ្តល់អោយនូវសំណងសមរម្យទេ។ ក្រុមហ៊ុន Shukaku Inc. មានម្ចាស់ជាសមាជិកព្រឹទ្ធសភាមកពីគណបក្សប្រជាជនកម្ពុជាគឺលោក ឡៅ ម៉េងឃីន។

- ឧត្តមសេនីយ ទូច ណារថ ស្នងការនគរបាលរាជធានីភ្នំពេញបាននិយាយថា គាត់មានការទទួលខុសត្រូវដើម្បី "ធានានូវសណ្តាប់ធ្នាប់សាធារណៈ"។
- ពេលនោះមានអ្នកភូមិប្រហែលជា ១០០នាក់បានចេញទៅឈរតវ៉ានៅវិមានឯករាជ្យ។ ពួកគេបានជួបជាមួយនឹងកំលាំងប្រដាប់អាវុធ - ប្រដាប់ដោយគ្រឿងបំពាក់ការពារកុប្បកម្ម និងកាំភ្លើង - បញ្ឈប់ក្បួនតវ៉ានេះ។
- នៅខែកញ្ញា អ្នករស់នៅតំបន់នេះបានរាយការណ៍ថា អជ្ញាធរមូលដ្ឋាន និង "បុគ្គលិកដែលពាក់ម៉ាស់បិទមុខរបស់ក្រុមហ៊ុន Shukaku បានប្រើវិធីរបៀបភ័យខ្លាចផ្សេងៗ ដើម្បីធ្វើយ៉ាងណាបង្ខំពួកគេអោយយល់ព្រមទទួលយកសំណងមិនសមស្របជាកញ្ចប់ និងចាកចេញពីផ្ទះសំម្បែងរបស់ខ្លួន"។

▶▶▶
កញ្ញា ២០១០
រាជធានីភ្នំពេញ

**ករណីសិក្សា ១៦**

**ម្ចាស់ឧស្សាហកម្មកាត់ដេរសំលៀកបំពាក់ប្រើប្រាស់តុលាការកំទេចសហជីពកម្មករបន្ទាប់ពីកូដកម្មស្របច្បាប់[២៤]**

- កម្មករកាត់ដេររាប់ពាន់នាក់នៅទូទាំងប្រទេស បានដើរចេញពីការងារនៅថ្ងៃទី ១៣ ខែកញ្ញា ឆ្នាំ២០១០ ដើម្បីទាមទាអោយមានការតម្លើងប្រាក់ឈ្នួលអប្បរមា។ ការដើរចេញពីការងារធ្វើឡើងដើម្បីឆ្លើយតបទៅនឹងការសំរេចចិត្តរបស់រាជរដ្ឋាភិបាលពីខែកក្កដា ក្នុងការតម្លើងប្រាក់ឈ្នួលអប្បរមាដល់ ៦១ ដុល្លាសហរដ្ឋអាមេរិកក្នុងមួយខែ (តម្លើង៥ដុល្លាសហរដ្ឋអាមេរិក) ដែលតាមពិតទៅ សហជីពភាគច្រើនបានសុំអោយតម្លើងដល់ ៩៣ដុល្លាសហរដ្ឋអាមេរិកក្នុងមួយខែ។ មេដឹកនាំសហជីពបានជូនដំណឹងជាមុនជាង ២ខែ ទៅខាងរោងចក្រ និងរាជរដ្ឋាភិបាលអំពីគំរោងកូដកម្មរបស់ខ្លួន ។

[២៤] សំណុំរឿងផ្ទៃក្នុងអង្គការលីកាដូ។ សារព័ត៌មានកម្ពុជាថ្មីថ្ងៃទី២០ ខែសីហា ឆ្នាំ២០១០។ មុំ គន្ធា "កម្មកររាប់ពាន់នាក់ចូលរួមក្នុងកូដកម្មជាតិ" សារព័ត៌មានភ្នំពេញប៉ុស្ត៍ ថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១០។ គីម យុត្តាណា និងប្រូក ឡេវីស "កូដកម្មត្រូវបញ្ជាអោយបញ្ឈប់មុនពេល" សារព័ត៌មានភ្នំពេញប៉ុស្ត៍ ថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១០។ គន្ធា និងងួនសុវណ្ណ "នគរបាលប៉ះទង្គិចគ្នាជាមួយកម្មករកាត់ដេរ" សារព័ត៌មានភ្នំពេញប៉ុស្ត៍ ថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១០។ ងួនសុវណ្ណ "ថវិកាចំនួន ១៤លានដុល្លាសហរដ្ឋអាមេរិកបានខាតបង់ដោយសារកូដកម្ម" សារព័ត៌មានភ្នំពេញប៉ុស្ត៍ ថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១០។ មុំ គន្ធា និងប្រូក ឡេវីស "រដ្ឋាភិបាល កម្មករប្រកួតគ្នាតាមតុលាការ" សារព័ត៌មានភ្នំពេញប៉ុស្ត៍ ថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១០។ មុំ គន្ធា "កម្មករបន្តកូដកម្ម" សារព័ត៌មានភ្នំពេញប៉ុស្ត៍ ថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១០។ មុំ គន្ធា "រដ្ឋចោទសួរទៅមេដឹកនាំសហជីពកម្មករអំពីការបំភិតបំភ័យ" សារព័ត៌មានភ្នំពេញប៉ុស្ត៍ ថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១០។ មុំ គន្ធា "ក្រុមថ្មី សំរាប់ដោះស្រាយកូដកម្ម" កាសែតភ្នំពេញប៉ុស្ត៍ ថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០១០។ មុំ គន្ធា "កម្មករត្រូវបានបញ្ឈប់ពីការងារដោយសារកូដកម្មខុសច្បាប់" សារព័ត៌មានភ្នំពេញប៉ុស្ត៍ ថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១០។ មុំ គន្ធា "កម្មកររាប់ពាន់នាក់ត្រូវបានប្រាប់ មិនអោយមកចូលធ្វើការវិញ" សារព័ត៌មានភ្នំពេញប៉ុស្ត៍ ថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១០។ មុំ គន្ធា "តំណាងសហជីពកម្មករ ២២នាក់បានត្រលប់ចូលធ្វើការងារវិញ" សារព័ត៌មានភ្នំពេញប៉ុស្ត៍ ថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១០។

កូដកម្មបានកំណត់ធ្វើសំរាប់រយៈពេល ៥ថ្ងៃ ប៉ុន្តែមេដឹកនាំសហជីពបានប្រាប់ទៅកម្មករអោយបញ្ចប់វិញនៅថ្ងៃទី១៦ ខែកញ្ញា បន្ទាប់ពីក្រសួងសង្គមកិច្ចបានអញ្ជើញនយោជក និងតំណាងសហជីពមកប្រជុំនៅថ្ងៃទី២៧ ខែកញ្ញា ដើម្បីពិភាក្សាពី "ផលប្រយោជន៍ផ្សេងៗ" បន្ថែមពីលើប្រាក់ឈ្នួលអប្បរមា។ ការតវ៉ានោះប្រព្រឹត្តទៅដោយសន្តិវិធី ប៉ុន្តែយ៉ាងហោចណាស់មានកម្មករពីរនាក់បានរងរបួស - នយោជិតភេទស្រីអាយុ ២៨ឆ្នាំនៃរោងចក្រ ថប វើល (Top World) ស្ថិតក្នុងខេត្តកណ្តាល និងនយោជិកភេទប្រុសអាយុ ២៩ឆ្នាំ និងមន្ត្រីសហជីពមកពីរោងចក្រនៅក្បាលកោះ ខេត្តកណ្តាល។ មន្ត្រីសហជីពទាំងនេះត្រូវបានចាប់ខ្លួនផងដែរ។

### *តុលាការចូលមកពាក់ព័ន្ធ នាំអោយមានកូដកម្មបន្ត*

- កម្មករបានត្រលប់ចូលធ្វើការតាមរោងចក្រពួកគេវិញនៅថ្ងៃបន្ទាប់ ហើយបានដឹងថា អ្នកដឹកនាំរៀបចំសហជីពរាប់រយនាក់ត្រូវបានរោងចក្រព្យួរការងាររបស់ពួកគេ។ ម្ចាស់រោងចក្របានចាត់ទុកកូដកម្មថា "ខុសច្បាប់"។ ការព្យួរការងារអ្នកសហជីពមានការគាំទ្រដោយសេចក្តីបង្គាប់របស់តុលាការ។ នៅលើកដំបូងនៃការព្យួរការងារ យ៉ាងហោចណាស់មានចៅក្រមកម្ពុជាផ្សេងៗគ្នា ៦រូបបានចេញសេចក្តីបង្គាប់អនុញ្ញាតអោយម្ចាស់រោងចក្រព្យួរការងាររបស់តំណាងសហជីពជិត ២០០នាក់។ សេចក្តីបង្គាប់តុលាការបានចេញបន្ទាប់ពីមេដឹកនាំសហជីពបានចរចារ ដោយសន្តិវិធីបញ្ចប់ការធ្វើកូដកម្មរបស់ខ្លួនមុនពេលកំណត់។
- មានរោងចក្រយ៉ាងហោចណាស់ក៏ ១០ដែរ ដែលបានដាក់ពាក្យប្តឹងប្រឆាំងនឹងសហជីព ដោយទាមទារសំណងចំពោះការខាតបង់ប្រាក់ចំណូលមានតំលៃប៉ាន់ស្មាន ១៥លានដុល្លាសហរដ្ឋអាមេរិក។
- ព្រឹត្តិការត្រលប់ក្រោយនេះ នាំអោយកើតមានភ្លាមៗនូវការដើរចេញពីការងារជាលើកទី២នៃកម្មកររាប់ពាន់នាក់ ដោយពួកគេបានទាមទារអោយមេដឹកនាំសហជីពបានត្រលប់ចូលធ្វើការងារវិញ។
- ខាងរោងចក្រក៏បានទទួលសេចក្តីបង្គាប់របស់តុលាការ ប្រកាសពីភាពខុសច្បាប់នៃកូដកម្មលើកទី២ និងតំរូវអោយកម្មករត្រលប់ចូលធ្វើការងារវិញ ឬក៏ប្រឈមមុខនឹងការបណ្តេញចេញពីការងារ។ មកដល់ត្រឹមថ្ងៃទី២១ ខែកញ្ញា កម្មកររាប់ពាន់នាក់មិនអនុវត្តតាមបង្គាប់តុលាការ។ ពួកគេត្រូវបានទុកពេលអោយរយៈពេល ៤៨ម៉ោងសំរាប់ត្រលប់ចូលធ្វើការងារវិញ ឬក៏ប្រឈមមុខនឹងការបណ្តេញចេញ ។

*ការបំភិតបំភ័យ និងគំរាមកំហែង*

- នគរបាលប្រើកំលាំងបង្ក្រាបលើកូដកម្មលើកទី២។ នៅថ្ងៃទី១៨ ខែកញ្ញាមានកម្មករ ១២នាក់បានរងរបួសក្នុងពេលប៉ះទង្គិចគ្នាជាមួយនគរបាលខាងក្រៅរោងចក្រនៅរាជធានីភ្នំពេញ និងខេត្តកណ្តាល។ ស្ត្រីកម្មករម្នាក់នៃរោងចក្រ រីវើ រេច ត្រូវបានបញ្ជូនទៅព្យាបាលនៅមន្ទីរពេទ្យដោយសារមានបញ្ហាបេះដូងបន្ទាប់ពីគាត់ត្រូវបាននគរបាលប្រើដំបងឆក់ឆក់គាត់។
- បន្ទាប់ពីកូដកម្ម យ៉ាងហោចណាស់មានមេដឹកនាំកម្មករបីនាក់អះអាងថា ពួកគេទទួលរងការបំភិតបំភ័យតាមរយៈទូរស័ព្ទ និងតាមសារ SMS។ ពួកគេក៏អះអាងផងដែរថា ពួកគេត្រូវបានតាមយាមឃើ និងជិះម៉ូតូដេញតាមដោយបុរសមិនស្គាល់អត្តសញ្ញាណ។

*ដំណើរឆ្ពោះទៅរកដំណោះស្រាយ*

- នៅឯកិច្ចប្រជុំថ្ងៃទី២៧ ខែកញ្ញា ជាកិច្ចប្រជុំដែលស្នើឡើងដោយក្រសួងសង្គមកិច្ច រដ្ឋាភិបាលបានស្នើសុំអោយរោងចក្រទាំងអស់ទទួលយកកម្មករដែលព្យួរការងារចូលធ្វើការងារវិញ និងអោយបញ្ឈប់បទចោទប្រកាន់តាមផ្លូវតុលាការទាំងអស់ជាថ្នូរទៅនឹងការសន្យាឈប់ធ្វើកូដកម្ម។ សហជីពទាំងអស់បានយល់ព្រមជាគោលការណ៍តាមសំណើរនេះ។
- បន្ទាប់មក មានកម្មករកាត់ដេរ ៣០០០នាក់ក្នុងខេត្តកណ្តាលត្រូវបានបណ្តេញចេញពីការងារ ដោយសារតែពួកគេចូលរួមក្នុងកូដកម្មលេកទី២ បើទោះបីជាកម្មករភាគច្រើន ត្រូវបានគេអនុញ្ញាតអោយចូលធ្វើការវិញ។ សហជីពប្រជាធិបតេយ្យកម្មករ Apparel កម្ពុជាបានរាយការណ៍ថា គិតមកត្រឹមពាក់កណ្តាលខែតុលាមានតំណាងសហជីពកម្មករ ១០៦នាក់ និងកម្មករកម្មាការនី ៦៧៧នាក់មកពីរោងចក្រចំនួន ១៦ ដែលត្រូវបានគេព្យួរការងារ និងមិនទាន់ត្រូវបានអនុញ្ញាតអោយត្រលប់ចូលធ្វើការវិញ។

*ការប្រើពាក្យសំដីដ៏ប្លែកដាក់អោយបរទេស*

- នៅក្នុងការវិវត្តមួយពាក់ព័ន្ធនឹងរឿងនេះដែរ អង្គការលើកលែងទោសអន្តរជាតិបានអំពាវនាវដល់អ្នកគាំទ្រខ្លួនទាំងអស់អោយធ្វើការតវ៉ា ចំពោះការគំរាមកំហែងមេដឹកនាំសហជីព ដោយបានសរសេរលិខិតទៅឯកអគ្គរាជទូតរបស់កម្ពុជាប្រចាំនៅចក្រភពអង់គ្លេស។ ស្ថានទូតបានឆ្លើយតបមកកាន់មនុស្សមួយចំនួនតាមរយៈសារអេឡិចត្រូនិកថា: *"ជូនចំពោះមនុស្សភ្លើលីលាទាំងអស់! សូមកុំលក់ឧត្តមគតិរបស់អ្នកឯងដើម្បីទិញសណ្តែកដីអោយស្វាស៊ី ឬក៏អ្នកឯងទៅផ្ទុះកញ្ជក់ទៅអ្នកឯងនឹងឃើញសត្វសេកហើយ! ការណ៍នេះមិន*

*មែនជារឿងរបស់ពួកអ្នកឯងទាំងអស់គ្នាទេ! សូមរាយការណ៍ទៅមេត្លុករបស់អ្នកឯងរាល់គ្នាអោយបញ្ឈប់ល្បែងបែបកូនក្មេងនេះទៅ........និងឈប់សំដែងសៀករហ៊េសសកម្មបែបនេះភ្លាម? [sic] អរគុណ˝ ["To all of idiots! Don't sell your soul to buy peanuts for the monkeys or if you look at the mirror you see a parrot! It is none of your business ! Please report to your clown boss to stop this childish game ... and stop this circus at once?[sic] Thank you."]*

- សកម្មជនការងាររបស់អង់គ្លេសម្នាក់ បានតាមដានការឆ្លើយឆ្លងនេះដោយទាមទារនូវការឆ្លើយតបប្រកបដោយហេតុផល និងច្បាស់លាស់ ហើយគាត់បានទទួលការឆ្លើយតបមកវិញថា: ˶*សូមទៅកាន់ឋានព្រះច័ន្ទហើយនៅទីនោះរហូតដល់អ្នកឯងទទួលចម្លើយ។ ប្រទេសកម្ពុជាមិនមែនជាផ្នែកមួយនៃចក្រភពអង់គ្លេសទេ។˝*[២៥]

□□□

[២៥] សូមមើលគេហទំព័រ http://www.unionbook.org/profiles/blog/show?id=6287332%3ABlogPost%3A17145&commentId=6287332%3Acomment%3A17380&xg_source=activity ។ ជេមស៍ អូធូល និងមុំ គន្ធា ˶សាកល្បងឋានព្រះច័ន្ទ˝ សារព័ត៌មានភ្នំពេញប៉ុស្តិ៍ ថ្ងៃទី១០ ខែតុលា ឆ្នាំ២០១០។

# ៣. ការប្រើប្រាស់ប្រព័ន្ធតុលាការគំរាមកំហែង និងបំបិទមាត់អ្នករិះគន់

## *ករណីសិក្សា ១៧៖ លាង សុខជឿន: ការបង្ក្រាបអ្នកនាំសំបុត្រ*[២៦]

---

លាង សុខជឿន មិនបានគិតដល់ថាការចាប់ខ្លួនគាត់នឹងមកដល់ទេ។

នាព្រឹកថ្ងៃសៅរ៍ វេលាម៉ោង ៦.១៥នាទី គាត់នៅកំពុងតែសំរាន្តនៅឡើយ។ ថ្ងៃសៅរ៍ គឺជាថ្ងៃដែលគាត់សំរាកពីការងារជាអ្នករត់សំបុត្រនៅអង្គការលីកាដូ ហើយក៏ជាថ្ងៃដែលនគរបាលបានមកចាប់ខ្លួនគាត់ពីផ្ទះដែរ។

មិនមាននរណាម្នាក់សំភាសន៍គាត់ ពីពេលមុនមកទេ ហើយគាត់ក៏មិនបានដឹងថាមានដីការចេញចាប់ខ្លួនគាត់ដែរ។នគរបាលមិនបានប្រាប់គាត់អំពីមូលហេតុ ដែលពួកគេបានមកផ្ទះគាត់ទេ ហើយពួកគេគ្រាន់តែនាំគាត់ទៅកាន់ទីបញ្ជាការអគ្គស្នងការ នគរបាលជាតិក្នុងរាជធានីភ្នំពេញ ដែលនៅទីនោះ គាត់ត្រូវបានដាក់អោយស្ថិតក្នុង*ការផ្តាច់ទំនាក់ទំនង* រយៈពេល ៣៣ម៉ោង។

នគរបាលបានសាកសួរគាត់អំពីការជាប់ពាក់ព័ន្ធរបស់គាត់ក្នុងការចែកចាយ "ខិតប័ណ្ណប្រឆាំងរដ្ឋាភិបាល" នៅក្នុងខេត្តតាកែវកាលពីថ្ងៃទី៤ ខែមករា។ លោក សុខជឿន មានការច្របូកច្របល់ក្នុងចិត្ត។ គាត់មិនដែលបានចែកចាយខិតប័ណ្ណម្តងណាឡើយ ហើយគាត់បានស្ថិតនៅរាជធានីភ្នំពេញកាលពីថ្ងៃទី៤ ខែមករា។


*លោក លាង សុខជឿននៅថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១០ កំឡុងពេលសំរាកសវនាការ*

ប៉ុន្តែនេះមិនមែនជាចំលើយដែលនគរបាលចង់បាននោះទេ។ នគរបាលចង់បានចម្លើយសារភាព។ មកទល់ពេលនេះ នគរបាលមានតែឯកសារដែលកត់ត្រាពីទំនាក់ទំនងតាមទូរស័ព្ទ ដើម្បីបង្ហាញថា មានគេបានប្រើទូរស័ព្ទដែលចុះបញ្ជីឈ្មោះ សុខជឿន ដើម្បីហៅទូរស័ព្ទទៅកាន់ "ជនជាមេគំនិត" នៃគំរោងការនេះ។ នគរបាលមិនមានសេចក្តីបរិយាយពីអ្វី ដែលជាការនិយាយទាក់ទងគ្នាតាមទូរស័ព្ទទេ - ឬក៏មានអ្វីច្រើនផ្សេងទៀតដែរ។ ការស៊ើបអង្កេតទាំងមូលចំណាយអស់ពេលតិចជាងមួយថ្ងៃ ហើយចំនែកឯចៅក្រមស៊ើបសួរមិនព្រមធ្វើការសម្ភាសន៍សាក្សីនៅមុនពេលនៃការ

---

[២៦] មាស សុខជា "មនុស្ស ៤នាក់ត្រូវបានកាត់ទោសទាក់ទងនឹងរឿងខិតប័ណ្ណ" សារព័ត៌មានភ្នំពេញប៉ុស្តិ៍ ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១០។ ឈាង សុខា "គណបក្ស សម រង្ស៊ី ចង្អុលទៅប្រទេសវៀយណាម" សារព័ត៌មានភ្នំពេញប៉ុស្តិ៍ ថ្ងៃទី៣ ខែកញ្ញា ឆ្នាំ២០១០។

ចេញដីការចាប់ខ្លួនទេ។

បន្ទាប់មកគេមើលពីបញ្ហានៃខិតប័ណ្ណៈ វាទាក់ទងនឹង "ថ្ងៃរំដោះ" ថ្ងៃបុណ្យ ៧ មករា ជាថ្ងៃដែលកត់សំគាល់ពីជ័យជំនះលើខ្មែរក្រហមក្នុងឆ្នាំ១៩៧៩ ដោយកំលាំងរំដោះ។ ខិតប័ណ្ណត្រូវបានគេរាយការណ៍ថាបាននិយាយថា ថ្ងៃ៧ មករា មិនមែនជាថ្ងៃរំដោះទេ ប៉ុន្តែជាថ្ងៃដែលប្រទេសកម្ពុជាធ្លាក់ចូលក្នុង "ការកាន់កាប់ និងរំលោភបំពាន" ដោយប្រទេសវៀតណាម។

ដោយសារតែការសម្តែងនូវគំនិតយោបល់នេះហើយ ដែលនាំអោយកើតមានការចោទប្រកាន់ពីបទល្មើស។

សំណើរជាបន្តបន្ទាប់ដើម្បីចូលជួបលោក សុខជឿន ពីសំណាក់ក្រុមគ្រួសារ និងមេធាវីរបស់គាត់ត្រូវបានជំទាស់។ ទីបំផុតនៅថ្ងៃទី៣០ ខែឧសភា លោក សុខជឿនបានបង្ហាញមុខ។ គាត់ត្រូវបានគេនាំខ្លួនមកចំពោះមុខចៅក្រមក្នុងខេត្តតាកែវ និងត្រូវបានចោទប្រកាន់ពីបទផ្សព្វផ្សាយព័ត៌មានមិនពិត។

មេធាវីរបស់លោក សុខជឿន បានស្នើធានាខ្លួនគាត់នៅក្រៅឃុំ។ ពួកគេបានកត់សំគាល់ថា មានឈ្មោះបុគ្គលផ្សេងនៅក្នុង "ដីការបង្គាប់អោយនាំខ្លួន" ចេញដោយតុលាការគឺៈ "លាង សុខលី ហៅ ជឿន ដែលជាជនជាតិវៀតណាមស្នាក់នៅក្នុងខណ្ឌឫស្សីកែវ"។ លាង សុខជឿន គឺជាជនជាតិខ្មែរដែលនាពេលនោះកំពុងតែស្នាក់នៅខណ្ឌសែនសុខ។ ជាងនេះទៅទៀតបទចោទគឺជាបទល្មើសមជ្ឈឹម។ ច្បាប់ប្រទេសកម្ពុជាបានចែងថា ការឃុំឃាំងជាបណ្តោះអាសន្ន គឺជាវិធានការពិសេសដែលអនុវត្តសំរាប់តែករណីពិសេសប៉ុណ្ណោះ[២៧]។

ទោះបីជាយ៉ាងណាក៏ដោយ ដោយក៏ចៅក្រមបង្គាប់អោយធ្វើការឃុំឃាំងខ្លួនគាត់។



*សុខជឿនសន្លប់បន្ទាប់ពីស្តាប់លឺសាលក្រមកាត់ក្តី។ ម្តាយរបស់គាត់ព្យាយាមធ្វើអោយគាត់ដឹងខ្លួន*

លោក សុខជឿន បាននៅជាប់ឃុំឃាំងជាបណ្តោះអាសន្នរយៈពេលបីខែ។ នគរបាលបានចាប់ខ្លួនបុរសពីរនាក់ផ្សេងទៀតមានឈ្មោះ ថាច់ វណ្ណៈ ជាអតីតព្រះសង្ឃកម្ពុជាក្រោម និងឈ្មោះ ថាច់ ឡេ ជាអ្នករត់ម៉ូតូឌុប ជនជាតិខ្មែរកម្ពុជាក្រោម។ ជនសង្ស័យទី៣ ដែលមានឈ្មោះហៅថា ថាច់ ខុង ផុង ជា "មេគំនិត" មិនមានវត្តមាននៅក្នុងសវនាការទេ។ ជននេះក៏ជាព្រះសង្ឃខ្មែរកម្ពុជាក្រោមដែរ។

[២៧] ក្រមនីតិវិធីព្រហ្មទណ្ឌ មាត្រា ២០៣។

ការជាប់ពាក់ព័ន្ធរបស់ព្រះសង្ឃខ្មែរកម្ពុជាក្រោមពីរអង្គជារឿងសំខាន់។ ខ្មែរកម្ពុជាក្រោមគឺជាឈ្មោះដែលដាក់អោយជនជាតិខ្មែររស់នៅប្រទេសវៀតណាមភាគខាងត្បូង ដែលធ្លាប់ជាផ្នែកមួយនៃប្រទេសកម្ពុជា។ សកម្មជនខ្មែរកម្ពុជាក្រោមរួមទាំងព្រះសង្ឃផង បង្ហាញជាចំហរនូវទស្សនៈ និងការយល់ឃើញរបស់ខ្លួនថា ប្រទេសវៀតណាមបានដាក់ឥទ្ធិពលយ៉ាងខ្លាំងមកលើរដ្ឋាភិបាលកម្ពុជា។

ប្រធានបទនេះ គឺជារឿងរសើបសំរាប់មេដឹកនាំប្រទេសទាំងពីរ កម្ពុជា និងវៀតណាម។ គ្រាន់តែរយៈពេល ៤សប្តាហ៍មុនសវនាការអនុរដ្ឋមន្ត្រីសន្តិសុខសាធារណៈវៀតណាមបានមកធ្វើទស្សនៈកិច្ចនៅរាជធានីភ្នំពេញ ហើយបានជំរុញជាសាធារណៈដល់រដ្ឋាភិបាលកម្ពុជាអោយ "កាត់បន្ថយ" សកម្មភាពរបស់ខ្មែរកម្ពុជាក្រោម និង"ធ្វើអោយរួមតូច" នូវព័ត៌មានដែលរិះគន់ទំនាក់ទំនងដ៏ល្អរវាងប្រទេសទាំងពីរ[២៨]។

ប្រធានាធិបតីប្រទេសវៀតណាម លោក ង្វៀន មិញទ្រៀត បានបន្តតាមដានកិច្ចការនេះតាមរយៈទស្សនៈកិច្ចផ្ទាល់ខ្លួនមកកាន់កម្ពុជា[២៩]។ គាត់បានចាកចេញពីប្រទេសតែរយៈពេលពីរថ្ងៃមុនការចាប់ផ្តើមសវនាការកាត់សេចក្តីលោក សុខជឿន។

សវនាការប្រព្រឹត្តទៅនៅថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១០។ មានភស្តុតាងបង្ហាញពីកំហុសរបស់លោក សុខជឿន តែមួយគត់គឺការហៅទូរស័ព្ទ - ដោយគ្មានសេចក្តីសន្ទនានៃការនិយាយតាមទូរស័ព្ទទេ ប៉ុន្តែមានត្រឹមតែជាព្រឹត្តិការនៃការធ្វើទំនាក់ទំនងតាមទូរស័ព្ទប៉ុណ្ណោះ។

ជនជាប់ចោទម្នាក់ក្នុងចំណោមពួកគេបានប្រាប់នគរបាលពីដំបូងថា លោក សុខជឿនបានពាក់ព័ន្ធក្នុងការចែកចាយខិតប័ណ្ណ។ ប៉ុន្តែ គាត់បានដកពាក្យសំដីផ្នែកខ្លះចេញពីចម្លើយវិញក្នុងពេលសវនាការដោយនិយាយថា គាត់បានឆ្លើយដាក់លោក សុខជឿនអោយជាប់ទាក់ទិនក្នុងរឿងនេះពីព្រោះតែមានការសន្យាបោកប្រាស់ពីនគរបាលសួរចម្លើយ។ ចៅក្រមបានទាត់ចោលការដកពាក្យសំដីនេះ ដោយគ្មានចាត់អោយមានការស៊ើបអង្កេតបន្តឡើយ។

ដំណើរការកាត់ទោសប្រព្រឹត្តទៅដោយគ្មានបង្ហាញចម្លើយសាក្សី ឬភស្តុតាងពីខាងតុលាការទេ។ ចៅក្រមផ្អែកទាំងស្រុងលើសេចក្តីថ្លែងការណ៍ជាលាយលក្ខណ៍អក្សរ និងចម្លើយជាលាយលក្ខណ៍អក្សរនៃសាក្សីបួនរូប ដែលស្រង់យកបានមកដោយមន្ត្រីនគរបាល។ មិនមាននរណាម្នាក់ក្នុងចំណោមសាក្សីទាំងនេះ ត្រូវបានកោះហៅមកតុលាការដើម្បីសាកសួរពីចៅក្រមស៊ើបសួរឡើយទាំងមុនពេល និងក្នុងកំឡុងពេលសវនាការ។

ម្យ៉ាងវិញទៀត មេធាវីរបស់លោក សុខជឿន បានបង្ហាញភស្តុតាងក្នុងតុលាការយ៉ាងច្រើនសន្ធឹកសន្ធាប់ ដែលរួមមានទាំងភស្តុតាងបញ្ជាក់ថា លោក សុខជឿនបានកំពុងតែនៅក្នុងទីក្រុងភ្នំពេញ - មិនមែន

[២៨] ព័ត៌មានវិទ្យុសំលេងសហរដ្ឋអាមេរិក ថ្ងៃទី៣ ខែសីហា ឆ្នាំ២០១០។ ព័តមានវិទ្យុអាស៊ីសេរី ថ្ងៃទី៤ ខែសីហា ឆ្នាំ២០១០។

[២៩] សារព័ត៌មាននគរវត្ត ថ្ងៃទី២១ ខែសីហា ឆ្នាំ២០១០។ ព័តមានវិទ្យុសំលេងសហរដ្ឋអាមេរិក ថ្ងៃទី២៤ ខែសីហា ឆ្នាំ២០១០។

នៅក្នុងខេត្តតាកែវទេ - នៅថ្ងៃទី៤ ខែមករា ឆ្នាំ២០១០។

ចៅក្រមបានលើកចោលសក្ខីកម្មក្នុងតុលាការ - រួមមានទាំងសក្ខីកម្មរបស់ជនជាប់ម្នាក់ដែលមានវត្តមាននៅពេលសវនាការចោទផង - ថាជាការមិនគួរអោយជឿបាន។

បន្ទាប់មកចៅក្រមចូលទៅក្នុងបញ្ហាខិតប័ណ្ណតែម្តង: ខិតប័ណ្ណមានសេចក្តីថ្លែងការណ៍ជាលក្ខណៈនយោបាយទាក់ទងនឹងថ្ងៃបុណ្យ ៧ មករា។ អ្នកសរសេរខិតប័ណ្ណគិតថា វាគឺជាថ្ងៃដ៏អាម៉ាស់ ហើយមិនត្រូវមើលឃើញថាជាថ្ងៃរំដោះទេ។

ចៅក្រមកំណត់ថា ការសម្តែងយោបល់នេះ គឺជាបទល្មើសនៅក្នុងប្រទេសកម្ពុជា ដែលវាបង្កជាព័ត៌មាន "មិនពិត ប្រឌិត ឬ ក្លែងក្លាយ" ដែលអាចបណ្តាលអោយកើតកោលាហលដល់សន្តិសុខសាធារណៈ[៣០]។ ចៅក្រមបានធ្វើសេចក្តីសន្និដ្ឋានថា "សកម្មភាពរបស់ជនជាប់ចោទទាំងអស់ប៉ះពាល់ដល់មេដឹកនាំជាតិ និង បង្ករអស្ថេរភាពក្នុងសង្គម"។

ជនជាប់ចោទទាំងបួននាក់ត្រូវបានរកឃើញថា មានកំហុសពីបទផ្សាយព័ត៌មានមិនពិត។ ពួកគេត្រូវបានកាត់ទោសអោយជាប់ពន្ធនាគាររយៈពេល ២ឆ្នាំពីបទផ្សាយព័ត៌មានមិនពិត ថ្វីបើជនជនជាប់ចោទម្នាក់នៅកំពុងតែរត់គេចខ្លួន។ លោក សុខ ជឿន បានប្តឹងឧទ្ធរណ៍លើសេចក្តីសំរេចនេះ។

### *ការដាក់ទម្ងន់: តុលាការជាអាវុធអយុត្តិធម៌*

ករណីដូចជា ករណីលោក សុខជឿន វាជារឿងរំខានដ៏សាមញ្ញទៅហើយក្នុងរយៈពេល ៦ខែនៃការសិក្សាសំរាប់របាយការណ៍នេះ។ តុលាការបានក្លាយប្រហែលទៅជាអាវុធដ៏ប្រសិទ្ធិភាពសំរាប់មន្ត្រីរដ្ឋាភិបាល និងបុគ្គលមានខ្នងបង្អែកដែលចង់បំបិទមាត់អ្នករិះគន់ ឬ ធ្វើអោយស្របច្បាប់នូវកិច្ចព្រមព្រៀងជំនួញខុសច្បាប់នានា។ តុលាការ មានជំនួយពីច្បាប់មួយចំនួនដែលមានលក្ខណៈអនុគ្រោះជាមួយនឹងចៅក្រមមានភាពលំអៀង និងព្រះរាជអាជ្ញាដែលមាននិន្នាការនយោបាយ។

តុលាការមិនប្រើច្បាប់ជាឧបករណ៍ទេ ប៉ុន្តែប្រើអំណាច ឥទ្ធិពល ប្រាក់កាស និងភក្តីភាពខាងគណបក្សនយោបាយ។ អ្នកទាំងឡាយណាដែលខ្វះនូវធាតុសំខាន់ៗទាំងនេះ នឹងគ្មានឱកាសនៅក្នុងមុខតំណែងនេះបានទេ។ ប៉ុន្តែតុលាការ ផ្តល់នូវបញ្ជីពេញលេញទៅដោយចំណាត់ការនានាសំរាប់អ្នកដែលប្រើប្រាស់តុលាការដែលមានលទ្ធភាពអាចជ្រើសរើសយកមកប្រើ:

***បទព្រហ្មទណ្ឌបរិហារកេរ្តិ៍*** ជាជម្រើសពេញនិយមបំផុតតាំងពីយូរមកហើយ[៣១]។ អ្នកនយោបាយមកពីគណ

[៣០] ច្បាប់ព្រហ្មទណ្ឌអន្តរកាល មាត្រា៦២។

[៣១] ច្បាប់ព្រហ្មទណ្ឌអន្តរកាលមាត្រា៦៣ (បានជំនួសដោយក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាថ្មីឆ្នាំ២០០៩ [ចាប់ពីពេលនេះទៅហៅថា "ក្រមព្រហ្មទណ្ឌ"] ដែលចូលជាធរមានយ៉ាងពេញលេញក្នុងខែវិច្ឆិកា ឆ្នាំ២០១០។ ក្រមព្រហ្មទណ្ឌរក្សាទុកបទបរិហារកេរ្តិ៍ ជាបទល្មើសព្រហ្មទណ្ឌ ប៉ុន្តែវាបន្សល់ការដាក់ទណ្ឌកម្មត្រឹមតែការពិន័យជាប្រាក់។ វាអនុញ្ញាត្តអោយមានការកាត់សេចក្តីបុគ្គល ដែលបរិហារិះគន់ស្ថាប័នផងដែរមានដូចជា ក្រសួងនានារបស់រដ្ឋាភិបាលជាដើម ។ សូមមើលក្រមព្រហ្មទណ្ឌមាត្រា៣០៥ (បទបរិហារកេរ្តិ៍ជាសាធារណៈ)។ ជាបន្ថែម ច្បាប់ប្រឆាំងអំពើពុករលួយថ្មីរួមមាន បទបញ្ញត្តិដោយឡែកស្តីពីបទព្រហ្មទណ្ឌបរិហារកេរ្តិ៍ ដែលផ្តន្ទាទោសជាប់ពន្ធនាគាររហូតដល់៦ខែ។ សូមមើល ច្បាប់ប្រឆាំងអំពើពុករលួយឆ្នាំ២០១០ មាត្រា៤១

បក្សជំទាស់ សកម្មជន និងសមាជិកនានានៃសារព័ត៌មាន ជាញឹកញាប់រងនូវការចោទប្រកាន់ពីបទបរិហារកេរ្តិ៍ ចំពោះការផ្សព្វផ្សាយព័ត៌មាន ដែលគេចាត់ទុកថាជាការគំរាមកំហែងដល់ក្រុមអ្នកកាន់អំណាច។ បទបរិហារកេរ្តិ៍ មានការអនុវត្តដាក់ទោសពន្ធនាគាររហូតដល់ឆ្នាំ២០០៦ ជាពេលដែលវាត្រូវបានគេធ្វើការកែប្រែអោយមកដាក់ទណ្ឌកម្មជាការពិន័យជាប្រាក់វិញ[៣២]។ ប៉ុន្តែការខកខានមិនបានបង់ប្រាក់ពិន័យនោះ ជាលទ្ធផលនឹងនៅតែជាប់ទោសពន្ធនាគាររហូតដល់រយៈពេល ២ឆ្នាំដដែល[៣៣]។

ជួនកាលគេហៅថា "ការប្រមាថ" ចំពោះសេចក្តីអត្ថាធិប្បាយ ដែលវាមើលទៅហាក់ដូចជាមិនមានទោសពៃរ៍ និងដែលការគំរាមកំហែងមិនស្តែងចេញអោយឃើញភ្លាមៗនោះទេ។ ជាឧទាហរណ៍ក្នុងខែមិនា ឆ្នាំ២០១០ អ្នកបោះពុម្ពផ្សាយសារព័ត៌ប្រឆាំងត្រូវបានប្តឹងពីបទបរិហារកេរ្តិ៍បន្ទាប់ពីធ្វើសេចក្តីរាយការណ៍ថា មហាវិទ្យាល័យមួយ បានយកថ្លៃទម្រង់បែបបទសំរាប់សុំអាហារូបករណ៍ពីនិស្សិតមានតម្លៃហួសប្រមាណជាខ្លាំង។ ទាំងអ្នកឧបត្ថមអាហារូបករណ៍ទាំងរដ្ឋាភិបាលជប៉ុន និងលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ជាអ្នកដែលមិនពាក់ពន្ធ័លើប្រាក់កំរៃនេះទេ[៣៤]។ វាប្រាកដជាមានអ្នកណាផ្សេងបានយកប្រាក់នោះដាក់ហោប៉ៅ។

អ្នកណាម្នាក់ក៏គិតថា ការបង្ហាញនូវអំពើពុករលួយបែបនេះ នឹងញ៉ាំងអោយនាយកមហាវិទ្យាល័យមានការខឹងសម្បារ និងទាមទារអោយមានការស៊ើបអង្កេតអំពើនេះ។ ជាជំនួសវាញ៉ាំងអោយមានការចោទប្រកាន់ពីបទព្រហ្មទណ្ឌប្រឆាំងនឹងអ្នកសារព័ត៌មាន។ ពីដំបូង នាយកមហាវិទ្យាល័យបានប្តឹងអ្នកបោះពុម្ពផ្សាយជាបុគ្គលចំពោះការបរិហារកេរ្តិ៍ ហើយព្រះរាជអាជ្ញាក្រោយមកទៀតធ្វើការចោទប្រកាន់ពីបទព្រហ្មទណ្ឌផ្សព្វផ្សាយព័ត៌មានមិនពិត។ វាជួយជំរុញដល់ដំណើរការនៃបណ្តឹងព្រោះថា នាយកមហាវិទ្យាល័យក៏បំរើការជារដ្ឋលេខាធិការនៃក្រសួងការបរទេស។

ការបន្ថែមបទចោទផ្សព្វផ្សាយព័ត៌មានមិនពិត ពិតជារឿងធ្ងន់ធ្ងរ ព្រោះការផ្តន្ទាទោសអាចនាំមកនូវទោសជាប់ពន្ធនាគារ រហូតដល់ ៣ឆ្នាំ[៣៥]។ ការផ្តន្ទាទោសអាចមានការពិន័យជាប្រាក់ ដែលការខកខានមិនបានបង់ប្រាក់ពិន័យ នាំមកនូវការបន្ថែមរយៈពេលជាប់ពន្ធនាគារ។

ការផ្សព្វផ្សាយព័ត៌មានមិនពិត ជាទ្រឹស្តីមានការលំបាកក្នុងការបង្ហាញភស្តុតាងច្រើនជាងការបរិហារកេរ្តិ៍ ពីព្រោះវាតំរូវអោយមាននូវការបោះពុម្ពផ្សាយ ឬការបញ្ជូនសារនូវ "ព័ត៌មានមិនពិត ព័ត៌មានប្រឌិត ព័ត៌មានក្លែងក្លាយ ឬដោយកុហកទំលាក់កំហុសទៅលើជនទីបីដោយអសុទ្ធចិត្ត និងក្នុងគោលបំណងបំផ្លិច

---

[៣២] ក្រមព្រហ្មទណ្ឌអ៊ុនតាក់ មាត្រា៦៣។

[៣៣] ក្រមនិតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា (ចាប់ពីពេលនេះទៅហៅ "ក្រមនិតិវិធីព្រហ្មទណ្ឌ") មាត្រា ៥២៥ និងមាត្រា៥៣០។

[៣៤] សារព័ត៌មានវិទ្យុអាស៊ីសេរី ថ្ងៃទី២១ ខែមិនា ឆ្នាំ២០១០។ សារព័ត៌មានដើមអំពិល ថ្ងៃទី២១ ខែមិនា ឆ្នាំ២០១០។ សារព័ត៌មានដើមអំពិល ថ្ងៃទី២២ ខែមិនា ឆ្នាំ២០១០ ច្រាន់ ចំរើន "អ្នកបោះពុម្ពផ្សាយស្ថិតនៅក្នុងតុលាការដោយសារតែមានការចោទប្រកាន់" សារព័ត៌មានភ្នំពេញប៉ុស្តិ៍ ថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១០

[៣៥] ក្រមព្រហ្មទណ្ឌអ៊ុនតាក់ មាត្រា៦២។

បំផ្លាញ"។[៣៦] ច្បាប់ក៏តំរូវអោយបង្ហាញថា ការផ្សព្វផ្សាយនូវព័ត៌មាននេះ*ធ្វើអោយកើតកោលាហលដល់សន្តិសុខសាធារណៈ ឬអាចបណ្តាលអោយកើត កោលាហលដល់សន្តិសុខសាធារណៈ*។ ប៉ុន្តែបទបញ្ញត្តិ "សន្តិសុខសាធារណៈ" មានការបកស្រាយទូលំទូលាយខ្លាំង - នៅពេលដែលវាស្របនឹងសេចក្តីត្រូវការ ឬផែនការរបស់គេ[៣៧]។

ជាឧទាហរណ៍ក្នុងខែវិច្ឆិកា ឆ្នាំ២០០៩ អ្នកសារព័ត៌មានឈ្មោះ រស់ សុខែត ត្រូវបានកាត់ទោសពីបទផ្សព្វផ្សាយព័ត៌មានមិនពិត បន្ទាប់ពីគាត់បានបញ្ជូនបន្ត "សារជាអក្សរតាមទូរស័ព្ទមានអត្ថន័យបង្កាច់បង្ខូច" អ្នកអត្ថាធិប្បាយព័ត៌មានទូរទស្សន៍ ដែលគេស្គាល់ជាទូទៅថាជាអ្នកលំអៀងទៅរករដ្ឋាភិបាល - ដែលគេក៏ដឹងថា ជាទីប្រឹក្សានាយករដ្ឋមន្ត្រី - និងមនុស្សប្រូននាក់ផ្សេងទៀត។ សារបានចោទសួរអ្នកអត្ថាធិប្បាយព័ត៌មានទូរទស្សន៍អំពីបទចោទប្រកាន់អំពើពុករលួយ។ នៅឯសវនាការ ចៅក្រមបានសន្និដ្ឋានថា សារនេះ "ធ្វើអោយខូចកេរ្តិ៍ឈ្មោះ" អ្នកអត្ថាធិប្បាយព័ត៌មានទូរទស្សន៍ និង"បង្កអោយមានបញ្ហាដល់សង្គម"។ ការណ៍នេះត្រូវបានចាត់ទុកថា មានលក្ខណៈគ្រប់គ្រាន់ដូចគ្នានឹងពាក្យប្រើប្រាស់ក្នុងបញ្ញត្តិផ្សព្វផ្សាយព័ត៌មានមិនពិត។

លោក សុខែត គឺជាអ្នកសារព័ត៌មានម្នាក់ក្នុងចំនោមអ្នកសារព័ត៌មានយ៉ាងហោចណាស់ក៏ ១០នាក់ដែរ ដែលបានប្រឈមមុខនឹងការចោទប្រកាន់តាមផ្លូវតុលាការក្នុងអំឡុងពេលពីខែឧសភា ឆ្នាំ២០០៩ ដល់ខែឧសភា ឆ្នាំ២០១០ នេះបើផ្អែកតាមការសិក្សាមួយរបស់ក្លឹបអ្នកសារព័ត៌មានកម្ពុជា[៣៨]។ ពួកគេភាគច្រើនប្រឈមមុខនឹងបទបរិហារកេរ្តិ៍ និងបទផ្សាយព័ត៌មានមិនពិតទាក់ទងនឹងការងាររបស់ពួកគេ។ ការណ៍នេះប្រហែលជាមិនមែនជារឿងគួរភ្ញាក់ផ្អើលទេ ដែលនាពេលនេះ ប្រទេសកម្ពុជាត្រូវបានដាក់នៅចំណាត់ថ្នាក់ដ៏សង្វេកគឺទី១២៨ ក្នុងចំណោម ១៧៨ប្រទេសក្នុងចំណាត់ថ្នាក់សេរីភាពសារព័ត៌មានសាកលសំរាប់ឆ្នាំ២០១០ របស់អង្គការអ្នកសារព័ត៌មានគ្មានព្រំដែន (Reporters Without Borders)[៣៩]។

---

[៣៦] ក្រមព្រហ្មទណ្ឌអ៊ុនតាក់មាត្រា៦២។ មកដល់ខែវិច្ឆិកា ឆ្នាំ២០១០ មាត្រានេះត្រូវបានជំនួសដោយក្រមព្រហ្មទណ្ឌឆ្នាំ២០០៩ ប៉ុន្តែក្រមថ្មីនៅរក្សាទុកវាជាបទល្មើសដែលមានទោសជាប់ពន្ធនាគារ ហើយអាចត្រូវគេប្រើប្រាស់វាក្នុងស្ថានភាពប្រហាក់ប្រហែលគ្នា។ សូមមើលមាត្រា ៣១១ដល់មាត្រា ៣១៣ ("ការប្តឹងបរិហារបង្កាច់កេរ្តិ៍" ត្រូវផ្តន្ទាទោសដាក់ពន្ធនាគាររហូតដល់មួយឆ្នាំ) និងមាត្រា៤៩៤ ដល់មាត្រា៤៩៨ ("ការញុះញង់អោយប្រព្រឹត្តបទល្មើស" ត្រូវផ្តន្ទាទោសដាក់ពន្ធនាគាររហូតដល់បីឆ្នាំ)។

[៣៧] ដូចគ្នា

[៣៨] សារព័ត៌មានកម្ពុជាថ្មី "អ្នកសារព័ត៌មាន ២៤នាក់បានចាប់ខ្លួន និង១០នាក់ទៀតរងការប្តឹងផ្តល់ក្នុងរយៈពេលមួយឆ្នាំ ក្នុងប្រទេសកម្ពុជា" ថ្ងៃទី៣ ខែឧសភា ឆ្នាំ២០១០ (ដកស្រង់ចេញពីការសិក្សាចេញផ្សាយដោយក្លឹបអ្នកសារព័ត៌មានកម្ពុជា) (អត្ថបទបកប្រែជាភាសារអង់គ្លេសមាននៅគេហទំព័រ: (http://ki-media.blogspot.com/2010/05/24-journalists-arrested-and-10-sued-in.html )។

[៣៩] ម៉ាត់ ឡង់ឌី "សេរីភាពសារព័ត៌មាន: ប្រទេសកម្ពុជាធ្លាក់លេខក្នុងចំណាត់ថ្នាក់ជាសាកល" សារព័ត៌មានភ្នំពេញប៉ុស្តិ៍ ថ្ងៃទី២១ ខែតុលា ឆ្នាំ២០១០។

***គម្លាតខុសគ្នា នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ជាមួយក្រមព្រហ្មទណ្ឌថ្មី***

បទបញ្ញត្តិនៃក្រមព្រហ្មទណ្ឌថ្មីនៃព្រះរាជាណាចក្រកម្ពុជា បានចូលជាធរមាននៅថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០១០។ ច្បាប់នេះលក្ខណៈខុសគ្នាពីរចំនុច - បទបញ្ញត្តិពីបទផ្សាយព័ត៌មានមិនពិតត្រូវបានលប់ចេញ ហើយក្រមនេះតម្រូវឲ្យមានការដោះស្រាយករណីបទបរិហារកេរ្តិ៍ ដោយប្រើប្រាស់ច្បាប់របបសារព័ត៌មានវិញ។

ប៉ុន្តែក្រមថ្មីនេះក៏មានបន្ថែមនូវ៩ចំនុចថ្មីទៀតផងដែរ។ អង្គការលីកាដូ បានរកឃើញបទឧក្រិដ្ឋចំនួន៩ រួមទាំងបទបញ្ញត្តិថ្មីចំនួន ៥ ដែលចង្អុលបង្ហាញអំពីការគំរាមកំហែង យ៉ាងធ្ងន់ធ្ងរចំពោះសេរីភាពក្នុងការបញ្ចេញមតិនៅក្នុងប្រទេសកម្ពុជា។

បញ្ញត្តិខ្លះគ្រាន់តែបង្ហាញនូវសក្តានុពល ចំពោះការ រំលោភបំពាន ចំណែកបញ្ញត្តិខ្លះទៀតបង្ហាញយ៉ាងជាក់ស្តែង ដូចជាការហាមឃាត់លើការរិះគន់សេចក្តីសម្រេចរបស់តុលាការ និងសេចក្តីថ្លែងការណ៍សាធារណៈ ***ដែលបណ្តាលឲ្យកើតមានកោលាហលក្នុងសង្គម។*** ចុងក្រោយ ក៏លេចចេញជាបទបញ្ញត្តិដែលមានលក្ខណៈរឹតបន្តឹងកាន់តែខ្លាំង ចំពោះបទផ្សាយព័ត៌មានមិនពិតក្រោមច្បាប់ព្រហ្មទណ្ឌអន្តរកាល។

ក្រមថ្មីនេះក៏តម្រូវឲ្យបង់ប្រាក់ពិន័យជាចាំបាច់ និងបន្ថែមរបៀបនៃការដាក់ទោសទណ្ឌបន្ថែមដោយព្យួរសិទ្ធិពលរដ្ឋដោយមិនកំណត់ពេលវេលាច្បាស់លាស់ តាមរយៈការដកហូតសិទ្ធិមិនឲ្យបំពេញការងារ។ តារាងខាងក្រោមនេះប្រៀបធៀបក្រមព្រហ្មទណ្ឌថ្មី និងច្បាប់ព្រហ្មទណ្ឌអន្តរកាល។

សេចក្តីលំអិតអំពីការវិភាគទៅលើច្បាប់ទាំងពីរនេះមាននៅក្នុងឧបសម្ព័ន្ធ ១ និង ២។

| **បទល្មើស** | **ក្រមចាស់** | **ក្រមថ្មី** |
|---|---|---|
| បទបរិហារកេរ្តិ៍ | មាត្រា ៦៣ | មាត្រា ៣០៥ |
| បទផ្សាយព័ត៌មានមិនពិត | មាត្រា ៦២ | មិនមាន |
| បទជេរប្រមាថជាសាធារណៈ | មាត្រា ៦៣ | មាត្រា ៣០៧ |
| បទប្តឹងបរិហារបង្កាច់កេរ្តិ៍ | មិនមាន | មាត្រា ៣១១ |
| បទញុះញង់ឲ្យប្រព្រឹត្តបទឧក្រិដ្ឋជាអាទិ៍ | មាត្រា ៥៩-៦០ | មាត្រា ៤៩៥ |
| បទញុះញង់ឲ្យមានការរើសអើង | មាត្រា ៦១ | មាត្រា៤៩៦ |
| បទប្រមាថ | មិនមាន | មាត្រា ៥០២ |
| បទផ្សព្វផ្សាយនូវការអត្ថាធិប្បាយដើម្បីធ្វើសម្ពាធលើយុត្តាធិការ | មិនមាន | មាត្រា ៥២២ |
| បទធ្វើឲ្យបាត់ជំនឿលើសេចក្តីសម្រេចរបស់តុលាការ | មិនមាន | មាត្រា ៥២៣ |
| បទប្តឹងបរិហារដោយភូតកុហកដល់អាជ្ញាធរតុលាការ | មិនមាន | មាត្រា ៥២៤ |
| **ចំនួនបទឧក្រិដ្ឋ** | **៥** | **៩** |

អាជ្ញាធរបានដាក់ទណ្ឌកម្មលើសេរីភាពខាងការបញ្ចេញមតិ មានបែបផែនជាក់លាក់មួយចំនួនដោយចាត់ចូលជាប្រភេទបទញុះញង់ ក្រោមច្បាប់ព្រហ្មទណ្ឌអ៊ុនតាក់។ បញ្ញត្តិច្បាប់ទាំងនេះ ដូចជាមានចែងក្នុងមាត្រា៥៩ និងមាត្រា៦០ នៃច្បាប់អ៊ុនតាក់ មានគោលបំណងដាក់ទណ្ឌកម្មលើការបញ្ចេញមតិដែលញុះញង់អោយមនុស្សប្រព្រឹត្ត ឬប៉ុនប៉ងប្រព្រឹត្តបទល្មើស។ ដូចគ្នានេះដែរ មាត្រា៦១ហាមប្រាមការញុះញង់អោយមានសម្អប់ជាតិសាសន៍។

ចៅក្រម និងព្រះរាជអាជ្ញា បានប្រកាន់យកនូវគំនិតស្ដីពី "បទល្មើស" ទូលំទូលាយយ៉ាងខ្លាំងនៅពេលបកស្រាយបញ្ញត្តិញុះញង់។ ពួកគេ បានអនុវត្តបញ្ញត្តិញុះញង់ក្នុងករណីពាក់ព័ន្ធជាមួយមេដឹកនាំសហជីពកម្មករដែលដឹកនាំកូដកម្ម[៤០] អ្នកនយោបាយមកពីគណបក្សជំទាស់[៤១] និងសមាជិកសហគមន៍ដែលហ៊ាននិយាយប្រឆាំងទៅនឹងការរំលោភដែលខ្លួនបានដឹង ដែលវាបានប្រព្រឹត្តឡើងដោយអង្គការក្រៅរដ្ឋាភិបាលមួយមានការផ្សារភ្ជាប់ទៅនឹងរដ្ឋាភិបាល[៤២]។

តែទោះជាយ៉ាងណាក៏ដោយ មាន**បទចោទប្រកាន់ព្រហ្មទណ្ឌដទៃទៀត** មិនទំនងជាមានការផ្សាភ្ជាប់ទៅនឹងសេរីភាពខាងការបញ្ចេញមតិទាល់តែសោះ។ ការចោទប្រកាន់ទាំងនោះ វាគ្រាន់តែជាអាវុធសងសឹកដ៏មុតស្រួចប្រឆាំងនឹងសកម្មជន ដែលគេចង់ដកយកចេញពីមុខរបស់គេប៉ុណ្ណោះ។ មានអ្នកភូមិនៅជីក្រែងជាឧទាហរណ៍ស្រាប់ ដែលពួកគេបានប្រឈមមុខនឹងការចោទប្រកាន់ពី**បទប្លន់** បន្ទាប់ពីពួកគេបានច្រូតកាត់ប្រមូលផលស្រូវនៅលើដីមានទំនាស់។ ពួកគេបានសាបព្រួសដាំស្រូវដោយខ្លួនគេផ្ទាល់ ប៉ុន្តែក្រោយមកមានអ្នកជំនួញឯកជន បានអះអាងថា ខ្លួនជាម្ចាស់កម្មសិទ្ធិនៃដីនោះ។ អាជ្ញាធរបានវាយប្រហារទៅលើតំណាងសហគមន៍ និងជួយទំនុកបំរុងរៀបចំជាបទចោទប្រកាន់យ៉ាងសមទំនងមួយក្នុងបំណងធ្វើអោយចុះខ្សោយដល់ឆន្ទះអ្នកភូមិដែលបន្តការតស៊ូក្នុងរឿងទំនាស់ដីធ្លី។

តាមការពិនិត្យមើលឡើងវិញនៃករណីគំរាមកំហែងតាមផ្លូវតុលាការក្នុងរយៈពេល ៦ខែ យើងឃើញថា ការពិពណ៌នាអោយបានល្អិតល្អន់បន្តិចក្នុងរឿងនេះមិនមានតម្លៃអ្វីទេៈ វាស្ដែងចេញអោយឃើញយ៉ាងច្បាស់នូវកង្វះសកម្មភាពបន្តការតាមដានលើរឿងទាំងនោះពីសំណាក់អជ្ញាធរ។ ជនសង្ស័យអាចត្រូវគេចាប់ខ្លួននាំខ្លួនមកសាកសួរ ឬក៏ចោទប្រកាន់។ ប៉ុន្តែក្នុងចំនួនករណីមួយចំនួន ជនសង្ស័យត្រូវបានដោះលែងវិញតែនៅរង់ចាំ "ការស៊ើបអង្កេត"។ បន្ទាប់មករឿងរ៉ាវក៏បាត់ដំណឹងពីសារព័ត៌មាន។

ការណ៍នេះមិនចាំបាច់ថា ជាលទ្ធផលនៃការខ្ជិលច្រអូសក្នុងការបោះពុម្ពផ្សាយពីអ្នកសារព័ត៌មានទេ ជាញឹកញាប់វា គឺជាកលល្បិចប្រកបដោយចេតនាដែលបានប្រើប្រាស់ដោយអជ្ញាធរ។

មានករណីជាច្រើន ដែលការស៊ើបអង្កេតជាបន្តមិនបានប្រព្រឹត្តធ្វើទេ អោយតែជនសង្ស័យ "ប្រព្រឹត្ត

---

[៤០] *សូមអានករណីសិក្សាលេខ១៤*

[៤១] *សូមអានករណីសិក្សាលេខ៣៦*

[៤២] *សូមអានករណីសិក្សាលេខ២៣*

ត្រឹមត្រូវ"។ ជួនកាល ការចោទប្រកាន់បទព្រហ្មទណ្ឌតែមួយមុខ - ដោយមិនមានកាត់ទោស ឬការឃុំឃាំងជាបណ្ដោះអាសន្ន - គឺគ្រប់គ្រាន់ដើម្បីបំបិទមាត់នរណាម្នាក់។ ជាពិសេសអ្នកការពារសិទ្ធិមនុស្សតែងតែត្រូវបានចាប់ខ្លួនពីបទចោទប្រកាន់ដែលគ្មានការពិត ហើយបន្ទាប់មកក៏ត្រូវបានដោះលែងតាមរយៈការធានាអោយនៅក្រៅឃុំដោយមានលក្ខខ័ណ្ឌថា ពួកគេបញ្ឈប់សកម្មភាពជាក់លាក់របស់ខ្លួន។ នាពេលនេះ បទចោទប្រកាន់អាចនៅបង្អង់ក្នុងអំឡុងពេលនៃអជ្ញាយុកាលនៃបទល្មើស - ដែលមានរហូតដល់ ១៥ឆ្នាំចំពោះបទឧក្រិដ្ឋ[៤៣]។ ក្នុងរយៈពេលនេះ ការគំរាមកំហែងពីការកាត់ទោសជាបន្ត និងការគំរាមដាក់ពន្ធនាគារនៅតែមានមិនចេះចប់។

មធ្យោបាយនេះ ប្រហែលជាមធ្យោបាយដែលមានប្រសិទ្ធិភាពជាងការកាត់ទោសយោលទៅលើការប៉ះទង្គិចផ្លូវចិត្តពាក់ព័ន្ធនឹងការភ្ជាប់ពួកគេយ៉ាងជិតបំផុតទៅនឹងការដាក់ពន្ធនាគារ។ ជនជាប់ចោទបង្ហាញមុខជាមួយនឹងសេរីភាពរបស់ខ្លួន ប៉ុន្តែអារម្មណ៍របស់គេពោរពេញដោយការដាក់កំហិតថា ដូចជាគ្មានសេរីភាពដដែល។ ភាពភ័យខ្លាចនាពេលនោះអាចនឹងសាយភាយទៅដល់បងប្អូន មិត្តភក្តិ និងសកម្មជននានា ហើយការបំភិតបំភ័យបែបនេះមានប្រសិទ្ធិភាពធ្វើអោយពួកគេមិនអាចកំរើកខ្លួនរួច។

នេះជាមធ្យោបាយគំរាមគំហែងដ៏មានប្រសិទ្ធភាព ហេតុដូចនេះគេមិនចាំបាច់ខំព្យាយាម និងកាត់ទោសនរណាម្នាក់ នៅពេលដែលអ្នកនោះអាចបំបិទមាត់បានជាមួយនឹងការដាក់នូវការអនុវត្តច្បាប់ត្រឹមកំរិតអប្បរមាតាមផ្លូវតុលាការ និងប្រព័ន្ធពន្ធនាគារ?

ខណៈដែលច្បាប់មានតែនៅលើក្រដាសរបស់កម្ពុជា អាចនឹងមានទៅដោយបញ្ញត្តិច្បាប់ដែលគេជឿថា មានគោលបំណងអាក្រក់ ប៉ុន្តែពង្រាងច្បាប់ធ្វើឡើងមិនបានល្អមិនមែនជាកត្តាដែលទទួលខុសត្រូវជាចម្បងសំរាប់បណ្ដាលអោយមានការដាក់កំហិតសេរីភាពខាងការបញ្ចេញមតិនៅកម្ពុជាទេ។ បញ្ហាធំបំផុតនោះ គឺការអនុវត្តច្បាប់ទាំងនេះដោយតុលាការមិនបានស្មើគ្នា មិនទៀងទាត់ និងបែបសងសឹក។ នេះគឺជាបញ្ហាដែលវានឹងបន្តមានរហូត ទោះបីជាស្ថិតក្រោមទំរង់ច្បាប់ បែបណាក៏ដោយ។

> *"គ្រប់ៗគ្នា...ដឹងថាតុលាការមិនមានភាពឯករាជ្យទេ"*
>
> *មេដឹកនាំគណបក្សជំទាស់លោក កឹម សុខា*

ជិត ២ទសវត្សមកហើយនេះ ចំនួនបញ្ញត្តិច្បាប់ សេចក្ដីប្រកាស និងគោលការណ៍នៃនាំនានា - ដែលចំនួនភាគច្រើនត្រូវបានព្រាងឡើង ដោយមានជំនួយពីអន្តរជាតិ - យុត្តិធម៌មិនត្រូវបានធានាទេ នៅខាងក្នុងបន្ទប់តុលាការនៃប្រទេសកម្ពុជា។ ដូចដែលអ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិទទួលបន្ទុកកិច្ចការសិទ្ធិមនុស្សលោក សឺរិយា ស៊ូប៊ីឌី បានធ្វើការកត់សំគាល់កាលពីខែកញ្ញា ឆ្នាំ២០១០ ថា "ផ្នែកនិតិប្រតិបត្តិគ្របសង្កត់ផ្នែកតុលាការ"[៤៤]។

មេដឹកនាំគណបក្សជំទាស់លោក កឹម សុខា បានធ្វើសេចក្ដីសន្និដ្ឋានស្រដៀងគ្នា បន្ទាប់ពីការចាប់ខ្លួន

---

[៤៣] សូមមើលក្រមនិតិវិធីព្រហ្មទណ្ឌ មាត្រា៧ និងមាត្រា១០

[៤៤] សេបាស្ទាន ស្រ្តាងហ្គីយ៉ូ "អ្នកកាទូតអង្គការសហប្រជាជាតិបរិហារប្រព័ន្ធតុលាការ" សារព័ត៌មានភ្នំពេញប៉ុស្តិ៍ ថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១០

គាត់ពីបទបរិហារកេរ្តិ៍ក្នុងឆ្នាំ២០០៥ ដែលនាពេលនោះ បទល្មើសនេះនៅអនុវត្តទោសដាក់ពន្ធនាគារនៅឡើយ។ គាត់បានប្រាប់ទៅសារព័ត៌មានឈ្មោះដំណឹងប្រចាំសប្តាហ៍ (Newsweek) ថា: "បន្ទាប់ពីចៅក្រមសាកសួរខ្ញុំ គាត់មើលទៅពិតជាស្ថិតក្នុងសភាពភ័យខ្លាចព្រោះគាត់ដឹងថា មិនដឹងជាបានអ្វីយកមកចោទប្រកាន់ចំពោះរូបខ្ញុំ។ គាត់បានទៅជួបជាមួយចៅហ្វាយនាយគាត់ ហើយនៅពេលដែលគាត់ត្រលប់មកវិញ គាត់បាននិយាយថា គាត់សំរេចចិត្តអោយមានការចាប់ខ្លួនខ្ញុំ"។

"គ្រប់ៗគ្នា...ដឹងថាតុលាការមិនមានភាពឯករាជ្យទេ។"[៤៥]

ភាពខ្វះឯករាជ្យភាពរបស់តុលាការពីអំណាចប្រតិបត្តិ ធ្វើអោយវាងាយធ្លាក់ចូលទៅនឹងអំពើពុករលួយជាបុគ្គលផងដែរ ពោលគឺអោយតែផលប្រយោជន៍នៃភាគីបុគ្គលនោះ មិនមានទំនាស់ទៅនឹងខាងអំណាចប្រតិបត្តិ។ ជាលទ្ធផលវា គឺជាប្រព័ន្ធមួយដែលអ្នកមានទ្រព្យសម្បត្តិ និងអ្នកមានអំណាចមានលទ្ធភាពកេងយកចំណេញពីលើច្បាប់នានា ដើម្បីផលប្រយោជន៍របស់ពួកគេ បើទោះបីជាវាគោរពតាម ឬមិនតាមស្តង់ដាអន្តរជាតិក៏ដោយ។

ពិតមែនតែប្រព័ន្ធនេះជាអ្វីក៏ដោយ ប៉ុន្តែបញ្ហាគឺថា វាជាប្រព័ន្ធដែលអ្នកមានទ្រព្យសម្បត្តិ និងអ្នកមានអំណាចប្រើប្រាស់ច្បាប់ដើម្បីប្រឆាំងនឹងអ្នករិះគន់ និងអ្នកប្រកួតប្រជែងខាងសេដ្ឋកិច្ច។ បែបនេះ វាគឺជាលក្ខខ័ណ្ឌជាមុន - លក្ខណៈពិសេសកំនត់យ៉ាងច្បាស់ - សំរាប់សង្គមដែលគ្រប់គ្រងដោយអំណាច ជាជាងគ្រប់គ្រងដោយច្បាប់។ តុលាការ គឺជាឧបករណ៍ ហើយដែលវាចាំបាច់សំរាប់ការបន្តក្តោបក្តាប់អំណាចរបស់ពួកគេ។

ខាងក្រោមនេះ គឺជាគំរូនៃឧប្បត្តិហេតុ ដែលតុលាការត្រូវបានគេប្រើប្រាស់ដើម្បីបំបិទសំលេងអ្នករិះគន់ចំពោះអ្នកកាន់អំណាច និងបក្សពួកអ្នកកាន់អំណាចនៃប្រទេសកម្ពុជា។ គំរូនេះមិនមានចំនួនច្រើនទេពីព្រោះ ឧប្បត្តិហេតុដទៃទៀតភាគច្រើន ដែលរៀបរាប់ក្នុងរបាយការណ៍នេះមានដាក់បញ្ចូលក្នុងតួយ៉ាងនៃការគំរាមកំហែងតាមផ្លូវតុលាការ។ ករណីទាំងអស់នេះមិនមានបញ្ចូលនៅក្នុងផ្នែកនេះទេ ពីព្រោះករណីទាំងនោះបានចាត់ចូលទៅតាមប្រភេទផ្សេងទៀត - ដូចជា ការជាប់ពាក់ព័ន្ធទៅនឹងទិដ្ឋភាពនយោបាយ ការរារាំងបាតុកម្ម ការបំភិតបំភ័យខាងរាងកាយ ឬការចោទប្រកាន់ដោយគ្មានភស្តុតាងការជំរិតទារប្រាក់ពីឈ្មួញឈើ។

---

[៤៥] អេរិក ប៉ាប៉េ "អ្នកប្រឆាំងកម្ពុជាដែលមានសេរីភាព: បាទខ្ញុំខ្លាច" ដំណឹងប្រចាំសប្តាហ៍ថ្ងៃទី២១ ខែមករា ឆ្នាំ២០០៦ (មាននៅគេហទំព័រ: http://www.msnbc.msn.com/id/10960823/site/newsweek/)

**ករណីសិក្សាខាងក្រោមនេះផ្តល់ឧទាហរណ៍ច្រើនថែមទៀតអំពីការចូលជ្រៀតជ្រែករបស់ រដ្ឋាភិបាលទៅក្នុងកិច្ចខិតខំប្រឹងប្រែងចូលរួមក្នុងការប្រមូលផ្តុំដោយសន្តិវិធីនិងជាសាធារណៈរបស់ប្រជាពលរដ្ឋកម្ពុជា:**

►►►
៥ ឧសភា ២០១០
រាជធានីភ្នំពេញ

**ករណីសិក្សា ១៨**

**សំណើរសុំលើកលែងទោស ចំពោះអ្នកកាសែតជាប់ពន្ធនាគារ**[៤៦]

- ក្រុមប្រឹក្សាអ្នកកាសែតកម្ពុជា (PCC) បានប្រកាសកាលពីថ្ងៃទី៥ ខែឧសភា ឆ្នាំ ២០១០ថា ខ្លួនមានគំរោងធ្វើសំណើរសុំលើកលែងទោសចំពោះ អ្នកកាសែត លោក រស់ សុខែត ដែលបានជាប់ពន្ធនាគារពីបទផ្សព្វផ្សាយព័ត៌មានមិនពិត បន្ទាប់ពីគាត់បានបញ្ជូន "សារជាអក្សរតាមទូរស័ព្ទមានអត្ថន័យបង្កាច់បង្ខូចគេ"។
- លោក រស់ សុខែត ត្រូវបានកាត់ទោសអោយជាប់ពន្ធនាគាររយៈពេល ២ឆ្នាំ កាលពីថ្ងៃទី៦ ខែវិច្ឆិកា ឆ្នាំ២០០៩ ចំពោះការបញ្ជូនសារជាអក្សរទៅកាន់ លោក សយ សុភាព អ្នកអត្ថាធិប្បាយព័ត៌មានទូរទស្សន៍ CTN ដែលគេស្គាល់ជាទូទៅថាជាអ្នកលំអៀងទៅរករដ្ឋាភិបាល ហើយដែលម្តងម្កាលធ្វើអត្ថាធិប្បាយព័ត៌មានអោយវិទ្យុបាយ័ន្ត។
- ការសំរេចផ្តន្ទាទោស ដោយលោកចៅក្រម ឆាយ គង់ នៃតុលាការរាជធានីភ្នំពេញបានរងនូវការរិះគន់ពីសហព័ន្ធអ្នកសារព័ត៌មានអន្តរជាតិ (IFJ) ដែលបានថ្លែងថា បណ្តឹងបែបនេះគួរតែត្រូវបានដោះស្រាយតាមច្បាប់រដ្ឋប្បវេណី មិនមែនតាមច្បាប់ព្រហ្មទណ្ឌទេ។
- លោក រស់ សុខែត បានប្តឹងឧទ្ធរណ៍ចំពោះការសំរេចសេចក្តីនេះ ប៉ុន្តែគាត់បានអះអាងក្នុងខែសីហា ថានគរបាលបានទារប្រាក់សំណូកពីគាត់ចំនួន ១០០០ ដុល្លាសហរដ្ឋអាមេរិចដើម្បីផ្តល់ដំណឹងដល់គាត់ពីកាលបរិច្ឆេទនៃសវនាការ។ មានការកំណត់កាលបរិច្ឆេទនៃសវនាការជាច្រើនលើកសារ ហើយដែលត្រូវបានលុបចោលវិញក្នុងរយៈពេលពេញកន្លះឆ្នាំនេះ នៅទីបំផុតតុលាការសាលាឧទ្ធរណ៍បើកសវនាការនៅថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១០ ហើយតុលាការបានកាត់បន្ថយទោសចំពោះលោក សុខែត មកត្រឹមមួយឆ្នាំវិញ។ គាត់បានទទួលការដោះលែងពីពន្ធនាគារនៅថ្ងៃទី២៩ ខែតុលា ឆ្នាំ ២០១០។

[៤៦] ឈាង សុខា "សំណើរសុំលើកលែងទោសចំពោះអ្នកសារព័ត៌មាន" សារព័ត៌មានភ្នំពេញប៉ុស្ដិ៍ថ្ងៃទី៦ ខែឧសភា ឆ្នាំ២០១០ ។ ឆាយ ចាន់ឌីណា "អ្នកសារព័ត៌មានជាប់ពន្ធនាគាររាយការណ៍ពីរឿងពុករលួយ" សារព័ត៌មានភ្នំពេញប៉ុស្ដិ៍ ថ្ងៃទី៣ ខែសីហា ឆ្នាំ២០១០។

►►►
២៥ ឧសភា ២០១០
ខេត្តកំពង់ឆ្នាំង

**ករណីសិក្សា ១៩**

## ក្រុមហ៊ុនប្ដឹងសកម្មជនចំពោះបទអត្ថាធិប្បាយតាមវិទ្យុអំពីរឿងទំនាស់ដីធ្លី[៤៧]

- ភរិយារបស់លោករដ្ឋមន្ត្រីម្នាក់នៃរដ្ឋាភិបាល ដែលជាម្ចាស់ក្រុមហ៊ុនឯកជនមួយបានដាក់ពាក្យបណ្ដឹងចោទប្រកាន់បុគ្គលិកបំរើការអង្គការ អាដហុក ពីបទផ្សព្វផ្សាយព័ត៌មានមិនពិត។ ក្រុមហ៊ុនឈ្មោះ KDC អន្តរជាតិកំពុងតែជាប់ពាក់ព័ន្ធក្នុងជម្លោះដីធ្លីជាមួយអ្នកភូមិនៅមូលដ្ឋាន។ ក្រុមហ៊ុនគ្រប់គ្រងដោយលោកស្រី ជា ខេង ដែលជាភរិយារបស់លោក ស៊ុយ សែម រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល។
- អ្នកដែលជាគោលដៅនៃបណ្ដឹងនេះ គឺលោក សោម ចាន់គា ហើយគាត់បាននិយាយថា ពាក្យបណ្ដឹងនោះទាក់ទងនឹងបទសម្ភាសន៍របស់គាត់ជាមួយវិទ្យុអាស៊ីសេរីកាលពីខែធ្នូ ឆ្នាំ២០០៩។ គាត់បានថ្លែងក្នុងអំឡុងពេលនៃបទសម្ភាសន៍នោះថា ក្រុមហ៊ុនបានចាប់ផ្ដើមឈូសឆាយដីរបស់អ្នកភូមិដោយខុសច្បាប់។ ក្រុមហ៊ុនបដិសេធថាបានឈូសឆាយដី ប៉ុន្តែនិយាយថា ខ្លួនបានទិញដីនោះក្នុងឆ្នាំ១៩៩៦។ ក្រុមហ៊ុនបានចាប់ផ្ដើមអះអាងពីកម្មសិទ្ធិលើដីក្នុងឆ្នាំ២០០៧ ប៉ុន្តែមានប្រជាពលរដ្ឋជាង ១០០គ្រួសារមិនព្រមចុះហត្ថលេខាប្រគល់ដីរបស់ពួកគេមកអោយក្រុមហ៊ុនទេ។
- នេះជាការកត់សម្គាល់លើកទី៦ ដែលក្រុមហ៊ុន KDC អន្តរជាតិប្រើប្រាស់ប្រព័ន្ធច្បាប់ដើម្បីដោះស្រាយលើជម្លោះដីធ្លី។ ពាក្យបណ្ដឹងប្រាំផ្សេងទៀត ប្ដឹងប្រឆាំងនឹងអ្នកភូមិដែលក្នុងចំនោមបណ្ដឹងនោះ មានបណ្ដឹងមួយដែលមេភូមិម្នាក់ត្រូវបានតុលាការកាត់ទោសពីបទក្លែងបន្លំស្នាមមេដៃអ្នកភូមិ ដែលក្នុងពាក្យបណ្ដឹងនេះបានអះអាងថា អ្នកភូមិមិនដែលបានលក់ដីរបស់ពួកគេអោយទៅក្រុមហ៊ុន KDC ទេ។
- លោកសោម ចាន់គា បាននិយាយថា ពាក្យបណ្ដឹងពីខាងក្រុមហ៊ុន គឺជាកិច្ចខិតខំប្រឹងប្រែងមួយដើម្បីបំភិតបំភ័យគាត់ ពីព្រោះនាពេលថ្មីៗនេះ គាត់បានជំរុញអោយតុលាការធ្វើការស៊ើបអង្កេតរឿងឆបោកពាក់ព័ន្ធនឹង KDC ក្នុងរឿងដីធ្លីនេះ។

►►►
៥ កក្កដា ២០១០
រាជធានីភ្នំពេញ

## បិទសារព័ត៌មានជំទាស់ បន្ទាប់ពីអ្នកបោះពុម្ពផ្សាយជាប់ពន្ធនាគារពីបទផ្សព្វផ្សាយព័ត៌មានមិនពិត[៤៨]

- *ខ្មែរម្ចាស់ស្រុក* ជាកាសែតខ្មែរមាននិន្នាការប្រឆាំងយ៉ាងចេញមុខបានបញ្ឈប់

[៤៧] មេឃ ទិត្ថារ៉ា និងអឺវិន ឡយ " ក្រុមហ៊ុន KDC ប្ដឹងសកម្មជនក្នុងរឿងជម្លោះដីធ្លី" ភ្នំពេញប៉ុស្តិ៍ ថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០១០ សារព័ត៌មានកម្ពុជា ថ្មីថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១០។

[៤៨] សម រិទ្ធ "បិទសារព័ត៌មានប្រឆាំង" ភ្នំពេញប៉ុស្តិ៍ ថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០១០។ សម រិទ្ធ "សារព័ត៌មានជំទាស់កំណត់យកពេលចុងឆ្នាំសំរាប់ដំណើរការសារព័ត៌មានឡើងវិញ" ភ្នំពេញប៉ុស្តិ៍ ថ្ងៃទី១៨ ខែសីហា ឆ្នាំ២០១០។

**ករណីសិក្សា ២០**

ការបោះពុម្ពផ្សាយពីថ្ងៃទី៥ ខែកក្កដា ឆ្នាំ២០១០ ដោយសារខ្វះខាត ថវិកា។

- លោក ជុំ សុផល អ្នកនិពន្ធសារព័ត៌មានបានបង្ហាញប្រាប់ថា ការលក់កាសែតដែលជាប្រភពចំណូលតែមួយគត់របស់ខ្លួនមានការធ្លាក់ចុះជាខ្លាំង បន្ទាប់ពីនាយកការផ្សាយលោក ហង្ស ចក្រា ត្រូវបានជាប់ពន្ធនាគារពីថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០០៩ ពីបទផ្សព្វផ្សាយព័ត៌មានមិនពិត។ លោក ហង្ស ចក្រា ជាប់ចោទទាក់ទងនឹងការផ្សាយតាមសារព័ត៌មានខ្មែរម្ចាស់ស្រុក នូវអត្ថបទចោទប្រកាន់មន្ត្រីនៅក្បែរលោកឧបនាយករដ្ឋមន្ត្រី សុខ អាន ពីរឿងពុករលួយ។
- លោក ជុំ សុផល បានបញ្ជាក់ថា អ្នកសារព័ត៌មានខ្មែរម្ចាស់ស្រុកបានបន្ទន់សំលេងរិះគន់ចំពោះរាជរដ្ឋាភិបាល បន្ទាប់ពីការចាប់ខ្លួនលោក ហង្ស ចក្រា ដោយសារភ័យខ្លាចដោយខ្លួនឯងថា ពួកគេអាចត្រូវគេចាប់ខ្លួនដែរ។ ការលក់សារព័ត៌មានមានការធ្លាក់ចុះក្រោយពីបន្ថយការរិះគន់។
- លោក ហង្ស ចក្រា ត្រូវបានដោះលែងបន្ទាប់ពីទទួលបានការលើកលែងទោសពីព្រះមហាក្សត្រនៅថ្ងៃទី១៣ ខែមេសា ឆ្នាំ២០១០ ហើយគាត់សន្យាបន្តធ្វើការរិះគន់រដ្ឋាភិបាល។ នៅក្នុងបទសម្ភាសន៍មួយជាមួយអង្គការ លីកាដូ កាលពីថ្ងៃទី៥ ខែកក្កដា ឆ្នាំ២០១០ គាត់បានពន្យល់ថា បញ្ហាលំបាកខាងថវិកាសំរាប់សារព័ត៌មានរបស់គាត់ ជាចម្បងបណ្តាលមកពីខ្វះអ្នកផ្សាយឃោសនា ឬអ្នកជានា ដែលអ្នកទាំងអស់នោះត្រូវបានមន្ត្រីរដ្ឋាភិបាលគំរាមអោយនៅអោយឆ្ងាយពីសារព័ត៌មានរបស់គាត់។
- លោក ចក្រា បានចាប់ផ្តើមធ្វើការផ្សាយសារព័ត៌មានឡើងវិញតាមបណ្តាញអ៊ីនធឺណែតនៅពាក់កណ្តាលឆ្នាំ២០១០ ហើយគាត់បាននិយាយថានឹងគ្រោងធ្វើការបោះពុម្ពផ្សាយតាមសារព័ត៌មាននៅខែធ្នូ ឆ្នាំ២០១០។ អ្នករាយការណ៍នៃសារព័ត៌មាននេះបានថ្លែងថា គាត់មានសេចក្តីសប្បាយរីករាយដើម្បីបំរើការងារអោយសារព័ត៌មាន *ខ្មែរម្ចាស់ស្រុក* ប៉ុន្តែគាត់នៅ "មានការភ័យខ្លាចបន្តិច" ផងដែរ។

►►►
៦ កក្កដា ២០១០
រាជធានីភ្នំពេញ

**រដ្ឋាភិបាលដកពាក្យបណ្តឹងជំទាស់នឹងសារព័ត៌មានរាជានិយម បន្ទាប់ពីអ្នកបោះពុម្ពផ្សាយ 'ធ្វើការកែតំរូវ' ពាក្យរិះគន់ចំពោះលោក ហ៊ុន សែន[៤៩]**

**ករណីសិក្សា ២១**

- ក្រសួងព័ត៌មាន បានដកពាក្យបណ្តឹងប្រឆាំងនឹងសារព័ត៌មានទំនោររាជានិយមឈ្មោះ ខ្មែរអមតៈ បន្ទាប់ពីអ្នកបោះពុម្ពផ្សាយសារព័ត៌មាននេះសន្យាកែតម្រូវអត្ថបទសរសេរពីការកត់សំគាល់ថ្ងៃបុណ្យខួបទី១៣ នៃព្រឹត្តិការណ៍វាយ

[៤៩] គីម យុត្តាណា "មន្ត្រីដកពាក្យបណ្តឹងប្រឆាំងនឹងកាសែតរាជានិយម" ភ្នំពេញប៉ុស្ត៍ ថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១០។ ដំណឹងពីវិទ្យុអាស៊ីសេរី ថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១០។ ដេប៊ូរី លី "បណ្ណសារសារព័ត៌មានអាស៊ី(Asia Media Archives) កម្ពុជា: អាជ្ញាប័ណ្ណ របស់សារព័ត៌មានក្នុងស្រុក ត្រូវបានព្យួរ" ថ្ងៃទី១៨ ខែតុលា ឆ្នាំ២០០៧ (មាននៅគេហទំព័រ http://www.asiamedia.ucla.edu/article.asp?parentid=80026)។

ប្រហារដ៏បង្ហូរឈាមខែកក្កដា ឆ្នាំ១៩៩៧ រវាងគណបក្សធំពីរ។

- លោក ប៊ុន ថា អ្នកបោះពុម្ពផ្សាយសារព័ត៌មានខ្មែរអមតៈ បានប្រាប់អោយដឹងថា រដ្ឋមន្ត្រីក្រសួងព័ត៌មាន លោក ខៀវ កាញារីទ្ធ បានយល់ព្រមដកពាក្យបណ្តឹងបន្ទាប់ពីលោក ប៊ុន ថា សុខចិត្តធ្វើការកែតម្រូវឡើងវិញចំពោះអត្ថបទដែលមានចំណងជើងថា "ថ្ងៃបុណ្យខួបទី១៣ នៃព្រឹត្តិការណ៍រដ្ឋប្រហារថ្ងៃទី ៥-៦ ខែកក្កដា ឆ្នាំ១៩៩៧ ជាសញ្ញានៃការក្តោបក្តាប់អំណាចផ្តាច់មុខរបស់លោក ហ៊ុន សែន។"
- ក្រសួងព័ត៌មានបានវែកញែកថា អត្ថបទនេះមានតម្លៃស្មើនឹង "ការផ្សាយព័ត៌មានមិនពិតដោយចេតនា" ដោយសារវាមិនបានចុះពីការដកស្រង់ពាក្យសំដីរបស់រដ្ឋាភិបាលអំពីព្រឹត្តិការណ៍ឆ្នាំ១៩៩៧។ លោក ទិត សុធា ប្រធានអង្គភាពព័ត៌មាន និងប្រតិកម្មរហ័សនៃគណៈរដ្ឋមន្ត្រីបានថ្លែងថា ពាក្យបណ្តឹងធ្វើឡើងក្នុងគោលបំណង ដើម្បីរំលឹកដល់អ្នកសារព័ត៌មានទាំងអស់ អោយពិនិត្យឡើងវិញ និងធ្វើអោយប្រសើរឡើងការអនុវត្តតាមនិតិវិធីប្រតិបត្តិរបស់ខ្លួន។
- នេះមិនមែនជាលើកទីមួយទេ ដែលលោក ប៊ុន ថា និងខ្មែរអមតៈត្រូវបានវាយប្រហារដោយរាជរដ្ឋាភិបាល។ លោក ប៊ុន ថា ធ្លាប់រងការគំរាមកំហែងផងដែរ ដោយបណ្តឹងបរិហារកេរ្តិ៍ចំពោះអត្ថបទចុះផ្សាយពីបញ្ហាពុករលួយ ទាក់ទងនឹងបែបបទសុំអាហារូបករណ៍នៅសកលវិទ្យាល័យកម្ពុជា ដែលពាក្យប្តឹងបានធ្វើឡើងដោយក្រសួងការបរទេស។ [សូមអានករណីសិក្សា ២២]។ កាលពីក្នុងខែតុលា ឆ្នាំ២០០៧ អាជ្ញាប័ណ្ណសំរាប់សារព័ត៌មាននេះ ត្រូវបានព្យួរដោយរាជរដ្ឋាភិបាល ចំពោះអត្ថបទសរសេរពីរឿងលោកនាយករដ្ឋមន្ត្រី។

►►►
២៥ កក្កដា ២០១០
រាជធានីភ្នំពេញ

**ករណីសិក្សា ២២**

**អ្នកបោះពុម្ពផ្សាយប្រឈមមុខនឹងបទចោទប្រកាន់បរិហារកេរ្តិ៍ និងផ្សព្វផ្សាយព័ត៌មានមិនពិត**[៥០]

- អ្នកបោះពុម្ពផ្សាយត្រូវបានចោទប្រកាន់ពីបទផ្សព្វផ្សាយព័ត៌មានមិនពិត និងបរិហារកេរ្តិ៍ បន្ទាប់ពីកាសែតរបស់គាត់បានចុះផ្សាយអត្ថបទនិយាយពីអំពើពុករលួយនៅសកលវិទ្យាល័យកម្ពុជា។
- លោក ប៊ុន ថា អ្នកបោះពុម្ពផ្សាយសារព័ត៌មានមានទំនោរប្រឆាំងឈ្មោះខ្មែរអមតៈ ត្រូវបានចោទប្រកាន់ទាក់ទងនឹងអត្ថបទចុះផ្សាយក្នុងសារព័ត៌មានរបស់គាត់កាលពីខែតុលា ឆ្នាំ២០០៩។ សារព័ត៌មានបានរាយការណ៍ថា មន្ត្រី

[៥០] ដំណឹងពីវិទ្យុអាស៊ីសេរី ថ្ងៃទី២១ ខែមិនា ឆ្នាំ២០១០។ សារព័ត៌មានដើមអំពិលថ្ងៃទី២១ ខែមិនា ឆ្នាំ២០១០។ សារព័ត៌មានដើមអំពិល ថ្ងៃទី២២ ខែមិនា ឆ្នាំ២០១០។ ប្រាន់ ចំរើន "អ្នកបោះពុម្ពផ្សាយចូលតុលាការចំពោះការចោទប្រកាន់" សារព័ត៌មានភ្នំពេញប៉ុស្តិ៍ថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១០។ វិទ្យុអាស៊ីសេរី ថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១០

នៃមហាវិទ្យាល័យ បានទារយកថ្លៃទំរង់បែបបទសុំអាហារូបករណ៍ពីនិសិត្ស ដល់ទៅតម្លៃ ២០,០០០រៀល ទៅ ២៥,០០០រៀល (៤,៧១ដុល្លាសហរដ្ឋអាមេរិក ទៅ ៥.៨៨ ដុល្លាសហរដ្ឋអាមេរិច) នៅពេលដែលវាផលិតអស់តែតម្លៃ ៥០០រៀល។ អាហារូបករណ៍មានអ្នកផានា គឺរដ្ឋាភិបាលជប៉ុន និងលោក ហ៊ុន សែន។

- បណ្ឌិត កៅ គីមហួន នាយកមហាវិទ្យាល័យ បន្ទាប់មកបានប្តឹងលោក ប៊ុន ថា ពីបទបរិហារកេរ្តិ៍ និងបានទាមទារសំណងជំងឺចិត្តចំនួន ១០០,០០០ដុល្លាសហរដ្ឋអាមេរិក។ បណ្ឌិត កៅ គីមហួនក៏បំរើការជារដ្ឋលេខាធិការក្រសួងការបរទេសផងដែរ។ លោក ប៊ុន ថា ក៏ត្រូវបានចោទប្រកាន់ពីបទល្មើសផ្សព្វផ្សាយព័ត៌មានមិនពិតដែលវាជាទោសជាប់ពន្ធនាគារ។
- លោក ប៊ុន ថា បានជៀសវាងបានពីការឃុំខ្លួនបណ្តោះអាសន្ន បន្ទាប់ពីតុលាការរាជធានីភ្នំពេញបដិសេធមិនចេញដីការបង្គាប់ អោយឃុំខ្លួនបណ្តោះអាសន្ននៅថ្ងៃទី២២ ខែមីនា ឆ្នាំ២០១០។
- នៅចុងខែកក្កដា លោក ប៊ុន ថា តាមដឹងមកថា បានយល់ព្រមចុះផ្សាយសេចក្តីកែតម្រូវទាក់ទងនឹងអត្ថបទនេះ ដោយសង្ឃឹមថានឹងមានការបញ្ឈប់ករណីប្រឆាំងនឹងខ្លួនគាត់។ ប៉ុន្តែវិទ្យុអាស៊ីសេរីបានរាយការណ៍នៅថ្ងៃទី២៥ ខែកក្កដាថា បណ្តឹងជំទាស់នឹងរូបគាត់នឹងដំណើរការទៅមុខ។

►►►
៦ កញ្ញា ២០១០
ខេត្តព្រះវិហារ

**ករណីសិក្សា ២៣**

## អ្នកភូមិ រងការចោទប្រកាន់ពីបទញុះញង់ចំពោះការធ្វើបាតុកម្ម[៥១]

- អ្នកភូមិបីនាក់ក្នុងខេត្តព្រះវិហារ ត្រូវបានដាក់អោយជាប់ឃុំឃាំងជាបណ្តោះអាសន្ន និងបានជាប់ចោទពីបទញុះញង់អោយមានបាតុកម្មប្រឆាំងនឹងអង្គការស្រាវជ្រាវ និងទប់ស្កាត់គ្រឿងញៀននិងជំងឺអេសដ៍ (DARPO) ដែលជាអង្គការបានទទួលដីសម្បទានទំហំ ៥៥៦ហិកតាសំរាប់សំដែងថា ខ្លួនជួយគ្រួសារប្រជាពលរដ្ឋក្នុងតំបន់។ អ្នកភូមិត្រូវបានគេចោទប្រកាន់ផងដែរពីបទផ្សព្វផ្សាយព័ត៌មានមិនពិត និងក្លែងបន្លំ។ ដីសម្បទាននេះស្ថិតនៅក្នុងស្រុកជាំក្សាន្តនៃខេត្តព្រះវិហារ។
- អ្នកភូមិទាំងបីនាក់ក្រោយមកត្រូវបានដោះលែងពីការឃុំខ្លួនបណ្តោះអាសន្ន។
- DARPO ត្រូវបានបង្កើតឡើងក្នុងបំណងជួយគាំទ្រផ្នែកសេដ្ឋកិច្ចដល់គ្រួសារប្រជាពលរដ្ឋដែលជាជនបាត់បង់ឱកាសនៅក្នុងតំបន់ ប៉ុន្តែអ្នកភូមិ និងអង្គការ

[៥១] ឆាយ ចាន់ឌីណា "អ្នកភូមិប្រឈមមុខនឹងការចោទប្រកាន់ពីបទញុះញង់" សារព័ត៌មានភ្នំពេញប៉ុស្ដិ៍ ថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០១០។ ឆាយ ចាន់ឌីណា "អង្គការក្រៅរដ្ឋាភិបាលរួមគ្នាអំពាវនាវអោយមានការពិនិត្យដ៏ហ្មត់ចត់លើសិទ្ធិ" សារព័ត៌មានភ្នំពេញប៉ុស្ដិ៍ ថ្ងៃទី៧ ខែកញ្ញា ឆ្នាំ ២០១០។ ចាន់ ចំណាន សារព័ត៌មានមនសិការខ្មែរ ថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០១០។ ថេត សម្បត្តិ "តុលាការសាកសួរបុគ្គលពីររូបក្នុងករណី DARPO" សារព័ត៌មានភ្នំពេញប៉ុស្ដិ៍ ថ្ងៃទី១ ខែតុលា ឆ្នាំ ២០១០

ក្រៅរដ្ឋាភិបាលនានានិយាយថា អង្គការនេះបានបង្ខំគ្រួសារប្រជាពលរដ្ឋរស់នៅលើដីមានទំនាស់នេះ អោយចាកចេញពីផ្ទះសម្បែងរបស់ពួកគេក្រោមភាពភ័យខ្លាច "ការគំរាមកំហែងរំលោភសេពសន្ថវៈ និងទារុណកម្ម"។

- អ្នកភូមិដែលរងការចោទប្រកាន់ឈ្មោះ ស្រី សុភ័ណ ឈ្មោះ សាធ រឿន និង គីម សុផល បានប្រមូលស្នាមមេដៃដាក់លើពាក្យបណ្តឹងដែលបានដាក់ទៅក្រសួងមហាផ្ទៃ។
- លោក ប៉ែន លឹម ប្រធានអង្គការDARPO ដែលជាឧត្តមសេនីយផ្កាយមួយ និងជាទីប្រឹក្សាលោក ជា ស៊ីម ប្រធានព្រឹទ្ធសភា និងជាប្រធានគណបក្សប្រជាជនកម្ពុជាបាននិយាយថា អ្នកភូមិបានប្រមូលស្នាមមេដៃដើម្បី "ចោទប្រកាន់" គាត់ពីបទល្មើសមិនពិតមួយ។ គាត់បានព្យាករថា ក្រសួង "ប្រាកដជាមិនជឿ" លើការចោទប្រកាន់ប្រឆាំងនឹងរូបគាត់ទេ។
- នៅឯសន្និសិទ្ធិសារព័ត៌មានក្នុងរាជធានីភ្នំពេញនាថ្ងៃទី៦ ខែកញ្ញា អ្នកភូមិម្នាក់បានចោទសន្តិសុខបំរើការអោយ DARPO ថា បានរំលោភសេពសន្ថវៈកូនស្រីអាយុ១៣ឆ្នាំរបស់គាត់ ហើយគាត់បាននិយាយថា មានបុរសមិនស្គាល់អត្តសញ្ញាណ ច្រើននាក់បានវាយដំលើរូបគាត់ បន្ទាប់ពីគាត់ដាក់ពាក្យប្តឹងចំពោះរឿងនេះ។

►►►
១៥ កញ្ញា ២០១០
ខេត្តកំពង់ស្ពឺ

**ករណីសិក្សា ២៤**

**ប្រធានអង្គការក្រៅរដ្ឋាភិបាលខាងអភិរក្សត្រូវបានចាប់ខ្លួន បន្ទាប់ពីបានចោទមន្ត្រីច្រើនរូប ពីរឿងកាប់ឈើខុសច្បាប់**[៥២]

- ប្រធានអង្គការមួយរូប ត្រូវបានគេចាប់ខ្លួន និងដាក់អោយជាប់ឃុំឃាំងជាបណ្តោះអាសន្ន ក្រោយពីគាត់បានដាក់ពាក្យបណ្តឹងរឿងពុករលួយប្រឆាំងនឹងមន្ត្រីរដ្ឋាភិបាល ២៤១នាក់។
- លោក ជា ហ៊ាន ប្រធានអង្គការធនធានធម្មជាតិ និងអភិរក្សសត្វព្រៃនិយាយថា គាត់បានដាក់ពាក្យបណ្តឹងប្រឆាំងអំពើពុករលួយនៅថ្ងៃទី៣០ ខែសីហា។ គាត់បានអះអាងថា មន្ត្រីទាំងនោះបានធ្វើជាមិនដឹងមិនលឺចំពោះការកាប់ឈើខុសច្បាប់នៅក្នុងខេត្តកំពង់ស្ពឺ។
- មន្ត្រីមួយរូបក្នុងចំនោមមន្ត្រីទាំងអស់ ដែលមានឈ្មោះក្នុងពាក្យបណ្តឹងគឺលោក ឈុន ជាហេង ជាប្រធានទីជម្រកសត្វភ្នំឱរ៉ាល់ស្ថិតក្នុងស្រុកឱរ៉ាល់ បានឆ្លើយតបវិញដោយការដាក់បណ្តឹងទៅតុលាការខេត្ត។ ពាក្យបណ្តឹងបានចោទលោក ជា ហ៊ាន ពីរឿងកាប់ឈើខុសច្បាប់ និងជំរិតទារប្រាក់។ សមាជិកនៃអង្គការរបស់លោកជា ហ៊ាន ចំនួន ៩រូប ក៏ត្រូវបានកោះហៅមកសាកសួរ

[៥២] មាស សុខជា "តុលាការឃុំខ្លួនប្រធានអង្គការក្រៅរដ្ឋាភិបាល" សារព័ត៌មានភ្នំពេញប៉ុស្តិ៍ ថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១០។ មាស សុខជា "ជនសង្ស័យរឿងពុករលួយហៅអ្នកចោទប្រកាន់ខ្លួនថា ជាអ្នកកាប់ឈើខុសច្បាប់" សារព័ត៌មានភ្នំពេញប៉ុស្តិ៍ ថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០១០

ផងដែរ។

- លោក ជា ហ៊ាន ត្រូវបានដាក់អោយជាប់ឃុំឃាំង បន្ទាប់ពីតុលាការកោះហៅគាត់ មកសាកសួរជាលើកដំបូងនៅថ្ងៃទី១៥ ខែកញ្ញា។ មេធាវីរបស់គាត់បានអះអាងថា តុលាការមិនស្តាប់យកចម្លើយរបស់គាត់ទេ។
- លោក ជា ហ៊ាន បានដាក់ពាក្យបណ្តឹងពីពេលមុនៗមកចំនួនបី ដែលពាក្យទាំងនោះចោទប្រកាន់លោក ឈុន ជាហេង ពីការកាប់ឈើខុសច្បាប់។ នាពេលថ្មីៗនេះគាត់ក៏បានដាក់ពាក្យបណ្តឹងទាមទារអោយមានការចាប់ខ្លួនដាក់ពន្ធនាគារ និងពិន័យជាប្រាក់លើលោក ឈុន ជាហេង និងមន្ត្រី ៦រូបផ្សេងទៀតចំពោះការជាប់ពាក់ព័ន្ធរបស់ពួកគេក្នុងសកម្មភាពកាប់ឈើខុសច្បាប់។

►►►
៣០ កញ្ញា ២០១០
ខេត្ត បន្ទាយមានជ័យ

**ករណីសិក្សា ២៥**

**តុលាការកោះហៅអ្នកបំរើការនៅទូរទស្សន៍ CTN អំពីបទចោទប្រកាន់ផ្សព្វផ្សាយព័ត៌មានមិនពិត[៥៣]**

- តុលាការខេត្តបន្ទាយមានជ័យ បានកោះហៅ លោក ឡាយ លី អ្នកយកព័ត៌មានទូរទស្សន៍CTN ដើម្បីសាកសួរអំពីការចោទប្រកាន់ផ្សព្វផ្សាយព័ត៌មានមិនពិត។ លោកឡាយ លី ត្រូវបានកំនត់អោយចូលបង្ហាញខ្លួននៅតុលាការ នៅថ្ងៃទី១១ ខែតុលា ប៉ុន្តែគាត់មិនបានចូលរួមក្នុងសវនាការទេ។
- ការចោទពីបទល្មើសផ្សព្វផ្សាយព័ត៌មានមិនពិត កើតមានឡើងក្នុងដើមខែកញ្ញា ឆ្នាំ២០១០ ហើយវាផ្សារភ្ជាប់ទៅនឹងទំនាស់ដីធ្លីមួយពាក់ព័ន្ធជាមួយក្រុមហ៊ុន ARP-OITC គ្រុប។ តំណាងក្រុមហ៊ុនម្នាក់បាននិយាយថា សេចក្តីរាយការណ៍នៃស្ថានីយទូរទស្សន៍នេះ ធ្វើអោយខូចខាតដល់ "កិត្តិយស" របស់ក្រុមហ៊ុនពីព្រោះក្រុមហ៊ុនបានទិញដីពីអ្នកភូមិ ប៉ុន្តែនៅតែអនុញ្ញាតអោយអ្នកភូមិដាំដុះស្រូវលើដីនោះ។
- មានការអះអាងសិទ្ធិកម្មសិទ្ធិលើចំនែកដីមួយផ្នែកនៃដីទំនាស់នេះផងដែរ ពីលោក ឡាយ សារ៉ាន់ មេបញ្ជាការរងកងយោធពលខេមរភូមិន្ទប្រចាំស្រុកភ្នំស្រុក។

[៥៣] សារព័ត៌មាននគរវត្ត ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០១០។ មេយ ទិត្ថារ៉ា "កោះហៅអ្នកយកព័ត៌មានទូរទស្សន៍ CTN" សារព័ត៌មានភ្នំពេញប៉ុស្តិ៍ ថ្ងៃទី១ ខែតុលា ឆ្នាំ២០១០។ ឆាយ ចាន់ឌីណា "អ្នកយកព័តមានទូរទស្សន៍CTN ខកខានក្នុងការផ្តល់សក្ខីកម្មនៅថ្ងៃឈប់សំរាក" សារព័ត៌មានភ្នំពេញប៉ុស្តិ៍ ថ្ងៃទី១២ ខែតុលា ឆ្នាំ២០១០

# ៤. ការគំរាមកំហែងក្រៅផ្លូវតុលាការ ការវាយប្រហារ និងការសំលាប់

### *ករណីសិក្សា ២៦៖ ពេជ្រ សុភ័ណ: ស្លាប់ព្រោះតែដីធ្លីក្នុងខេត្តបាត់ដំបង*[៥៤]



លោកស៊ីម ម៉េយ មិត្តភ័ក្តរបស់លោក ពេជ្រ សុភ័ណត្រូវបានបាញ់របួសកាលបីសប្តាហ៍មុនពេលពីឃាតកម្មរបស់ ពេជ្រ សុភ័ណ

វាគឺជាស្ថិតិដ៏គួរភ្ញាក់ផ្អើល និងមិនគួរជឿមួយ: ចាប់តាំងពីឆ្នាំ២០០៤ មក មានប្រជាពលរដ្ឋកម្ពុជា ជិត ៣០០,០០០នាក់ បានក្លាយជាជនរងគ្រោះនៃការដណ្តើមយកដី។ ចំនួននេះ វាប្រហាក់ប្រហែលនឹងម្នាក់នៃរៀងរាល់ប្រជាពលរដ្ឋកម្ពុជា ៥០ នាក់ជាជនរងគ្រោះ។

ពេជ្រ សុភ័ណ អាយុ ៦០ឆ្នាំ មិនចង់ក្លាយទៅជាតួលេខមួយក្នុងស្ថិតិនេះទេ។

តំណាងសហគមន៍មកពីស្រុកសំឡូត នៃខេត្តបាត់ដំបង បានរស់នៅលើដីរបស់គាត់អស់ពេល ជាច្រើនឆ្នាំមកហើយនៅពេលដែលរាជរដ្ឋាភិបាលបានសំរេចលក់ដីអោយគេ។

ទំហំដីមួយចំនែក លក់អោយទៅក្រុមហ៊ុនមួយរបស់កូរ៉េខាងត្បូងហើយ និងទំហំដីពីរចំនែកទៀតអោយទៅមូលដ្ឋានកងយោធពលខេមរភូមិន្ទ (ខ.ភ.ម) យោធភូមិភាគប្រាំ។ សំណង សំរាប់ផ្តល់អោយអ្នកភូមិទាំងអស់នឹងធ្វើអោយ ពេជ្រ សុភ័ណ និងអ្នកជិតខាងរបស់គាត់ធ្លាក់ក្នុងភាពទុរគិត ដូច្នេះពួកគេបដិសេធចំពោះសំណងនេះ។ នៅពេលនោះហើយ ដែលបញ្ហាបានចាប់ផ្តើមឡើង។

មន្ត្រីយោធាចាប់ផ្តើមចូលមើលភូមិជាមួយនឹងក្រុមហ៊ុនក្នុងឆ្នាំ២០០៧ និងព្យាយាមលើកទឹកចិត្តអ្នកភូមិអោយចាកចេញពីភូមិ។ ពេជ្រ សុភ័ណ បានតបតវិញ ដោយការរៀបចំចងក្រងអ្នកភូមិឡើង។ ជារួមទំនាស់នេះប៉ះពាល់ប្រជាពលរដ្ឋចំនួន១៩១គ្រួសារ។ ភាពជាអ្នកដឹកនាំ និងការនិយាយដោយគ្មានសំចៃរបស់គាត់ជួយអោយអ្នកភូមិទាំងអស់មានជំហររឹងមាំ។ ទាហានបានព្យាយាមម្តងទៀត ដែលនាំអោយមានការប៉ះទង្គិចគ្នាជាមួយអ្នកភូមិ ហើយស្ថានការណ៍ ចាប់ផ្តើមអាក្រក់ទៅៗយ៉ាងឆាប់រហ័ស។

នៅថ្ងៃទី៤ ខែមេសា មានជនល្មើសពីររូប បាញ់ទៅលើតំណាងសហគមន៍ ដែលជាអ្នកស្និទ្ធស្នាលរបស់ពេជ្រ សុភ័ណ ឈ្មោះ ស៊ីម ម៉េយ។ ហេតុការណ៍នេះបង្ហាញអោយបានឃើញគ្រប់គ្រាន់សំរាប់សុភ័ណ ដែលជ្រើសរើសមធ្យោបាយនាំយកករណីជម្លោះដីធ្លីរបស់ពួកគេទៅដល់អជ្ញាធរខេត្ត

[៥៤] មេយ ទិត្ថារ៉ា "អ្នកភូមិនិយាយថា ការសំលាប់ដ៏ឃោរឃៅមានការជាប់ពាក់ព័ន្ធនឹងទំនាស់ដីធ្លី" កាសែតភ្នំពេញប៉ុស្តិ៍ ថ្ងៃទី២៨ ខែមេសា ឆ្នាំ២០១០។ មេយ ទិត្ថារ៉ា "ទាហានរងការចោទប្រកាន់ថា បានវាយដំកសិករ" សារព័ត៌មានភ្នំពេញប៉ុស្តិ៍ ថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០១០។ *សូមមើលផងដែរ* ករណីលេខ BB029AK10, BB035K10 របស់អង្គការលីកាដូ

តាមរយៈការដាក់ពាក្យបណ្តឹង ប្រឆាំងនឹងក្រុមហ៊ុន និងកងយោធពលខេមរភូមិន្ទ។ នៅថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១០ គាត់បានចេញទៅ ប្រមូលយកស្នាមមេដៃ ពីអ្នកភូមិរបស់គាត់សំរាប់ដាក់ក្នុងពាក្យបណ្តឹង។

នៅតាមផ្លូវត្រលប់មកផ្ទះវិញ គាត់ត្រូវបានគេបាញ់សំលាប់។

ឃាតករដែលសំលាប់គាត់ប្រើប្រាស់កាំភ្លើង AK-47 បាញ់ទៅលើគាត់ចំនួនបួនគ្រាប់។ សាក្សីជាច្រើនបានប្រាប់អ្នកស៊ើបអង្កេតអង្គការ លីកាដូ ថា តាមពិតទៅ សុភ័ណរងការបាញ់ប្រហារចំនួនប្រាំបីគ្រាប់ - ប្រាំពីរគ្រាប់ត្រូវចំលើទ្រូង និងមួយគ្រាប់ត្រូវចំមុខរបស់គាត់។

វាហាក់បីដូចជាករណីនៃការសងសឹកដ៏ច្បាស់ក្រលែតៈ ពេជ្រ សុភ័ណ គឺជាតំណាងសហគមន៍ដ៏សំខាន់មួយរូប។ គាត់បានរៀបចំពាក្យបណ្តឹងរារាំងរថយន្តធំៗពីការឈូសឆាយដី និងផ្តល់ទីតាំងផ្ទះរបស់គាត់សំរាប់ការប្រជុំនានា។ គាត់គឺជាសាក្សីមួយរូបគត់ ដែលបាននិយាយប្រាប់ទៅនគរបាលអំពីអំពើប៉ុនប៉ងសំលាប់លើ ស៊ឹម ម៉េយ។

អជ្ញាធរនាខណៈពេលនេះ បន្តយាយីរុកគួនអ្នកភូមិ។ នៅថ្ងៃទី៥ ខែកក្កដា ឆ្នាំ២០១០ ទាហានបានបាញ់ប្រហារទៅលើកសិករមួយក្រុមមានគ្នា ៦០នាក់ ដែលកំពុងតែធ្វើស្រែចំការលើដីទំនាស់ក្នុងស្រុកសំឡូត។ មិនមាននរណាម្នាក់រងរបួសទេ ប៉ុន្តែទាហានដដែលទាំងនេះបន្ទាប់មកបានវាយដំអ្នកភូមិពីរនាក់ដែលបដិសេធមិនព្រមឈប់ធ្វើស្រែចំការ។ មេបញ្ជាការរងកងយោធពលខេមរភូមិន្ទយោធភូមិភាគប្រាំបាននិយាយថា គាត់នឹងស៊ើបអង្កេតរឿងនេះ ប៉ុន្តែគាត់បាននិយាយបន្ថែមថា វាគ្មានភាពច្បាស់លាស់ថា "នរណាបានប្រើអំពើហិង្សាលើនរណា"។

## *ការស្លាប់-ចប់ការស៊ើបអង្កេត និងនិទណ្ឌភាព*

នគរបាលមិនបានចាប់ខ្លួននរណាម្នាក់ ទាក់ទងជាមួយនឹងការស្លាប់របស់ ពេជ្រ សុភ័ណ ឬក៏ការបាញ់ប្រហារលើលោក ស៊ឹម ម៉េយ ហើយក៏ដូចជាបទពិសោធន៍ក្នុងពេលកន្លងមកដែរ វាគ្មានការគួរអោយជឿថា នគរបាលនឹងចាប់ខ្លួនអ្នកប្រព្រឹត្តក្នុងករណីនេះទេ។

ការអនុវត្តច្បាប់ក្នុងប្រទេសកម្ពុជាគឺជា ឧបករណ៍សំរាប់អ្នកមានអំណាច ហើយនិទណ្ឌភាព គឺជាបទដ្ឋានសំរាប់ ជនដែលប្រព្រឹត្តឧក្រិដ្ឋកម្មជូសមុខអោយអ្នកមានអំណាច។ ការវាយប្រហារ និងការបំភិតបំភ័យទៅលើអ្នកសារព័ត៌មាន អ្នកបំរើការងារតាមអង្គការក្រៅរដ្ឋាភិបាល សកម្មជន សហគមន៍ និងអ្នកដទៃទៀតជាទម្លាប់ប្រព្រឹត្តទៅដោយគ្មានការស៊ើបអង្កេត ឬការដាក់ទណ្ឌកម្មអ្នកប្រព្រឹត្ត។

ស្ថិតិជាក់ស្តែងបំផុតទាក់ទងនឹងរឿងនេះ គឺថាមានអ្នកសារព័ត៌មានដប់នាក់បានត្រូវគេសំលាប់នៅក្នុងប្រទេសកម្ពុជាតាំងពីឆ្នាំ១៩៩៣មក ដែលករណីសំលាប់អ្នកកាសែតចុងក្រោយគឺក្នុងពាក់កណ្តាលនៃឆ្នាំ

២០០៨[៥៥] ។ គ្មានឃាតករណាម្នាក់ដែលបានសំលាប់អ្នកសារព័ត៌មាន ត្រូវបានគេនាំយកមកផ្តន្ទាទោសទេ[៥៦] ។ ដូចគ្នានេះដែរ ក៏មានសកម្មជនសហជីពកម្មករដ៏លេចធ្លោបីនាក់ត្រូវគេសំលាប់តាំងពីឆ្នាំ២០០៤មក[៥៧] ។ ជនដែលបានសំលាប់ពួកគេពិតប្រាកដមិនត្រូវគេនាំយកមកកាត់ទោសទេ ប៉ុន្តែក្នុងករណីចំនួនពីររដ្ឋាភិបាលបានឃុបឃិតទំលាក់កំហុសទៅលើមនុស្សសរុបទាំងអស់បីរូប ហើយបានកាត់ទោសពួកគេអោយជាប់ពន្ធនាគារ បើទោះបីជាគ្មានភស្តុតាងអ្វីទាំងអស់ក៏ដោយ។ ក្នុងចំនោមពួកគេបីនាក់ មានពីរនាក់ត្រូវបានតុលាការកំពូលសំរេចអោយដោះលែងក្រៅឃុំ ប៉ុន្តែនៅតែប្រឈមមុខនឹងសវនការឡើងវិញនៅពេលខាងមុខ។

ក្នុងអំឡុងឆ្នាំ២០០៨ និង២០០៩ អង្គការ លីកាដូ ប្រមូលចងក្រងករណីបានចំនួន៣០ ជាករណីពាក់ព័ន្ធនឹងអំពើហិង្សា ឬការបំភិតបំភ័យនៃអំពើហិង្សាប្រឆាំងនឹងអ្នកការពារសិទ្ធិមនុស្ស[៥៨] ។ ជនរងគ្រោះជាច្រើននៅក្នុងករណីទាំងអស់នេះ អនុវត្តសិទ្ធិរបស់ខ្លួនចំពោះការជួបប្រជុំជាសាធារណៈ និយាយស្តីដោយសេរីសារព័ត៌មានសេរី និងការដាក់ពាក្យបណ្តឹងជូនទៅរដ្ឋាភិបាល។

ស្ថានភាពនៅក្នុងឆ្នាំ២០១០ មិនមានអ្វីប្រសើរនោះទេ។

អ្នកសារព័ត៌មាន គឺជាក្រុមដែលងាយរងគ្រោះថ្នាក់បំផុត។ យ៉ាងហោចណាស់មានអ្នកសារព័ត៌មាន ៧នាក់បានមានសេចក្តីរាយការណ៍ថា រងការគំរាមកំហែងធ្ងន់ធ្ងរ វាយដំលើរាងកាយ ឬរងការប៉ុនប៉ងវាយប្រហារតែក្នុងរយៈពេលខ្លីដែលគ្របដណ្តប់ក្នុងរបាយការណ៍នេះ។ ហេតុការណ៍ទាំងនេះរួមមាន ការគំរាមកំហែងសំលាប់មានបីករណីវាយដំលើរាងកាយមានបីករណី និងប៉ុនប៉ងមនុស្សឃាតមានមួយករណី។

សូម្បីតែអ្នកប្រើប្រាស់សារព័ត៌មាន ក៏មានគ្រោះថ្នាក់ដែរ: នៅក្នុងភូមិមួយអជ្ញាធរបានវាយដំបុរសម្នាក់ដោយសារគាត់ស្តាប់ការផ្សាយវិទ្យុអាស៊ីសេរី (RFA) និងវិទ្យុសំលេងសហរដ្ឋអាមេរិក (VOA)[៥៩] ។

---

[៥៥] “ការដាក់កំហិតសេរីភាពខាងការបញ្ចេញមតិក្នុងប្រព័ន្ធផ្សព្វផ្សាយរបស់កម្ពុជា” របាយការណ៍សង្ខេបអង្គការ លីកាដូ ខែឧសភា ឆ្នាំ២០០៩ ទំព័រ១៧-១៩

[៥៦] សូមអានអត្ថបទដដែល

[៥៧] “ប្រទេសកម្ពុជា: សេរីភាពខាងការបញ្ចេញមតិ សមាគម និងការជួបប្រជុំ: ទំហំកាន់តែរួមតូច” របាយការណ៍អង្កេត (The Observatory report) ខែកញ្ញា ឆ្នាំ២០១០ ទំព័រ ២៦-២៧

[៥៨] “ការវាយប្រហារ និងការបំភិតបំភ័យលើអ្នកការពារសិទ្ធិមនុស្សក្នុងប្រទេសកម្ពុជា ២០០៨-២០០៩” អង្គការលីកាដូ ខែកញ្ញា ឆ្នាំ២០១០

[៥៩] ព័ត៌មានវិទ្យុអាស៊ីសេរី ថ្ងៃទី៤ ខែសីហា ឆ្នាំ២០១០

**ខាងក្រោមនេះគឺជាសេចក្តីសង្ខេបនៃករណីទាក់ទងនឹង ការគំរាមកំហែងក្រៅប្រព័ន្ធតុលាការ ការវាយប្រហារ និងការសំលាប់ទៅលើបុគ្គលដែលអនុវត្តសិទ្ធិខាងការបញ្ចេញមតិរបស់ខ្លួន:**

►►►
៦ មេសា ២០១០
ខេត្តបន្ទាយមានជ័យ

**ករណីសិក្សា ២៧**

**អ្នកសារព័ត៌មានរងការវាយដំពីទាហានខ.ភ.ម ខណៈពេល កំពុងស៊ើបអង្កេតរឿង ហើយបទចោទប្រកាន់ត្រូវលើកលែងចោល[៦០]**

- នៅថ្ងៃទី១ ខែមិនា ឆ្នាំ២០១០ ខណៈពេលកំពុងតែស្រាវជ្រាវសំរាប់ការសរសេរអត្ថបទពីរឿងល្បែងស៊ីសងខុសច្បាប់ នៅក្នុងភូមិក្បាលស្ពាននៃឃុំប៉ោយប៉ែត អ្នកសារព័ត៌មានកាសែតរស្មីកម្ពុជាឈ្មោះ វង់ ថូ បានប្រឈមមុខជាមួយមនុស្សបីនាក់ និងត្រូវបានពួកគេវាយដំ។ បុគ្គលទាំងនោះក្រោយមកត្រូវបានគេស្គាល់អត្តសញ្ញាណថាជាលោក ងឹម ត្រឹម កូនរបស់គាត់ឈ្មោះ លីម ហ៊ុយ និងប្រពន្ធរបស់គាត់ឈ្មោះ លីម ឡាង។ លោក ងឹម ត្រឹម គឺជាទាហាន កងវរសេនាតូចព្រំដែននៃ ខ.ភ.ម លេខ503។ អ្នកវាយប្រហារចង់រារាំងការសរសេរចុះផ្សាយជាសាធារណៈ ពីរឿងដែលពួកគេជាប់ពាក់ព័ន្ធក្នុងការប្រព្រឹត្តល្បែងស៊ីសងខុសច្បាប់។
- ជនសង្ស័យទាំងនេះក្រោយមកត្រូវបានចាប់ខ្លួនដោយនគរបាល ហើយបានជាប់ឃុំឃាំងជាបណ្តោះអាសន្នអស់រយៈពេលមួយខែ។ វង់ ថូ បានយល់ព្រមដកពាក្យបណ្តឹងរបស់ខ្លួនវិញ បន្ទាប់ពីបានទទួលលិខិតសុំទោស និងការបង់ប្រាក់នូវចំនួនដែលគេដឹងមិនច្បាស់ពីលោក ងឹម ត្រឹម និងគ្រួសាររបស់គាត់។ ក្នុងខែមេសា ព្រះរាជអាជ្ញាតុលាការខេត្តបន្ទាយមានជ័យ ក៏បានយល់ព្រមផងដែរ លើកលែងការចោទប្រកាន់បទព្រហ្មទណ្ឌដែលបានប្តឹងប្រឆាំងអ្នកសារព័ត៌មានរូបនេះ។

►►►
៨ មេសា ២០១០
ខេត្តសៀមរាប

**ករណីសិក្សា ២៨**

**អ្នកសារព័ត៌មានរងការវាយដំ បន្ទាប់ពីបានព្យាយាមថតរូបមន្ត្រីពុករលួយ[៦១]**

- កេង ផុន អ្នកសារព័ត៌មានអោយសារព័ត៌មានស្ថាបនាជាតិខ្មែរមកពីខេត្តសៀមរាប ត្រូវបានកោះហៅអោយចូលបង្ហាញខ្លួននៅតុលាការនៅថ្ងៃទី៨ ខែមេសា ឆ្នាំ២០១០ ក្រោយពេលដែលគាត់បានព្យាយាមថតរូបមន្ត្រីរដ្ឋបាលព្រៃឈើពីរនាក់ដែលគេចោទថា បានទទួលយកប្រាក់សំណូក។ ហេតុការណ៍នោះកើតឡើងក្នុងខែមិនា ឆ្នាំ២០១០។
- អ្នកសារព័ត៌មានបានព្យាយាមថតរូបភាពមន្ត្រីរដ្ឋបាលព្រៃឈើ នៅពេល

---

[៦០] គីម យុត្តាណា "បីនាក់ ត្រូវបានដោះលែងអោយមានសេរីភាព បន្ទាប់ពីជំលោះស្រាយគួរចាប់អារម្មណ៍មួយជាមួយអ្នកសារព័ត៌មាន" សារព័ត៌មានភ្នំពេញប៉ុស្ដិ៍ ថ្ងៃទី៧ ខែមេសា ឆ្នាំ២០១០។ អង្គការ លីកាដូ ករណីលេខ BM041PA10

[៦១] មេឃ ទិត្ថារ៉ា "អ្នកសារព័ត៌មានត្រូវបានកោះហៅឡើងតុលាការពីរឿងថតរូប" សារព័ត៌មានភ្នំពេញប៉ុស្ដិ៍ ថ្ងៃទី៨ ខែមេសា ឆ្នាំ២០១០។ វ៉ាន់ រឿយ "អ្នកសារព័ត៌មានខេត្តសៀមរាបផ្តល់ចម្លើយ" សារព័ត៌មានភ្នំពេញប៉ុស្ដិ៍ ថ្ងៃទី៩ ខែមេសា ឆ្នាំ២០១០

ដែលមន្ត្រីទាំងនោះបានបញ្ឈប់រទេះដឹកឈើចំនួន៣ នៅខាងក្រៅឃុំកំពង់ឃ្លេង។ គាត់បានអះអាងថា បានឃើញមន្ត្រីទាំងនោះទទួលយកប្រាក់សំណូក ៤០,០០០រៀល (១០ដុល្លាដុល្លាសហរដ្ឋអាមេរិក) ដើម្បីអនុញ្ញាតអោយមានការកាប់ឈើខុសច្បាប់។

- ពេលដែលគាត់ព្យាយាមសាកសួរទៅមន្ត្រីទាំងនោះ ស្រាប់តែពួកគេចាប់ក្របួចគាត់យ៉ាងហិង្សា និងបានលុបរូបភាពចេញពីកាម៉េរ៉ាថតរូបរបស់គាត់។
- មន្ត្រីរដ្ឋបាលព្រៃឈើបន្ទាប់មក បានដាក់ពាក្យបណ្តឹងមិនជាក់លាក់មួយទៅតុលាការប្រឆាំងនឹងលោក កេង ផុន។ លោក កេង ផុន ក៏បានដាក់ពាក្យបណ្តឹងប្រឆាំងនឹងមន្ត្រីរដ្ឋបាលព្រៃឈើពីការបំផ្លាញឯកសាររបស់គាត់ និងការគំរាមកំហែងលើគាត់ទៅកាន់ព្រះរាជអជ្ញាតុលាការខេត្តសៀមរាប លោក ទី សុរិនថុល។
- នៅឯជំនួបជាមួយក្រឡាបញ្ជីរបស់ព្រះរាជអាជ្ញានាថ្ងៃទី៨ ខែមេសា ឆ្នាំ២០១០ លោក កេង ផុន ត្រូវបានដាក់សំពាធអោយដកការចោទប្រកាន់ប្រឆាំងនឹងមន្ត្រីរដ្ឋបាលព្រៃឈើ ប៉ុន្តែគាត់បានបដិសេធមិនធ្វើតាមទេ។

►►►
៩ កក្កដា ២០១០
ខេត្តក្រចេះ

**ករណីសិក្សា ២៩**

**មន្ត្រីយោធាវាយប្រហារ គំរាមកំហែងសំលាប់អ្នកសារព័ត៌មាន ដែលធ្វើការស៊ើបអង្កេតរឿងកាប់ឈើខុសច្បាប់**[៦២]

- មន្ត្រីកងរាជអាវុធហត្ថក្នុងខេត្តក្រចេះ បានគំរាមកំហែងសំលាប់អ្នកសារព័ត៌មានពីរនាក់ បន្ទាប់ពីពួកគេថតយករូបភាពនៃប្រតិបត្តការកាប់ឈើខុសច្បាប់មួយ។
- អ្នកសារព័ត៌មានឈ្មោះ លោក អោក ងន់ និងលោក ថន សុខគង់បានប្រាប់ពីអត្តសញ្ញាណនៃមន្ត្រីនោះថាឈ្មោះលោក ជា សាំងហុង។ អត្ថបទសារព័ត៌មានជាភាសាខ្មែរ មិនបានបង្ហាញអោយដឹងពីឈ្មោះសារព័ត៌មាន ដែលអ្នកសារព័ត៌មានទាំងពីរនាក់បំរើការទេ។
- អ្នកសារព័ត៌មានអះអាងថា ក្រោយពីការស៊ើបអង្កេតរបស់ពួកគេ មន្ត្រីរូបនេះ និងសហការីគាត់បានមកកាន់ការិយាល័យរបស់ពួកគេ ហើយវាយចំលើយមុខរបស់លោក ថន សុខគង់ ហើយគំរាមថា ពួកគេនឹង"បាត់ខ្លួន" បើសិនជាពួកគេបន្តការស៊ើបអង្កេតតាមដានទៀត។ ក្រុមនោះ ក្រោយមកបានត្រលប់មកម្តងទៀត និងបានគប់ដុំថ្មមកលើការិយាល័យរបស់អ្នកសារព័ត៌មានធ្វើអោយខូចខាតសម្ភារៈមួយចំនួន។
- នៅថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១០ អ្នកសារព័ត៌មានបានដាក់ពាក្យបណ្តឹងប្រឆាំងនឹងលោក ជា សាំងហុង ទៅតុលាការចោទប្រកាន់គាត់ថា បានគំរាម

[៦២] សារព័ត៌មាននគរវត្ត ថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១០

សំលាប់។ វាហាក់បីដូចជា មិនមានការចាត់វិធានការអ្វីទេលើករណីនេះមកទល់នឹងពេលនេះ។

►►►
១៣ កក្កដា ២០១០
ខេត្តរតនគីរី

**ករណីសិក្សា ៣០**

**លំនៅដ្ឋានរបស់អ្នកសារព័ត៌មាន រងការវាយប្រហារដោយបុរសប្រដាប់អាវុធ[៦៣]**

- នៅថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០១០ វេលាម៉ោង ៣និង១៥នាទីព្រឹកមានបុរសប្រដាប់ដោយអាវុធមួយក្រុមមានគ្នាបួននាក់ បានបាញ់ទៅលើលំនៅដ្ឋានរបស់លោក សុខ គីមសាន ជាអ្នកយកព័តមានអោយទូរទស្សន៍បាយ័ន្ត និងជាអ្នកកាសែត។ ហេតុការណ៍នោះបានកើតឡើងក្នុងឃុំឡាបានសៀក ក្រុងបានលុង ខេត្តរតនគីរី។
- មិនមានការរងរបួសត្រូវបានគេរាយការណ៍ទេហើយ បន្ទាប់ពីការបាញ់ប្រហារ បុរសទាំងបួននាក់ បានជិះម៉ូតូគេចទៅបាត់ក្នុងទិសដៅឆ្ពោះទៅព្រលានយន្តហោះ។

►►►
១៦ កក្កដា ២០១០
រាជធានីភ្នំពេញ

**ករណីសិក្សា ៣១**

**អ្នកនិពន្ធ-អ្នកសារព័ត៌មានខាងគណបក្សជំទាស់ទទួលការគំរាមសំលាប់ បន្ទាប់ពីមានការហាមប្រាមលើសៀវភៅ[៦៤]**

- លោក ប៉ែន ពុទ្ធសភា ជាអ្នកនិពន្ធ និងជាអ្នកសារព័ត៌មានវិទ្យុគណបក្ស សមរង្ស៊ី បានទទួលការគំរាមសំលាប់ បន្ទាប់ពីសៀវភៅរបស់គាត់ចំនួនពីរ ត្រូវបានហាមប្រាមដោយរដ្ឋាភិបាល។
 បុរសអនាមិកម្នាក់បានទូរស័ព្ទទៅកាន់ទូរស័ព្ទដៃរបស់លោកពុទ្ធសភា និងបានព្រមានថា "កុំខ្លាំងពេក ហើយអោយប្រយ័ត្ន បើមិនអញ្ចឹងទេឯងនឹងត្រូវសំលាប់"។
- សៀវភៅត្រៀមប្រឡងសំរាប់និស្សិត លើកឡើងពីបញ្ហាពុករលួយរបស់រដ្ឋាភិបាល និងការខកខានមិនគោរពសិទ្ធិមនុស្សរបស់អជ្ញាធរ។ រដ្ឋមន្ត្រីក្រសួងអប់រំលោក អ៊ឹម សិទ្ធី បានដាក់បំរាមជាផ្លូវការលើសៀវភៅទាំងនោះរយៈពេលពីរថ្ងៃមុនមានការគំរាមសំលាប់។
- សៀវភៅមួយក្នុងចំណោមសៀវភៅទាំងនេះ មានសរសេរនូវសំនួរថា "នៅក្នុងពេលអនាគតដ៏ឆាប់ខាងមុខនេះ តើប្រទេសកម្ពុជាអាចនឹងអភិវឌ្ឍបានដែរឬទេ? ហេតុអ្វី?" និង"តើអ្នកគិតឃើញដូចម្តេចពីការអនុវត្តសិទ្ធិមនុស្ស និងសេរីភាពក្នុងសង្គមកម្ពុជា?" ចម្លើយដែលផ្តល់ចំពោះសំនួរនេះ សរសេរថាប្រទេសកម្ពុជានឹងមិនអាចអភិវឌ្ឍក្រោមការដឹកនាំបច្ចុប្បន្ននេះទេ ដោយសារតែមានអំពើពុករលួយដ៏រីករាលដាល។

---

[៦៣] ព័តមានវិទ្យុអាស៊ីសេរី ថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០១០

[៦៤] អង្គការ លីកាដូ ករណីលេខ PP079THI10

►►► ១៩ កក្កដា ២០១០ ខេត្តស្វាយរៀង

**ករណីសិក្សា ៣២**

**អាជ្ញាធរវាយដំលើបុរសអ្នកភូមិម្នាក់ ដែលស្តាប់ការផ្សាយនៃស្ថានីយវិទ្យុឯករាជ្យ**[៦៥]

- អនុប្រធានភូមិ និងបងប្អូនប្រុសរបស់គាត់ បានវាយដំអោយសន្លប់បុរសម្នាក់ក្នុងខេត្តស្វាយរៀង បន្ទាប់ពីបុរសនោះ ត្រូវបានប្រទះឃើញកំពុងតែស្តាប់វិទ្យុសំលេងសហរដ្ឋអាមេរិក និងវិទ្យុអាស៊ីសេរី។ ស្ថានីយវិទ្យុទាំងនេះ រងការវាយប្រហារម្តងម្កាលពីអាជ្ញាធរនៃគណបក្ស គ្រប់គ្រងប្រទេសកម្ពុជា។
- ការវាយដំនេះកើតមានឡើងក្នុងភូមិកៃរជេស ឃុំបន្ទាយក្រាំង ស្រុកកំពង់រោទ៍។ ជនសង្ស័យត្រូវបានគេស្គាល់ថា ជាមន្ត្រីភូមិលោក ឃឹម មីន និងបងប្អូនប្រុសរបស់គាត់លោក ឃឹម រុន។ ជនរងគ្រោះត្រូវបានគេស្គាល់ថា ជាលោក អឿន សាហ៊ុយ។
- លោក ឃឹម សុខា អធិការរងនគរបាលស្រុកបាននិយាយថា ការិយាល័យរបស់លោកកំពុងតែធ្វើការស៊ើបអង្កេតរឿងនេះ។

►►► ២៦ សីហា ២០១០ រាជធានីភ្នំពេញ

**ករណីសិក្សា ៣៣**

**ព្រះសង្ឃខ្មែរកម្ពុជាក្រោម រងការគំរាមកំហែងចំពោះ ការបោះពុម្ពផ្សាយ កាសែត**[៦៦]

- ព្រះសង្ឃ ថាច់ ព្រៃ ជា ខឿន ព្រះសង្ឃពុទ្ធសាសនាខ្មែរកម្ពុជាក្រោមគង់នៅរាជធានីភ្នំពេញទទួលការគំរាមកំហែងពីប្រធានសង្ឃ និងតំណាងមកពីក្រសួងមហាផ្ទៃ ចំពោះការជាប់ពាក់ព័ន្ធរបស់ព្រះអង្គនៅក្នុងការបោះពុម្ពផ្សាយសារព័ត៌មានព្រៃនគរដែលជាកាសែតតំរង់ទិសទៅរកខ្មែរកម្ពុជាក្រោម។ ព្រះសង្ឃ ដែលបានកំពង់តែគង់នៅជាបណ្តោះអាសន្នឯវត្តអង្គតាមិញត្រូវបានប្រធានសង្ឃដកហូតយកលិខិតឆ្លងដែន។
- តំណាងក្រសួងមហាផ្ទៃបានប្រាប់ទៅព្រះអង្គថា ព្រះអង្គចាំបាច់ត្រូវបញ្ឈប់ការបោះពុម្ពផ្សាយសារព័ត៌មាន និងបានទាមទារអោយព្រះអង្គចុះហត្ថលេខាលើឯកសារយល់ព្រមបញ្ឈប់ការបោះពុម្ពផ្សាយកាសែតនេះ។
- អ្នកសារព័ត៌មានបានបញ្ឈប់ការបោះពុម្ពផ្សាយពីមុនមកជាច្រើនខែ ហើយឆ្លើយតបទៅនឹងការគំរាមកំហែងពីដំបូងពីអជ្ញាធរ។

►►► ៣ កញ្ញា ២០១០ ខេត្តកំពង់ស្ពឺ

**តំណាងសហជីពចូលសំរាកព្យាបាលនៅមន្ទីរពេទ្យ បន្ទាប់ពីរងការវាយដំពីជនមិនស្គាល់មុខច្រើននាក់**[៦៧]

- តំណាងសហជីពឈ្មោះ ផៅ សាក់ រងនូវការវាយដំពីបុរសពីរនាក់ កាលពីថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០១០ គឺបន្ទាប់ពីគាត់បានព្យាយាមចរចារពីបញ្ហាប្រាក់

---

[៦៥] ព័ត៌មានវិទ្យុអាស៊ីសេរី ថ្ងៃទី៤ ខែសីហា ឆ្នាំ២០១០

[៦៦] ព័ត៌មានវិទ្យុអាស៊ីសេរី ថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០១០។ ការស្រាវជ្រាវរបស់អង្គការ លីកាដូ

[៦៧] ហេង រស្មី វិទ្យុសំលេងសហរដ្ឋអាមេរិកជាភាសារខ្មែរ "តំណាងសហជីពសំរាកព្យាបាលនៅមន្ទីរពេទ្យបន្ទាប់ពីរងការវាយប្រហារ" ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០១០ (មាននៅគេហទំព័រ http://www.voanews.com/khmer-english/news/Union-Rep-Hospitalized-After-Assault-104097563.html )

**ករណីសិក្សា ៣៤**

រង្វាន់ជូនដល់កម្មករសំរាប់ឱកាសបុណ្យភ្ជុំបិណ្ឌ។

- ផៅ សាក់ ជាអ្នកដែលបានកំពុងព្យាយាមចរចារពីប្រាក់រង្វាន់ជូនដល់កម្មករនៅរោងចក្រកាត់ដេរសំលៀកបំពាក់ Generation ក្នុងខេត្តកំពង់ស្ពឺ រងការវាយប្រហារខណៈពេលដែលគាត់កំពុងតែជិះម៉ូតូទៅកាន់រោងចក្រ។ បុរសមិនស្គាល់អត្តសញ្ញាណពីរនាក់បានប្រើបន្ទះក្តារវាយលើក្បាលគាត់ផ្ទួនៗ។
- ផៅ សាក់ បានសំរាកព្យាបាលនៅមន្ទីរពេទ្យ បន្ទាប់ពីការវាយប្រហារលើរូបគាត់។ គាត់ចូលរួមជាមួយសហជីពសេរីកម្មករ ដែលមេដឹកនាំសហជីពនេះគឺលោក ជាវិជ្ជា ត្រូវបានគេសំលាប់ក្នុងឆ្នាំ២០០៤។ ប្រធានសហជីពនេះនាពេលបច្ចុប្បន្នគឺលោក ជា មុន្នី បានហៅអំពើវាយប្រហារនេះថាជា "អំពើប៉ុនប៉ងសំលាប់លើតំណាងសហជីពសេរីកម្មករ"។
- មិនមានជនសង្ស័យណាម្នាក់ត្រូវបានគេចាប់ខ្លួនទេ ប៉ុន្តែអធិការនគរបាលស្រុកសំរោងទង លោក យុត សុផល បានបដិសេធថា វាមិនមែនជាករណីប៉ុនប៉ងមនុស្សឃាតទេ។ គាត់និយាយថា វាគឺជាករណី "ផឹកស៊ីឈ្លោះគ្នា"។

# ៥. ការគំរាមកំហែងផ្នែកនយោបាយ

## *ករណីសិក្សា ៣៥៖ ហូ វ៉ាន់ -ញុះញង់អោយប្រជាពលរដ្ឋបាត់បង់ឧត្តមគតិ*[៦៨]

អ្នកអាចនិយាយបានថាស្ថានភាពរបស់ លោក ហូ វ៉ាន់ ដូចពេលបច្ចុប្បន្ន មិនមានអ្វីខុសប្លែកពីពេលមុន មានការប្រែប្រួលនាពេលថ្មីៗទេ ប៉ុន្តែក្នុងនាមគាត់ជាសមាជិកសភាមកពីគណបក្សជំទាស់ ស្ថានភាពនេះប្រហែលជាគ្មានអ្វីគួរអោយភ្ញាក់ផ្អើលទេ។

តំណាងរាស្ត្រប្រចាំមណ្ឌលភ្នំពេញ ដែលជាសមាជិកគណបក្សប្រឆាំងមកពីគណបក្ស សម រង្ស៊ី បានធ្វើការឃោសនាបោះឆ្នោតពីកម្មវិធីនយោបាយសំរាប់ការផ្លាស់ប្តូរ។ បន្ទាប់ពីការជាប់ឆ្នោត ជាតំណាងរាស្ត្រគាត់បានរក្សានូវការសន្យានោះ ហើយបានតស៊ូពុះពារដើម្បី បុព្វហេតុការពារដល់ប្រជាពលរដ្ឋ នៅក្នុងតំបន់មួយចំនួនក្នុងមណ្ឌលបោះឆ្នោតរបស់គាត់ ដែលឡោមព័ទ្ធទៅដោយបញ្ហា ដែលក្នុងចំណោមនោះ ក៏មានបញ្ហានៃអ្នករស់នៅជុំវិញបឹងកក់ផងដែរ។

បឹងនៅភ្នំពេញនេះ ដែលមួយផ្នែកនៃបឹង គឺជាទីកន្លែងស្នាក់នៅនៃអ្នកទេសចរណ៍ស្ពាយបង្វិចដ៏មានប្រជាប្រិយភាព ដោយសារវាមានផ្ទះសំណាក់មានតម្លៃថោក និងអាចមើលឃើញ ថ្ងៃអស្តង្គតយ៉ាងស្អាត ត្រូវបានគេរៀបចំគំរោងផែនការសំរាប់ការផ្លាស់ប្តូរដ៏ធំសម្បើមមួយ។ ដីបឹងទំហំ ១៣៣ហិកតា ត្រូវបានគេប្រគល់ទៅអោយក្រុមហ៊ុន ស៊ូកាគូ អ៊ីន (Shukaku Inc.) ជាក្រុមហ៊ុនរបស់សមាជិកព្រឹទ្ធសភាមកពីគណបក្សប្រជាជនកម្ពុជា លោក ឡៅ ម៉េងឃិន។ ក្រុមហ៊ុន ស៊ូកាគូ បានមានផែនការអភិវឌ្ឍន៍លើផ្ទៃដីនេះ ដោយតំរូវនូវការចាក់ដីបំពេញបឹង និងបំផ្លាញចោលផ្ទះសម្បែងរបស់អ្នករស់នៅតំបន់នោះ។ វាសនានៃប្រជាពលរដ្ឋចំនួន ៤,000 គ្រួសារ ដែលរស់នៅតំបន់នោះស្ថិតក្នុងស្ថានភាពគ្មានស្ថេរភាព។

ការណ៍នេះមិនមែនជាប្រភេទនៃការផ្លាស់ប្តូរដែលលោក ហូវ៉ាន់ បានគិតទៅដល់ទេ។

គាត់បានគិតថាវាជារឿងគ្រោះថ្នាក់មួយ ព្រោះការចាក់ដីបំពេញបឹងនឹងបណ្តាលអោយមានទឹកជំនន់ជាប្រចាំក្នុងរាជធានីភ្នំពេញ ហើយគាត់ចង់អោយគេធ្វើការវាយតម្លៃពីផលប៉ះពាល់បរិដ្ឋាន បានប្រព្រឹត្តទៅមុនពេលគំរោងការណ៍ការនេះចាប់ដំណើរការ។ ហើយពេលនោះ មានបញ្ហាកើតឡើងចំពោះប្រជាពលរដ្ឋនៅមណ្ឌលរបស់គាត់: ក្រុមហ៊ុនដែលនឹងទទួលផលប្រយោជន៍ពីគំរោង ដែលអោយកំរៃបានច្រើននេះ មានកាតព្វកិច្ចដើម្បីធានាថា អ្នករស់នៅឯតំបន់បឹងនេះត្រូវអោយផ្លាស់ប្តូរទីលំនៅ។

មន្ត្រីក្នុងតំបន់ខាងលើនៃគណបក្សប្រជាជនកម្ពុជា លោក ឆាយ ធីរិទ្ធ បានឆ្លើយតបតដោយការដាក់

---

[៦៨] មណ្ឌល កែវ "*មន្ត្រីនៃគណបក្សសម រង្ស៊ី រងការចោទប្រកាន់ថា បានឃោសនារកសំលេងឆ្នោតមុនពេលកំនត់*" វិទ្យុអាស៊ីសេរី ថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០០៧ (អត្ថបទបកប្រែមាននៅគេហទំព័រ http://www.khmerfuture.com/index.php?name=News&file=article&sid=2488&theme=Printer)។ សុខ សេរី "*ប្រធានការផ្សាយ នៃសារព័ត៌មានឃ្មែមបូឌា ដេលី ត្រូវបានកាត់ទោសពីបទបរិហាកេរ្តិ៍* វិទ្យុអាស៊ីសេរី ថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០០៩។ មាស សុខជា និង ជេមស៍ អូធូល "*តុលាការប្រកាសអោយលោក ហូ វ៉ាន់ រួចទោស*" ភ្នំពេញប៉ុស្តិ៍ ថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០០៩

ពាក្យបណ្តឹងប្រឆាំងនឹងលោក ហូ វ៉ាន់ ចោទប្រកាន់គាត់ពីការញុះញង់ និងធ្វើការឃោសនាបោះឆ្នោតមុនកាលកំនត់ និងរំលោភច្បាប់បោះឆ្នោត។

លោក ឆាយ ធីរិទ្ធ បាននិយាយក្នុងឆ្នាំ២០០៧ ថា "ទីមួយ គាត់ញុះញង់ប្រជាពលរដ្ឋ បណ្តាលអោយពួកគាត់បាត់បង់ឧត្តមគតិ បាត់បង់សន្តិសុខក្នុងបរិវេណមូលដ្ឋាន" និង "ទី2 វាមិនមែនជាពេលបោះឆ្នោតទេ តែគាត់បានយកឱកាសនេះ ធ្វើការឃោសនាបោះឆ្នោត ដើម្បីបានចំនេញសន្លឹកឆ្នោត។"

លោក ហូ វ៉ាន់ បានឆ្លើយតបតវិញថា ការស្តាប់ពីកង្វល់របស់ប្រជាពលរដ្ឋក្នុងមណ្ឌលរបស់ខ្លួន គឺជាតួនាទីរបស់គាត់ក្នុងនាមជាអ្នកតំណាងរាស្ត្រ។

លោក ហូ វ៉ាន់ បានគេចផុតពីបច្ច័យអាក្រក់នានាដែលកើតចេញពីព្រឹត្តការនោះ ប៉ុន្តែមុនពេលបន្តិចនៃការបោះឆ្នោតជាទូទៅឆ្នាំ២០០៨ គាត់បានព្យាយាមលើកស្លាកគណបក្ស សម រង្ស៊ី ក្នុងខណ្ឌឬស្សីកែវ ដែលនៅពេលនោះស្លាកគណបក្សនេះ ត្រូវបានមន្ត្រីនគរបាល ហែកទម្លាក់ចោល ហើយដែលរូបភាពធ្វើសកម្មភាពរបស់នគរបាលត្រូវគេថតបាន។ លោក ហូ វ៉ាន់ អះអាងថា នគរបាលប្រើដំបងវាយលើគាត់ ហើយរូបភាពបង្ហាញពីស្នាមជាំលើជើងរបស់គាត់ ត្រូវបានគេចែកចាយជាសាធារណៈ[៦៩]។

ក្នុងខែមេសា ឆ្នាំ២០០៩ គាត់ត្រូវបានគេវាយប្រហារម្តងទៀត។

តាមប្រមើលមើលទៅ ឧប្បត្តិហេតុនេះហាក់ដូចជារឿងចម្លែក ជាជាងជារឿងធ្ងន់ធ្ងរ: លោក ហូ វ៉ាន់ បានផ្តល់បទសម្ភាសន៍អោយកាសែត ខឹយែម បូឌា ដេលី ជាភាសាអង់គ្លេស ហើយគាត់បានធ្វើអត្ថាធិប្បាយពីលក្ខណ:សម្បត្តិនៃការសិក្សាអប់រំរបស់មន្ត្រីយោធាចំនួន ២២រូប។ មន្ត្រីទាំងនោះ បានសិក្សានៅប្រទេសវៀតណាម ហើយការស្រង់សំដីទាក់ទងនឹងការដែលលោក ហូ វ៉ាន់ ចោទសួរពីគុណភាពនៃការអប់រំហ្វឹកហ្វឺនរបស់មន្ត្រីទាំងអស់នេះ។

លោក ហូ វ៉ាន់ បានអះអាងថា អត្ថបទកាសែតបានដកស្រង់សំដីគាត់ខុស ហើយគាត់បានសរសេរលិខិតទៅកាន់បណ្ណាធិការសារព័ត៌មានរៀបរាប់ពីបញ្ហានេះ។ ទោះបីជាយ៉ាងណាក៏ដោយ នៅថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០០៩ រដ្ឋសភាជាតិ បានបោះឆ្នោតដកអភ័យឯកសិទ្ធិតំណាងរាស្ត្ររបស់លោក ហូ វ៉ាន់ បើកផ្លូវអោយមានការកាត់ទោសព្រហ្មទណ្ឌលើរូបគាត់។ នៅថ្ងៃដដែលនោះ រដ្ឋសភា ក៏បានដកហូតអភ័យឯកសិទ្ធិតំណាងរាស្ត្ររបស់លោកស្រី មូរ សុខហួរ តំណាងរាស្ត្រមកពីគណបក្ស សម រង្ស៊ីជាមួយគ្នា ដើម្បីអាចអោយគេប្តឹងប្រឆាំងនឹងគាត់ពីបទបរិហារកេរ្តិ៍ នៅក្នុងករណីដោយ ឡែកមួយទៀត។

នៅថ្ងៃទី៩ ខែសីហា ឆ្នាំ២០០៩ លោក ហូ វ៉ាន់ ត្រូវបានជាប់ចោទពីបទព្រហ្មទណ្ឌបរិហារកេរ្តិ៍។

[៦៩] ជាប មុនី "*តំណាងរាស្ត្រគណបក្សសម រង្ស៊ី ដាក់ពាក្យបណ្តឹងពីរឿងវាយដំ*" វិទ្យុសំលេងសហរដ្ឋអាមេរិកជាភាសារខ្មែរ ថ្ងៃទី២៥ ខែមីនា ឆ្នាំ២០០៨ (អត្ថបទបកប្រែមាននៅគេហទំព័រ http://ki-media.blogspot.com/2008/03/srp-lawmaker-files-suit-for-assault.html) សូមមើលផងដែរ សារព័ត៌មាន KI Media នគរបាលបំផ្លាញបដាស្លាកគណបក្ស សម រង្ស៊ី និងវាយដំលើលោក ហូ វ៉ាន់ សមាជិកសភា គណបក្ស សម រង្ស៊ី នៅពេលដែលការបោះឆ្នោតខិតជិតចូលមកដល់ (រូបថតបង្ហាញពីស្លាកគណបក្ស សម រង្ស៊ី ត្រូវបានបំផ្លាញ) (មាននៅគេហទំព័រ http://ki-media.blogspot.com/2008/03/police-destroyed-srp-banner-sign-and.html)

អ្នកសារព័ត៌មានពីររូប នៃសារព័ត៌មាន ឌឹ ឃែម បូឌាដេលី ក៏ត្រូវបានជាប់ចោទចំពោះការសរសេរបទអត្ថាធិប្បាយរបស់គាត់ដែរ។ នៅឯសវនាការ ព្រះរាជអាជ្ញារដ្ឋាភិបាល បានប្រាប់តុលាការថា លោក ហូ វ៉ាន់ "បានធ្វើអោយអន្តរាយដល់កេរ្តិ៍ឈ្មោះរបស់មន្ត្រី នៃក្រសួងការពារជាតិ ដែលជាអ្នកការពារជាតិ និងប៉ះពាល់ដល់សាមគ្គីភាពនៃប្រទេសជាតិ"។

ដោយមានការគាបសង្កត់យ៉ាងខ្លាំងពីសង្គមស៊ីវិល និងអ្នកផ្តល់ជំនួយជាអន្តរជាតិ តុលាការ បានសំរេចអោយលោក ហូវ៉ាន់ រួចខ្លួនពីការចោទប្រកាន់នៅថ្ងៃទី៩ ខែកញ្ញា ឆ្នាំ២០១០។ ទោះបីជាយ៉ាងណាក៏ដោយ ក៏បណ្ណាធិការជនជាតិបរទេសនៃសារព័ត៌មាន ឌឹ ឃែម បូឌាដេលី ត្រូវបានតុលាការកាត់ទោស និងបង្គាប់អោយបង់ប្រាក់ពិន័យចំនួន៤លានរៀល (១,០០០ដុល្លាសហរដ្ឋអាមេរិក)។

ប៉ុន្តែចាប់ពីខែសីហា ឆ្នាំ២០១០មក លោក ហូ វ៉ាន់ បានត្រលប់មកឃើញតាមអត្ថបទសារព័ត៌មានវិញ។ ពេលនេះ មានពាក្យចចាមអារ៉ាមថា អនុប្រធានរដ្ឋសភា លោក ងួន ញ៉ិល - ជាសមាជិកគណបក្សប្រជាជនកម្ពុជា - មាន "ទីប្រឹក្សាផ្ទាល់ខ្លួន" ៧១នាក់ លើបញ្ជីបុគ្គលិករបស់គាត់ ដែលក្នុងនោះ យ៉ាងហោចណាស់ក៏មានសាច់ញាតិគាត់ម្នាក់ផង[៧០]។ សមាជិកសភាជាច្រើនរូបបានអះអាងថា ប្រាក់ខែរបស់ទីប្រឹក្សាទាំងនោះសរុបទាំងអស់ ២៦,៧៣០ដុល្លាសហរដ្ឋអាមេរិក ក្នុងមួយខែ។

ទោះបីជាយ៉ាងណាក៏ដោយ ក៏ភាពត្រឹមត្រូវអំពី ចំនួនតួលេខនៃប្រាក់ខែនេះ អាចជារឿងក្រៅប្រធានបទ។ ប្រធានមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា លោក អ៊ូ វីរៈ បានប្រាប់សារព័ត៌មានភ្នំពេញប៉ុស្ដិ៍ ថា ចំនួនតួលេខនៃទីប្រឹក្សាទាំងអស់ គឺជាការខ្ជះខ្ជាយថវិកាសាធារណៈ។ គាត់បាននិយាយថា "បុគ្គលគ្រប់រូបក្នុងប្រទេសកម្ពុជាដឹងថា ទីប្រឹក្សាទាំងអស់នេះ ពិតជាមិនមានការទទួលខុសត្រូវចំពោះមុខបុគ្គល ឬស្ថាប័នទេ - ពួកគេមិនបានផ្តល់ការប្រឹក្សាទេ"។

លោក ហូ វ៉ាន់ រួមជាមួយតំណាងរាស្ត្រ មកពីគណបក្ស សម រង្ស៊ី ១២នាក់ផ្សេងទៀត ក្នុងលិខិតសរសេរទៅកាន់លោក ហេង សំរិន ប្រធានរដ្ឋសភា ពួកគេចង់អោយមានការស៊ើបអង្កេតរឿងនេះ។

ក្នុងបទសម្ភាសន៍មួយជាមួយសារព័ត៌មាន លោក ងួន ញ៉ិល បដិសេធមិនព្រមបង្ហាញពីចំនួនទីប្រឹក្សាដែលគាត់ជួលទេ។ គាត់បែរទៅជានិយាយប្រាប់សារព័ត៌មានយ៉ាងច្បាស់ថា គាត់នឹងពិចារណាដាក់ពាក្យបណ្ដឹងបរិហាកេរ្តិ៍ ប្រឆាំងនឹងសមាជិកសភាទាំងនោះ។

ខណៈពេលនោះ លោក ហេង សំរិន បានឆ្លើយតបទៅនឹងការស្នើសុំស៊ើបអង្កេត ដោយនិយាយថា ការមានទីប្រឹក្សា គឺជា "ការស្របតាមច្បាប់ និងជាសិទ្ធិរបស់មន្ត្រីទាំងអស់នៅកំរិតជួរថ្នាក់ដឹកនាំ ដោយមិនអាចប្រកែកតវ៉ាបាន"។ បន្ទាប់មក លោក ងួន ញ៉ិល បានដកការគំរាមប្តឹងរបស់គាត់វិញ។

លោក ហូ វ៉ាន់ បាននិយាយថា គាត់គ្រាន់តែស្វះស្វែងរកព័ត៌មានប៉ុណ្ណោះ។

[៧០] ថេត សម្បត្តិ និងជេមស៍ អូធូល "អនុប្រធានរដ្ឋសភាឆ្លើយតបទៅសេចក្តីកត់សំគាល់របស់បក្សជំទាស់" សារព័ត៌មានភ្នំពេញប៉ុស្ដិ៍ ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១០។ ទេព និមល "លោក ហេង សំរិន ការពារអនុប្រធានរដ្ឋសភា" សារព័ត៌មានភ្នំពេញប៉ុស្ដិ៍ ថ្ងៃទី៣ ខែកញ្ញា ឆ្នាំ២០១០

គាត់បានប្រាប់ទៅកាសែតភ្នំពេញប៉ុស្តិ៍ថា "យើងខ្ញុំបានសាកសួររឿងនេះ ធ្វើដូច្នេះដើម្បីអោយតម្លាភាពអាចត្រូវបានធានាសំរាប់រដ្ឋសភាជាតិ សមាជិកសភា និងប្រជាពលរដ្ឋ"។ "វាគ្រាន់តែជា សំណើរសុំការពន្យល់បកស្រាយប៉ុណ្ណោះ"។

## *អស់ទីកន្លែងសំរាប់ការធ្វើនយោបាយ*

លោក ហូ វ៉ាន់ មិនទាន់ត្រូវបានគេកាត់ទោសពីបទល្មើសណាមួយនៅឡើយ ប៉ុន្តែគណបក្ស គ្រប់គ្រងអំណាច បានបញ្ជូនសារយ៉ាងច្បាស់ចំពោះគាត់៖ អ្នកនយោបាយគណបក្សជំទាស់ មិនគួរពឹងផ្អែកលើរបាំងការពារនៃអភ័យឯកសិទ្ធិសភាទេ ពេលដែលពួកគេធ្វើសេចក្តីថ្លែងមានលក្ខណៈចំរូងចំរាស់ បើទោះបីជាសេចក្តីថ្លែងទាំងនោះតំណាងមតិយោបល់ខាងនយោបាយក៏ដោយ។

ការនិយាយស្តីបែបនយោបាយមានព្រំដែនកំណត់របស់វា ទោះបីជាសំរាប់អ្នកតំណាងរាស្ត្រដែលជាប់ឆ្នោតក៏ដោយ។

តាមពិតទៅ អភ័យឯកសិទ្ធិសភារបស់លោក ហូ វ៉ាន់ - ដែលគួរតែត្រូវបានប្រគល់អោយវិញ ជាស្វ័យប្រវត្តិ ដោយយោលទៅលើការសំរេចអោយរួចខ្លួនពីការចោទប្រកាន់[៧១] - មិនត្រូវបានប្រគល់អោយរហូតដល់ខែមិនា ឆ្នាំ២០១០ រយៈពេល ៦ខែបន្ទាប់ពីសវនា។

លោក ហូ វ៉ាន់ មិនមែនជាសមាជិកសភាតែមួយរូប ដែលត្រូវបានគេដកអភ័យឯកសិទ្ធិសភា ក្នុងឆ្នាំ ២០០៩ នោះទេ។ សមាជិកសភា មកពីគណបក្សសម រង្ស៊ី ជាមួយគ្នា មានទាំងលោកស្រី មូរ សុខហួរ ផងដែរ បានបាត់បង់អភ័យឯកសិទ្ធិសភា បន្ទាប់ពីសេចក្តីថ្លែងមានលក្ខណៈចំរូងចំរាស់របស់ខ្លួន។ កំលាំងនៃយុទ្ធនាការរបស់រដ្ឋាភិបាលប្រឆាំងនឹងសមាជិកគណបក្ស សម រង្ស៊ី ក្នុងពាក់កណ្តាល ឆ្នាំ២០០៩ រួមផ្សំជាមួយវិធីនៃការគំរាមកំហែងតាមផ្លូវតុលាការប្រឆាំងនឹងអ្នកសារព័ត៌មាន បុគ្គលិកអង្គការមិនមែនរដ្ឋាភិបាល និងមេធាវី បាននាំអោយ អង្គការឃ្លាំមើលសិទ្ធិមនុស្ស (Human Rights Watch) ធ្វើសេចក្តីសន្និដ្ឋានថា ប្រទេសកម្ពុជា "បានកំពុងតែធ្វើការ បង្ក្រាបយ៉ាងធ្ងន់ធ្ងរលើសេរីភាពខាងការបញ្ចេញមតិនាឆ្នាំថ្មីៗនេះ និងកំពុងតែចេញជារូបរាងនៃរាជរដ្ឋាភិបាលផ្តាច់ការកាន់តែខ្លាំងឡើងៗ"[៧២]។

---

[៧១] សូមមើល ច្បាប់ស្តីពីលក្ខន្តិកៈតំណាងរាស្ត្រ (២០០៦) មាត្រា១៦

[៧២] អង្គការឃ្លាំមើលសិទ្ធិមនុស្ស ប្រទេសកម្ពុជា: បញ្ចប់ការវាយប្រហារលើគណបក្សជំទាស់ និងអ្នករិះគន់ សេចក្តីថ្លែងការសារព័ត៌មាន ថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៩ មាននៅគេហទំព័រ: (http://www.hrw.org/en/news/2009/07/14/cambodia-end-assault-opposition-critics)។ ឧប្បត្តិហេតុផ្សេងទៀតដែលកើតមានឡើងរវាងខែមិថុនា និងខែកក្កដា ឆ្នាំ២០០៩ រួមមាន: (១) ការកាត់ទោសលោក ហង្ស ចក្រា ចាងហ្វាងការផ្សាយសារព័ត៌មានជំទាស់ *ខ្មែរម្ចាស់ស្រុក* ។ (២) ការបង្ខំលោក គង់ សំអុន អោយចុះចូលគណបក្សប្រជាជនកម្ពុជាដែលគាត់គឺជាមេធាវីម្នាក់ ក្នុងចំណោមមេធាវីតែពីរ ឬបីនាក់ដែលមានឆន្ទះធ្វើជាតំណាងអោយសមាជិកគណបក្សជំទាស់ សម រង្ស៊ី នៅតុលាការ។ គាត់ក៏ត្រូវបានលោក ហ៊ុន សែន ប្តឹងពីបទបរិហារកេរ្តិ៍ និងបានគំរាមបណ្តេញចេញពីគណមេធាវី ដែលបណ្តាលអោយគាត់ឈប់តំណាងអោយលោកស្រី មូរ សុខហួរ និងលោក ហូ វ៉ាន់។ (៣) ការបិទសារព័ត៌មាន*មនសិកាខ្មែរ*របស់លោក ដាំ សិទ្ធិ ជា សារព័ត៌មានជំទាស់ មានអាយុចាស់ជាងគេ និងមានឥទ្ធិពលបំផុត។ គាត់បានបិទកាសែតរបស់គាត់ ដើម្បីជៀសផុតពីការកាត់ទោសព្រហ្មទណ្ឌមកលើរូបគាត់ ចំពោះការរិះគន់មន្ត្រីរាជរដ្ឋាភិបាល និង(៤) ការកាត់ទោស លោក មឿង សុន ប្រធានអង្គការមិនមែនរដ្ឋាភិបាលមូលនិធិអារិយធម៌ខ្មែរ ដែលតុលាការសំរេចអោយគាត់ជាប់ពន្ធនាគាររយៈពេល ២ឆ្នាំ ពីបទផ្សព្វផ្សាយព័ត៌មានមិនពិត បន្ទាប់ពីគាត់បានលើកឡើងនូវកង្វល់អំពីផលប៉ះពាល់ពីការបំពាក់ភ្លើងបំភ្លឺនៅប្រាសាទអង្គរវត្ត

តាំងពីពេលនោះមកអ្វីៗមានតែទៅរកស្ថានភាពអាក្រក់ទៅៗ។ មានការប្តឹងផ្តល់តាមផ្លូវតុលាការដោយមិនត្រឹមត្រូវជាច្រើន មកលើមេដឹកនាំគណបក្សប្រឆាំង លោក សម រង្ស៊ី។ មកត្រឹមខែកញ្ញា ឆ្នាំ២០១០ គិតជារួម គាត់ត្រូវជាប់ពន្ធនាគាររយៈពេលរហូតដល់ ១២ឆ្នាំ និងប្រាក់ពិន័យរាប់ពាន់ដុល្លាសហរដ្ឋអាមេរិក ដែលជាលទ្ធផលនៃការកាត់សេចក្តីលើរូបគាត់ក្នុងករណីពីរដាច់ដោយឡែកពីគ្នា (ករណីទាំងពីរនេះសុទ្ធតែទាក់ទងនឹងឧប្បត្តិហេតុ"បង្គោលព្រំដែន"ដូចគ្នានៅព្រំដែនវៀតណាម)។ គាត់នៅតែប្រឈមមុខនឹងការសើររើពិនិត្យឡើងវិញនាពេលថ្មីៗនេះ នូវពាក្យបណ្តឹងបរិហារកេរ្តិ៍ ដែលបានប្តឹងប្រឆាំងនឹងរូបគាត់ ដោយមន្ត្រីគណបក្សប្រជាជនកម្ពុជាកាលពី២ឆ្នាំកន្លងមក[៧៣]។ការកាត់សេចក្តីលើករណីនៃបណ្តឹងនេះ ជាលទ្ធផលអាចអោយគាត់មានទោសជាប់ពន្ធនាគារ ជាបន្ថែមទៀត បើសិនជាគាត់បដិសេធមិនបង់ប្រាក់ពិន័យដែលនឹងកំណត់ដោយតុលាការ។ នៅពេល ដែលសេចក្តីសំរេចទាំងអស់ចំពោះគាត់ចូលជាស្ថាពរវានឹងធ្វើអោយគាត់គ្មានសិទ្ធិកាន់កាប់អសនៈ ក្នុងរដ្ឋសភាទេ។


លោកស្រី មូរ សុខហួរ សមាជិកសភាមកពីគណបក្ស សម រង្ស៊ី

លោកស្រី មូរ សុខហួរ ត្រូវបានកាត់ទោសពីការបរិហារកេរ្តិ៍លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន កាលពីក្នុងពាក់កណ្តាលឆ្នាំ២០០៩ ហើយគាត់បានចាញ់ក្តីចំពោះបណ្តឹងឧទ្ធរណ៍ និងបណ្តឹងសារទុក្ខរបស់គាត់ជាបន្តបន្ទាប់។ គាត់បានបដិសេធមិនបង់ប្រាក់ពិន័យដែលកំនត់ដោយតុលាការទេ ហើយគាត់បានជៀសវាងបានពីការចាប់ដាក់ពន្ធនាគារ បន្ទាប់ពីគេតំរូវអោយរដ្ឋសភាជាតិរឹបអូសប្រាក់មួយចំនួនពីប្រាក់បៀវត្សរបស់គាត់។

ខណៈពេលនេះ អ្នកបង្កើតគណបក្សជំទាស់មួយទៀតដែលសំខាន់ផងដែរ - គណបក្សសិទ្ធិមនុស្ស - កំពុងតែស្ថិតក្នុងគ្រោះថ្នាក់នៃការបាត់បង់អភ័យឯកសិទ្ធិតំណាងរាស្ត្ររបស់គាត់ផងដែរ។ លោក កឹម សុខា ដែលពីមុនមកបានបង្កើតមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា(CCHR) ប្រឈមមុខ នឹងបទចោទប្រកាន់រំលោភសេចក្តីទុកចិត្ត ទាក់ទងនឹងការងារពីមុនរបស់គាត់នៅ CCHR[74]។ ការចោទប្រកាន់នេះធ្វើឡើងដោយអតីតបុគ្គលិកអង្គការ CCHR ដែលបុគ្គលិកនេះហាក់ដូចជា មិនឃើញថាមានទំនាក់ទំនងជាមួយរដ្ឋាភិបាលទេ។

ប៉ុន្តែការដកហូតអភ័យឯកសិទ្ធិសភា មិនមែនគ្រាន់តែជាមធ្យោបាយតែមួយគត់ដែលគេប្រើប្រាស់ដើម្បីដាក់កំហិតលើការនិយាយស្តីខាងនយោបាយ និង មិតិយោបល់ចំរុះគ្នា។

ក្នុងខេត្តកំពង់ធំ សកម្មជនគណបក្សសម រង្ស៊ី ត្រូវបានគេចាប់ខ្លួន និងចោទប្រកាន់ពីបទភ្លែងបន្លំ បន្ទាប់ពីគាត់ដាក់ពាក្យបណ្តឹង ដែលមានស្នាមមេដៃរបស់អ្នកភូមិទាមទារអោយអាជ្ញាធរប្រគល់ដី អោយពួក

---

[៧៣] សូមមើល ករណីសិក្សា ៤៤

[៧៤] សូមមើល ករណីសិក្សា ៤២

គេវិញ[៧៥]។ ករណីនេះកើតឡើងភ្លាមៗ បន្ទាប់ពីការកាត់សេចក្តីក្នុងទ្រង់ទ្រាយដ៏គួរកត់សំគាល់មួយលើសមាជិកក្រុមប្រឹក្សាឃុំមកពីគណបក្សជំទាស់ លោក ទួត សារ៉ន ក្នុងឆ្នាំ២០០៩ ដែលក៏កើតមានឡើងនៅក្នុងខេត្តកំពង់ធំដែរ។ លោក សារ៉ន ត្រូវបានកាត់សេចក្តីដោយអយុត្តិធម៌ ពីរឿងបង្ខាំងអតីតអ្នកនយោបាយគណបក្សសម រង្ស៊ី ដោយខុសច្បាប់ក្នុងកំឡុងពេលនៃការបោះឆ្នោតឆ្នាំ២០០៨ ខិតជិតចូលមកដល់[៧៦]។

នៅទីកន្លែងឯទៀតៗ មន្ត្រីមូលដ្ឋាននៃគណបក្ស សម រង្ស៊ី ត្រូវរងការចោទប្រកាន់ពីបទបរិហារកេរ្តិ៍ និងផ្សព្វផ្សាយព័ត៌មានមិនពិត ចំពោះការរិះគន់លើផែនការការងារសាងសង់ផ្លូវ - គាត់គិតថា ថវិកាសាធារណៈត្រូវបានគេប្រើប្រាស់សំរាប់បំរើផលប្រយោជន៍របស់អ្នកមានអំណាចក្នុងមូលដ្ឋានម្នាក់[៧៧]។

អាជ្ញាធរបានបង្ក្រាបលើបុគ្គលនានា ដែលសង្ស័យថាមានជាប់ពាក់ព័ន្ធជាមួយករណីដាច់ដោយឡែកពីគ្នាពីរនៃការចែកចាយខិតប័ណ្ណនយោបាយ[៧៨]។ ខិតប័ណ្ណទាំងនោះ រិះគន់ដល់ទំនាក់ទំនងរបស់រាជរដ្ឋាភិបាលជាមួយប្រទេសវៀតណាម ជាប្រធានបទដែលគណបក្សជំទាស់តែងតែលើកយកមកនិយាយជាញឹកញាប់។

---

[៧៥] សូមមើល ករណីសិក្សា ៣៩

[៧៦] ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា "*សេចក្តីថ្លែងការណ៍របស់ OHCHR ស្តីពីករណី លោក ទួត សារ៉ន*" ថ្ងៃទី៣០ ខែមីនា ឆ្នាំ២០០៩។ មាននៅគេហទំព័រ:http://cambodia.ohchr.org/WebDOCs/DocStatements/2009/032009/StatementOnToutSaran_30032009E.pdf) សេចក្តីថ្លែងការណ៍របស់អង្គការសហប្រជាជាតិនេះ ពិពណ៌នាពីការកាត់សេចក្តីថាគឺជា "*ការអនុវត្តន៍យុត្តិធម៌មិនបានត្រឹមត្រូវសំរេចមិនមែនផ្អែកលើអង្គហេតុដែលសមនឹងទទួលទោសទេ ប៉ុន្តែក្រោមឥទ្ធិពលនយោបាយ។*"

[៧៧] សូមមើល ករណីសិក្សា ៤១

[៧៨] សូមមើល ករណីសិក្សា ១៧ និង ៤០

**ខាងក្រោមនេះជាសេចក្ដីសង្ខេបនៃករណីទាក់ទងនឹងសកម្មភាពប្រកបដោយការគាបសង្កត់របស់រាជរដ្ឋាភិបាលទៅលើបុគ្គល ដែលសំដែងមតិយោបល់ខាងនយោបាយ ឬអនុវត្តភារកិច្ចខាងនយោបាយ៖**

►►►
កំពុងកើតមាន
ឆ្នាំ២០១០
ខេត្តស្វាយរៀង

**ករណីសិក្សា ៣៦**

**លោក សម រង្ស៊ី ត្រូវបានគេកាត់ទោសពីបទ ‘ញុះញង់អោយមានការរើសអើងជាតិសាន៍’ បន្ទាប់ពីការដកបង្គោលព្រំដែន**[៧៩]

- ប្រធានគណបក្សជំទាស់ លោក សម រង្ស៊ី ត្រូវបានតុលាការកាត់ទោសកំបាំងមុខលើបទចោទប្រកាន់ពីការញុះញង់អោយមានការរើសអើងជាតិសាសន៍ និងការបំផ្លិចបំផ្លាញទ្រព្យសម្បត្តិសាធារណៈ ចំពោះការដករំលើងបង្គោលសំគាល់ព្រំដែនរវាងប្រទេសកម្ពុជា-វៀតណាម។ គាត់ត្រូវបានកាត់ទោសអោយជាប់ពន្ធនាគាររយៈពេល២ឆ្នាំ។ អ្នកភូមិស្វាយរៀងពីរនាក់ ក៏ត្រូវបានតុលាការកាត់ទោសផងដែរ ហើយពួកគេទទួលទោសជាប់ពន្ធនាគារមួយឆ្នាំ។
- ប្រទេសកម្ពុជា និងវៀតណាម កំពុងតែដំណើរការដាក់បង្គោលសំគាល់លើព្រំដែន ដែលមានប្រវត្តិស្រពិចស្រពិល ប៉ុន្តែលោក សម រង្ស៊ី អះអាងថាព្រំប្រទល់ថ្មីនេះ បានបណ្ដាលអោយអ្នកភូមិនៃប្រទេសកម្ពុជាបាត់បង់ដីធ្លីរបស់ពួកគេ។ នៅថ្ងៃទី២៥ ខែសីហា ឆ្នាំ២០០៩ គាត់បានធ្វើសន្និសិទ្ធិសារព័ត៌មាននៅភូមិគាស់ក្បានកណ្ដាលក្នុងខេត្តស្វាយរៀង។ នៅក្នុងព្រឹត្តិការណ៍នោះ គាត់បានចូលរួមជាសាធារណៈជាមួយអ្នកភូមិពីរនាក់ ដករំលើងបង្គោលព្រំដែនលេខ១៨៥ ដែលគាត់អះអាងថាបានដាក់ដោយខុសច្បាប់។
- សវនាការលើបណ្ដឹងឧទ្ធរណ៍របស់លោកសម រង្ស៊ី ត្រូវបានពន្យាពេលជាច្រើនលើកពេញមួយរដូវប្រាំងឆ្នាំ២០១០ រហូតដល់ទីបំផុតសាលាឧទ្ធរណ៍បើកសវនាការនៅថ្ងៃទី១២ ខែតុលា ឆ្នាំ២០១០ សំរេចបដិសេធការទាមទាររបស់គាត់។ សហចុងចោទរបស់គាត់ទាំងពីរនាក់ ត្រូវបានសាលាឧទ្ធរណ៍កាត់តំរឹមដោយបន្ថយទោសចំនួន ២ខែចេញ។
- លោក សម រង្ស៊ី ក៏ប្រឈមមុខនឹងបទចោទប្រកាន់ផ្សព្វផ្សាយព័ត៌មានមិនពិតនិងក្លែងបន្លំ ទាក់ទិននឹងព្រឹត្តិការណ៍នេះ៖ គាត់បានចែកចាយផែនទីបង្ហាញពីខ្សែបន្ទាត់ព្រំដែនកម្ពុជា-វៀតណាម ដែលមានភាពខុសគ្នា ពីឯកសារផ្លូវការរបស់រាជរដ្ឋាភិបាល [សូមអានករណីសិក្សាលេខ៤៥]។
- គាត់ក៏ប្រឈមមុខនឹងបទបរិហារកេរ្តិ៍ផ្សេងមួយទៀតផងដែរ ទាក់ទងនឹងការធ្វើអត្ថាធិប្បាយរបស់គាត់ចំពោះមន្ត្រីជាន់ខ្ពស់រដ្ឋាភិបាលក្នុងឆ្នាំ២០០៨ និង២០០៩ [សូមអាន ករណីសិក្សាលេខ៤៤]។

---

[៧៩] សារព័ត៌មានកម្ពុជាថ្មី ថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០១០។ ហ្គាយ ឌឺ ឡូនីយ “ប្រទេសកម្ពុជា ផ្ដន្ទាទោស លោក សម រង្ស៊ី” ព័ត៌មាន BBC News ថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០០៥។ អង្គការឃ្លាំមើលសិទ្ធិមនុស្ស *“ប្រទេសកម្ពុជា: សវនាការលើមេដឹកនាំគណបក្សជំទាស់ លោក សមរង្ស៊ី ជា ការសម្ដែងល្ខោន”* ថ្ងៃទី២៨ ខែមករា ឆ្នាំ២០១០ (មាននៅគេហទំព័រ: http://www.hrw.org/en/news/2010/01/28/cambodia-opposition-leader-sam-rainsy-s-trial-farce)។ មាស សុខជា “តម្កល់សេចក្ដីសំរេចលើ លោក សម រង្ស៊ី” ភ្នំពេញប៉ុស្ដិ៍ ថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១០

▶▶▶
៩ កក្កដា ២០១០
ខេត្តកំពង់ធំ

**ករណីសិក្សា ៣៧**

**សកម្មជនគណបក្សសម រង្ស៊ី រងការចោទប្រកាន់ពីបទធ្វើភេរវកម្ម បន្ទាប់ពីការនិយាយប្រឆាំងនឹងក្រុមហ៊ុន[៨០]**

- តុលាការក្នុងខេត្តកំពង់ធំ បានសើរើបើកសំណុំរឿងអាយុ៦ឆ្នាំមួយឡើងវិញ ដោយចោទប្រកាន់លើសមាជិកបួនរូបនៃគណបក្សជំទាស់សម រង្ស៊ី ពីបទធ្វើភេរវកម្ម។ ជនជាប់ចោទមានលោក គីម ហុង ជាក្រុមប្រឹក្សាឃុំ ក្រយា លោក អ៊ុក ថន ជាក្រុមប្រឹក្សាក្នុងស្រុកប្រាសាទបាល្ល័ង លោក គុយ គឿន ជាក្រុមប្រឹក្សាឃុំក្រយាខាងជើង និងលោក ជុំ ជាវ ក៏ជាក្រុមប្រឹក្សាឃុំក្រយាខាងជើង។
- អ្នកទាំងបួនត្រូវបានគេចោទប្រកាន់ជាលើកដំបូងពី បទធ្វើភេរវកម្ម ក្នុងឆ្នាំ ២០០៤ បន្ទាប់ ពីពួកគេប្រមូលស្នាមមេដៃអ្នកភូមិសំរាប់ធ្វើញត្តិដែលនិយាយរៀបរាប់ពីពាក្យចចាមអារាមថា ក្រុមដែលមានឈ្មោះ "ខ្លាក្រដាស" មានផែនការដើរចាក់បញ្ចូលសារធាតុ ដែលគេមិនស្គាល់ទៅក្នុងខ្លួនប្រជាពលរដ្ឋនៅពេលពួកគេដេកលក់។ អ្នកទាំងបួនបានអំពាវនាវដល់ក្រសួងមហាផ្ទៃ អោយធ្វើការស៊ើបអង្កេតពាក្យចចាមអារ៉ាមនេះ ប៉ុន្តែបែរជាត្រូវគេចោទប្រកាន់ខ្លួនថាជាសមាជិកនៃក្រុមនេះទៅវិញ។
- តុលាការមិនបានចាត់វិធានការលើរឿងនេះទេ រហូតដល់ខែឧសភា ឆ្នាំ២០១០ ទើបតុលាការកោះហៅអ្នកទាំងបួនមកសាកសួរ។
- ក្រុមអង្គការសិទ្ធិមនុស្សបានថ្កោលទោសសកម្មភាពនេះថាជា "ការប៉ុនប៉ងយ៉ាងច្បាស់ ក្រលែត ដើម្បីបំភិតបំភ័យអ្នកនយោបាយគណបក្សជំទាស់"។ អ្នកនាំពាក្យគណបក្ស សម រង្ស៊ី បាននិយាយថា អ្នកទាំងបួនត្រូវបានវាយប្រហារ ដោយសារភាពជោគជ័យរបស់ពួកគេក្នុងការប្រមូលការគាំទ្រចំពោះគណបក្សសម រង្ស៊ី នៅមូលដ្ឋាន។

▶▶▶
កក្កដា ២០១០
រាជធានីភ្នំពេញ

**ករណីសិក្សា ៣៨**

**សមាជិកសភាគណបក្សប្រឆាំង លោកស្រី មូរ សុខហួរ ប្រឈមមុខជាប់ពន្ធនាគារ ចំពោះ ការបរិហាកេរ្តិ៍ លោកនាយករដ្ឋមន្ត្រី[៨១]**

- តុលាការកំពូលតំកល់សេចក្តីសំរេច ចំពោះលោកស្រី មូរ សុខហួរ សមាជិកសភាគណបក្ស សម រង្ស៊ី ក្នុងករណីបរិហារកេរ្តិ៍លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន។
- លោកស្រី មូរ សុខហួរ គឺជាតំណាងរាស្ត្រមកពីខេត្តកំពត ដែលបានប្តឹង លោក

[៨០] វង់ សុខេង "ក្រុមអង្គការសិទ្ធិមនុស្សជំរុញតុលាការអោយបញ្ឈប់ការស៊ើបសួររឿងភេរវកម្ម" សារព័ត៌មានភ្នំពេញប៉ុស្តិ៍ ថ្ងៃទី២៦ ខែ កក្កដា ឆ្នាំ២០១០។ សារព័ត៌មានមនសិកាខ្មែរ ថ្ងៃទី៨ ខែកក្កដា ឆ្នាំ២០១០។ ព័ត៌មានវិទ្យុសំលេងសហរដ្ឋអាមេរិក ថ្ងៃទី៩ កក្កដា ឆ្នាំ ២០១០

[៨១] វិទ្យុអាស៊ីសេរីថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១០។ មាស សុខជា "ប្រាក់ពិន័យលើលោកស្រី សុខហួរ នឹងត្រូវគេកាត់ចេញពីប្រាក់បៀវត្សរ៍" សារព័ត៌មានភ្នំពេញប៉ុស្តិ៍ ថ្ងៃទី១២ ខែសីហា ឆ្នាំ២០១០។ "សាលក្រម លោកស្រី មូរ សុខហួរ: រឿងតក់ស្លត់មួយទៀតដែលប៉ះពាល់ដល់ប្រជាធិបតេយ្យប្រទេសកម្ពុជា" សេចក្តីថ្លែងការសារព័ត៌មានអង្គការលីកាដូ ថ្ងៃទី៤ ខែសីហា ឆ្នាំ២០១០

ហ៊ុន សែន ក្នុងឆ្នាំ២០០៩ បន្ទាប់ពីលោក ហ៊ុន សែន នៅក្នុងការថ្លែងជាសាធារណៈរបស់គាត់និយាយសំដៅលើស្ត្រីមកពីខេត្តកំពត ដែលមិនបញ្ចេញឈ្មោះក្នុងលក្ខណៈបន្ទាបបន្ថោក។ លោកនាយករដ្ឋមន្ត្រី បន្ទាប់មកបានប្ដឹងបកត្រលប់មកលើលោកស្រីវិញ ដោយអះអាងថា ពាក្យបណ្ដឹង របស់លោកស្រី មូរ សុខហួរ ស្មើនឹងការបរិហារកេរ្តិ៍។ លោកស្រី មូរ សុខហួរ ពេលនោះត្រូវបានគេដកអភ័យឯកសិទ្ធិសភារបស់គាត់។

- ពាក្យបណ្ដឹងរបស់សមាជិកសភាមកពីគណបក្សជំទាស់រូបនេះ ត្រូវបានតុលាការទាត់ ចោលមិនពិចារណា ប៉ុន្តែពាក្យបណ្ដឹងរបស់លោកនាយករដ្ឋមន្ត្រីត្រូវបានគេដាក់អោយដំណើរការ និងនាំទៅដល់ការកាត់សេចក្ដីលោកស្រី មូរ សុខហួរ ក្នុងឆ្នាំ២០១០។
- សេចក្ដីសំរេចមិនតំរូវអោយដាក់ពន្ធនាគារទេ ប៉ុន្តែលោកស្រីត្រូវបានតុលាការបង្គាប់អោយបង់ប្រាក់ចំនួន៨,៥លានរៀល (២,០០០ ដុល្លាសហរដ្ឋអាមេរិក) ជាសំណងជំងឺចិត្ត ចំពោះលោក ហ៊ុន សែន និងបង់ប្រាក់ពិន័យចំនួន ៨លានរៀលទៀត។ លោកស្រី មូរ សុខហួរ បានបដិសេធមិនព្រមបង់ប្រាក់ ហើយដែលការណ៍នេះ អាចអោយគាត់ប្រឈមមុខនឹងការជាប់ពន្ធនាគាររហូតដល់ ៦ខែ។ នៅទីបំផុតប្រាក់ ត្រូវបានគេកាត់ចេញពីប្រាក់ខែសមាជិកសភារបស់គាត់ ហើយគាត់ជៀសវាងបានពីការជាប់ពន្ធនាគារ។

►►►
០៩ សីហា ២០១០
ខេត្តកំពង់ធំ

**ករណីសិក្សា ៣៩**

**សកម្មជនគណបក្សប្រឆាំង ត្រូវបានគេចាប់ខ្លួនពីបទចោទប្រកាន់ថា បានក្លែងបន្លំស្នាមមេដៃ លើញត្តិ**[៨២]

- សកម្មជនគណបក្ស សមរង្ស៊ី ត្រូវបានគេចាប់ខ្លួន និងចោទប្រកាន់ពីបទក្លែងបន្លំ បន្ទាប់ពីគាត់បានដាក់ញត្តិ ដែលមានស្នាមមេដៃរបស់អ្នកភូមិទាមទារអោយអាជ្ញាធរប្រគល់ដីអោយពួកគេវិញ។
- អ្នកស្រី លឹម ណាត ត្រូវបានអជ្ញាធរខេត្តចាប់ខ្លួន ដោយអះអាងថា ស្នាមមេដៃទាំង ៤០០ មានលើញត្តិជាស្នាមមេដៃក្លែងក្លាយ។ អ្នកស្រី លឹម ណាត បច្ចុប្បន្នរស់នៅភូមិលាបទង ឃុំបន្ទាយស្ទោង ស្រុកស្ទោង។ អាជ្ញាធរចាប់យកដីនោះក្នុងឆ្នាំ២០០៧។
- អ្នកនាំពាក្យរបស់គណបក្ស សម រង្ស៊ី ហៅករណីនេះខ្លាំងៗថា ជារឿង "នយោបាយ" និងបាននិយាយថា អ្នកភូមិខ្លះដែលបានផ្ដិតមេដៃលើញត្តិនេះបានស្លាប់បាត់ទៅហើយ។

[៨២] សារព័ត៌មានរស្មីកម្ពុជា ថ្ងៃទី១១ ខែសីហា ឆ្នាំ២០១០

►►►
១១ សីហា ២០១០
រាជធានីភ្នំពេញ

**ករណីសិក្សា៤០**

**នគរបាល តាមចាប់ខ្លួនសកម្មជនគណបក្សជំទាស់ ដែលសង្ស័យថា បានចែកចាយខិតប័ណ្ណ[៨៣]**

- នគរបាលបាននិយាយថា សកម្មជនគណបក្ស សម រង្ស៊ី ពីរនាក់ ត្រូវបានសង្ស័យថា បានចែកចាយខិតប័ណ្ណនយោបាយជំទាស់រាជរដ្ឋាភិបាលនៅជិតវត្តភ្នំ និងសួនសម្តេចហ៊ុន សែន។ ខិតប័ណ្ណរិះគន់គណបក្សប្រជាជនកម្ពុជាដែលកាន់អំណាច និងនិយាយថាមន្ត្រីនៃគណបក្សនេះ ស្ថិតក្រោមការគ្រប់គ្រងរបស់វៀតណាម។
- សកម្មជនទាំងពីររូប គឺលោក ជា សុភាព និងប្រពន្ធរបស់គាត់ ជា ដាលី ក្រោយមក បានរត់គេចទៅប្រទេសថៃ ប៉ុន្តែនៅបន្តធ្វើការបដិសេធចំពោះការជាប់ពាក់ព័ន្ធរបស់ខ្លួនក្នុងព្រឹត្តិការណ៍នោះ។

►►►
២០ សីហា ២០១០
ខេត្តព្រៃវែង

**ករណីសិក្សា៤១**

**សមាជិកគណបក្សជំទាស់ ត្រូវគេកាត់ទោសពីបទផ្សព្វផ្សាយព័ត៌មានមិនពិត ក្រោយពីគាត់បាន រិះគន់ផែនការការងារសាងសង់ផ្លូវ[៨៤]**

- មន្ត្រីនៅមូលដ្ឋានរបស់គណបក្ស សម រង្ស៊ី ត្រូវបានគេចោទពីបទបរិហារកេរ្តិ៍ និងផ្សព្វផ្សាយព័ត៌មានមិនពិត បន្ទាប់ពីគាត់ធ្វើអត្ថាធិប្បាយ យ៉ាងសំខាន់ទាក់ទងនឹងផែនការពង្រីកផ្លូវសាធារណៈរបស់អាជ្ញាធរ។
- លោក អ៊ុន សំអឿន ប្រធានយុវជនខេត្តនៃគណបក្ស សម រង្ស៊ី ត្រូវបានតុលាការកំនត់ អោយចូលខ្លួនមកសវនាការនៅថ្ងៃទី២០ ខែសីហា ឆ្នាំ២០១០ ប៉ុន្តែគាត់បាននិយាយថា គាត់នឹងមិនចូលខ្លួនទេ។ ទោះបីជាយ៉ាងណាក៏ដោយ ក្នុងអត្ថាធិប្បាយជាសាធារណៈ គាត់បានអះអាងថា ខ្សែរផ្លូវដែលគេសង្ស័យនេះរត់កាត់តាមគេហដ្ឋានរបស់ឧកញ៉ាដ៏មានអំណាចម្នាក់ក្នុងតំបន់ ដែលជាអ្នកជំរុញចំពោះគំរោងផែនការនេះ។ លោក សំអឿន អះអាងថាការពង្រីកផ្លូវនឹងនាំទៅដល់ការរំលោភចូលលើដីរបស់អ្នកភូមិ។
- លោកហែម ហ៊ុន ប្រធានឃុំស្តៅគង់ ក្នុងស្រុកបាភ្នំ បាននិយាយថា អត្ថាធិប្បាយរបស់លោក សំអឿន ជាការបន្ទាបបន្ថោកដល់ក្រុមប្រឹក្សាឃុំ។

---

[៨៣] វិទ្យុអាស៊ីសេរី ថ្ងៃទី១២ ខែសីហា ឆ្នាំ២០១០។ សារព័ត៌មាននគរវត្ត ថ្ងៃទី១៤ ខែសីហា ឆ្នាំ២០១០។ មាស សុខជា "ពីរនាក់ប្តីប្រពន្ធរត់ចេញពីប្រទេសដោយសារការចោទប្រកាន់រឿងខិតប័ណ្ណ" ភ្នំពេញប៉ុស្តិ៍ ថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១០

[៨៤] សារព័ត៌មានកម្ពុជាថ្មី ថ្ងៃទី២០ ខែសីហា ឆ្នាំ២០១០

►►►
៣០ សីហា ២០១០
រាជធានីភ្នំពេញ

**ករណីសិក្សា ៤២**

## អ្នកបង្កើតគណបក្សជំទាស់ ប្រឈមមុខនឹងបទចោទប្រកាន់ព្រហ្មទណ្ឌ[៨៥]

- អ្នកបង្កើតគណបក្សជំទាស់សិទ្ធិមនុស្ស អាចនឹងត្រូវគេដកហូតអភ័យឯកសិទ្ធិសភារបស់គាត់ និងបង្ខំអោយចូលខ្លួនមកសវនាការ ចំពោះបទចោទប្រកាន់ដែលមានមកតាំងពី ៤ឆ្នាំកន្លងមក។
- លោក កឹម សុខា ជាអ្នកដែលបានបង្កើតមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (CCHR) រងការចោទប្រកាន់ពីបទគៃបន្លំថវិកាជំនួយក្នុងអំឡុងពេល ដែលគាត់ធ្វើជាប្រធាន CCHR។ គាត់ប្រឈមមុខនឹងបទរំលោភសេចក្តីទុកចិត្តដែលគេអាចចោទប្រកាន់បាន ដែលវាតំរូវអោយដាក់ទោសជាប់ពន្ធនាគាររហូតដល់ ៥ឆ្នាំ។
- ពាក្យបណ្តឹងពីដំបូង ត្រូវបានប្តឹងដោយអតីតបុគ្គលិករបស់ CCHR ជាអ្នកដែលហាក់បីដូចជាមិនមានទំនាក់ទំនងអ្វីជាមួយរដ្ឋាភិបាលទេ។ ទោះបីជាយ៉ាងណាក៏ដោយ ក៏សមាជិកសភា តាមធម្មតាមានសិទ្ធិរួចផុតពីការចោទប្រកាន់ព្រហ្មទណ្ឌ ការចាប់ខ្លួន ការឃាត់ខ្លួន ឬការឃុំខ្លួន។ ព្រះរាជអាជ្ញាក្នុងករណីនេះ បានស្នើទៅរដ្ឋសភាជាតិ អោយដកយកសិទ្ធិនេះពីគាត់។ ប្រធានរដ្ឋសភាជាតិ លោក ហេង សំរិន បាននិយាយថា រដ្ឋសភាត្រូវតែ "គោរពនិតិវិធីច្បាប់"។
- រដ្ឋធម្មនុញ្ញប្រទេសកម្ពុជាចែងថា តំណាងរាស្ត្រមិនអាចត្រូវបានចោទប្រកាន់ ចាប់ខ្លួន ឃាត់ខ្លួន ឬឃុំខ្លួនឡើយ ដែលនឹងអាចធ្វើទៅបាន លុះត្រាតែសមាជិករដ្ឋសភាទាំងមូលបោះឆ្នោតអនុម័តដោយសម្លេងពីរភាគបី ដើម្បីផ្អាកអភ័យឯកសិទ្ធិសភារបស់អ្នកតំណាងរាស្ត្រ។
- ករណីនេះត្រូវបានផ្តើមប្តឹងដំបូងក្នុងឆ្នាំ២០០៦ ប៉ុន្តែគេទុកចោលដោយស្ងៀមស្ងាត់។ បណ្តឹងថ្មីមួយត្រូវបានគេដាក់ប្តឹងនៅថ្ងៃទី៣០ ខែសីហា។ គាត់ត្រូវបានគេកោះហៅក្នុងថ្ងៃជាមួយគ្នានឹងថ្ងៃដែលពាក្យបណ្តឹងត្រូវបានដាក់។ លោក សុខាបានបដិសេធថា ខ្លួនមិនបានប្រព្រឹត្តិកំហុសណាមួយទេ និងបាននិយាយថា វាជារឿងមិនធម្មតាមួយ ដែលតុលាការចាត់ការលើពាក្យបណ្តឹងយ៉ាងឆាប់រហ័ស។
- លោក សុខា បានចូលខ្លួនក្នុងតុលាការដើម្បីឆ្លើយសំនួរក្នុងថ្ងៃទី២១ ខែតុលា ឆ្នាំ២០១០ ប៉ុន្តែសេចក្តីលំអិតនៃករណីនេះ នៅមានកំរិតនៅឡើយក្នុងពេលនៃការបោះពុម្ពផ្សាយរបាយការណ៍នេះ។
- លោក កឹម សុខា ត្រូវបានគេចាប់ខ្លួនពីពេលមុន ពីបទព្រហ្មទណ្ឌបរិហារកេរ្តិ៍

---

[៨៥] សារព័ត៌មានកម្ពុជាថ្មី ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១០។ មាស សុខជា *"លោក កឹម សុខាអាចបាត់បង់អភ័យឯកសិទ្ធិសភា"* សារព័ត៌មានភ្នំពេញប៉ុស្ត៍ ថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០១០។ អេរិក ប៉ាប៉េ *"អ្នកប្រឆាំងកម្ពុជាដែលមានសេរីភាព: 'បាទខ្ញុំខ្លាច'"* ដំណឹងប្រចាំសប្តាហ៍ ថ្ងៃទី២១ ខែមករា ឆ្នាំ២០០៦។ មាស សុខជា "លោក កឹម សុខានឹងមកបង្ហាញខ្លួននៅតុលាការ" សារព័ត៌មានភ្នំពេញប៉ុស្ត៍ ថ្ងៃទី២១ ខែតុលា ឆ្នាំ២០១០។ មាស សុខជា "លោក កឹម សុខា បានបង្ហាញខ្លួននៅតុលាការ" សារព័ត៌មានភ្នំពេញប៉ុស្ត៍ ថ្ងៃទី២២ ខែតុលា ឆ្នាំ២០១០

បន្ទាប់ពីគាត់បានចូលរួមគ្នារៀបចំការប្រារព្ធពិធីកត់សំគាល់ ថ្ងៃសិទ្ធិមនុស្សអន្តរជាតិក្នុងខែធ្នូ ឆ្នាំ២០០៥។ គាត់បានចំណាយពេល១៧ថ្ងៃ នៅក្នុងពន្ធនាគារ និងត្រូវបានដោះលែងវិញ ក្រោយពីមានការគាបសង្កត់យ៉ាងខ្លាំងពីអន្តរជាតិ។

►►►
០២ កញ្ញា ២០១០
រាជធានីភ្នំពេញ

**ករណីសិក្សា៤៣**

**តំណាងរាស្ត្រគណបក្សជំទាស់ ត្រូវបានគេកោះហៅចំពោះករណីបរិហារកេរ្តិ៍ ឆ្នាំ ២០០៤**[៨៦]

- តុលាការរាជធានីភ្នំពេញ បានកោះហៅសមាជិកសភាគណបក្ស សម រង្ស៊ី លោក ជា ប៉ូច អោយចូលខ្លួនមកតុលាការទាក់ទងនឹងបណ្តឹងព្រហ្មទណ្ឌ បរិហារកេរ្តិ៍ មានអាយុ៦ឆ្នាំមួយ បើទោះបីជាគាត់នៅមានអភ័យឯកសិទ្ធិសភារួចផុតពីការចោទប្រកាន់ និងកាត់ទោសក៏ដោយ។
- ព្រះរាជអាជ្ញារង ឯក ឆេងហួត បង្គាប់អោយលោក ជា ប៉ូច ចូលខ្លួនមកតុលាការនៅថ្ងៃទី២៩ ខែកញ្ញា ប៉ុន្តែការបង្គាប់អោយចូលខ្លួនត្រូវបានលុបចោល និងលើកទៅពេលក្រោយវិញ ដោយមិនមានកំនត់កាលបរិច្ឆេទច្បាស់លាស់។
- ករណីនេះកើតចេញមកពីឧប្បត្តិហេតុក្នុងឆ្នាំ២០០៤ ដែលពេលនោះអ្នកនយោបាយខាងរាជានិយមស្តេចក្រុមព្រះនរោត្តម រណឫទ្ធិ បានប្តឹងលោក ជា ប៉ូច និងលោកប្រធានគណបក្ស សម រង្ស៊ី ចំពោះការថ្លែងថា គាត់បានទទួលយកប្រាក់សំណូកជាថ្នូរនឹងការបង្កើតរាជរដ្ឋាភិបាលចំរុះ ជាមួយគណបក្សប្រជាជនកម្ពុជា។
- រដ្ឋសភាជាតិបានផ្អាកអភ័យឯកសិទ្ធិសភារបស់សមាជិកសភាទាំងពីររូប ក្នុងខែកុម្ភៈ ឆ្នាំ២០០៥ ដែលជាការបង្ខំអោយពួកគេគេចខ្លួនចេញពីប្រទេស។ ពួកគេបានវិលត្រលប់មកក្នុងប្រទេសវិញក្នុង ឆ្នាំ២០០៦ បន្ទាប់ពីមានដំណោះស្រាយនយោបាយមួយ។
- លោក ជា ប៉ូច បានថ្លែងថា រដ្ឋសភាបានប្រគល់អភ័យឯកសិទ្ធិអោយគាត់វិញ និងមានការសំរេច អោយគាត់បានរួចផុតពីការចោទប្រកាន់ទាំងអស់តាំងពីច្រើនឆ្នាំមកហើយ។

[៨៦] សារព័ត៌មានខ្មែរម្ចាស់ស្រុក ថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១០។ មាស សុខជា *"សមាជិកសភា ត្រូវបានកោះហៅចំពោះករណីចាស់ៗ"* សារព័ត៌មានភ្នំពេញប៉ុស្តិ៍ ថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០១០។ សារព័ត៌មាននគរវត្ត ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០១០

►►►
៩ កញ្ញា ២០១០
រាជធានីភ្នំពេញ

**ករណីសិក្សា ៩៤**

**លោក សម រង្ស៊ី ត្រូវបានកោះហៅ ក្នុងករណីបរិហារកេរ្តិ៍ដែលមានអាយុ២ឆ្នាំ**[៨៧]

- តុលាការរាជធានីភ្នំពេញ បានកោះហៅមេដឹកនាំគណបក្សជំទាស់លោក សម រង្ស៊ី អោយមកប្រឈមមុខនឹងបណ្តឹងបរិហារកេរ្តិ៍មានអាយុ២ឆ្នាំ មួយដែលបានដាក់ប្តឹងដោយលោករដ្ឋមន្ត្រីក្រសួងការបរទេស ហោ ណាំហុង។
- បទអត្ថាធិប្បាយដែលនាំមកនូវការប្តឹងប្តល់នេះ ដំបូងឡើយត្រូវបានបោះពុម្ពក្នុងជីវប្រវត្តិសរសេរដោយខ្លួនឯងរបស់ លោក សម រង្ស៊ី ដែលគាត់បានចោទប្រកាន់លោករដ្ឋមន្ត្រីក្រសួងការបរទេសថា បានដឹកនាំពន្ធនាគារខ្មែរក្រហមនៅបឹងត្របែក។ លោក រង្ស៊ី បាននិយាយឡើងវិញនូវអត្ថាធិប្បាយរបស់គាត់ក្នុងអំឡុងពេល ដែលគាត់ថ្លែងសន្ទរកថា នៅកន្លែងវាលពិឃាតជើងឯកនាថ្ងៃទី១៧ ខែមេសា ឆ្នាំ២០០៨។ ពាក្យបណ្តឹងត្រូវបានដាក់ ប្តឹងភ្លាមៗ ប៉ុន្តែតុលាការមិនដែលចាត់ការលើបណ្តឹងនេះទេ។
- មេធាវីរបស់លោក សម រង្ស៊ី បាននិយាយថា គាត់ចង់ដឹងយ៉ាងខ្លាំងថាហេតុអ្វីបានជាតុលាការស្រាប់តែចាប់ផ្តើមដាក់អោយរឿងក្តីនេះ មានដំណើរការ។
- លោក រង្ស៊ី កំពុងតែរស់នៅក្រៅប្រទេសដោយនិរទេសខ្លួនឯង តាំងពីឆ្នាំ២០១០មក។

►►►
២២ កញ្ញា ២០១០
រាជធានីភ្នំពេញ

**ករណីសិក្សា ៩៥**

**លោក សម រង្ស៊ី ត្រូវបានកាត់ទោសពីបទល្មើសច្រើនថែមទៀត ទាក់ទងនឹងការកំណត់ព្រំដែន**[៨៨]

- មេដឹកនាំបក្សប្រឆាំង លោក សម រង្ស៊ី ត្រូវបានកាត់ទោសកំបាំងមុខពីបទចោទប្រកាន់ផ្សព្វផ្សាយព័ត៌មានមិនពិត និងក្លែងបន្លំឯកសារ ចំពោះការជជែកតវ៉ាជាសាធារណ:លើទីតាំងនៃព្រំដែនប្រទេសកម្ពុជា-វៀតណាម។ តុលាការបានកាត់ទោសអោយគាត់ជាប់ពន្ធនាគារ ១០ឆ្នាំ និងអោយបង់ប្រាក់ពិន័យចំនួន ១៦,០០០ដុល្លាសហរដ្ឋអាមេរិក។
- លោក សម រង្ស៊ី ត្រូវបានកាត់ទោសចំពោះការផ្សព្វផ្សាយផែនទី ក្នុងឆ្នាំ២០០៩ ជាផែនទី ដែលព្រំប្រទល់ប្រទេសកម្ពុជា និងវៀតណាម មានភាពខុសគ្នាពីព្រំប្រទល់ក្នុងផែនទីដែលរដ្ឋាភិបាលប្រើប្រាស់។ ព្រះរាអាជ្ញារាជរដ្ឋាភិបាលបានជជែកវែកញែកក្នុងពេលសវនាការថា ការណ៍នេះចាត់ចូលទៅក្នុងការផ្សាយព័ត៌មានមិនពិត និងក្លែងបន្លំឯកសារសាធារណ:។
- ផែនទីត្រូវបានចែកចាយ ដោយជាប់ពាក់ព័ន្ធជាមួយនឹងព្រឹត្តិការឆ្នាំ២០០៩

[៨៧] មាស សុខជា "លោក រង្ស៊ី ត្រូវបានហៅចូលតុលាការឡើងវិញ" សារព័ត៌មានភ្នំពេញប៉ុស្តិ៍ ថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១០

[៨៨] មាស សុខជា "លោក សម រង្ស៊ី ត្រូវកាត់អោយជាប់ទោស១០ឆ្នាំ" សារព័ត៌មានភ្នំពេញប៉ុស្តិ៍ ថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១០។ រ៉ូបឺត កាមី ខឺល "មេដឹកនាំគណបក្សជំទាស់កម្ពុជា ដែលនិរទេសខ្លួនត្រូវកាត់អោយជាប់ពន្ធនាគាររយ:ពេល១០ឆ្នាំ" ព័ត៌មានវិទ្យុសំលេងសហរដ្ឋអាមេរិក ថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១០

ដែលលោក សម រង្ស៊ី និងអ្នកភូមិពីរនាក់បានដកបង្គោលកំនត់សំគាល់ព្រំដែនរបស់ប្រទេសកម្ពុជាជាមួយប្រទេសវៀតណាម។ លោក សម រង្ស៊ី បានអះអាងថា ព្រំដែនបានខិតចូលមកក្នុងដីធ្លីរបស់អ្នកភូមិ [សូមអានករណីសិក្សា ៣៦]។

- នេះគឺជាការកាត់ទោសលើ លោក សម រង្ស៊ី ជាលើកទី២ ទាក់ទងនឹងឧប្បត្តិហេតុបង្គោលព្រំដែន។ គាត់ត្រូវបានកាត់ទោសនៅលើកដំបូងពីបទញុះញង់ - សវនាការដោយកំបាំងមុខផងដែរ - ដោយកំណត់អោយជាប់ពន្ធនាគាររយៈពេល២ឆ្នាំ ចំពោះការកាត់សេចក្តីករណីនេះ។ បណ្តឹងឧទ្ធរណ៍របស់គាត់ត្រូវបានបដិសេធចោលនៅថ្ងៃទី១២ ខែតុលា ឆ្នាំ២០១០។ លោក រង្ស៊ី បន្តរស់នៅនិរទេសខ្លួន។

# ៦. ការគំរាមកំហែងផ្នែកការទូត

### *ករណីសិក្សា ៨៦: ប្រទេសកម្ពុជា- 'យើងមិនមែនជាបាណាណា រីផាប្លិក [ Banana Republic]'*

---

លិខិតបានសរសេរយ៉ាងខ្លី ប៉ុន្តែវាមានន័យយ៉ាងច្បាស់។

នៅថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១០ ក្រសួងការបរទេសបានសរសេរលិខិតទៅកាន់ បេសកកម្មការទូតទាំងអស់ដែលតាំងនៅក្នុងប្រទេសកម្ពុជា។ សាររបស់លិខិតគឺ៖ អ្នកការទូតបរទេសទាំងអស់ មានភារកិច្ចមិនជ្រៀតជ្រែកចូលក្នុងកិច្ចការផ្ទៃក្នុងនៃ រដ្ឋដែលទទួលខ្លួនជាភ្ញៀវ។

លិខិតបាននិយាយទៀតថា "មានច្រើនលើកច្រើនគ្រាហើយ ដែលប្រធានបេសកកម្មការទូត បានប្រព្រឹត្តិចំពោះប្រទេសកម្ពុជាដូចជា'ទេសាភិបាលអាណាប្រទេសខ្លួន'"។ "ពួកគេលើកខ្លួនឯង ដើម្បីរិះគន់ ឬផ្តល់មេរៀនដល់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា។ អាកប្បកិរិយាបែបនេះ [sic] មិនអាចទទួលយកបានទេ..."

"ប្រទេសកម្ពុជាមិនមែនជា 'បាណាណារីផាប្លិក[BANANA REPUBLIC]'"[៨៩]។

លិខិតបានផ្ញើរចេញ រយៈពេលមិនយូរប៉ុន្មាន ក្រោយពីដំណើរការអនុម័តច្បាប់ប្រឆាំងអំពើពុករលួយរបស់កម្ពុជា ដែលការអនុម័តច្បាប់នេះដោយរដ្ឋសភាលឿនដូចផ្លេកបន្ទោរ បានរងនូវការរិះគន់ពីអ្នកសង្កេតការអន្តរជាតិមួយចំនួន រួមមានទាំងអង្គការសហប្រជាជាតិ។ សមាជិកសភា ត្រូវបានគេផ្តល់ពេលតែមួយសប្តាហ៍ ដើម្បីពិនិត្យមាត្រានៃអត្ថបទច្បាប់នេះ ហើយការបោះឆ្នោត ចុងក្រោយអនុម័តលើច្បាប់បានធ្វើឡើងបន្ទាប់ពីរយៈពេលតិចជាងពីរថ្ងៃ នៃការជជែកដេញដោលរបស់សភា។ សមាជិកសភាគណបក្សជំទាស់បាននាំគ្នាដើរចេញ និងបាននិយាយថា ច្បាប់នេះ មានតម្លៃតិចតួច សំរាប់ធ្វើការជាមួយរឿងពុករលួយ ហើយអ្វីៗដែលមានក្នុងច្បាប់នេះគឺសំរាប់ "ត្រួតត្រាខាងនយោបាយ"។

ក្នុងបរិបទនេះ អ្នកសំរបសំរួលប្រចាំប្រទេសរបស់អង្គការសហប្រជាជាតិ លោក ដូក្លាស ប្រូឌីរីក បានចេញនូវសេចក្តីថ្លែងការ ដោយស្នើរសុំអោយមានដំណើរការធ្វើច្បាប់ប្រព្រឹត្តិទៅ "ប្រកបដោយតម្លាភាព និងការចូលរួម" ច្រើនថែមទៀត។ ប្រទេសកម្ពុជា បានឆ្លើយតបវិញ ដោយការគំរាមកំហែងបណ្តេញគាត់ចេញពីប្រទេស។ នៅក្នុងលិខិតសរសេរទៅលោក ប្រូឌីរីក លោករដ្ឋមន្ត្រី ក្រសួងការបរទេស ហោ ណាំហុង បាននិយាយថា សេចក្តីថ្លែងការរបស់លោក ប្រូឌីរីក គឺជា "ការជ្រៀតជ្រែកចូលក្នុងកិច្ចការផ្ទៃក្នុងរបស់ប្រទេសកម្ពុជាយ៉ាងជាក់ស្តែង និងមិនអាចទទួលយកបាន"។ លិខិតសរសេរបន្តទៀតថា ការប្រព្រឹត្តនូវអាកប្បកិរិយាបែបនេះដដែលទៀត នោះនឹងមានការប្រកាសពីភាពនៃ "បុគ្គលដែលមិនអាចទទួលយកបាន [persona non

---

[៨៩] លិខិតលេខ ៨០៧ MFA-IC/DC ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១០ របស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិនៃប្រទេសកម្ពុជាផ្ញើជូន *"បេសកកម្មការទូតទាំងអស់ ប្រចាំនៅក្នុងព្រះរាជាណាចក្រកម្ពុជា"*

grata]" ចំពោះលោក ប្រូឌីរីក ហើយនឹងត្រូវបណ្តេញចេញពីប្រទេស[៩០]។

ខណៈពេលនេះដែរ ប្រភពមិនបញ្ចេញឈ្មោះពីក្រសួងការបរទេសបានប្រាប់ សារព័ត៌មាន ឌឺឃែម បូឌាដេលី ថា លិខិតដែលនិយាយពី "បាណាណារិផាប្លិក [Banana Republic]" ត្រូវបានចេញ ឆ្លើយតបទៅនឹងការកត់សំគាល់ របស់ឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិក លោកស្រីការ៉ូល រុដលីយ៍ អំពីបញ្ហាកាប់ឈើខុសច្បាប់។ លោកស្រីឯកអគ្គរដ្ឋទូត បានប្រាប់អ្នកសារព័ត៌មាននៅថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១០ ថា គាត់សូម "ស្វាគមន៍ចំពោះវិធានការរបស់រដ្ឋាភិបាល ទៅលើសកម្មភាពកាប់បំផ្លាញព្រៃឈើ ខ្ញុំសង្ឃឹមថា វិធានការទាំងនេះនឹងនាំទៅដល់ការចាប់ខ្លួន និងដាក់ទណ្ឌកម្ម ដោយតុលាការនៃជនទាំងឡាយណាដែលរំលោភច្បាប់។"[៩១]

លោក គុយ គួង អ្នកនាំពាក្យក្រសួងការបរទេស បាននិយាយថា លិខិតមិនមែនចេញសំដៅទៅលើនរណាម្នាក់ជាពិសេសនោះទេ ប៉ុន្តែគ្រាន់តែជាការរំលឹកដាស់តឿនដល់ អ្នកការទូតទាំងអស់ កុំអោយធ្វើ "ហួសដែនកំណត់នៃអាណត្តិការងាររបស់ខ្លួន"។[92]

ប្រភពមិនប្រាប់ឈ្មោះពីក្រសួងការបរទេស បានប្រាប់សារព័ត៌មាន ឌឺឃែម បូឌា ដេលី ថា "ប្រទេសកម្ពុជាត្រូវដោះស្រាយជាមួយបញ្ហានៃការកាប់ឈើ ហើយយើងមិនត្រូវការជនបរទេស មកប្រាប់ យើងទេ"។

### *យកនំពីគេមកហូប ដោយមិនអោយលុយគេ*

សេចក្តីថ្លែងការរបស់លោកស្រី រុដលីយ៍ និងលោក ប្រូឌីរីក មិនមានអ្វីចំរូងចំរាស់ធ្ងន់ធ្ងរទេ។ វាស្ទើរតែដូចគ្នា នឹងសេចក្តីថ្លែងការ ឬការកត់សំគាល់បែបការទូត ដែលធ្លាប់បានធ្វើជាញឹកញាប់ កន្លងមក - មានកំរិតប្រើពាក្យដ៏ប្រយ័ត្នប្រយែង និងឆ្លុះបញ្ចាំងពីគំនិតទស្សនៈដែលអាចទទួលយកបាន។

រាជរដ្ឋាភិបាលកម្ពុជា ទៅជាមានការរំជួលចិត្តយ៉ាងងាយៗ។ រាជរដ្ឋាភិបាលមានអារម្មណ៍ថា ទទួលការគំរាមមំហែង ពីការណ៍ដែរអ្នកការទូតបរទេសអំពាវនាវអោយមាន "ការចាប់ខ្លួន និងដាក់ទណ្ឌកម្ម" អ្នកប្រព្រឹត្តបទល្មើស និងអំពាវនាវអោយមាន "តម្លាភាព" និង "ការចូលរួម" ព្រមទាំង បានអំពាវនាវអោយមាននិតិរដ្ឋ។ ប្រតិកម្មរបស់រដ្ឋាភិបាល គឺជាការគួរអោយកត់សំគាល់ជាខ្លាំង។

វាជាការច្បាស់ណាស់ ដែលអ្នកការទូតបរទេស ជាធម្មតាមានព្រំដែនកំណត់ ក្នុងការរិះគន់ជាសាធារណៈចំពោះកិច្ចការក្នុងប្រទេស នៃប្រទេសជាម្ចាស់ដែលទទួលខ្លួនជាភ្ញៀវ។ ប៉ុន្តែស្ថានភាពនៅក្នុង

---

[៩០] សារព័ត៌មាន Agence-France Presse "ប្រទេសកម្ពុជា គំរាមបណ្តេញប្រេសិតអង្គការសហប្រជាជាតិ" ថ្ងៃទី២២ ខែមីនា ឆ្នាំ២០១០។ រ៉ូបឺត កាមីខឺល "ប្រទេសកម្ពុជាអនុម័តច្បាប់ប្រឆាំងអំពើពុករលួយយ៉ាងប្រញាប់ប្រញាល់ដោយរដ្ឋសភា" វិទ្យុសំលេងអូស្ត្រាលី ថ្ងៃទី ១២ ខែមីនា ឆ្នាំ២០១០

[៩១] សូមអានអត្ថបទដដែល

[៩២] សារព័ត៌មាន Agence-France Presse "ប្រទេសកម្ពុជា ប្រាប់អ្នកកាទូតថា ខ្លួនមិនមែនជា 'បាណាណារិផាប្លិក [banana republic]'" ថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១០។ អែនឌ្រូ ប៊ីមុន "រដ្ឋាភិបាលព្រមានអ្នកកាទូត អោយជៀសវាងការជ្រៀតជ្រែក ម្តងទៀត" សារព័ត៌មាន ឌឺឃែម បូឌាដេលី ថ្ងៃទី២៨ ខែមេសា ឆ្នាំ២០១០

ប្រទេសកម្ពុជា មានភាពខុសគ្នាបន្តិចៈ អ្នកការទូតមកពីប្រទេសដែលផ្តល់ជំនួយ យ៉ាងច្រើនសន្ធឹកសន្ធាប់ ដូច្នេះមានហេតុផលត្រឹមត្រូវ ដើម្បីតាមមើលស្ថានការណ៍ដោយយកចិត្តទុកដាក់។ សហាគមន៍អន្តរជាតិ បានប្រគល់ថវិកានូវចំនួនច្រើនលើសលប់សំរាប់ ការស្តាបនាប្រទេសឡើងវិញ ការអភិវឌ្ឍ និងការធ្វើអោយមានការអនុវត្តន៍លទ្ធិប្រជាធិបតេយ្យនៃប្រទេសកម្ពុជា។ មានការប៉ាន់ស្មានថា អ្នកផ្តល់ជំនួយបរទេសបានផ្តល់ថវិកាច្រើនជាង ៥,៥កោដិដុល្លាសហរដ្ឋអាមេរិក ជាជំនួយអភិវឌ្ឍ ដល់ប្រទេសកម្ពុជា រវាងឆ្នាំ១៩៩៨ និងឆ្នាំ ២០០៨[៩៣]។ គ្រាន់តែក្នុងឆ្នាំ២០១០ ប្រទេសផ្តល់ជំនួយបានសន្យាផ្តល់ថវិការចំនួន ១,១កោដិដុល្លាសារដ្ឋអាមេរិក[៩៤]។

ប្រទេសជាច្រើនដែលផ្តល់ជំនួយដល់កម្ពុជា បានវិនិយោគប្រាក់ពន្ធអាកររបស់ប្រជាពលរដ្ឋខ្លួន លើកម្មវិធីនានា ដើម្បីជួយដល់ដំណើរការប្រជាធិបតេយ្យ ការអភិវឌ្ឍន៍ និតិរដ្ឋ និងសិទ្ធិមនុស្សនៅកម្ពុជា។ ពួកគេមានការយកចិត្តទុកដាក់ - តាមពិតទៅជាកាតព្វកិច្ច - ដើម្បីធានាថា លទ្ធផល ដែលអាចទទួលបានពីកម្មវិធីទាំងអស់នេះ មានភាពល្អប្រសើរបំផុត។

តួនាទីរបស់អង្គការសហប្រជាជាតិ នាខណៈពេលនេះ នឹងកាន់តែមានភាពច្បាស់លាស់ឡើងៈ អាណត្តិរបស់ស្ថាប័នអង្គការសហប្រជាជាតិ ដែលកំពុងប្រតិបត្តិការងារក្នុងប្រទេសកម្ពុជា ត្រូវតែអំពាវនាវច្រើនថែមទៀត អោយមានការចូលពាក់ព័ន្ធដោយផ្ទាល់ទៅក្នុងកិច្ចការប្រទេសកម្ពុជា។ ការណ៍នេះរួមមានត្រួតពិនិត្យមើល និងធ្វើរបាយការណ៍ពីការវិវត្តន៍រីកចំរើនរបស់ប្រទេស លើផ្នែកនានាដូចជា លើការប្រកាន់ខ្ជាប់ស្តង់ដាសិទ្ធិមនុស្សអន្តរជាតិ។ វាជាការលំបាកដើម្បីវែកញែកថា អត្ថាធិប្បាយដ៏មិនគួរភ្ញាក់ផ្អើលទាល់តែសោះរបស់លោក ប្រូឌីរីក ស្ថិតនៅក្រៅរង្វង់អាណត្តិនេះ។

ជាការគួរសោកស្តាយ ប្រតិកម្មរបស់រដ្ឋាភិបាលចំពោះអត្ថាធិប្បាយរបស់លោកស្រី រុដ លីយ៍ និងលោក ប្រូឌីរីក មិនមែនជាឧប្បត្តិហេតុដាច់ដោយឡែកនោះទេ។ យើងបានសរសេរចងក្រងនូវករណីផ្សេងទៀតមួយចំនួន ក្នុងរយៈពេល៦ខែ នៃការងារតាមដាននេះ។ យើងមានការព្រួយបារម្ភ ការបង្ក្រាបនាពេលថ្មីៗនេះ លើសេរីភាពខាងការបញ្ចេញមតិ គឺបានពង្រីកទៅដល់សហាគមន៍អន្តរជាតិ និងធ្វើអោយប៉ះពាល់ដល់លទ្ធភាពនៃប្រទេសផ្តល់ជំនួយ ដើម្បីផ្តល់ការរិះគន់ បែបស្ថាបនាចំពោះគោលនយោបាយនានារបស់រាជរដ្ឋាភិបាលកម្ពុជា។

ភាពជោគជ័យនៃការគំរាមកំហែងដល់ អ្នកពាក់ព័ន្ធអន្តរជាតិ នឹងទៅជាគ្រោះមហន្តរាយមួយសំរាប់សង្គមស៊ីវិលក្នុងស្រុក ដែលធ្វើការងារក្នុងប្រទេសកម្ពុជា។ ការគាបសង្កត់ជាអន្តរជាតិលើរាជរដ្ឋាភិបាលគឺជារឿងសំខាន់ នៅពេលកើតមានវិបត្តិ ហើយដូចដែលមានក្នុងអតីតកាល វាបាននាំអោយមានការប្រែត្រលប់វិញនូវសេចក្តីសំរេចទាំងឡាយ ដែលគេមិននិយមប្រើដោយមិនត្រឹមត្រូវ និងមិនស្របតាមច្បាប់។ វាជាការសំខាន់ណាស់ដែលសហាគមន៍អន្តរជាតិ ងើបឈរឡើងប្រឈម នឹងការគំរាមកំហែងរបស់រដ្ឋាភិបាល។

---

[៩៣] វិទ្យាស្ថាន ប្រុកគីង (Brookings Institution) "ប្រសិទ្ធភាពនៃជំនួយនៅប្រទេសកម្ពុជា" សេចក្តីសង្ខេប, ខែធ្នូ ឆ្នាំ២០០៨ (មាននៅគេហទំព័រ: http://www.brookings.edu/papers/2008/12_cambodia_aid_chanboreth.aspx)។

[៩៤] រ៉ូបឺត កាមីខឺល "ប្រទេសផ្តល់ជំនួយសន្យានូវប្រាក់ចំនួនច្រើន ដែលមិនធ្លាប់មានសំរាប់ប្រទេសកម្ពុជា" វិទ្យុសំលេងអូស្ត្រាលី ថ្ងៃទី៤ ខែ មិថុនា ឆ្នាំ២០១០

ជាងនេះទៅទៀត ការភ័យខ្លាចដើម្បីប្រឈមនឹងរឿងនេះ នឹងមិនបាននាំទៅដល់គោលដៅប្រកបដោយន័យស្ថាបនាទេ។

នៅពេលដែល អង្គការសហប្រជាជាតិ មិនអាចអំពាវនាវអោយមាន "តម្លាភាព" ដោយគ្មានរងការគំរាមកំហែង នោះប្រហែលជាដល់ពេលវេលាហើយដែលត្រូវតែប្រកាសពី រឿងថ្លិនភ្នែក របស់ រដ្ឋាភិបាល។

ពេលវេលានោះ គួរតែមកដល់ក្នុងពេលឆាប់ៗនេះ ជាជាងបង្អែបង្អង់យូរ។ កាលពីថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១០ - នៅពេលដែលកំពុងតែបញ្ចប់របាយការណ៍នេះ - អគ្គលេខាអង្គការសហប្រជាជាតិ លោក បាន គីមូន បានមកធ្វើទស្សនកិច្ចនៅរាជធានីភ្នំពេញ។ លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានស្វាគមន៍គាត់ជាមួយនឹងការដាក់លក្ខខ័ណ្ឌដាច់ណាត់មួយៈ ដកលោក ក្រេីស្ដូហ្វ ប៉េស៊្វ ចេញពីមុខតំណែងរបស់គាត់ ជាប្រធានការិយាល័យនៃឧត្តមស្នងការសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ (OHCHR) បើមិនដូច្នេះទេនឹងបិទការិយាល័យប្រចាំនៅកម្ពុជា[៩៥]។

លោក ភីល រ៉ូបឺតសុន អនុប្រធានប្រចាំតំបន់អាស៊ី របស់អង្គការឃ្លាំមើលសិទ្ធិមនុស្ស បាននិយាយ ថា ដំណើរការទៅរកការបំបាត់ចោល OHCHR គឺជាផ្នែកមួយនៃផែនការរបស់ លោក ហ៊ុន សែន ដើម្បីធានានូវ "និទណ្ឌភាពដ៏ពេញបរិបូរណ៍សំរាប់ខ្លួនគាត់ និងការពង្រឹងក្ដោបក្ដាប់អំណាចផ្ដាច់ការខ្ញុំគិតថាវាគ្រាន់តែជាកត្តានៃពេលវេលាប៉ុណ្ណោះមុនពេលដែល ហ៊ុន សែន ប្រើប្រាស់ការបំភិតបំភ័យ និងច្បាប់ និងនៅទីបំផុតបំបិទសម្លេងអង្គការមិនមែនរដ្ឋាភិបាល ដែលហ៊ាននិយាយ អ្នកការពារសិទ្ធិមនុស្ស សកម្មជនសហជីព ឯករាជ្យ ដែលកំពុងតែបន្តការការពារសិទ្ធិរបស់ពួកគេ និងទាមទារនូវយុត្តិធម៌"។[៩៦]

---

[៩៥] ហ្សមបឺ ភីតឺ និង ផន បុផា "លោកនាយករដ្ឋមន្ត្រីប្រាប់លោក បាន ថាមិនមានខ្មែរក្រហមផ្សេងទៀតសំរាប់កាត់ក្ដីទេ" សារព័ត៌មាន ឌឺឃែម បូឌាដេលី ថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១០

[៩៦] សូមអានអត្ថបទដែល

**ខាងក្រោមនេះគឺជាសេចក្តីសង្ខេបនៃករណីនានា ដែលរាជរដ្ឋាភិបាលកម្ពុជា បានប្រើប្រាស់វិធី គំរាមកំហែង ដល់រាជរដ្ឋាភិបាលបរទេស និងអង្គការផ្តល់ជំនួយទាក់ទងនឹងការរិះគន់របស់ពួកគេ លើគោលនយោបាយនានារបស់រាជរដ្ឋាភិបាលៈ**

►►►
២១ មិថុនា ២០១០
រាជធានីភ្នំពេញ

**ករណីសិក្សា ៩៧**

**នាយករដ្ឋមន្ត្រី វាយប្រហារដោយពាក្យសំដីយ៉ាងធ្ងន់ៗទៅលើអ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិចំពោះ "ការខ្វះសេចក្តីគោរព"[៩៧]**

- លោក ហ៊ុន សែន បានប្រើពាក្យសំដីវាយប្រហារទៅលើអ្នករាយការណ៍ពិសេសអង្គការសហប្រជាជាតិផ្នែកសិទ្ធិមនុស្សថា "មិនគួរអោយគោរព" បន្ទាប់ពីប្រេសិតរូបនេះបាននិយាយថា គាត់មាន"ការខកចិត្ត" ដែលកិច្ចប្រជុំរវាងពួកគាត់ត្រូវបានលុបចោលវិញ ដោយសារតែលោកនាយករដ្ឋមន្ត្រីមានជំងឺ។ លោកនាយករដ្ឋមន្ត្រីក៏បានមានប្រសាសន៍ផងដែរថា ក្នុងពេលអនាគត គាត់នឹងជួបជាមួយអ្នករាយការណ៍ពិសេស តែមួយដងគត់ក្នុងមួយឆ្នាំ ជាជាងការជួបបីដងក្នុងមួយឆ្នាំដូចពេលកន្លងមក។
- លោក សឺរិយ៉ា ស៊ូប៊ីឌី អ្នករាយការណ៍ពិសេស អង្គការសហប្រជាជាតិផ្នែកសិទ្ធិមនុស្សនៅកម្ពុជា បានធ្វើទស្សនកិច្ចមកកាន់ប្រទេសកម្ពុជាពីថ្ងៃទី៨ ដល់ ១៨ ខែមិថុនា ឆ្នាំ២០១០។ ទស្សនកិច្ចរបស់គាត់ផ្តោតលើប្រព័ន្ធយុត្តិធម៌របស់ប្រទេសកម្ពុជា។ មានការកំនត់កាលបរិច្ឆេទសំរាប់គាត់ជួបជាមួយលោកហ៊ុន សែន នៅទីចុងបញ្ចប់នៃទស្សនកិច្ច ប៉ុន្តែកិច្ចប្រជុំត្រូវបានលុបចោលវិញ ដោយសារតែបញ្ហាជំងឺរបស់លោកនាយករដ្ឋមន្ត្រី។ អ្នកសារព័ត៌មាន បានសួរគាត់ថា តើលោក ស៊ូប៊ីឌី "មានការខកចិត្ត" ដែរទេ ហើយគាត់បានឆ្លើយថា គាត់មានការខកចិត្ត។
- លោក ហ៊ុន សែន បានចោទលោក ស៊ូប៊ីឌី ជាជនជាតិនេប៉ាល់ ពីការចង់ធ្វើ "អាណានិគមលើ" ប្រទេសរបស់គាត់។ លោកហ៊ុន សែន បានមានប្រសាសន៍ថា "ខ្ញុំសង្ឃឹមថា គាត់នឹងស្តាប់លឺពាក្យនេះ។ ខ្ញុំមានជម្ងឺ ខ្ញុំមិនចាំបាច់រាយការណ៍អោយលោកឯងទេ។"
- លោក ហ៊ុន សែន បានមានប្រសាសន៍ថា លោក ស៊ូប៊ីឌី គួរតែបានប្រើពាក្យ "សោកស្តាយ"។

[៩៧] រ៉យទ័រ "នាយករដ្ឋមន្ត្រីកម្ពុជា សោកស្តាយចំពោះ មន្ត្រីអង្គការសហប្រជាជាតិដែល 'ខ្វះការគោរព'" ថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១០។ សេបាស្ទានស្ត្រាងហ្គីយ៉ូ និងឈាង សុខា "ហ៊ុន សែន និយាយថា ប្រេសិតអង្គការសហប្រជាជាតិ 'ខ្វះការគោរព'" សារព័ត៌មាន ភ្នំពេញប៉ុស្តិ៍ ថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១០

►►►
៦ កក្កដា ២០១០
រាជធានីភ្នំពេញ

**ករណីសិក្សា ៤៨**

**រដ្ឋាភិបាល ព្រមានតំណាងអង្គការសហប្រជាជាតិ ចំពោះការរិះគន់**[៩៨]

- ក្រសួងការបរទេស បានចោទប្រកាន់ការិយាល័យឧត្តមស្នងការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ (OHCHR) ពីការធ្វើហួសដែនសមត្ថកិច្ចការងាររបស់ខ្លួន ដោយបានរិះគន់ពីការបញ្ជូនចេញពីប្រទេសនៅថ្ងៃទី៥ ខែកក្កដា ឆ្នាំ ២០១០ នូវសកម្មជន "អាវក្រហម" ជនជាតិថៃពីរនាក់។
- ក្រសួងបានព្រមាន តំណាងប្រចាំប្រទេសរបស់ OHCHR លោក ហ្រ្គីស្តូហ្វ ប៉េស៊្វ ថាគាត់គ្មានសិទ្ធិដើម្បីរិៈគន់ចំពោះការបញ្ជូនចេញនេះទេ ហើយថាការរិះគន់ជា បន្តណាមួយនឹងនាំទៅដល់ការវាយតម្លៃឡើងវិញ នូវវត្តមានរបស់ទីភ្នាក់ងារនេះ ក្នុងប្រទេសកម្ពុជា។ លោក គុយ គួង អ្នកនាំពាក្យរបស់ក្រសួងការបរទេស បញ្ជាក់ថា លិខិតបានបញ្ជូនទៅលោក ប៉េស៊្វ ដើម្បីរំលឹកដល់គាត់អោយប្រកាន់ខ្ជាប់តាមលក្ខខ័ណ្ឌ ដែលមានចែង ក្នុងអនុសារណៈនៃការយោគយល់រវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋា ភិបាលកម្ពុជា។
- លោក ប៉េស៊្វ រងការវាយប្រហារម្តងទៀតក្នុងខែតុលា នៅពេលដែលលោក ហ៊ុន សែន បញ្ជាអោយអង្គការសហប្រជាជាតិ ដកគាត់ចេញពីដំណែង ឬក៏បិទការិយាល័យ OHCHR នេះ [សូមអានផ្នែកខាងលើ]។

►►►
១៥ កក្កដា ២០១០
រាជធានីភ្នំពេញ

**ករណីសិក្សា ៤៩**

**រដ្ឋាភិបាល ព្រមានអង្គការសហប្រជាជាតិ អោយនៅឆ្ងាយពីករណីរបស់លោកស្រី មូរ សុខហួរ**[៩៩]

- មន្ត្រីរាជរដ្ឋាភិបាលកម្ពុជា បានវាយប្រហារដោយពាក្យសំដីយ៉ាងធ្ងន់ៗ ទៅលើលោកស្រី ណាវី ភីលេយ៍ ឧត្តមស្នងការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ ដែលបានរិះគន់ដល់ ចំណាត់ការខាងនិតិវិធីច្បាប់ប្រឆាំងចំពោះលោកស្រី មូរ សុខហួរ តំណាងរាស្ត្រគណបក្ស សម រង្ស៊ី ពីសំណាក់ប្រព័ន្ធតុលាការកម្ពុជា។ លោកស្រី មូរ សុខហួរ ត្រូវបានតុលាការកាត់ទោសក្នុងខែសីហា ឆ្នាំ ២០០៩ ចំពោះការបរិហារ កេរ្តិ៍លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន និងបង្គាប់អោយបង់ប្រាក់ពិន័យ និងសំណងជំងឺចិត្តសរុបចំនួន ១៦,៥លាន រៀល (ប្រហែលជា ៣,៩២៨ដុល្លាសហរដ្ឋអាមេរិក)។
- សេចក្តីអត្ថាធិប្បាយជាក់ស្តែងគឺធ្វើឡើងដោយអ្នកនាំពាក្យនៃឧត្តមស្នងការ។ អ្នកនាំពាក្យបានថ្លែងថា លោកស្រី ភីលេយ៍ មានកង្វល់ថា តុលាការត្រូវបានគេប្រើ ប្រាស់ "ដូចជាញញួរ" សំរាប់ដំកំទេចសេរីភាពខាងការបញ្ចេញមតិ។ គាត់បាននិយាយបន្តថា "ករណីលោកស្រី មូរ សុខហួរ ដែលប្រកបដោយចរិក

---

[៩៨] សម រិទ្ធ និង សេបាស្ទាន ស្ត្រាងហ្គីយ៉ូ "រដ្ឋាភិបាលព្រមានមេសិទ្ធិមនុស្សអង្គការសហប្រជាជាតិ ចំពោះការរិះគន់" កាសែតភ្នំពេញប៉ុស្ត៍ ថ្ងៃទី៩ ខែកក្កដា ឆ្នាំ២០១០។ ព័ត៌មានវិទ្យុសំលេងសហរដ្ឋអាមេរិក ថ្ងៃទី៩ ខែកក្កដា ឆ្នាំ២០១០

[៩៩] ព័ត៌មានវិទ្យុអាស៊ីសេរី ថ្ងៃទី១៣ និង ១៤ ខែកក្កដា ឆ្នាំ២០១០។ កាសែតភ្នំពេញប៉ុស្ត៍ ថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១០

នយោបាយជាខ្លាំង បានបង្ហាញរូបរាងយ៉ាងច្បាស់នៃការសឹករិករីលដ៏គួរតក់ស្លុតទាំងលើសេរីភាពខាងការបញ្ចេញមតិ និងលើឯករាជ្យភាពនៃប្រព័ន្ធតុលាការកម្ពុជា។”

- លោក ផៃ ស៊ីផាន អ្នកនាំពាក្យរបស់ទីស្តីការគណៈរដ្ឋមន្ត្រីកម្ពុជា បានច្រានចោលការរិះគន់នេះ ដោយបានថ្លែងថា វាមានភាពខុសគ្នារវាងការសំដែងមតិ និងការបរិហារកេរ្តិ៍។ គាត់និយាយថា ករណីលោកស្រី សុខហួរ “អាចកើតមាននៅគ្រប់ទី កន្លែងក្នុងពិភពលោក”។
- អ្នកនាំពាក្យក្រសួងការបរទេសបាននិយាយថា បញ្ហានេះគឺជា “កិច្ចការផ្ទៃក្នុង” និងថា អង្គការសហប្រជាជាតិ គួរតែជៀសវាងពីការចូលជ្រៀតជ្រែក។

# ៧. ករណីអ្នកសារព័ត៌មានជម្រិតទារប្រាក់

*ការបង្ក្រាបសកម្មភាពកាប់ឈើខុសច្បាប់*

សេចក្ដីលំអិតពីរឿងបង្ក្រាបមានសរសេរក្នុងរបាយការណ៍នេះ មើលទៅដូចជាស្ថានភាពមានលក្ខណៈប្រសើរបានមួយចំនែកដែរ សំរាប់រយៈពេលមួយនៃឆ្នាំ ប៉ុន្តែរឿងរ៉ាវទាំងនេះវាស្ថិត នៅឆ្ងាយណាស់ពីភាពច្បាស់លាស់។

ក្នុងខែមករា ឆ្នាំ២០១០ លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានបើកយុទ្ធនាការបង្ក្រាបជាសាធារណៈសកម្មភាពកាប់ឈើខុសច្បាប់ក្នុងប្រទេសកម្ពុជា[១០០]។ គាត់បានភ្ជាប់ដោយផ្ទាល់ ការជាប់ពាក់ព័ន្ធជាមួយបញ្ហានេះ របស់មេដឹកនាំយោធាជាន់ខ្ពស់ច្រើនរូប និងអ្នកមានឥទ្ធិពលដទៃទៀត។ គាត់បានហៅចំៗឈ្មោះ។ គាត់បានសន្យាថា នឹងដាក់ទណ្ឌកម្មយ៉ាងធ្ងន់ធ្ងរដល់អ្នកប្រព្រឹត្ត។ គាត់បានហៅអ្នកប្រព្រឹត្តសកម្មភាពនេះថាជា "ជនក្បត់ជាតិ"[១០១]

សកម្មភាពពីដំបូងមានភាពរហ័សរហួន៖ អាជ្ញាធរបានប្រកាសពីការឆ្មក់ចាប់ឈើ ស្ទើរតែជាប្រចាំសប្ដាហ៍។ សារព័ត៌មានបានផ្សព្វផ្សាយពីរឿងនេះ។ ក្នុងដំណាក់កាលបួនខែដំបូង នៃឆ្នាំ២០១០ អាជ្ញាធរបានធ្វើសកម្មភាពឆ្មក់ចាប់ឈើ ១០០លើក និងរឹបអូសឈើខុសច្បាប់បានច្រើនជាង ៣,០០០ ម៉ែត្រគូប - ច្រើនជាងចំនួនឈើចាប់បានសរុបក្នុងឆ្នាំ២០១០[១០២]។ ក្នុងខែមេសា លោកនាយករដ្ឋមន្ត្រី បានដើរទៅមុខមួយជំហ៊ានទៀត គឺការបណ្ដេញចេញពីមុខតំណែង លោក ទី សុគន្ធ ប្រធានរដ្ឋបាលព្រៃឈើ។[១០៣]

ប៉ុន្តែក្រៅពីសកម្មភាពមួយប្រាវ និងការវាយប្រហារព្រឹបៗលើ អ្នកសារព័ត៌មាន ប្រកបដោយការរៀបចំយ៉ាងប្រយ័ត្នប្រយែង អជ្ញាធរនៅតែមានភាពស្រពេចស្រពិលដោយគ្មានប្រែប្រួល ចំពោះប្រធានបទមួយ៖ ការចាប់ខ្លួន និងការផ្ដន្ទាទោស អ្នកពាក់ព័ន្ធសកម្មភាពកាប់ឈើ។

តាមពិត នៅពេលដែលសកម្មភាពអារឈើបានរំងាប់ និងសកម្មភាពឆ្មក់ចាប់ឈើបានបន្ថយ នោះរូបភាព ខុសប្លែកគ្នាមួយផុសចេញមក៖ រវាងខែមេសា និងខែកក្កដា សារព័ត៌មានភ្នំពេញបុស្តិ៍បានចុះផ្សាយសេចក្ដីរាយការណ៍ ពីការចាប់ខ្លួនអ្នកសារព័ត៌មាន យ៉ាងហោចណាស់ក៏ ១៦នាក់ដែរ និងមន្ត្រីនៅមូលដ្ឋានមួយចំនួន ដែលបានស៊ើបអង្កេតយ៉ាងចេញមុខលើ សកម្មភាពកាប់ឈើខុសច្បាប់។ បុគ្គលទាំងអស់នេះ ត្រូវបានជាប់ចោទពីបទល្មើស ដែលក្នុងនោះមានតាំងពី ជំរិតទារប្រាក់ ក្លែងបន្លំ និងបរិហារកេរ្តិ៍។

---

[១០០] វង់ សុខេង និងសម រិទ្ធ "នាយករដ្ឋមន្ត្រីចង្អុលដាក់មេយោធាពុករលួយ" សារព័ត៌មានភ្នំពេញប៉ុស្តិ៍ ថ្ងៃទី២៩ ខែមករា ឆ្នាំ២០១០

[១០១] ឈាង សុខា និងសេបាស្ទាន ស្ត្រាងហ្គីយ៉ូ "មន្ត្រីថា: ការឆ្មក់ចាប់ឈើ ជារឿងជោគជ័យ" សារព័ត៌មានភ្នំពេញប៉ុស្តិ៍ ថ្ងៃទី៣០ ខែមីនា ឆ្នាំ ២០១០

[១០២] "មន្ត្រីសាទរចំពោះភាពជោគជ័យនៃការបង្ក្រាបការកាប់ឈើ" សារព័ត៌មានភ្នំពេញប៉ុស្តិ៍ ថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០១០។ "មន្ត្រីថា: ការឆ្មក់ ចាប់ឈើជារឿងជោគជ័យ" សារព័ត៌មានភ្នំពេញប៉ុស្តិ៍ ថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១០

[១០៣] ឈាង សុខា និងឆាយ ចាន់ឌីណា "លោក ហ៊ុន សែន ដកប្រធានរដ្ឋបាលព្រៃឈើ" សារព័ត៌មានភ្នំពេញប៉ុស្តិ៍ ថ្ងៃទី៧ ខែមេសា ឆ្នាំ២០១០

ក្នុងខណៈពេលនេះដែរ អជ្ញាធរទាំងអស់សុទ្ធតែមានភាពស្រពេចស្រពិលដូចគ្នា អំពីការចាប់ខ្លួនឈ្មួញឈើ។ ក្រៅពីការបង្ក្រាប - ដែលបង្ហាញពីឱកាសដ៏ល្អប្រសើរ ដើម្បីផ្សព្វផ្សាយពីភាពជោគជ័យនៃការអនុវត្តន៍ច្បាប់ - ព័ត៌មាន គឺមានភាពខ្វះខាត។

ជាឧទាហរណ៍ ក្នុងខែមីនា ឆ្នាំ២០១០ អគ្គមេបញ្ជាការរងនៃខ.ភ.ម លោក ជា តារា បានរាយការណ៍ពីការចាប់ប្រមូលបានឈើខុសច្បាប់ចំនួន ៨០០ម៉ែត្រគូប និងរថយន្តទំនើបៗ នៅក្នុងខេត្តមួយចំនួន[១០៤]។ ប៉ុន្តែ ទាក់ទងនឹងការចាប់ខ្លួននេះ គាត់គ្រាន់តែបានអធិប្បាយខ្លីថា ពួកគេបានចាប់ខ្លួន "ជនល្មើសមួយចំនួន"។ គាត់មិនបានរៀបរាប់ឈ្មោះជនល្មើសទាំងនោះទេ ប៉ុន្តែបានបញ្ជាក់ថា អាជ្ញាធរនៅកំពុងតែតាមប្រមាញ់មន្ត្រីមានបុណ្យសក្តិខ្ពស់ដែលរឹងរូស ដែលបានពាក់ព័ន្ធក្នុងសកម្មភាពកាប់ឈើខុសច្បាប់"។ បុគ្គលទាំងនេះ គឺមិនស្ថិតក្នុងចំនោម "ជនល្មើសខ្លះ" ដែលបានចាប់ខ្លួនរួចហើយទេ។

សកម្មភាពគួរកត់សំគាល់បំផុត ប្រហែលជា នៅក្នុងចុងខែមីនា ដែលមានការចាប់ខ្លួនឈ្មោះ ជា សុផល - កូនប្រុសរបស់លោក ជា ម៉ន មេបញ្ជាការយោធាភូមិភាគបួន - និងមនុស្សសំខាន់ និងជោគជ័យខាងជំនួញឈើ ហៅ យាយម៉ាប់ - គេស្គាល់គាត់ផងដែរថាឈ្មោះ ឌុច សារឿន - នៅខេត្តសៀមរាប[១០៥]។

ប៉ុន្តែករណីរបស់ពួកគេ មានលទ្ធផលចំរុះ៖ ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន ពីដំបូងបានរាយការណ៍ថា ជា សុផល ត្រូវបានចាប់ខ្លួនចំពោះការកាប់ឈើខុសច្បាប់។ បន្ទាប់មករឿងនេះមានការផ្លាស់ប្តូរភ្លាមៗ៖ របាយការណ៍ ក្រោយមកនិយាយថា គាត់តាមពិតទៅត្រូវបានចាប់ខ្លួន ទាក់ទងនឹងការផ្តន្ទាទោសពីករណីប្លន់ មួយដែលមានអាយុ ៥ឆ្នាំ។ ទោសជាប់ពន្ធនាគាររបស់គាត់គឺរយៈពេល ៦ឆ្នាំកន្លះ ប៉ុន្តែគាត់បានប្តឹងឧទ្ធរណ៍ ហើយត្រូវបានដោះលែងប្រហែលជា៦ខែក្រោយមក។ យើងមិនអាចរកបានអត្ថបទសារព័ត៌មានដែលនិយាយអំពី បច្ចុប្បន្នភាពនៃករណីរបស់ យាយ ម៉ាប់ ទេដោយទោះបីជាព្រះរាជអាជ្ញាខេត្តសៀមរាប បានប្រាប់សារព័ត៌មានភ្នំពេញបុស្តិ៍ក្នុងខែសីហាថា ការិយាល័យរបស់គាត់មិនមាននៅសល់ករណីកាប់ឈើខុសច្បាប់ដែលមិនទាន់ដោះស្រាយនោះក៏ដោយ[១០៦]។

ច្រើនថ្ងៃបន្ទាប់មក លោក ទី សុគន្ធ ដែលនៅពេលនោះជាប្រធានរដ្ឋបាលព្រៃឈើ បានថ្លែងថាមានករណី ជាច្រើននឹងត្រូវដាក់ទៅតុលាការនៅទីបំផុត ប៉ុន្តែថាមន្ត្រីកំពុងតែស៊ើបអង្កេតលើម្ចាស់នៃឈើដែលរឹបអូសបាន[១០៧]។ សកម្មភាពបង្ក្រាប បាននាំអោយមានការបង្ហាញពីការជាប់ពាក់ព័ន្ធរបស់អ្នកជំនួញសំខាន់ៗ

---

[១០៤] ទេព និមល "ខ.ភ.ម បង្ក្រាបសកម្មភាពកាប់ឈើ" សារព័ត៌មានភ្នំពេញប៉ុស្តិ៍ ថ្ងៃទី២២ ខែមីនា ឆ្នាំ២០១០

[១០៥] "កូនប្រុស លោកជា ម៉ន ឧត្តមសេនីយផ្កាយ២ ត្រូវបានចាប់ខ្លួនចំពោះបទប្លន់" Everyday.com.kh តាមរយៈ KI-Media ថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១០ (មាននៅគេហទំព័រ http://ki-media.blogspot.com/2010/03/son-of-2-star-general-chea-morn.html)។ "កូនប្រុសមេបញ្ជាការកងទ័ព ត្រូវបានចាប់ខ្លួនចំពោះការកាប់ឈើ" ព័ត៌មាន DAP News ថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១០។ "មនុស្សសំខាន់ និងជោគជ័យខាងជំនួញឈើ ត្រូវបានចាប់ខ្លួន" ព័ត៌មាន DAP News ថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១០។ អត្ថបទព័ត៌មាន DAP News បានរាយការណ៍ថា មានមនុស្ស ១២នាក់ត្រូវបានចាប់ខ្លួន និង៦នាក់កំពុងស្ថិតក្នុងការឃុំឃាំងជាបណ្តោះអាសន្ន ប៉ុន្តែរៀបរាប់តែឈ្មោះ ជា សុផល និង យាយម៉ាប់ ប៉ុណ្ណោះ

[១០៦] សូមអានអត្ថបទដដែល

[១០៧] ឈាង សុខា និង សេបាស្ទាន ស្ត្រាងហ្គីយ៉ូ "មន្ត្រីថា: ការឆ្មក់ចូលចាប់ឈើ ជារឿងជោគជ័យ" សារព័ត៌មានភ្នំពេញប៉ុស្តិ៍ ថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១០

ច្រើននាក់ ដែលក្នុងចំនោមនោះមាន ឧកញ៉ា សុក គង់ លោកឡៅ ម៉េងឃិន សមាជិកព្រឹទ្ធសភា និងជាអ្នកជំនួញ និងលោក អាំង ទ្រី ជាម្ចាស់ស្រាបៀថៃហ្គឺដែលទទួលសិទ្ធិផ្តាច់មុខសំរាប់ប្រទេសកម្ពុជា[១០៨]។ ប៉ុន្តែលោក ទី សុគន្ធ បានចេញមកបញ្ជាក់យ៉ាងច្បាស់ភ្លាមៗថា បុគ្គលទាំងអស់នេះ នឹងមិនប្រឈមមុខនឹងការកាត់ទោសទេ។ លោក សុក គង់ មានអាជ្ញាប័ណ្ណឈើត្រឹមត្រូវ ហើយមន្ត្រីប្រតិបត្តិច្បាប់បានពិនិត្យ រួចរាល់ហើយថា មិនមានភស្តុតាងគ្រប់គ្រាន់ប្រឆាំងនឹងបុគ្គលផ្សេងទៀតទេ[១០៩]។

ក្នុងខែមេសា ឆ្នាំ២០១០ ការឆ្មក់ចូលទៅក្នុងឃ្លាំងឈើមួយក្នុងខេត្តសៀមរាប បានរកឃើញឈើរាប់រយម៉ែត្រគូប ដែលសង្ស័យថាជាឈើខុសច្បាប់[១១០]។ ឃ្លាំងនោះ មានទីតាំងស្ថិតនៅលើដីនៃភូមិរប្បធមិកម្ពុជា ដែលគ្រប់គ្រងដោយធនាគារកាណាឌីយ៉ា[១១១]។ មិនមានការចាប់ខ្លួនណាមួយត្រូវបានគេរាយការណ៍ទេ។

*មានការឆ្មក់ ចាប់ប្រមូលឈើច្រើនជាង ២០ករណី នៅក្នុងខេត្តព្រះវិហារ ប៉ុន្តែគ្មានការផ្តន្ទាទោស និងការចាប់ខ្លួនសោះ។*

*នៅក្នុងខេត្តរតនគីរី ការឆ្មក់ចាប់ប្រមូលឈើចំនួន ៩៥ករណី ក៏មិនមាននរណាម្នាក់ ត្រូវបានចាប់ខ្លួនយកមកទទួលខុសត្រូវដែរ*

លោក ទី សុគន្ធ បានអះអាងក្នុងខែមេសា ថា ការផ្តន្ទាទោសចំពោះ "មន្ត្រីរដ្ឋាភិបាល និងអ្នកជំនួញ ច្រើនជាង១០០នាក់" កំពុងតែស្ថិតនៅក្នុងការរង់ចាំ ប៉ុន្តែថាមានតែមនុស្ស១៤នាក់ទេ ដែលបានចាប់ខ្លួន[១១២]។ ទោះបីជាយ៉ាងណាក៏ដោយ ព័ត៌មានពីអត្តសញ្ញាណនៃជនទាំងនោះមានតិចតួចណាស់។ ក្នុងចំណោមពួកគេមាន "មន្ត្រីកងរាជអាវុធហត្ថមានឋានៈទាប"[១១៣] ដែលគេមិនស្គាល់ឈ្មោះពីរនាក់ មន្ត្រីរដ្ឋបាលព្រៃឈើខេត្តពោធិ៍សាត់មិនដឹងអត្តសញ្ញាណបីនាក់[១១៤] និងកម្មករស៊ីឈ្នួលដែលគេចាប់បានកំពុងកាប់ឈើបីនាក់ ដែលពួកគេបានអះអាងថា មេរបស់ពួកគេបានសន្យាថា ពួកគេនឹង "គ្មានទោសពៃរ៍"[១១៥]។ មន្ត្រីរដ្ឋបាលព្រៃឈើពីរនាក់ផ្សេងទៀត - និងបុគ្គលិកពីរនាក់មកពី អង្គការមិនមែនរដ្ឋាភិបាលខាងអភិរក្ស - ត្រូវបានកោះហៅមកសាកសួរ ដោយតុលាការខេត្តកោះកុងក្នុងខែមិថុនា ប៉ុន្តែមិនត្រូវបានគេចាប់ខ្លួនពេលនោះទេ[១១៦]។ មន្ត្រីតុលាការក្នុងខេត្តរតនគីរីក៏បានអះអាងផងដែរថា បានកោះហៅ "មន្ត្រីរដ្ឋបាលព្រៃឈើផ្សេងៗគ្នា" មកសាកសួរក្នុងខែមិថុនា ប៉ុន្តែបដិសេធមិនបង្ហាញ

---

[១០៨] សូមអានអត្ថបទដដែល

[១០៩] សូមអានអត្ថបទដដែល

[១១០] វ៉ាន់ វើយ "ឈើច្រើនថែមទៀតត្រូវចាប់ប្រមូលបាន នៅក្នុងខេត្តសៀមរាប" សារព័ត៌មានភ្នំពេញប៉ុស្ត៍ ថ្ងៃទី៦ ខែមេសា ឆ្នាំ២០១០

[១១១] សូមអានអត្ថបទដដែល

[១១២] ឈាង សុខា និងឆាយ ចាន់ឌីណា "លោក ហ៊ុន សែន ដកប្រធានរដ្ឋបាលព្រៃឈើ" សារព័ត៌មានភ្នំពេញប៉ុស្ត៍ ថ្ងៃទី៧ ខែមេសា ឆ្នាំ២០១០

[១១៣] ឈាង សុខា និង សេបាស្ទាន ស្ត្រាងហ្គីយ៉ូ "មន្ត្រីថា: ការឆ្មក់ចាប់ឈើ ជារឿងជោគជ័យ" សារព័ត៌មានភ្នំពេញប៉ុស្ត៍ ថ្ងៃទី៣០ ខែមិនា ឆ្នាំ២០១០

[១១៤] ឈាង សុខា និង ទេព និមល "មន្ត្រីរដ្ឋាភិបាល ត្រូវចាប់ខ្លួនក្នុងយុទ្ធនាការបង្ក្រាបការកាប់ឈើ" សារព័ត៌មានភ្នំពេញប៉ុស្ត៍ ថ្ងៃទី៥ ខែមេសា ឆ្នាំ២០១០

[១១៥] មុំ គន្ធា "កម្មករស៊ីឈ្នួលកាប់ឈើនិយាយថា ពួកគេត្រូវបានសន្យាថានឹងមិនមានទោស" សារព័ត៌មានភ្នំពេញប៉ុស្ត៍ ថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០១០

[១១៦] ច្រាន់ ចំរើន និងកាមេរុណ វេលស៍ "មន្ត្រីរដ្ឋបាលព្រៃឈើត្រូវបានកោះហៅ" សារព័ត៌មានភ្នំពេញប៉ុស្ត៍ ថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០១០

ឈ្មោះ ពួកគេទេ[១១៧]។

នៅក្នុងខេត្តខ្លះ មន្ត្រីនានាទទួលស្គាល់ថា ពួកគេមិនមានបានចាប់ខ្លួននរណាម្នាក់ទេ។ មានការឆ្មក់ចាប់ប្រមូលឈើច្រើនជាង ២០ករណីនៅក្នុងខេត្តព្រះវិហារ ប៉ុន្តែគ្មានការផ្តន្ទាទោស និងការចាប់ខ្លួនសោះឡើយគិតមកត្រឹមខែមិថុនា ឆ្នាំ២០១០[១១៨]។ នៅក្នុងខេត្តរតនគីរី ការឆ្មក់ចាប់ប្រមូលឈើចំនួន ៩៥ករណីក៏មិនមាននរណាម្នាក់ ត្រូវបានចាប់ខ្លួនយកមកទទួលខុសត្រូវដែរ[១១៩]។ ប្រធានព្រះរាជអាជ្ញាក្នុងខេត្តមណ្ឌលគីរីបានបដិសេធមិននិយាយអំពី ថាតើមានមនុស្សប៉ុន្មាននាក់ត្រូវបានចាប់ខ្លួន[១២០]។

ក្នុងខែសីហា រដ្ឋមន្ត្រីក្រសួងកសិកម្ម លោក ចាន់ សារុន បានធ្វើសន្ទរកថាមួយ ស្តីបន្ទោសតុលាការចំពោះភាពគ្មានការផ្តន្ទាទោស។ គាត់បានអះអាងថា ៧០ភាគរយ នៃករណីទាំងអស់ មិនទាន់មានការនាំយកមកកាត់ទោសទេ[១២១]។ គាត់មិនបាននិយាយថា មានប៉ុន្មានករណីដែលកំពុងតែរង់ចាំសវនាការ។

ទោះជាដូច្នេះក្តី ក៏មន្ត្រីតុលាការ បាននិយាយផ្ទុយទៅនឹងការអះអាងរបស់លោករដ្ឋមន្ត្រី។ លោក ជីវ កេង ប្រធានតុលាការរាជធានីភ្នំពេញ បានមានប្រសាន៍ថា តុលាការរបស់គាត់ និងតុលាការផ្សេងទៀតបាន "បើកសវនាការលើស្ទើរតែគ្រប់ករណីទាំងអស់។"[១២២] ព្រះរាជអាជ្ញាតុលាការខេត្ត សៀមរាប លោក ទី សុវណ្ណថុល បានប្រាប់សារព័ត៌មានភ្នំពេញប៉ុស្ត៍ ក្នុងខែសីហា ឆ្នាំ២០១០ ថា តុលាការរបស់គាត់មិនមាននៅសល់ករណីកាប់ឈើខុសច្បាប់ដែលមិនទាន់បញ្ចប់នោះទេ[១២៣]។ គាត់ក៏មិនបានដឹងពិតប្រាកដដែរ អំពីចំនួនករណីដែលត្រូវបានសវនាការ ប៉ុន្តែគាត់បាននិយាយ ពីមុនមកថា ករណីបង្ក្រាបបានភាគច្រើនបំផុត នឹងមិននាំទៅដល់ការផ្តន្ទាទោសទេ ពីព្រោះអជ្ញាធរបានរកឃើញត្រឹមតែគំនរឈើប៉ុណ្ណោះ[១២៤]។ គំនរឈើដែលគ្មានច្បាប់អនុញ្ញាត នឹងត្រូវផ្តន្ទាទោសត្រឹមតែការពិន័យជាប្រាក់ ហើយគាត់និយាយថាការផ្តន្ទាទោសព្រហ្មទណ្ឌ វាតំរូវអោយមានភស្តុតាងថា ឈើនោះបានមកដោយខុសច្បាប់[១២៥]។ គាត់មិនបានពន្យល់អំពីឈើដែលបានមកតាម របៀបណា "ស្របច្បាប់" ឬថាតើ ឈើខុសច្បាប់ត្រូវពិចារណាស្មើនឹងភស្តុតាង នៃការបានមកដោយខុស

---

[១១៧] ថេតសម្បត្តិ និងច្រាន់ ចំរើន "រដ្ឋបាលព្រៃឈើផ្លាស់ប្តូរគំរោងសំរាប់ខេត្តសៀមរាប" ភ្នំពេញប៉ុស្ត៍ ថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១០

[១១៨] ច្រាន់ ចំរើន និងកាមេរុណ វេលស៍ "គ្មានការចោទប្រកាន់ត្រូវបានធ្វើឡើងក្នុងខេត្តព្រះវិហារ ទាក់ទងនឹងការឆ្មក់ចាប់ប្រមូលឈើ" សារព័ត៌មានភ្នំពេញប៉ុស្ត៍ ថ្ងៃទី៩ ខែមិថុនា ឆ្នាំ២០១០

[១១៩] សូមអានអត្ថបទដដែល

[១២០] សូមអានអត្ថបទដដែល

[១២១] ឃួត សុភ័ក្រចរិយា "រដ្ឋមន្ត្រីថា: បទល្មើសព្រៃឈើ និងបទល្មើសនេសាទ បាត់ដានក្នុងអំឡុងនៃប្រតិបត្តិការបង្ក្រាប" សារព័ត៌មាន ភ្នំពេញប៉ុស្ត៍ ថ្ងៃទី៣ ខែសីហា ឆ្នាំ២០១០

[១២២] សូមអានអត្ថបទដដែល

[១២៣] សូមអានអត្ថបទដដែល

[១២៤] សូមអានអត្ថបទដដែល

[១២៥] វ៉ាន់ រើយ "ឈើច្រើនថែមទៀត ត្រូវចាប់ប្រមូលបានពីតាមសណ្ឋាគារនៅក្នុងខេត្តសៀមរាប ពេលដែលការបង្ក្រាបបន្ត" សារព័ត៌មានភ្នំពេញប៉ុស្ត៍ ថ្ងៃទី ១៣ ខែមេសា ឆ្នាំ២០១០

ច្បាប់។

ក្រៅពីការបង្ក្រាប នាខណៈពេលនេះដែរ យ៉ាងហោចណាស់ក៏មានប្រជាពលរដ្ឋកម្ពុជាខ្លះ បន្តអះអាងថា សេចក្តីរាយការណ៍របស់ពួកគេ អំពីការកាប់ឈើខុសច្បាប់ត្រូវបានអាជ្ញាធរធ្វើមិនដឹងមិនលឺ[១២៦]។

*បង្ក្រាបអ្នករាយការណ៍*

វាផ្ទុយគ្នាទៅនឹងរឿងនិយាយពី ការបង្ក្រាបសកម្មភាពកាប់ឈើ រឿងដែលរៀបរាប់ពីការចាប់ខ្លួនអ្នកសារព័ត៌មាន ជាធម្មតាមានភាពក្បោះក្បាយ។ ឈ្មោះរបស់អ្នកសារព័ត៌មានទាំងអស់ និងសារព័ត៌មាន ក៏ដូចជាអត្ថាធិប្បាយផ្សេងៗពីជនរងគ្រោះដែលអះអាងពី រឿងជំរិតទារប្រាក់ ត្រូវបានគេប្រើប្រាស់។

ស្ទើរតែដូចគ្នាទាំងអស់ "អ្នកសារព័ត៌មាន" ទាំងអស់នេះ ត្រូវបានគេចោទប្រកាន់ពីការព្យាយាមជំរិតទារប្រាក់ពីឈ្មួញឈើ។ អជ្ញាធរមិនបានធ្វើសេចក្តីរាយការណ៍ពី ឋានៈផ្លូវច្បាប់នៃឈ្មួញឈើទាំងអស់នោះទេ និងក៏មិនបានចាប់ខ្លួន "ជនរងគ្រោះ" ដែលជាឈ្មួញឈើណាម្នាក់ដែរ។

នេះគឺមិនមែនចង់និយាយថា អ្នកសារព័ត៌មានទាំងអស់នេះ មិនមានកំហុសនោះទេ។ តាមពិតជារឿងផ្ទុយគ្នាទៅវិញទេ។ អង្គការ លីកាដូ បានស៊ើបអង្កេតលើករណីទាំងនេះមួយចំនួន ដែលមានករណីខ្លះពាក់ព័ន្ធនឹងអ្នកសារព័ត៌មានពិតប្រាកដ ដែលត្រូវគេចោទប្រកាន់ដោយបំពានពីរឿងជំរិតទារប្រាក់។ ប៉ុន្តែ វាច្បាស់ណាស់ថា ការជំរិតទារប្រាក់ពិតជាបានកើតឡើងយ៉ាងពិតប្រាកដ នៅក្នុងព្រៃរបស់ប្រទេសកម្ពុជា និងជារឿងសាមញ្ញបំផុតដែលវាជាប់ពាក់ព័ន្ធនឹងអ្នកកាសែតមានបណ្ណសំគាល់ខ្លួនដ៏គួរសង្ស័យ ដែលពួកគេមួយចំនួនប្រហែលជាចូលទៅក្នុងវិជ្ជាជីវៈនេះ សំរាប់គោលបំណងតែមួយគត់ គឺជំរិតទារប្រាក់។ អ្នកដែលជាគោលដៅនៃការជំរិតទារប្រាក់របស់ពួកគេ គឺមានអ្នកផ្សេងទៀត មិនមែនមានត្រឹមតែឈ្មួញ ឈើទេ[១២៧]។

ប៉ុន្តែការជំរិតទារប្រាក់ដោយអ្នកកាសែត - អ្នកសារព័ត៌មានក្លែងក្លាយ - មិនមែនជារឿងថ្មីនៅប្រទេសកម្ពុជាទេ ឬក៏ជាអ្វីដែលប្លែកសំរាប់ឈ្មួញឈើដែរ ហើយអង្គការលីកាដូ បានប្រមូលចងក្រងបាតុភូតនេះក្នុងពេលកន្លងមក[១២៨]។ អ្វីដែលជាការចាប់អារម្មណ៍អំពីការប្រញាប់ប្រញាល់ចាប់ខ្លួនអ្នកសារព័ត៌មាន គឺជាបញ្ហា

---

[១២៦] ឆាយ ចាន់ឌីណា និង ទេព និមល "អង្គការមិនមែនរដ្ឋាភិបាលអំពាវនាវអោយបង្កើនការបង្ក្រាបសកម្មភាពកាប់ឈើខុសច្បាប់" សារព័ត៌មានភ្នំពេញប៉ុស្តិ៍ ថ្ងៃទី១២ ខែមេសា ឆ្នាំ២០១០ (ដកស្រង់ពាក្យសំដីតំណាងសហគមន៍ដែលនិយាយថា "អ្នកភូមិខ្លះក្នុងចំនោមពួកយើង ត្រូវបានរងការគំរាមកំហែងនៅពេលដែលពួកយើងព្យាយាមការពារព្រៃឈើ។")

[១២៧] សូមមើល ឧទាហរណ៍ វង់ សុខេង "អ្នកគេចពន្ធអះអាងថា: អ្នកសារព័ត៌មានត្រូវបានចោទប្រកាន់ពីរឿងជំរិតទារប្រាក់" សារព័ត៌មាន ភ្នំពេញប៉ុស្តិ៍ ថ្ងៃទី៥ ខែសីហា ឆ្នាំ២០១០ (អ្នកសារព័ត៌មានបីរូបត្រូវបានចាប់ខ្លួនក្នុងខេត្តកំពង់ចាម ខណៈកំពុងតាមដានករណីនាំជ្រូក គេចពន្ធឆ្លងកាត់ព្រំដែន។ អ្នកសារព័ត៌មានត្រូវបានចោទប្រកាន់ថា បានគំរាមទារប្រាក់ពីឈ្មួញជ្រូក និងព្យាយាមយកអាវុធពីនគរបាលម្នាក់។ ក្រុមអ្នកសារព័ត៌មានចោទនគរបាលថា បានរួមគំនិតជាមួយឈ្មួញជ្រូកប្រឌិតរឿងអោយអ្នកសារព័ត៌មាន)

[១២៨] "ការស្វែងយល់ចំពោះអត្ថន័យដែលមើលមិនឃើញ: នយោបាយ ប្រាក់កាស និងការភ័យខ្លាច គ្របគ្រងលើប្រព័ន្ធផ្សាយព័ត៌មាន កម្ពុជា ដោយរបៀបណា" របាយការណ៍អង្គការ លីកាដូ ខែឧសភា ឆ្នាំ២០០៨ ទំព័រ ១២ (រៀបរាប់ពីអ្វីដែលគេហៅថា "បិទខ្ទប់ ព័ត៌មាន" ដែលប្រើការគំរាមបែបជំរិតទារប្រាក់ពីបុគ្គលដែលមានភាពលេចធ្លោ ឬអ្នកជំនួញ ដើម្បីមិនចុះផ្សាយរឿងពួកគេ ក្នុងអត្ថបទសារព័ត៌មាន ជាពិសេសនៅពេលដែលរឿងទាំងនោះ ទាក់ទងនឹងការកាប់ឈើខុសច្បាប់ ការគេចពន្ធ រឿងពុករលួយ ឬ រឿងក្បត់ចិត្ត ប្តីប្រពន្ធ។ រឿងអាស្រូវសំខាន់ៗ ការប្រាក់បង់អាចមានតម្លៃខ្ពស់ - មានច្រើនរហូតដល់

ពេលវេលា និងបញ្ហាចំនួនអ្នកសារព័ត៌មានដែលតាមដានរឿងនេះ។

អ្នកសារព័ត៌មានហាក់ដូចជាបានឃើញឱកាស ដើម្បីជញ្ជក់ផលប្រយោជន៍បានពីចំណាត់ការបង្ក្រាបការកាប់ឈើរបស់លោកនាយករដ្ឋមន្ត្រី។ មូលហេតុនៅពីក្រោយការបង្ក្រាបរបស់អាជ្ញាធរ ខណៈពេលនេះ អាចមានកត្តាផ្សេងៗជាច្រើនដូចជា:

- វាអាចមាននូវទិដ្ឋភាពនៃ**ការអនុវត្តន៍ច្បាប់យ៉ាងពិតប្រាកដ។** ការជំរិតទារប្រាក់ក្នុងចំណោមអ្នកសារ-ព័ត៌មាន មានសេចក្តីរាយការណ៍ថា ជារឿងដ៏សាមញ្ញ ហើយដែលតាមពិតទៅ វាជាបទល្មើសធ្ងន់ធ្ងរមួយ - សូម្បីតែជនរងគ្រោះក៏ពាក់ព័ន្ធក្នុងសកម្មភាពខុសច្បាប់ដែរ។ ប៉ុន្តែ សួរថា តើបញ្ហានេះសមនឹងទទួលបាននូវចំណាប់អារម្មណ៍ការអនុវត្តច្បាប់ នៅកំរិតនេះឬ ក្នុងអំឡុងពេលនៃអ្វី ដែលគេគិតថាជាការបង្ក្រាបអ្នកពាក់ព័ន្ធការកាប់ឈើខុសច្បាប់? ជាការសំខាន់ថែមទៀត ថាតើហេតុអ្វីមិនមានការផ្តន្ទាទោសឈ្មួញឈើ (និងអ្នកពាក់ព័ន្ធផ្សេងទៀត) ដែលបានវាយដំ និងគំរាមកំហែងអ្នកសារព័ត៌មានពិតប្រាកដ ដែលជាករណី បានសរសេរចងក្រងដោយសារព័ត៌មាន និងមាននៅក្នុងរបាយការណ៍នេះ[129]? និងសួរថា តើហេតុអ្វីបានជាផ្តោតការលៃលកការអនុវត្តច្បាប់ដោយកម្រ តែលើករណីជំរិតទារប្រាក់។ ហេតុអ្វីបានជាឧទាហរណ៍ មិនមានការស៊ើបអង្កេតលើអ្នកដែលជាគោលដៅ នៃការជំរិតទារប្រាក់ ឬក៏ចាប់ខ្លួនអ្នកពាក់ព័ន្ធក្នុងសកម្មភាពកាប់ឈើខុសច្បាប់?

- ប្រហែលជាមានការព្រួយបារម្ភណ៍ថា **ចំណាប់អារម្មណ៍ពីប្រព័ន្ធសារព័ត៌មានខ្លាំងពេក** នឹងនាំអោយមានការរំខានដល់យុទ្ធនាការទំនាក់ទំនងសាធារណៈ ដែលមានការរៀបចំជាមុនដោយប្រុងប្រយ័ត្នជុំវិញការបង្ក្រាបនេះ។ រាជរដ្ឋាភិបាលចង់គ្រប់គ្រងរឿងនេះទាំងស្រុង តាមគ្រប់រូបភាព និងមធ្យោបាយរបស់ខ្លួនទាំងអស់។ ហេតុផលនៅពីក្រោយយុទ្ធនាការបង្ក្រាបការកាប់ឈើ គឺច្បាស់ជាមានគោលបំណងធ្វើអោយមុខមាត់របស់កម្ពុជាបានប្រសើរឡើង ក្នុងមជ្ឈដ្ឋានអភិរក្ស ទាំងនៅក្នុងប្រទេស និងជាអន្តរជាតិ។

- និងប្រហែលជាហាក់ដូចជាមាន**គោលបំណងដើម្បីបង្ខូចកិត្យានុភាពអ្នកសារព័ត៌មាន និងបន្តនូវអ្វីៗដែលមានពីមុនមក មុនពេលមានយុទ្ធនាការបង្ក្រាបការកាប់ឈើនេះ។** អ្នកសារព័ត៌មាន មានកិត្តិស័ព្ទតិចតួចក្នុងចំនោមប្រជាពលរដ្ឋកម្ពុជាជាទូទៅ ហើយជាលទ្ធផល វាមិនមែនជា ការលំបាកដើម្បីបង្វិលមតិសាធារណៈជនប្រឆាំងនឹងពួកគេទេ។ យុទ្ធនាការ ដើម្បីបង្ខូចកិត្យានុភាព អ្នកសារព័ត៌មានដែលជាអ្នកបានធ្វើសេចក្តីរាយការណ៍ពីការកាប់ឈើខុសច្បាប់ ក៏បានផ្តល់អោយអាជ្ញាធរ នូវលទ្ធភាព

១,000ដុល្លាសាហរដ្ឋអាមេរិក ដើម្បីខ្ទប់រឿងពី ការចេញផ្សាយ នេះបើយោងតាមអ្នកនិពន្ធសារព័ត៌មានជាន់ខ្ពស់ម្នាក់។ អ្នកដែលតាំងខ្លួនឯងជាអ្នកសារព័ត៌មានខ្លះអាចឈានទៅធ្វើការបោះពុម្ពអត្ថបទពីរឿងអាស្រូវនោះ ចំនួនពីរ ឬបីច្បាប់លើទំព័រសារព័ត៌មានមុនការផ្សព្វផ្សាយ ដើម្បីបង្ហាញអោយឃើញច្បាស់ពីរឿងដ៏ខូចខាតនេះ។ អ្នកសារព័ត៌មានខ្លះទៀតយកសំណូកផ្ទាល់នៅហ្នឹងកន្លែង ហើយបិទភ្នែកចំពោះរឿងអាក្រក់ទាំងនោះ។")។ សូមមើលផងដែរ ទំព័រ ២១ ដែលពិព័ណ៌នាពីលទ្ធផលពីការសិក្សាក្នុងចំនោមអ្នកសារព័ត៌មានកម្ពុជា ដែលអ្នកសារព័ត៌មានជាច្រើនទទួលស្គាល់ថា បានចូលរួមក្នុង ឬបានដឹងពីការចូលរួមក្នុង - អំពើពុករលួយ របស់សហការីខ្លួន។

១២៩ សូមមើល ករណីសិក្សា ២៧, ២៨ និង ២៩

> គ្រប់គ្រងបាននូវសារទាំងអស់។ អាជ្ញាធរ អាចធ្វើអោយគេមើលឃើញថា ការបង្ក្រាបកំពុងតែវិវត្តទៅមុខយ៉ាងប្រសើរ នៅពេលដែលរឿងពិតជាក់ស្តែងមានភាពខុសគ្នាខ្លះ។ ឈ្មួញឈើ និងអាជ្ញាធរពិតជាបានព្យាយាមប្រើមធ្យោបាយដទៃទៀតដើម្បីគ្រប់គ្រងអ្នកសារព័ត៌មាន ដែលមានទាំងការគំរាមកំហែង និងការវាយប្រហារលើរាងកាយ[១៣០]។ ការប្រើ បទចោទប្រកាន់ព្រហ្មទណ្ឌ គឺជាមធ្យោបាយមួយទៀត។

តើអ្វីទៅជាមូលហេតុពិត នៃការបង្ក្រាបអ្នកសារព័ត៌មាន? របាយការណ៍នេះ មិនមានគោលបំណងដើម្បីឆ្លើយសំណួរនេះទេ។ យើងគ្រាន់តែជឿជាក់យ៉ាងសាមញ្ញថាការបង្ក្រាបយ៉ាងទូលំទូលាយដូច្នេះលើសកម្មភាពខាងសារព័ត៌មាន ពាក់ព័ន្ធនឹងប្រធានបទមួយ - ទោះបីជាករណីខ្លះពាក់ព័ន្ធសកម្មភាពព្រហ្មទណ្ឌ- ដែលត្រូវតែមានការចងក្រងជាឯកសារ ពិនិត្យ និងជជែកដេញដោល។

នៅទីបញ្ចប់នេះ យើងសូមផ្តល់នូវកម្រង នៃឧប្បត្តិហេតុ ដែលអ្នកសារព័ត៌មានជំរិតទារប្រាក់ ដែលមានចុះផ្សាយក្នុងប្រព័ន្ធសារព័ត៌មាន ក្នុងអំឡុងពេលពីខែមេសា ដល់ ខែកញ្ញា ឆ្នាំ២០១០។ បញ្ជីរនៃករណីនេះ មិនមែនទូលំទូលាយជាចាំបាច់នោះទេ ប៉ុន្តែវារួមមានផ្នែកជាសំខាន់ នៃករណីដែលបានចុះផ្សាយតាមសារព័ត៌មាន។ សូមកត់សំគាល់ថា បញ្ជីរនេះបញ្ចូលតែឧប្បត្តិហេតុ ដែលអ្នកសារព័ត៌មានត្រូវបានចោទប្រកាន់ពីការជំរិតទារប្រាក់ឈ្មួញឈើ។ វាមិនបានរាប់បញ្ចូលឧប្បត្តិហេតុផ្សេងទៀត ដែលកើតឡើងរវាងអ្នកសារព័ត៌មាន និងឈ្មួញឈើ ដូចជា ការវាយប្រហារ ឬការគំរាមកំហែង ចំពោះអ្នកសារព័ត៌មានទេ។ ឧប្បត្តិហេតុប្រភេទនេះ មានបញ្ចូលនៅក្នុងផ្នែកផ្សេងទៀតក្នុងរបាយការណ៍នេះ។

---

[១៣០] "អ្នកសារព័ត៌មាន ជំរុញរដ្ឋាភិបាលអោយផ្តល់ការការពារ" សារព័ត៌មានភ្នំពេញប៉ុស្តិ៍ ថ្ងៃទី៤ ខែមករា ឆ្នាំ២០១០ (ធ្វើសេចក្តីរាយការណ៍ពីករណីនៃអ្នកសារព័ត៌មានចំនួន១១នាក់ ក្នុងខេត្តឧត្តរមានជ័យ ជាអ្នកដែលបានអះអាងថា ពួកគេត្រូវបានឃុំខ្លួនក្រោមការភ្ជង់កាំភ្លើងពីទាហាននៃខ.ភ.ម ខណៈពេលដែលស៊ើបអង្កេតតាមដានករណីកាប់ឈើខុសច្បាប់។ អ្នកសារព័ត៌មាន បានថតរូបទាហានកំពុងដឹកឈើមូលពីរឡាន។ រាក់ ដូ អ្នកសារព័ត៌មានជាប់ឃុំម្នាក់ ក្នុងចំនោមពួកគេបាននិយាយថា វាមានគ្រោះថ្នាក់ណាស់ដើម្បីសរសេរអត្ថបទពីរឿងការកាប់ឈើខុសច្បាប់ "ពីព្រោះឈ្មួញឈើពិតជាមនុស្សមានអំណាចខ្លាំងណាស់។")។ សូមមើលផងដែរករណី សិក្សាលេខ២៨ និង២៩

**ខាងក្រោមនេះជាករណីសង្ខេបមួយចំនួនទាក់ទងនឹងការគំរាមកំហែងលើអ្នកសារព័ត៌មាន**

►►►
៥ មេសា ២០១០
ខេត្តកំពង់ចាម

**ករណីសិក្សា ក១**

*ចាប់ខ្លួន:*
*អ្នកសារព័ត៌មាន4នាក់*
*មន្ត្រីខេត្តម្នាក់*

**អ្នកសារព័ត៌មានត្រូវបានចាប់ខ្លួនក្នុងខេត្តកំពង់ចាម បន្ទាប់ពីអ្នកលក់ឈើអះអាងពីការជំរិតទារប្រាក់[១៣១]**

- អ្នកសារព័ត៌មានបួននាក់ ត្រូវបានចាប់ខ្លួនក្នុងស្រុក ស្ទឹងត្រង់ បន្ទាប់ពីអ្នកលក់ឈើចោទពួកគេពីការប៉ុនប៉ងជំរិតទារប្រាក់។ ជា លីហ៊ាង, តុង សុភ័ណ, ថង គីម ហួត, និង ឈី ហុក គីមស្រ៊ាន ត្រូវបានចាប់ខ្លួនជាមួយប្រធានគណកម្មការអភិវឌ្ឍន៍ជនបទ ខេត្តកំពង់ចាម។

- អ្នកលក់ឈើឈ្មោះ មេឃ គីមហួន បានអះអាងថា អ្នកសារព័ត៌មាន បានគំរាមចុះផ្សាយព័តមានចោទប្រកាន់គាត់ពីការលក់ឈើខុសច្បាប់ បើមិនចង់អោយចុះផ្សាយទេ គាត់ត្រូវបង់លុយអោយពួកគេចំនួន ៣០០ដុល្លាសហរដ្ឋអាមេរិក។ ជាយថាហេតុ អ្នកសារព័ត៌មានបានចុះផ្សាយព័ត៌មាន ពីរថ្ងៃក្រោយមកដោយ ចោទអាជីវកម្មឈើរបស់មេឃ គីមហួន ថាជាការខុសច្បាប់។

- អ្នកសារព័ត៌មានបដិសេធថា មិនបានប្រព្រឹត្តកំហុសទេ និងនិយាយថា កសិករនៅមូលដ្ឋានបានផ្តល់ព័តមានដល់ពួកគេ។ ពួកគេនិយាយថា អាជ្ញាធរមិនបានចាត់វិធានការអ្វីដើម្បីចាប់ឈើខុសច្បាប់ទេ។

- នៅថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១០ ចុងចោទទាំងប្រាំនាក់ បានដាក់ពាក្យបណ្តឹងបរិហារកេរ្តិ៍ប្រឆាំងនឹង មេឃ គីមហួន។ មេធាវីរបស់ក្រុមចុងចោទទាំងនេះ ក៏បាននិយាយផងដែរថា កូនក្តីរបស់គាត់មានបំណងចង់ដាក់ពាក្យបណ្តឹងប្រឆាំងនឹងមេឃ គីមហួន និងអ្នកលក់ឈើប្រាំមួយនាក់ផ្សេងទៀត ដែលបានចោទប្រកាន់ពួកគេពីការធ្វើជំនួញក្នុងអាជីវកម្មឈើខុសច្បាប់។

►►►
៩ មេសា ២០១០
ខេត្តសៀមរាប

**ករណីសិក្សា ក២**

*ចាប់ខ្លួន:*
*អ្នកសារព័ត៌មានម្នាក់*

**អ្នកសារព័ត៌មាន ត្រូវបានជាប់ឃុំឃាំងជាបណ្តោះអាសន្ន ពីបទចោទប្រកាន់ជំរិតទារប្រាក់ និងក្លែងបន្លំ[១៣២]**

- ស៊ឹម សំណាង អ្នកសារព័ត៌មានកាសែតកោះសន្តិភាព ត្រូវបានជាប់ឃុំឃាំងជាបណ្តោះអាសន្ន ពីបទចោទប្រកាន់ជំរិតទារប្រាក់ និងក្លែងបន្លំ។

- ព្រះរាជអាជ្ញាតុលាការខេត្ត សៀមរាប លោក ទី សុវណ្ណថល ចង្អុលបង្ហាញថា ស៊ឹម សំណាង ត្រូវបានសង្ស័យថា បានគំរាមកំហែងបង្ហាញពីសកម្មភាពខុសច្បាប់នៃឃ្លាំងស្តុកឈើមួយ និងទាមទារអោយផ្តល់ប្រាក់សំណូកបើមិនចង់

[១៣១] យុត សុភក្តិចរិយា "អ្នកលក់ឈើត្រូវបានគេប្តឹងពីបទបរិហាកេរ្តិ៍" សារព័ត៌មានភ្នំពេញប៉ុស្តិ៍ ថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១០

[១៣២] វ៉ាន់ រើយ "អ្នកសារព័ត៌មានត្រូវបានចោទប្រកាន់ក្នុងករណីប្លន់" សារព័ត៌មានភ្នំពេញប៉ុស្តិ៍ ថ្ងៃទី៩ ខែមេសា ឆ្នាំ២០១០

អោយមានការបង្ហាញរឿងទេ។

- ស៊ឹម សំណាង ប្រកាសអះអាងពីភាពគ្មានកំហុសរបស់គាត់ ដោយបញ្ជាក់ថា គាត់គ្រាន់តែបានសុំអោយម្ចាស់ឃ្លាំងស្តុកឈើ ចេញថ្លៃចំណាយលើប្រេងសាំង ដល់អ្នកសារព័ត៌មានផ្សេងទៀត។
- មិនទាន់មានការកំណត់កាលបរិច្ឆេទសវនាការ សំរាប់ករណីនេះទេ។

►►►
២៦ មេសា ២០១០
ខេត្តសៀមរាប

**ករណីសិក្សា ក៣**

*ចាប់ខ្លួន:*
*អ្នកសារព័ត៌មានម្នាក់*

**អ្នកសារព័ត៌មាន ជាប់ឃុំឃាំងជាបណ្តោះអាសន្ន ដោយសង្ស័យពីរឿង ជំរិតទារប្រាក់ និងក្លែងបន្លំ**[១៣៣]

- ខន បូរ៉ា អ្នកសារព័ត៌មាននៃសារព័ត៌មាន ពន្លឺថ្មី ត្រូវបានជាប់ឃុំឃាំងជាបណ្តោះអាសន្ន នៅថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១០ តាមដីការតុលាការខេត្តសៀមរាប។ គាត់ត្រូវបានចោទប្រកាន់ពីរឿងជំរិតទារប្រាក់ចំនួន ៣០០ដុល្លាសហរដ្ឋអាមេរិក ពីម្ចាស់ឃ្លាំងស្តុកឈើមួយ។
- អ្នកសារព័ត៌មានមិនមានឈ្មោះទី២ ត្រូវបានគេស្វែងរកចាប់ខ្លួន ទាក់ទងនៅក្នុងករណីនេះដែរ តាមដីការព្រះរាជអាជ្ញារងតុលាការខេត្តសៀមរាបលោក ហេង ផេង។
- ហ៊ុន ជូ អាយុ៥១ឆ្នាំ ជាម្ចាស់ឃ្លាំងស្តុកឈើ បានប្តឹងថា ខន បូរ៉ា និងអ្នកសារ-ព័ត៌មានផ្សេងទៀត បានគំរាមគាត់ថា នឹងប្រាប់អជ្ញាធរមូលដ្ឋាន ពីការជាប់ពាក់ព័ន្ធរបស់គាត់ក្នុងសកម្មភាពជំនួញឈើខុសច្បាប់ និងទាមទារអោយផ្តល់ប្រាក់សំណូកដល់ពួកគេចំនួន១,០០០ដុល្លាសហរដ្ឋអាមេរិក បើមិនចង់អោយពួកគេប្រាប់។ គាត់និយាយថា គាត់បានអោយពួកគេចំនួន ៣០០ដុល្លាសហរដ្ឋអាមេរិក។]
- អ៊ុំ សារិន ប្រធានសមាគមកម្ពុជាដើម្បីការពារអ្នកសារព័ត៌មាន (CAPJ) បានបញ្ជាក់ថា ខន បូរ៉ា បដិសេធការចោទប្រកាន់នោះ។

►►►
២៤ ឧសភា ២០១០
ខេត្តសៀមរាប

**ករណីសិក្សា ក៤**

*កោះហៅ*
*អ្នកសារព័ត៌មានម្នាក់*

**អ្នកសារព័ត៌មានកាសែតរស្មីកម្ពុជាប្រចាំថ្ងៃ ត្រូវបានកោះហៅចូលបំភ្លឺ តុលាការ**[១៣៤]

- អ្នកសារព័ត៌មានប្រចាំខេត្តសៀមរាប លោក ជា ស្រស់ ប្រឈមមុខនឹងការចោទប្រកាន់ មានតាំងពីបទចាប់ពង្រត់រហូតដល់ជំរិតទារប្រាក់ បន្ទាប់ពីគាត់ចុះ ផ្សាយអត្ថបទនិយាយថា ឈ្មួញឈើ និងទាហាន កងពលតូចលេខ៥ បានពាក់ព័ន្ធក្នុងការរកស៊ីឈើខុសច្បាប់។ ជា ស្រស់ បំរើការងារអោយសារព័ត៌មានរស្មីកម្ពុជាប្រចាំថ្ងៃ។
- គាត់ត្រូវបានកោះហៅអោយចូលខ្លួនមកតុលាការ សៀមរាប-ឧត្តរមានជ័យ នៅ

[១៣៣] ច្រាន់ ចំរើន "អ្នកសារព័ត៌មានត្រូវបានជាប់ឃុំឃាំងដោយសារសង្ស័យពីរឿងជំរិតទារប្រាក់" សារព័ត៌មានភ្នំពេញប៉ុស្តិ៍ ថ្ងៃទី២៦ ខែ មេសា ឆ្នាំ២០១០

[១៣៤] សារព័ត៌មានកម្ពុជាថ្មីប្រចាំថ្ងៃ ថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១០

ថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០១០ ដើម្បីឆ្លើយនឹងសំនួរ។ អត្ថបទត្រូវបានឃើញចុះផ្សាយនៅថ្ងៃទី១២ ខែឧសភា ឆ្នាំ២០១០។ បទចោទប្រកាន់លើរូបគាត់ រួមមាន ចាប់ពង្រត់ ជំរិតទារប្រាក់ វាយដំលើរាងកាយ និងផ្សព្វផ្សាយព័ត៌មានមិនពិត។

- ឧប្បត្តិហេតុនោះកើតឡើងក្នុងភូមិ ព្រៃគុយ សង្កាត់អំពិល ក្រុងសៀមរាប។

►►►
១៣ កក្កដា ២០១០
ខេត្តសៀមរាប

**ករណីសិក្សា ក៥**

*ចាប់ខ្លួន:*
*អ្នកសារព័ត៌មាន៤នាក់*

**អ្នកសារព័ត៌មាន បួននាក់ ត្រូវបានចាប់ខ្លួន បន្ទាប់ពីអ្នកភូមិអះអាងពីរឿងជំរិតទារប្រាក់[១៣៥]**

- អ្នកសារព័ត៌មានបួននាក់ ត្រូវបានចាប់ខ្លួនក្នុងខេត្តសៀមរាប ចំពោះការចោទប្រកាន់ថា បានព្យាយាមជំរិតទារប្រាក់ពីអ្នកភូមិ ជាអ្នកដែលពួកគេចោទថាបានជាប់ពាក់ព័ន្ធក្នុងសកម្មភាពរកស៊ីកាប់ឈើខុសច្បាប់។ ចៅក្រមស៊ើបសួរខេត្តសៀមរាបបានបង្គាប់អោយធ្វើការឃុំខ្លួនពួកគេជាបណ្តោះអាសន្ននាថ្ងៃបន្ទាប់។
- អ្នកសារព័ត៌មានទាំងអស់មាន ចាន់ សារឹម (សារព័ត៌មានកូស៊ាំងស៊ីន), មៅ សារេត (សារព័ត៌មាន កូស៊ាំងស៊ីន), នរោត្តម រិទ្ធីវង្ស(សារព័ត៌មានកូស៊ាំងស៊ីន), និង ហ៊ាម សាន (សារព័ត៌មានតាព្រហ្ម)។
- អ្នកសារព័ត៌មានទាំងបួននាក់ បានចុះផ្សាយអត្ថបទរឿងជួញដូរឈើខុសច្បាប់។ អ្នកភូមិនិយាយអះអាងថា អ្នកសារព័ត៌មានបានមកដល់ផ្ទះពួកគេ ហើយបានស្នើរអោយបង់ប្រាក់ពី ៣០,០០០រៀល ទៅ ៥០ដុល្លាសហរដ្ឋអាមេរិក។ ក្រុមគ្រួសារអ្នកភូមិ បានបដិសេធមិនបង់ប្រាក់អោយទេ។ អ្នកសារព័ត៌មានម្នាក់ក្នុងចំនោមពួកគេ បានរាយការណ៍ពីរឿងអ្នកភូមិប្រាប់ទៅមន្ត្រីនគរបាលជាន់ខ្ពស់នៃក្រសួងមហាផ្ទៃថា អ្នកភូមិបានលាក់ឈើខុសច្បាប់ចំនួន ១០០ ម៉ែត្រគូប។ អជ្ញាធរខេត្តសៀមរាប បានធ្វើការស៊ើបអង្កេតលើព័ត៌មាននេះ និងនិយាយថាពួក គេបាន រកឃើញឈើតែចំនួនបន្តិចបន្តួចប៉ុណ្ណោះ។

►►►
២០ កក្កដា ២០១០
ខេត្តកំពង់ធំ

**ករណីសិក្សា ក៦**

*ចាប់ខ្លួន-កាត់ទោស:*
*អ្នកសារព័ត៌មានម្នាក់*

**បណ្ណាធិកាសារព័ត៌មាន ត្រូវបានកាត់ទោស ចំពោះការប្រើប្រាស់ផ្លាកលេខយានយន្តគ្មានច្បាប់អនុញ្ញាត[១៣៦]**

- បណ្ណាធិកាសារព័ត៌មាន នៅក្នុងខេត្តកំពង់ធំ ត្រូវបានកាត់ទោសពីបទ ក្លែងបន្លំ និងជំរិតទារប្រាក់ ចំពោះការប្រើប្រាស់ ផ្លាកលេខយានយន្ត ខាងសារព័ត៌មាន ដោយមិនបានចុះបញ្ជីជាមួយក្រសួងមហាផ្ទៃ។ គាត់ត្រូវបានចាប់ខ្លួននៅថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០១០ និងត្រូវបានទទួលការកាត់ទោស នៅថ្ងៃទី៤ ខែសីហា ឆ្នាំ២០១០។

---

[១៣៥] សារព័ត៌មានកម្ពុជាថ្មីប្រចាំថ្ងៃ ថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១០

[១៣៦] សារព័ត៌មានរស្មីកម្ពុជាថ្មី ថ្ងៃទី២២ និង២៤ ខែកក្កដា ឆ្នាំ២០១០។ មេឃ ទិត្ថារ៉ា "បណ្ណាធិកាសារព័ត៌មានត្រូវបានជាប់ចោទពីបទក្លែងបន្លំ និងជំរិតទារប្រាក់" សារព័ត៌មានភ្នំពេញប៉ុស្ដិ៍ ថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០១០។ មេឃ ទិត្ថារ៉ា "បទបញ្ញត្តិចរាចរណ៍លើផ្លូវថ្នល់: បណ្ណាធិកាសារព័ត៌មានត្រូវបានកាត់អោយជាប់ទោសពីរឿងផ្លាកលេខយានយន្តក្លែងក្លាយ" សារព័ត៌មានភ្នំពេញប៉ុស្ដិ៍ ថ្ងៃទី៥ ខែ សីហា ឆ្នាំ២០១០

- ឃុន ប៊ុនហួរ មេបញ្ជាការកងរាជអាវុធហត្ថស្រុកបារាយណ៍ ក្នុងខេត្តកំពង់ធំ បាននិយាយថា អ្នកសារព័ត៌មានបានដាក់ "កុងត្រូល" ដើម្បីបញ្ឈប់អ្នកលក់ឈើ និងទារយកលុយពីពួកគេ។ នគរបាលបាននិយាយថា ហាន តារាហុល បានប្រាប់ទៅអ្នកលក់ឈើថា គាត់នឹងសរសេរអត្ថបទមានលក្ខណៈបំផ្លាញដល់ពួកគេ បើសិនជាពួកគេមិនបង់ប្រាក់អោយទេ។ នគរបាលក៏បាននិយាយផងដែរថា អ្នកសារព័ត៌មានរូបនេះបានដាក់កុងត្រូល នៅជិតនគរបាលជា "ច្រើនលើក"។
- តុលាការបានផ្តន្ទាទោស ហាន តារាហុល អោយជាប់ពន្ធនាគារ រយៈពេល ២៤ខែ ដោយព្យួរទោស ២៣ខែ។ ទោះបីជាយ៉ាងណាក៏ដោយព្រះរាជអាជ្ញាបានប្តឹងឧទ្ធរណ៍ ពីសេចក្តីសំរេចរបស់តុលាការ ហើយ តារាហុល បន្តនៅជាប់ពន្ធនាគារ។ គាត់បោះពុម្ពផ្សាយសារព័ត៌មានប្រចាំខែ ឈ្មោះ ឆន្ទៈកូន។

►►►
២១ កក្កដា ២០១០
ខេត្តក្រចេះ

**ករណីសិក្សា ក៧**

*<u>ចាប់ខ្លួន:</u>*
*អ្នកសារព័ត៌មាន ៥នាក់មន្ត្រីរដ្ឋបាលព្រៃឈើ ២នាក់*

**អ្នកសារព័ត៌មានច្រើនថែមទៀត ត្រូវបានចាប់ខ្លួនពីបទជំរិតទារប្រាក់ពី ឈ្មួញឈើខុសច្បាប់**[១៣៧]

- បុរស៧នាក់ ត្រូវបានចាប់ខ្លួនក្នុងខេត្តក្រចេះ នៅថ្ងៃទី២១ ខែកក្កដា ឆ្នាំ ២០១០ ជាផ្នែកមួយនៃការបង្ក្រាបដ៏លេចធ្លោលើអ្នកសារព័ត៌មាន ដែលជំរិតទារប្រាក់ពីឈ្មួញឈើខុសច្បាប់។ បុរសទាំង៧នាក់ រួមមានអ្នកសារព័ត៌មាន ៥នាក់ និងមន្ត្រីរដ្ឋបាលព្រៃឈើរបស់រដ្ឋាភិបាល ២នាក់: ហ៊ាង សុគន្ធ (អ្នកសារព័ត៌មាននៃសារព័ត៌មានរស្មីឮសាន) ប្រាក់ ថា (បណ្ណាធិការនៃសារព័ត៌មានរស្មីឮសាន) ឈាន បូ អ្នកសារព័ត៌មាននៃសារព័ត៌មានរស្មីឮសាន) ពិន រ៉ា (អ្នកសារព័ត៌មាននៃសារព័ត៌មានរស្មីឮសាន) ឃិន សុវណ្ណារ៉ា (អ្នកសារព័ត៌មាននៃសារព័ត៌មាន រស្មីឮសាន) ស៊ីម តុល (មន្ត្រីរដ្ឋបាលព្រៃឈើ) និង ថេង សុះ (មន្ត្រីរដ្ឋបាលព្រៃឈើ)។
- ប្រាក់ ថា បានអះអាងថា ក្រុមរបស់គាត់ បានកំពុងតែធ្វើដំណើរទៅទីតាំងមួយក្នុងឃុំជ្រោយបន្ទាយ ជាកន្លែងដែលគាត់ត្រូវបានប្រាប់ថា មានមនុស្សដឹកឈើខុសច្បាប់តាមទូក-កាណូត។ ពួកគេបានចូលទៅ ដល់ជួបជនសង្ស័យកាប់ឈើខុសច្បាប់ ហើយបានបញ្ឈប់ពួកគេដើម្បីសាកសួរ ប៉ុន្តែមិនទាន់បានសួរសំណួរផង ស្រាប់តែក្រុមខ្លួនត្រូវបានចាប់ខ្លួនតែម្តង។ នគរបាលក៏បានដកហូតរថយន្ត និងសម្ភារៈរបស់គាត់។
- ក្នុងខែសីហា ក្រុមប្រឹក្សាអ្នកសារព័ត៌មានកម្ពុជាបានដាក់ពាក្យប្តឹង ក្នុងនាមលោក ប្រាក់ ថា ពីការ "បាត់បង់កិត្តិយស" ដោយទាមទារសំណងជំងឺចិត្ត

[១៣៧] សារព័ត៌មាននគរវត្ត ថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០១០។ វង់ សុខេង "អ្នកសារព័ត៌មានប្តឹងពីរឿងឃុំឃាំងខុសច្បាប់" ភ្នំពេញប៉ុស្តិ៍ ថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១០

១០លានរៀល (២,៣៥៣ដុល្លាសហរដ្ឋអាមេរិក)។ ក្រុមប្រឹក្សាបាននិយាយបង្អាប់ដល់ការចាប់ខ្លួននោះ ថាជាការដាក់កំហិតហួសហេតុលើសេរីភាពខាងការបញ្ចេញមតិ។

►►►
២ សីហា ២០១០
ខេត្តសៀមរាប

**ករណីសិក្សា ក៨**

*កោះហៅ:*
*អ្នកសារព័ត៌មានម្នាក់*

**អ្នកសារព័ត៌មាន ប្រឈមមុខនឹងបទចោទប្រកាន់ជំរិតទារប្រាក់ពីម្ចាស់ឃ្លាំងស្តុកឈើអារ**[១៣៨]

- អ្នកសារព័ត៌មាន ត្រូវបានបង្គាប់អោយមកបង្ហាញខ្លួននៅតុលាការ ពីបទចោទប្រកាន់ថាបានព្យាយាមជំរិតទារប្រាក់ចំនួន ២៥ដុល្លាសហរដ្ឋអាមេរិកពីម្ចាស់ឃ្លាំងឈើអារ ក្នុងឆ្នាំ២០០៩។ អ្នកសារព័ត៌មានឈ្មោះ ផ្លុង រ៉េត ក៏ប្រឈមមុខនឹងបទព្រហ្មទណ្ឌផ្សព្វផ្សាយព័ត៌មានមិនពិត ចំពោះការបោះពុម្ពផ្សាយអត្ថបទនិយាយអំពីម្ចាស់ឃ្លាំង។ ផ្លុង រ៉េត ធ្លាប់បានបំរើការងារអោយសារព័ត៌មានតាព្រហ្ម។
- ការជំរិតទារប្រាក់ដែលចោទឡើងនេះ បានកើតមានឡើងកាលពីថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០០៩ នៅពេលដែលអ្នកសារព័ត៌មាន ២០នាក់ បានថតរូបរថយន្តដឹកឈើដែលអមការពារដោយរថយន្តយោធា។ ម្ចាស់ឃ្លាំងស្តុកឈើ លោក ចាន់ បុល អះអាងថា នាពេលនោះ ប្លុង រ៉េត បានទារប្រាក់ពីគាត់ ចំនួន ២៥ដុល្លាសហរដ្ឋអាមេរិក។
- តែទោះជាយ៉ាងនេះក្តី អ្នកសារព័ត៌មាន និយាយថា គាត់ត្រូវបានទាហាននៃកងពលតូចលេខ៥ វាយដំលើរូបគាត់ បន្ទាប់ពីគាត់ថតរូបរថយន្តទាំងនោះ។
- ប្លុង រ៉េត បានបង្ហាញខ្លួននៅក្នុងតុលាការ នាថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១០ ហើយបានអះអាងពីភាពគ្មានកំហុសរបស់គាត់។ គាត់បាននិយាយថា ពាក្យបណ្តឹង គឺជាការព្យាយាមដើម្បីសងសឹក ក្រោយពីគាត់បានថតយករូបភាពនៃសកម្មភាពដឹកឈើ។ ករណីស្ថិតក្នុងដំណាក់កាលរង់ចាំសេចក្តីសំរេចពីតុលាការ។

►►►
១៧ សីហា ២០១០
ខេត្តក្រចេះ

**ករណីសិក្សា ក៩**

**បណ្ណាធិកាសារព័ត៌មាន ត្រូវបានពិន័យជាប្រាក់ ចំពោះការបរិហារកេរ្តិ៍ បន្ទាប់ពីគាត់ចោទមន្ត្រីយោធាថា ជាប់ពាក់ព័ន្ធក្នុងការកាប់ឈើខុសច្បាប់**[១៣៩]

- អ្នកសារព័ត៌មានពីរនាក់ មកពីខេត្តក្រចេះ ត្រូវបានកាត់អោយជាប់ទោសពីបទបរិហារកេរ្តិ៍មន្ត្រីយោធានៅមូលដ្ឋានម្នាក់ និងត្រូវបានពិន័យជាប្រាក់ចំនួន ២លានរៀល (៤៧១ដុល្លាសហរដ្ឋអាមេរិក)។ ពួកគេក៏ត្រូវបានបង្គាប់អោយបង់ប្រាក់សំណងជំងឺចិត្តដល់ដើមបណ្តឹងចំនួន ៤លានរៀល (៩៤១ដុល្លាសហរដ្ឋ

[១៣៨] វ៉ាន់ វើយ "តុលាការកោះហៅអ្នកសារព័ត៌មាន ដែលត្រូវបានចោទប្រកាន់ពីបទជំរិតទារប្រាក់" សារព័ត៌មានភ្នំពេញប៉ុស្តិ៍ ថ្ងៃទី២ ខែ សីហា ឆ្នាំ២០១០។ វ៉ាន់ វើយ "អ្នកសារព័ត៌មាន ត្រូវបានតុលាការកោះហៅអោយចូលខ្លួនពីរឿងជំរិតទារប្រាក់" សារព័ត៌មានភ្នំពេញ ប៉ុស្តិ៍ ថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១០។ អង្គការលីកាដូ ករណីលេខ SP012PA10

[១៣៩] ច្រាន់ ចំរើន "អ្នកសារព័ត៌មាន ប្រឈមមុខនឹងការពិន័យ ចំពោះការបរិហារកេរ្តិ៍" សារព័ត៌មានភ្នំពេញប៉ុស្តិ៍ ថ្ងៃទី១៨ ខែសីហា ឆ្នាំ២០១០។ អត្ថបទផ្សព្វផ្សាយ នៃសមាគមមិត្តអ្នកសារព័ត៌មានខ្មែរ

*កាត់ទោស:*
*អ្នកសារព័ត៌មាន ២នាក់*

អាមេរិក)។

- មិនមានអ្នកសារព័ត៌មានណាម្នាក់ - ជា ចាន់ប្រាកដ (បណ្ណាធិកាសារព័ត៌មានមាតុភូមិ) និង សុន សុផល (អ្នកនិពន្ធនៃសារព័ត៌មានមាតុភូមិ) - មិនមានវត្តមាន ក្នុងសវនាការទេ។
- អ្នកទាំងពីរ បានចុះផ្សាយអត្ថបទមួយក្នុងខែមេសា ឆ្នាំ២០០៩ រៀបរាប់យ៉ាងលំអិតអំពី លោក មាស សុភាព មេបញ្ជាការកងវរសេនាតូច លេខ២០៤ មានមូលដ្ឋានក្នុងស្រុកស្នួល ខេត្តក្រចេះ។ អត្ថបទសរសេរថា លោក មាស សុភាបានជាប់ពាក់ព័ន្ធក្នុងជំនួញឈើខុសច្បាប់ ហេតុដូច្នេះ គ្មានការជំរុញទឹកចិត្តដើម្បីបង្ក្រាបទេ។ មាស សុភាព បានដាក់ពាក្យបណ្តឹងចូលតុលាការក្នុងខែឧសភា ឆ្នាំ២០០៩ ចោទប្រកាន់ថា អ្នកសារព័ត៌មានបានរំលោភមាត្រា១០ នៃច្បាប់ស្តីពីរបបសារព័ត៌មាន ឆ្នាំ១៩៩៥។
- អ៊ុំ ចាន់ដារ៉ា ប្រធានសមាគមមិត្តអ្នកសារព័ត៌មានខ្មែរ បាននិយាយថា សេចក្តីសំរេចរបស់តុលាការនឹងធ្វើអោយអ្នកការសែតដទៃទៀត មានការរួញរា ក្នុងការសរសេរចុះផ្សាយអត្ថបទស្តីពីការ កាប់ឈើខុសច្បាប់។
- យ៉ាងហោយណាស់មានអ្នកសារព័ត៌មានពីរនាក់ បានចុះផ្សាយអត្ថបទរៀបរាប់លំអិតពីការជាប់ពាក់ព័ន្ធក្នុងជំនួញឈើរបស់ លោក មាស សុភាព។ (សារព័ត៌មានខ្មែរអមតៈ "មេបញ្ជាការកងវរសេនាតូចលេខ២០៤ ប្រើប្រាស់បន្ទាយយោធាសំរាប់ទុកឈើ" ថ្ងៃទី១៤ ខែមករា ឆ្នាំ២០១០ និងសារព័ត៌មានដើមអំពិល "ឥទ្ធិក្រហមនៅបន្តដឹកឈើនៅឡើយដោយគ្មានការភ័យខ្លាច" ថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១០។)

# ៨. សេចក្ដីសន្និដ្ឋាន និងអនុសាសន៍

*"រាជរដ្ឋាភិបាលកំពុងតែធ្វើការសាកល្បងមើលសហគមន៍អន្តរជាតិ។ នៅពេលដែលពួកគេចោទប្រកាន់ទៅលើ លោក សម រង្ស៊ី និងអ្នកផ្សេងទៀត មុនពេលចោទប្រកាន់មកលើខ្ញុំ ឃើញថា ប្រតិកម្មពីសហគមន៍អន្តរជាតិមានលក្ខណៈទន់ខ្សោយ។ រដ្ឋាភិបាលនៃប្រទេសជាច្រើន មិនបាននិយាយអ្វីទាល់តែសោះ។"*[១៤០]

ពាក្យសំដីខាងលើនេះ ត្រូវបាននិយាយដោយលោក កឹម សុខា ក្នុងឆ្នាំ២០០៦ បន្ទាប់ពីមានការចាប់ខ្លួនរបស់គាត់ - និងបន្ទាប់ពីការកាត់សេចក្ដីលើលោក សម រង្ស៊ី - ចំពោះបទបរិហារកេរ្តិ៍។ វាជាការគួរកត់សំគាល់ចំពោះការមើលឃើញថា មានការប្រែប្រួលតិចតួចក្នុងឆ្នាំ២០១០: លោក សម រង្ស៊ី ត្រូវបានកាត់ទោសជាថ្មីម្ដងទៀត លោក កឹម សុខា ប្រឈមមុខនឹងបទចោទប្រកាន់ថ្មីៗទៀត និងអ្នកនយោបាយគណបក្សជំទាស់មួយចំនួន ប្រឈមមុខនឹងការចោទប្រកាន់បទព្រហ្មទណ្ឌផងដែរ។ វាហាក់បីដូចជា ផលិតករនៃល្ខោននយោបាយនៅប្រទេសកម្ពុជា ផលិតនូវរឿង នយោបាយដដែលៗម្ដងហើយម្ដងទៀត។

ប៉ុន្តែអ្វីដែលការបានដឹង និងបានឃើញពីការផលិតរឿងដដែលទាំងនេះ មិនមែនមានដែនកំនត់តែក្នុងរង្វង់នយោបាយនោះទេ នគរបាលបន្តបង្ក្រាបយ៉ាងហិង្សាលើការតវ៉ាជាសាធារណៈ អ្នកសារព័ត៌មានត្រូវបានចាប់ខ្លួន និងជាប់ចោទពីបទព្រហ្មទណ្ឌ នៅពេលណាពួកគេ តទល់ជាមួយក្រុម អ្នកកាន់អំណាច ចំនែកឯសកម្មជនសហគមន៍ ប្រឈមមុខនឹងការបំភិតបំភ័យ ការគំរាមកំហែង និងរហូតដល់ការសម្លាប់ នៅពេលណាដែលពួកគេបញ្ចេញមតិ។

ហើយអ្វីៗអាចនឹងកាន់តែអាក្រក់ឡើងក្នុងប៉ុន្មានខែខាងមុខនេះ៖ នៅពេលដែលរបាយការណ៍នេះផ្សព្វផ្សាយតាមសារព័ត៌មាន រដ្ឋាភិបាលកំពុងតែត្រៀមរួចជាស្រេចនូវច្បាប់ថ្មី ដើម្បីដាក់កំហិតលើសមាគម និងអង្គការក្រៅរដ្ឋាភិបាល។ ទោះបីជារដ្ឋាភិបាលមិនទាន់បានបញ្ចេញអោយឃើញនូវ ពង្រាងច្បាប់ទាំងមូលក៏ដោយ ក៏សេចក្ដីដកស្រង់នៃពង្រាងច្បាប់ដែលបានផ្សព្វផ្សាយដល់សាធារណៈជន ចង្អុលបង្ហាញថា ច្បាប់នេះត្រូវបានរៀបចំឡើងដើម្បីគ្រប់គ្រង និងដាក់កំហិតលើសកម្មភាពអង្គការក្រៅរដ្ឋាភិបាល។ វាអាស្រ័យលើសេចក្ដីក្បោះក្បាយនៃបញ្ញត្តិច្បាប់នេះទាំងមូលច្បាប់នេះអាចទំនងជាគំរាមកំហែងយ៉ាងធ្ងន់ធ្ងរដល់

លទ្ធភាពរបស់អង្គការសិទ្ធិមនុស្សក្រៅរដ្ឋាភិបាល ដើម្បីនិយាយប្រឆាំងនឹងអំពើរំលោភបំពានរបស់រាជរដ្ឋាភិបាល និងបន្ទុចបង្អាក់ដល់ លទ្ធភាពរៀបចំចងក្រងគ្នារបស់សហគមន៍មូលដ្ឋាន។

អង្គការលីកាដូ អង្គការសង្គមស៊ីវិលដទៃទៀត បានធ្វើការព្រមានជាច្រើនឆ្នាំមកហើយ អំពីបរិយាកាសកាន់តែចង្អៀត សម្រាប់ការសំដែងមតិខាងនយោបាយរបស់ប្រទេសកម្ពុជា។ បរិយាកាសនេះមិនបានពង្រីកទេ។ អ្នកដឹកនាំរបស់ប្រទេសកម្ពុជាកំពុងតែភ័យខ្លាចឡើងៗ ចំពោះយោបល់ផ្ទុយ។ មូលហេតុនៃ

---

[១៤០] អេរិក ប៉ាប៉េ "អ្នកប្រឆាំងកម្ពុជាដែលមានសេរីភាព: 'បាទ ខ្ញុំខ្លាច'" ដំណឹងប្រចាំសប្ដាហ៍ ថ្ងៃទី២១ ខែមករា ឆ្នាំ២០០៦

ការភ័យខ្លាចរបស់ពួកគេ គឺមិនមានការលំបាកដើម្បីស្វែងយល់ទេ។

ក្រុមអ្នកកាន់អំណាច មានអំណាចរឹងមាំ ហើយក្តោបក្តាប់ និងប្រើអំណាចនេះដើម្បីផលប្រយោជន៍របស់ពួកគេ - ផលប្រយោជន៍ផ្តល់ភាពហ៊ឺហារដល់ពួកគេ។ ពួកគេមិនពេញចិត្ត បែងចែកនូវសិទ្ធិអំណាចរបស់ពួកគេទេ មិនថាវាត្រូវខាតបង់យ៉ាងណាក៏ដោយចុះ។ រដ្ឋគ្រប់គ្រងដោយច្បាប់ ត្រូវបានជំនួសដោយការគ្រប់គ្រងដោយអ្នកមានអំណាច។ ការបោះឆ្នោត គឺជាដំណើរការបោកប្រាក់មួយហើយ ប្រជាធិបតេយ្យ គឺជារឿងថ្មិនភ្នែក។

ប៉ុន្តែនៅមានសញ្ញាវិជ្ជមាននៅឡើយ។

ប្រជាពលរដ្ឋកម្ពុជាត្រូវបានធ្វើអោយអស់កំលាំង ដោយសារអំពើពុករលួយ បញ្ហាបក្សពួកនិយម និងសោកនាដកម្ម អស់ជាច្រើនជំនាន់មកហើយ។ ប៉ុន្តែ ប្រជាពលរដ្ឋកម្ពុជានៅរក្សាបាននូវ ឧត្តមគតិយុត្តិធម៌ និងបន្តការតស៊ូដើម្បីសម្រេចបានយុត្តិធម៌។ រឿងរ៉ាវមានក្នុងរបាយការណ៍នេះ គឺជាភស្តុតាងនៃការពិត។

អ្នកសារព័ត៌មាន មេដឹកនាំអង្គការមិនមែនរដ្ឋាភិបាល អ្នកនយោបាយ មេដឹកនាំសហគមន៍ សកម្មជនសហជីព និងអ្នកដែលស្ថិតក្នុងទម្រង់ដទៃទៀត នៅក្នុងរបាយការណ៍នេះ បានដឹងពីគ្រោះថ្នាក់ចំពោះសកម្ម-ភាពរបស់ខ្លួន។ ពួកគេមានការភ័យខ្លាចពីផលវិបាកនានា និងពីការប្រឈមមុខនឹងផលវិបាកទាំងនោះ។


*កម្មករៀបចំការដើរក្បួនយ៉ាងធំមួយក្នុងរាជធានីភ្នំពេញ ថ្ងៃទី១ ខែមេសា។ ព្រឹត្តិការណ៍នេះរៀបចំឡើងដោយសន្តិវិធី និងគ្មានការរារាំងពីសំណាក់អាជ្ញាធរឡើយ។*

ទោះជាយ៉ាងណាក្តីពួកគេបន្តរក្សានូវសកម្មភាពរបស់ខ្លួន។

លោក ហង្ស ចក្រា ជាអ្នកសារព័ត៌មាន និងជាអ្នកបោះពុម្ពផ្សាយសារព័ត៌មាន ដែលធ្លាប់បានជាប់ពន្ធនាគារ ដោយសារតែបានចុះផ្សាយពីរឿងអំពើពុករលួយរបស់រាជរដ្ឋាភិបាល បានមានប្រសាសន៍ថា "មានមនុស្សជាច្រើនភ័យខ្លាចថា ខ្ញុំក្បត់ឧត្តមគតិរបស់ខ្ញុំ" ។

"ចំពោះការភ័យខ្លាចនេះ ខ្ញុំមានចម្លើយតែមួយគត់: ខ្ញុំនឹងខិតខំការពារជំហររបស់ខ្ញុំរហូតដល់ថ្ងៃចុងបញ្ចប់នៃជីវិតខ្ញុំ។" លោក ចក្រា និងអ្នកផ្សេងទៀតដឹងថាពិភពលោកកំពុងតែសំលឹងមើលមកកម្ពុជា។ ពួកគេនៅតែរក្សាបាននូវអារម្មណ៍នៃការមានសង្ឃឹម និងជំនឿថា លទ្ធិប្រជាធិបតេយ្យរបស់ប្រទេសកម្ពុជា មិនមែនជាកម្មសិទ្ធិរបស់មនុស្សមួយក្រុម ឬរបស់គណបក្សមួយនោះទេ។ លទ្ធិប្រជាធិបតេយ្យ ជារបស់ពួកគេទាំងអស់

គ្នាដែលត្រូវប្រកាន់យក។

*អនុសាសន៍*

អង្គការលីកាដូ សូមផ្តល់អនុសាសន៍ដែលមានជាជំហានៗ ដូចខាងក្រោម ដើម្បីធានាថាសិទ្ធិបញ្ចេញមតិរបស់ប្រទេសកម្ពុជា ត្រូវបានគោរព ហើយលិទ្ធិប្រជាធិបតេយ្យមានភាពរីកចំរើនៈ

- រាជរដ្ឋាភិបាលកម្ពុជា ត្រូវធានា**អោយមានការស៊ើបអង្កេតពិតប្រាកដ និងផ្តន្ទាទោស** ចំពោះគ្រប់ករណីទាំងអស់ ដែលអំពើហិង្សាត្រូវបានគេប្រើប្រាស់ដើម្បីសងសឹកលើ ប្រជាពលរដ្ឋកម្ពុជា ចំពោះការអនុវត្តសិទ្ធិខាងការបញ្ចេញមតិរបស់ខ្លួន។ រាជរដ្ឋាភិបាលត្រូវធានាថា **ការស៊ើបអង្កេតទាំងអស់ប្រព្រឹត្តិទៅដោយគ្មានការបន្ទុចបង្អាក់ពីការជ្រៀតជ្រែកពីខាងក្រៅ។**
- មន្ត្រីទាំងឡាយ និងបុគ្គលក្នុងតួនាទីសាធារណៈគួរតែបង្ហាញនូវភាព **អធ្យាស្រ័យចំពោះ ការរិៈគន់** និងគោរពសិទ្ធិខាងការបញ្ចេញមតិ នៃអ្នកសារព័ត៌មាន និងអ្នកផ្សេងទៀត ព្រមទាំង **ទប់ចិត្ត និងអត់ធ្មត់ពីការប្តឹងរឿងព្រហ្មទណ្ឌ** ប្រឆាំងនឹងពួកគេ។
- រាជរដ្ឋាភិបាលត្រូវតែអនុញ្ញាត និងជំរុញលើកទឹកចិត្តដល់ **នគរបាលពេញច្បាប់ និងការស៊ើបអង្កេតតាមផ្លូវតុលាការ**លើ ករណីឃាតកម្មទាំងអស់ដែលបានប្រព្រឹត្តិចំពោះ អ្នកសារព័ត៌មាន អ្នកការពារសិទ្ធិមនុស្ស សកម្មជនសហជីព និងអ្នកផ្សេងទៀត ដែលការស្លាប់របស់ពួកគេទាក់ទងនឹងសកម្មភាពនៃការបញ្ចេញមតិ ក្នុងប្រទេសកម្ពុជា ដែលកើតមានឡើងតាំងពីឆ្នាំ១៩៩៣ មក។
- រដ្ឋសភាជាតិត្រូវតែ**ទប់ចិត្ត ពីការដកអភ័យឯកសិទ្ធិសភា**នៃអ្នកតំណាងរាស្ត្រ ដែលអនុវត្តភារកិច្ចបែបប្រជាធិបតេយ្យរបស់ខ្លួន ឬក៏សម្តែងនូវគំនិតយោបល់បែបនយោបាយ។
- រាជរដ្ឋាភិបាលគួរតែប្រកាន់យកជំហាន **កាត់បន្ថយ ឬលប់បំបាត់ចោល ការអនុវត្តន៍ការដាក់ពន្ធនាគារបុគ្គលដែលខកខានមិនបង់ប្រាក់ពិន័យខាងព្រហ្មទណ្ឌ និងបង់ប្រាក់តាមសេចក្តីសំរេចរបស់តុលាការ។** បញ្ញត្តិទាំងអស់នេះ មានការរើសអើងចំពោះអ្នកក្រីក្រ ហើយវាអនុញ្ញាតអោយមានការដាក់ទោសពន្ធនាគារចំពោះសកម្មភាពដែល "មិនមែនជាករណី ព្រហ្មទណ្ឌ" ដូចជា ករណីបរិហារកេរ្តិ៍ ជាដើម។ បញ្ញត្តិទាំងនេះ ក៏ជាបន្ទុកធ្ងន់ផងដែរ ដល់ប្រព័ន្ធពន្ធនាគារ ដែលជាការមិនចាំបាច់ពីព្រោះប្រព័ន្ធពន្ធនាគារ ផ្ទុកអ្នកទោស ដល់ទៅជិតពីរដងនៃសមត្ថភាពដែលអាចទទួលយកអ្នកទោសបាន។

**ដំណោះស្រាយអាចធ្វើទៅបានរួមមានៈ**

- លុបបំបាត់ទាំងស្រុងការអនុវត្តន៍ការដាក់ពន្ធនាគារ ចំពោះបុគ្គលដែលមិនបង់ប្រាក់ពិន័យខាងព្រហ្មទណ្ឌ ឬបង់ប្រាក់តាមសេចក្តីសំរេចរបស់តុលាការ
- **កំរិតលើប្រាក់ពិន័យ** ដោយផ្អែកលើប្រាក់ចំណូល និងធនធានដែលបុគ្គលរកបាន ឬលទ្ធភាពដែលបុគ្គលអាចបង់បាន

- បង្កើតអោយមានជា **គម្រោងបង់ប្រាក់**ជាដំណាក់កាលៗ និងអនុញ្ញាតអោយចុងចោទ នូវពេលវេលា ដើម្បីបង់ប្រាក់ពិន័យ មុននឹងងាកមកប្រើវិធីដាក់ពន្ធនាគារ និង
- ដាក់ចេញនូវ **សេវាសហគមន៍** ឬវិធានការគ្មានការឃុំឃាំង ជំនួសអោយពន្ធនាគារ ចំពោះការខកខាន មិនបង់ប្រាក់ពិន័យ។
- រដ្ឋាភិបាលត្រូវតែធានាថា **ច្បាប់បាតុកម្ម មិនត្រូវបានប្រើប្រាស់ ដោយរបៀបរើសអើង** ដើម្បីរារាំងដល់ក្រុមដែលគេមិនពេញចិត្តណាមួយ ពីការជួបប្រជុំដោយសន្តិវិធី ឬបញ្ចេញមិតិយោបល់ដែលផ្ទុយទៅនឹងទស្សនៈរបស់គណបក្សកាន់អំណាច។ ការជួបប្រជុំដោយសន្តិវិធី ដើម្បីបញ្ចេញមិតិមិនយល់ស្របជាមួយនឹងបុគ្គលនានាស្ថិតក្នុងអំណាច មិនគួរត្រូវបានមើលឃើញជាស្វ័យប្រវត្តិថា ជាការគំរាមកំហែងដល់ "សណ្តាប់ធ្នាប់សាធារណៈ" ឬ "សន្តិសុខជាតិ" ទេ។ ពាក្យស័ព្ទទាំងនេះ ជាមួយនឹងពាក្យ "ប្រពៃណីល្អរបស់សង្គមជាតិ" គួរតែមានការកំណត់អត្ថន័យអោយចង្អៀត នៅពេលណាពិនិត្យ និងកំណត់ថាតើអនុញ្ញាត អោយមាននូវការជួបប្រជុំជាសាធារណៈ។
- អាជ្ញាធរមូលដ្ឋាន និងអជ្ញាធរថ្នាក់ជាតិ ត្រូវតែ**ធានាថា សិទ្ធិមានសេរីភាពក្នុងការដើរហើរ តាមរដ្ឋធម្មនុញ្ញរបស់កម្ពុជា ត្រូវបានគោរព**។ ប្រជាពលរដ្ឋកម្ពុជា មានសិទ្ធិធ្វើដំណើរទៅចូលរួមស្តាប់សវនាការ និងបាតុកម្មដោយសន្តិវិធី។
- រាជរដ្ឋាភិបាលគួរតែ **ទប់ចិត្តពីការបញ្ចេញអារម្មណ៍ផ្ទាល់របស់ខ្លួនជាសាធារណៈ** ជាមួយសហគមន៍អន្តរជាតិ។ ការអនុវត្តរបស់រដ្ឋាភិបាល ក្នុងការជះការគំរាមកំហែងដ៏គ្រោតគ្រាត និងការជេរប្រមាថដល់អ្នករិះគន់បរទេស មានតែធ្វើអោយខូចខាតដល់ឋានៈរបស់កម្ពុជា ក្នុងសហគមន៍អន្តរជាតិ។
- រាជរដ្ឋាភិបាលគួរតែប្រកាន់យកជំហាន ដើម្បីធានាថា ការបង្ក្រាបកំពុងតែធ្វើលើសកម្មភាព កាប់ឈើខុសច្បាប់ នឹងមិននាំអោយមានការចាប់ខ្លួន **អ្នកសារព័ត៌មានទាំងឡាយណា ដែលធ្វើការស៊ើបអង្កេតសកម្មភាពនេះស្របតាមច្បាប់ទេ**។

## ឧបសម្ព័ន្ធ១៖ បទបញ្ញត្តិ និងច្បាប់ព្រហ្មទណ្ឌ និងនីតិវិធីព្រហ្មទណ្ឌអនុវត្តក្នុងសម័យអន្តរកាល (ច្បាប់ព្រហ្មទណ្ឌអន្តរកាល) ត្រូវបានប្រើដើម្បីដាក់កម្រិតលើសេរីភាព ក្នុងការបញ្ចេញមតិ

**ការញុះញង់ឲ្យប្រព្រឹត្តិបទឧក្រិដ្ឋដោយបានសម្រេចផល (មាត្រា៥៩ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល)**

| ធាតុផ្សំ | ជាប់ពន្ធនាគារ | ពិន័យជាប្រាក់[១៤១] | ច្បាប់ជំនួស/សំគាល់ |
|---|---|---|---|
| ១) តាមរយៈសន្ទរកថា តាមសម្រែក ឬការគំរាមកំហែង បន្ទរឡើងក្នុងកន្លែងនានា ឬក្នុងទីប្រជុំជនសាធារណៈ តាមការសរសេរ ការបោះពុម្ព គំនូរ ចម្លាក់ វិចិត្រកម្ម និម្មិតរូប រូបភាព ឬគ្រប់ការគាំទ្រនៃការសរសេរ សំដី ឬរូបភាពដែលដាក់លក់ ឬដាក់តាំងនៅកន្លែងនានា ឬក្នុងទីប្រជុំជនសាធារណៈ តាមផ្ទាំងបដា ឬបណ្ណប្រកាសដែលតាំងឲ្យសាធារណៈជនឃើញតាមគ្រប់មធ្យោបាយទំនាក់ទំនងសោតទស្សន៍<br>២) បានបង្កដោយផ្ទាល់ ឲ្យមនុស្សម្នាក់ ឬច្រើននាក់ ប្រព្រឹត្តអំពើដូចពោលខាងលើនេះ បើការញុះញង់នោះបានសម្រេចផល។ លក្ខន្តិកៈនេះអាចអនុវត្តបានដែរ កាលណាការញុះញង់នោះបានផលត្រឹមតែការប៉ុនប៉ងប្រព្រឹត្តអំពើឧក្រិដ្ឋប៉ុណ្ណោះ។ | មាន (បង្កើតភាពទទួលខុសត្រូវ ក្នុងនាមជាអ្នកសមគំនិត ចំពោះបទឧក្រិដ្ឋជាមូលដ្ឋាន ឬការប៉ុនប៉ងប្រព្រឹត្តិបទឧក្រិដ្ឋ) | មាន (អាស្រ័យតាមបទឧក្រិដ្ឋជាមូលដ្ឋាន) | មាត្រា ៤៩៥ |

[១៤១] ច្បាប់ព្រហ្មទណ្ឌអន្តរកាល តម្រូវឲ្យបង់ផាកពិន័យបន្ថែម ឬជំនួសឲ្យថេរវេលាជាប់ពន្ធនាគារ

**ការញុះញង់ឲ្យប្រព្រឹត្តបទល្មើសឧក្រិដ្ឋ និងមជ្ឈឹមដោយពុំបានសម្រេចផល (មាត្រា ៦០ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល)**

| ធាតុផ្សំ | ជាប់ពន្ធនាគារ | ពិន័យជាប្រាក់ | ច្បាប់ជំនួស /សំគាល់ |
|---|---|---|---|
| ១) ញុះញង់ដោយផ្ទាល់ឲ្យមានបទឧក្រិដ្ឋ ឬ មជ្ឈឹម<br>២) ក្នុងករណីដែលការញុះញង់នោះពុំបានសម្រេចផល<br>៣) តាមមធ្យោបាយណាមួយដែលមានចែងក្នុងមាត្រា ៥៩២)បានបង្កដោយផ្ទាល់ ឲ្យមនុស្សម្នាក់ ឬច្រើននាក់ប្រព្រឹត្តអំពើដូចពោលខាងលើនេះ បើការញុះញង់នោះបានសម្រេចផល។ លក្ខន្តិក: នេះអាចអនុវត្តបានដែរ កាលណាការញុះញង់នោះ បានផលត្រឹមតែការប៉ុនប៉ងប្រព្រឹត្តអំពើឧក្រិដ្ឋប៉ុណ្ណោះ។ | មាន (ត្រូវផ្តន្ទាទោសដាក់គុកពី ១ ឆ្នាំ ដល់ ៥ ឆ្នាំ) | មិនដាក់លាក់ | មាត្រា៩៥ |

**ការញុះញង់ឲ្យមានការរើសអើង (មាត្រា ៦១នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល)**

| ធាតុផ្សំ | ជាប់ពន្ធនាគារ | ពិន័យជាប្រាក់ | ច្បាប់ជំនួស /សំគាល់ |
|---|---|---|---|
| ១) ញុះញង់ឲ្យមានសម្អប់ជាតិ ពូជសាសន៍ ឬសាសនា<br>២) ដែលជាការញុះញង់ឲ្យមានការរើសអើង អរិភាព ឬហឹង្សា<br>៣) តាមមធ្យោបាយណាមួយដូចមានចែងក្នុងមាត្រា ៥៩ | ត្រូវផ្តន្ទាទោសពី១ខែ ដល់ ១០ ឆ្នាំ | ពី ១ លានរៀល ដល់ ១០លាន រៀល | មាត្រា៩៦ |

**ការផ្សាយព័ត៌មានមិនពិត (មាត្រា៦២ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល)**

| ធាតុផ្សំ | ជាប់ពន្ធនាគារ | ពិន័យជាប្រាក់ | ច្បាប់ជំនួស /សំគាល់ |
|---|---|---|---|
| ១) ការចុះផ្សាយ ការផ្សព្វផ្សាយ ឬការផ្សាយបន្តតាមមធ្យោបាយណាក៏ដោយ<br>២) នូវព័ត៌មានមិនពិត ព័ត៌មានប្រឌិត ព័ត៌មានក្លែងក្លាយ ឬដោយកុហកទម្លាក់កំហុស ដោយអសុទ្ធចិត្តទៅលើជនទីបី<br>៣) ក្នុងគោលបំណងបំផ្លិចបំផ្លាញ<br>៤) ធ្វើឲ្យកើតកោលាហលដល់សន្តិសុខសាធារណៈ ឬអាចបណ្តាលឲ្យកើតកោលាហលដល់សន្តិសុខសាធារណៈ | ត្រូវផ្តន្ទាទោសពី៦ខែ ដល់ ៣ឆ្នាំ) | ពី១លាន រៀល ដល់ ១០ លាន រៀល | ទោះបីជាយ៉ាងណាក៏ដោយការបង្វែច ឈ្មោះ មាត្រា ៤៩៥ (បទញុះញង់ឲ្យ ប្រព្រឹត្តបទឧក្រិដ្ឋ) បានអនុញ្ញាតិឲ្យមានការកាត់ទោសចំពោះបទល្មើសស្រដៀងគ្នានេះ។ តាមពិត មាត្រា ៤៩៥ ប្រហែងជាអាចធ្វើការកាត់ទោសងាយស្រួលជាង ពីព្រោះបទបញ្ញត្តិនេះពុំមានការទាមទារណាមួយដែលថា ព័ត៌មានមិនពិត ព័ត៌មានប្រឌិត ឬព័ត៌មានក្លែងក្លាយ និងការផ្សព្វផ្សាយ មានគោល |

បំណងបំផ្លិចបំផ្លាញ
នោះទេ

មាត្រា ៤៩៥ គ្រាន់តែ
កំណត់ថា មនុស្សម្នាក់
(១)ញុះញង់ដោយ
ផ្ទាល់ឲ្យប្រព្រឹត្តបទ
ឧក្រិដ្ឋ ឬអំពើណាមួយ
ដែលបង្កឲ្យកើតមាន
កោលាហលធ្ងន់ធ្ងរក្នុង
សង្គម (២) តាមរយៈ ក)
សន្ទរកថាដែលបានធ្វើ
ឡើងក្នុងកន្លែងសាធារ
ណៈឬក្នុងទីប្រជុំជនសា
ធារណៈ ខ) តាមការសរ
សេរ ឬគំនូរ ទោះជា
ប្រភេទណាក៏ដោយ
ដែលផ្សព្វផ្សាយនៅក្នុង
ចំណោមសាធារណជន
ឬដាក់តាំងឲ្យសាធារណ
ជនមើល គ) ការទំនាក់
ទំនងសោតទស្សន៍ដល់

សាធារណ:ជន។

មាត្រា ៦២ ការបង្កឲ្យកើតកោលាហលដល់សន្តិសុខសាធារណ: ត្រូវបានតុលាការឲ្យអន្តន័យយ៉ាងទូលំទូលាយ នៅពេលធ្វើការស្រាយបំភ្លឺករណីសិក្សាមួយចំនួននៅក្នុងរបាយការណ៍។ ឃ្លាកោលាហលធ្ងន់ធ្ងរ នៅក្នុងមាត្រា ៤៩៥ នៃក្រមព្រហ្មទណ្ឌថ្មីនេះ ទំនងជាងាយពេកក្នុងការបកប្រែទូលំទូលាយបែបនេះ

**ការបរិហារកេរ្តិ៍ និងការជេរប្រមាថ (មាត្រា ៦៣ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល)**

| ធាតុផ្សំ | ជាប់ពន្ធនាគារ | ពិន័យជាប្រាក់ | ច្បាប់ជំនួស /សំគាល់ |
|---|---|---|---|
| **ការបរិហារកេរ្តិ៍:**<br>១) គ្រប់ការពោលអះអាង ឬគ្រប់ការទំលាក់កំហុសដោយអសុទ្ធចិត្ត នូវអំពើជាកំណត់ណាមួយ<br>២) ដែលប៉ះពាល់ដល់កិត្តិយស ឬកេរ្តិ៍ឈ្មោះរបស់បុគ្គលឯកជន អំពើដែលនាំឲ្យកើតសៅហ្មងដល់ជននោះ គឺចាត់ជាការបរិហាកេរ្តិ៍<br>**ការជេរប្រមាថ:**<br>១) គ្រប់ពាក្យជេរប្រមាថធ្ងន់ៗ ពាក្យមើលងាយ<br>២) ឬពាក្យជេរដែលគ្មានការទម្លាក់កំហុសទៅលើអំពើណាមួយ គឺជាការជេរប្រមាថ | គ្មាន (លើកលែងតែមិនបង់ប្រាក់ពិន័យ: ចាប់ពី ៦ ខែឡើងទៅ ត្រូវបង់ ១០ លានរៀល និងរយៈពេលជាប់ពន្ធនាគារយូរបំផុត ២ឆ្នាំ បើសិនជាបង់ប្រាក់ពិន័យឬសំណង ៥០ លានរៀល ឬច្រើន) | ពី ១លានរៀល ដល់ ១០លានរៀល (ចំពោះបទបរិហាកេរ្តិ៍ ដែលធ្វើឡើងតាមមធ្យោបាយណាមួយ ដូចមានចែងក្នុងមាត្រា ៥៩ ឧទាហរណ៍ សន្ទរកថា នៅទីប្រជុំជនសាធារណៈតាមរយៈការសរសេរ និងការផ្សព្វផ្សាយ | មាត្រា ៣០៥(បទបរិហារកេរ្តិ៍) និងមាត្រា ៣០៧ (បទជេរប្រមាថ) |

□□□

# ឧបសម្ព័ន្ធ ២៖ បទបញ្ញត្តិនៃក្រមព្រហ្មទណ្ឌថ្មីដែលអាចត្រូវបានប្រើដើម្បីដាក់កម្រិតលើសេរីភាពក្នុងការបញ្ចេញមតិ

**បទបរិហារកេរ្តិ៍ជាសាធារណៈ (មាត្រា ៣០៥))**

| ធាតុផ្សំ | ជាប់ពន្ធនាគារ[១៤២] | ពិន័យជាប្រាក់ | សំគាល់ និងការដាក់ទណ្ឌកម្មបន្ថែម |
|---|---|---|---|
| ១) គ្រប់ការអះអាងបំផ្លើស ឬការទំលាក់កំហុសដោយអសុទ្ធចិត្តលើអំពើណាមួយ<br>២) ដែលនាំឲ្យប៉ះពាល់ដល់កិត្តិយស ឬកិត្តិស័ព្ទនៃបុគ្គល ឬនៃស្ថាប័ន គឺជាការបរិហាកេរ្តិ៍<br>៣) តាមមធ្យោបាយណាមួយដូចតទៅ ក) តាមសំដីទោះជាប្រភេទណាក៏ដោយ ដែលបញ្ចេញនៅទីសាធារណៈ ឬនៅក្នុងសាលប្រជុំសាធារណៈ ខ) តាមលិខិត ឬគំនូរ ទោះជាប្រភេទណាក៏ដោយដែលផ្សព្វផ្សាយនៅទីសាធារណៈ នៅក្នុងចំណោមសាធារណជន ឬដាក់តាំងឲ្យសាធារណជនមើល គ) តាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍សម្រាប់សាធារណជន | គ្មាន | ពី ១០ម៉ឺន ទៅ១០ លាន រៀល | សម្រាប់បទបរិហាកេរ្តិ៍លើមន្ត្រីរដ្ឋាភិបាល មន្ត្រីរាជការ ឬប្រជាពលរដ្ឋដែលទទួលអាណត្តិសាធារណៈ ការចោទប្រកាន់នឹងត្រូវធ្វើឡើងទៅតាមបណ្តឹងរបស់ពួកគេ ឬ បណ្តឹងរបស់ក្រសួងដែលពាក់ព័ន្ធនៅក្នុងករណីបរិហារកេរ្តិ៍លើប្រជាពលរដ្ឋធម្មតា |

[១៤២] គ្រប់ប្រាក់ពិន័យទាំងអស់ដែលបានកំណត់បញ្ជីក្នុងផ្នែកនេះ គឺតម្រូវដោយច្បាប់ និងប្រមូលពន្ធបន្ថែមចំពោះការបម្រើទោសក្នុងពន្ធនាគារ។ នេះជាច្រកចេញមួយបន្ថែមពីច្បាប់ព្រហ្មទណ្ឌ អន្តរកាល ដែលផ្តល់ឲ្យចៅក្រមនូវជម្រើសក្នុងការផ្សព្វផ្សាយប្រាក់ពិន័យ ប៉ុន្តែមិនចាំបាច់។ នេះមានសារសំខាន់ណាស់ដែលក្រមនិតិវិធីព្រហ្មទណ្ឌអនុញ្ញាតិឲ្យជាប់ពន្ធនាគារបន្ថែមពីរឆ្នាំចំពោះការមិនបង់ប្រាក់ពិន័យ។ លើសពីនេះទៀត ប្រាក់ពិន័យនៅមានសុពលភាព បន្ទាប់ពីបម្រើទោស រួច។ ជននោះមិនអាចត្រូវបានជាប់ពន្ធនាគារម្តងទៀតឡើយ ប៉ុន្តែគេនៅតែបង់ប្រាក់ពិន័យ។

ការចោទប្រកាន់នឹងអាចធ្វើទៅបានអាស្រ័យលើបណ្ដឹងរបស់អ្នកដែលត្រូវបានគេបរិហារកេរ្តិ៍ប៉ុណ្ណោះ។ ទោះជាយ៉ាងណាក៏ដោយ ការចោទប្រកាន់អាចធ្វើទៅបានដោយព្រះរាជអាជ្ញា ប្រសិនបើការបរិហារកេរ្តិ៍ត្រូវបានប្រព្រឹត្តទៅលើជនជាតិដើមភាគតិច ប្រទេសជាតិពូជសាសន៍ ឬសាសនា។

ឃ្លា

***ផ្សព្វផ្សាយក្នុងចំណោមសាធារណជន***

បញ្ជាក់ថា បុគ្គលនោះអាចប្រឈមនឹងការប្ដឹងចោទប្រកាន់រឿងព្រហ្មទណ្ឌចំពោះការធ្វើអត្តាធិប្បាយផ្ទាល់ខ្លួន ដែល

| | | | |
|---|---|---|---|
| | | | ក្រោយមកត្រូវបានផ្សព្វផ្សាយក្នុងចំណោមសាធារណជនដោយមិនបានដឹង ឬយល់ព្រមពីសាមីខ្លួន។ ឃ្លានេះត្រូវបានគេប្រើឡើងវិញក្នុងក្រមព្រហ្មទណ្ឌទាំងមូល |
| **បទជេរប្រមាថជាសាធារណៈ:(មាត្រា៣០៧)** | | | |
| **ធាតុផ្សំ** | **ជាប់ពន្ធនាគារ** | **ពិន័យជាប្រាក់** | **សំគាល់ និងការដាក់ទណ្ឌកម្មបន្ថែម** |
| ១) គ្រប់ពាក្យប្រមាថ គ្រប់ពាក្យមើលងាយ ឬគ្រប់ពាក្យទ្រគោះ<br>២) ដែលគ្មានការទំលាក់កំហុសទៅលើអំពើណាមួយ<br>៣) ប្រព្រឹត្តឡើងតាមមធ្យោបាយដូចតទៅ ក) តាមពាក្យសំដី ទោះជាប្រភេទណាក៏ដោយ ដែលបញ្ចេញនៅទីសាធារណៈ ឬនៅក្នុងពេលប្រជុំសាធារណៈ ខ) តាមលិខិត ឬគំនូរ ទោះជាប្រភេទណាក៏ដោយ ដែលផ្សព្វផ្សាយនៅក្នុងចំណោមសាធារណជន ឬដាក់តាំងឲ្យសាធារណជនមើល គ)តាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍សម្រាប់សាធារណជន | គ្មាន | ពី ១០ម៉ឺន ទៅ ១០លានរៀល | ចូរមើល ចំនុចសំគាល់ ***ផ្សព្វផ្សាយនៅក្នុងចំណោមសាធារណជន*** ខាងលើឡើងវិញ |

**បទប្តឹងបរិហារបង្កាច់កេរ្តិ៍ (មាត្រា៣១១)**

| ធាតុផ្សំ | ជាប់ពន្ធនាគារ | ពិន័យជាប្រាក់ | សំគាល់ និងទណ្ឌកម្មបន្ថែម |
|---|---|---|---|
| ១) ការប្តឹងបរិហាបង្កាច់កេរ្តិ៍ គឺជាអំពើប្តឹងបរិហាអំពីអំពើដែលគេដឹងថា មិនពិត<br>២) ហើយដែលនាំឲ្យមានទណ្ឌកម្មព្រហ្មទណ្ឌ ឬវិន័យ<br>៣) កាលបើការប្តឹងបរិហារនេះ ត្រូវបានផ្ញើរទៅដល់អាជ្ញាធរមានសមត្ថកិច្ចដើម្បីចាត់វិធានការណ៍ (ដូចជា ចៅក្រម មន្ត្រីនគរបាលយុត្តិធម៌ ឬនិយោជក) ឬបុគ្គលដែលមានអំណាចប្តឹងទៅអាជ្ញាធរមានសមត្ថកិច្ច។ | ពី ១ ខែ ដល់ ១ឆ្នាំ | ពី ១០ ម៉ឺនរៀល ដល់ ២លានរៀល | ការប្តឹងចោទប្រកាន់ត្រូវធ្វើឡើងក្នុងអំឡុងពេល ១ឆ្នាំ បន្ទាប់ពីថ្ងៃដែលអាជ្ញាធរមានសមត្ថកិច្ចទទួលបានពាក្យបណ្តឹង ឬថ្ងៃដែលប្តឹង។<br><br>នៅក្នុងករណីដែលការប្តឹងបរិហារបង្កាច់កេរ្តិ៍នាំអោយមានការចោទប្រកាន់ខាងព្រហ្មទណ្ឌនីតិវិធីផ្តើមការចោទប្រកាន់នោះ នាំអោយផ្អាកអាជ្ញាយុកាលរហូតដល់ពេលបញ្ចប់កិច្ចចោទប្រកាន់។ |

| បទញុះញង់ឲ្យប្រព្រឹត្តបទឧក្រិដ្ឋជាអាទិ៍(មាត្រា៤៩៥) | | | |
|---|---|---|---|
| **ធាតុផ្សំ** | **ជាប់ពន្ធនាគារ** | **ពិន័យជាប្រាក់** | **សំគាល់/ការដាក់ទណ្ឌកម្មបន្ថែម** |
| ១) អំពើញុះញង់ដោយផ្ទាល់ឲ្យប្រព្រឹត្តបទឧក្រិដ្ឋ ឬប្រព្រឹត្តអំពើបង្កឲ្យកើតមានភាពវិកវរធ្ងន់ធ្ងរដល់សន្តិសុខសង្គម<br>២) តាមមធ្យោបាយណាមួយ ក) តាមពាក្យសំដី ទោះជាប្រភេទណាក៏ដោយ ដែលបញ្ចេញនៅទីសាធារណៈ ឬនៅក្នុងពេលប្រជុំសាធារណៈ ខ) តាមលិខិត ឬគំនូរ ទោះជាប្រភេទណាក៏ដោយ ដែលផ្សព្វផ្សាយនៅក្នុងចំណោមសាធារណជន ឬដាក់តាំងឲ្យសាធារណជនមើល គ) តាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍សម្រាប់សាធារណជន | ពី ៦ខែ ដល់ ២ឆ្នាំ (ចំពោះអំពើញុះញង់ឲ្យប្រព្រឹត្តបទឧក្រិដ្ឋដែលមិនបានសម្រេចផល)<br><br>អំពើញុះញង់ឲ្យប្រព្រឹត្តបទឧក្រិដ្ឋដែលបានសំរេចផលត្រូវផ្តន្ទាទោសដូចគ្នាទៅនឹងបទឧក្រិដ្ឋដែលត្រូវបានប្រព្រឹត្ត (និយមន័យនៃអ្នកផ្តើមគំនិត មាត្រា២៨ ក្រមព្រហ្មទណ្ឌ)<br><br>ពី ២ឆ្នាំ ដល់ ៥ឆ្នាំ (ចំពោះអំពើញុះញង់ឲ្យ | ពី ១លានរៀល ដល់៤លានរៀល ( ចំពោះអំពើញុះញង់ឲ្យប្រព្រឹត្តបទឧក្រិដ្ឋដែលមិនបានសម្រេចផល) | ការដាក់ទណ្ឌកម្មបន្ថែមរួមបញ្ចូលទាំងការព្យួរសិទ្ធិពលរដ្ឋដោយមិនកំណត់ពេលវេលាជាក់លាក់។ អង្គការលីកាដូមានការព្រួយបារម្ភថាសិទ្ធិទាំងនេះរួមមានសិទ្ធិចូលរួមក្នុងការបោះឆ្នោត សិទ្ធិក្នុងការថ្លែងសន្ទរកថា ជាសាធារណៈ សិទ្ធិក្នុងការដើរហើរ និងសិទ្ធិដទៃទៀត។<br><br>អំពើញុះញង់ក្រោមច្បាប់ព្រហ្មទណ្ឌអន្តរកាលកំណត់យ៉ាងច្បាស់ថាជាបទឧក្រិដ្ឋ ឬប៉ុនប៉ង |

| | | | |
|---|---|---|---|
| | ប្រព្រឹត្តបទឧក្រិដ្ឋ)[១៤៣] | | ប្រព្រឹត្តបទឧក្រិដ្ឋ (ឬការមានចេតនាច្បាស់លាស់ក្នុងការញុះញង់ឲ្យប្រព្រឹត្តបទឧក្រិដ្ឋ)។<br><br>ក្រមព្រហ្មទណ្ឌថ្មីនេះតំរូវឲ្យមានត្រឹមតែអំពើញុះញង់បង្កឲ្យកើតមានកោលាហលក្នុងសង្គមតែប៉ុណ្ណោះ។ វិធីនេះវាស្រដៀងនឹងបទបញ្ញត្តិពីមុនដែលចែងអំពីបទផ្សាយព័ត៌មានមិនពិតដែលកំណត់ថាជាបទល្មើសព្រហ្មទណ្ឌនូវសកម្មភាពមួយចំនួនដែលបណ្តាលឲ្យកើតកោលាហលដល់សន្តិសុខសាធារណៈ |

[១៤៣] ពុំមានខចែងអំពីការចាប់ដាក់ពន្ធនាគារចំពោះ *អំពើញុះញង់ឲ្យប្រព្រឹត្តបទឧក្រិដ្ឋ ( ឬអំពើញុះញង់ដែលបានសម្រេចផល)* ត្រូវបានផ្តល់ឲ្យនៅក្នុងការបកស្រាយភាសាខ្មែរចុងក្រោយនៃក្រមនេះតាមដែលយើងទទួលបាន។ ការដាក់ទណ្ឌកម្មនេះ គឺយកចេញពីការបកស្រាយជាភាសាបារាំងមុន។ ក្រមនេះមិនទាន់ត្រូវបានបកប្រែជាភាសាអង់គ្លេសនៅឡើយទេ។ ចូរកត់ចំនាំថា ការបកប្រែជាភាសាខ្មែរចុងក្រោយនៃក្រមនេះបង្ហាញពីការពិន័យជាប្រាក់ដោយឡែកពីគ្នា ចំពោះបទញុះញង់ឲ្យប្រព្រឹត្តបទឧក្រិដ្ឋ និងបទញុះញង់ឲ្យប្រព្រឹត្តបទឧក្រិដ្ឋដែល

| | | | |
|---|---|---|---|
| | | | (ចូរមើលក្រមព្រហ្មទណ្ឌ អន្តរកាល មាត្រា ៦២) |
| **បទញុះញង់ឲ្យមានការរើសអើង (មាត្រា ៤៩៦)** | | | |
| **ធាតុផ្សំ** | **ជាប់ពន្ធនាគារ** | **ពិន័យជាប្រាក់** | **សំគាល់/ការដាក់ទណ្ឌកម្មបន្ថែម** |
| ១) អំពើញុះញង់ដោយផ្ទាល់តាមមធ្យោបាយណាមួយ ឲ្យប្រព្រឹត្តការរើសអើង ការគុំគួន ឬហិង្សាចំពោះបុគ្គលណាម្នាក់ ឬក្រុមណាមួយ ដោយមូលហេតុបុគ្គលនេះ ជាសមាជិក ឬមិនមែនជាសមាជិកនៃជាតិពិន្ទុ ក្រុមជាតិ ពូជសាសន៍ ឬនៃសាសនាណាមួយជាកំណត់នោះ<br>២) តាមមធ្យោបាយណាមួយ ក) តាមពាក្យសំដី ទោះជាប្រភេទណាក៏ដោយ ដែលបញ្ចេញនៅទីសាធារណៈ ឬនៅក្នុងពេលប្រជុំសាធារណៈ ខ) តាមលិខិត ឬគំនូរ ទោះជាប្រភេទណាក៏ដោយ ដែលផ្សព្វផ្សាយនៅក្នុងចំណោមសាធារណជន ឬដាក់តាំងឲ្យសាធារណជនមើល គ)តាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍សម្រាប់សាធារណជន | ពី១ ឆ្នាំ ដល់ ៣ឆ្នាំ (អំពើញុះញង់ដែលមិនបានសម្រេចផល) | ពី២លានរៀល ដល់ ៦លានរៀល (អំពើញុះញង់ដែលមិនបានសម្រេចផល) | ការដាក់ទណ្ឌកម្មបន្ថែម: ដូចគ្នានឹងមាត្រា ៤៩៥ ទាំងក្រមភាសាខ្មែរ និងក្រមភាសាបារាំង បញ្ជាក់ពីការដាក់ទណ្ឌកម្មចំពោះបទញុះញង់ដែលមិនបានសម្រេចផល។ពុំមានការកំណត់អំពីការដាក់ទណ្ឌកម្មចំពោះបទញុះញង់ដែលបានសម្រេចផល។<br><br>មានបញ្ហាស្មុគស្មាញបន្ថែមទៀត ការកាត់ឲ្យ |

ជាប់ទោសក្រោមមាត្រា ៤៩៦ មិនតម្រូវឲ្យមានការប្រព្រឹត្តបទឧក្រិដ្ឋដូច្នេះ ពុំមានការរៀបរាប់ច្បាស់លាស់រវាងនូវអ្វីជាអំពើញុះញង់ឲ្យប្រព្រឹត្តការរើសអើងពូជសាសន៍ដែលសម្រេចផល និងមិនសម្រេចផល។ មាត្រានេះមិនបញ្ជាក់ច្បាស់ពីធាតុផ្សំចំពោះបទឧក្រិដ្ឋទាំងពីរនេះ។

មានសញ្ញាមួយស្ថិតនៅមាត្រានេះ ឧទាហរណ៍ការតម្រូវថាជនត្រូវចោទត្រូវតែជាអ្នកបង្កឲ្យមានការរើសអើង ការគុំកួន ឬហិង្សា។ ការរើសអើងនិងហិង្សា
គឺជាព្រឹត្តិការណ៍ច្បាស់លាស់ និងដែលអាច

| | | | |
|---|---|---|---|
| | | | មើលឃើញ។ ការគុំកួន គឺមិនដូច្នេះទេ ហើយ អាចចាត់ទុកថាជាបទញុះញង់ឲ្យប្រព្រឹត្តការរើសអើងពូជសាសន៍ដែលមិនបានសម្រេចផល។ វានៅតែមិនច្បាស់ថា តើតុលាការនឹងសម្រេចយ៉ាងណាអំពីជនត្រូវចោទ ដែលញុះញង់ឲ្យមានការគុំកួនដែលជាការឆ្លើយតបដោយអារម្មណ៍។ |

**បទប្រមាថ (មាត្រា ៥០២)**

| ធាតុផ្សំ | ជាប់ពន្ធនាគារ | ពិន័យជាប្រាក់ | សំគាល់/ការដាក់ទណ្ឌកម្មបន្ថែម |
|---|---|---|---|
| ១) ការប្រមាថ គឺជាវាចា កាយវិការ សំណេរ គំនូរ ឬវត្ថុដែលប៉ះពាល់ដល់សេចក្ដីថ្លៃថ្នូរនៃបុគ្គល<br>២) ការប្រមាថចំពោះអ្នករាជការសាធារណៈ ឬចំពោះពលរដ្ឋទទួលអាណត្តិសាធារណៈដោយការបោះឆ្នោតនៅក្នុងក្របខ័ណ្ឌនៃមុខងារ ឬនៅក្នុងឱកាសនៃការបំពេញមុខងាររបស់ខ្លួន | ពី ១ថ្ងៃ ដល់ ៦ថ្ងៃ | ពី១ពាន់រៀល ដល់ ១០ ម៉ឺនរៀល | ធាតុផ្សំនៃបទឧក្រិដ្ឋនេះ មានលក្ខណៈស្រពិចស្រពិលមិនច្បាស់ និង |

អត្តនោម័តិ ដែលអាចធ្វើឲ្យមាត្រានេះកាន់តែតឹងរឹងទៅៗ ជាពិសេសធ្វើឲ្យការប្រព្រឹត្តទាំងឡាយដែលប៉ះពាល់ដល់អារម្មណ៍របស់មន្ត្រីរាជការសាធារណៈក្លាយជាបទល្មើសព្រហ្មទណ្ឌ។

អង្គការលីកាដូ មានការព្រួយបារម្ភថាខចែងនេះអាចត្រូវបានប្រើប្រាស់ក្នុងការបណ្តេញចេញពីដីធ្លីដើម្បីឃុំខ្លួនក្នុងរយៈពេលខ្លីលើសកម្មជនសហគមន៍ ដែលបានជេរប្រមាថដល់នគរបាលដែលព្យាយាមបណ្តេញពួកគេ អំឡុងពេលដីធ្លីរបស់ពួកគេត្រូវបានរឹបអូស។

**បទផ្សព្វផ្សាយនូវការអត្ថាធិប្បាយដើម្បីធ្វើសម្ពាធលើយុត្តាធិការ (មាត្រា ៥២២)**

| ធាតុផ្សំ | ជាប់ពន្ធនាគារ | ពិន័យជាប្រាក់ | សំគាល់/ការដាក់ទណ្ឌកម្មបន្ថែម |
|---|---|---|---|
| ១) ការផ្សាព្វផ្សាយមុនសេចក្តីសម្រេចជាស្ថាពររបស់តុលាការ នូវអត្ថាធិប្បាយ<br>២) ដោយមានគោលដៅធ្វើការគាបសង្កត់ទៅលើតុលាការ ដែលទទួលបណ្តឹង ដើម្បីជះឥទ្ធិពលទៅលើសេចក្តី សម្រេចរបស់តុលាការ | ពី១ខែ ដល់ ៦ ខែ | ពី ១០ម៉ឺនរៀល ដល់ ១លានរៀល | ការដាក់ទោសបន្ថែមរួមទាំងការព្យួរសិទ្ធិពលរដ្ឋដោយមិនកំណត់ពេលវេលា។ អង្គការលីកាដូមានការព្រួយបារម្ភថាសិទ្ធិទាំងនេះរួមមានសិទ្ធិចូលរួមការបោះឆ្នោត សិទ្ធិក្នុងការថ្លែងសន្ទរកថាជាសាធារណៈ សិទ្ធិក្នុងការដើរហើរ និងសិទ្ធិផ្សេងទៀត។<br><br>ការដាក់ទណ្ឌកម្មបន្ថែមផ្សេងទៀតរួមមាន: ១) ការបណ្តេញចេញពីការងារប្រសិនបើបទឧក្រិដ្ឋនោះបានកើតឡើងក្នុង |

អំឡុងពេលបំពេញមុខងាររបស់ខ្លួន និង២) ការរឹបអូសយកឧបករណ៍សម្ភារៈ ឬវត្ថុណាមួយដែលផ្តល់ឲ្យសម្រាប់ការប្រព្រឹត្តបទឧក្រិដ្ឋ។ អង្គការលីកាដូ មានការព្រួយបារម្ភថា ច្បាប់នេះអាចត្រូវបានប្រើប្រាស់ដើម្បីបណ្តេញគ្រូបង្រៀន មេធាវី អ្នកសារព័ត៌មាន និងអ្នកប្រកបវិជ្ជាជីវៈផ្សេងទៀតដោយមិនត្រឹមត្រូវចេញពីការងាររបស់ពួកគេ។ ខចែងអំពីការរឹបអូសអាចនាំឲ្យមានការរឹបអូសយកសម្ភារៈដូចជា: ឧបករណ៍កុំព្យូទ័រ យានជំនិះ ម៉ាស៊ីនបោះពុម្ព និងទ្រព្យសម្បត្តិទាំងឡា

យណាដែលជាកម្មសិទ្ធិ
របស់ជនត្រូវចោទ។

ខថែងនេះអាចបណ្ដាល
ឲ្យទៅជាបទឧក្រិដ្ឋដ៏
មានប្រសិទ្ធិភាពចំពោះ
សកម្មភាពតស៊ូមតិជា
សាធារណៈរបស់អង្គការ
មិនមែនរដ្ឋាភិបាល និង
ស្ថាប័នដទៃទៀត ដែល
ជារឿយៗចេញសេចក្ដី
ថ្លែងការណ៍ទាក់ទងទៅ
នឹង ការជាប់ឃុំរង់ចាំ
សវនាការ។

**បទធ្វើឲ្យបាត់ជំនឿលើសេចក្តីសម្រេចរបស់តុលាការ (មាត្រា ៥២៣)**

| ធាតុផ្សំ | ជាប់ពន្ធនាគារ | ពិន័យជាប្រាក់ | សំគាល់/ការដាក់ទណ្ឌកម្មបន្ថែម |
|---|---|---|---|
| ១) អំពើរិះគន់លិខិត ឬសេចក្តីសម្រេចរបស់តុលាការ<br>២) ក្នុងគោលបំណងបង្កឲ្យមានភាពរឹករវដល់សណ្តាប់ធ្នាប់សាធារណៈ ឬក៏បង្កឲ្យមានគ្រោះថ្នាក់ដល់ស្ថាប័ននៃព្រះរាជាណាចក្រកម្ពុជា | ពី ១ខែ ដល់ ៦ខែ | ពី ១០ ម៉ឺនរៀល ដល់ ១លានរៀល | ការដាក់ទណ្ឌកម្មបន្ថែម: ដូចគ្នានឹងមាត្រា ៥២២<br><br>ខចែងនេះមានគោលដៅធ្វើឲ្យអំពើរិះគន់សេចក្តីសម្រេចរបស់តុលាការទៅជាបទល្មើសព្រហ្មទណ្ឌ។<br><br>ការចែងដែលកំណត់ថាសេចក្តីថ្លែងការណ៍ដែលបង្កឲ្យមានភាពរឹករវដល់សណ្តាប់ធ្នាប់សាធារណៈ ឬក៏បង្កឲ្យគ្រោះថ្នាក់ដល់ស្ថាប័ននៃព្រះរាជាណាចក្រកម្ពុជា គឺមានលក្ខណៈស្រពិចស្រពិលក្រៃលែង និង |

ងាយនឹងប្រើប្រាស់ដោយតុលាការ

និយមន័យនៃពាក្យលិខិតរបស់តុលាការ គឺមិនច្បាស់លាស់ ប៉ុន្តែវាផ្សេងពីសេចក្តីសម្រេចរបស់តុលាការកំណត់បញ្ជី ដោយឡែកពីគ្នា។ យើងខ្ញុំមានការព្រួយបារម្ភថា តុលាការនឹងពន្លាតខចែងនេះដើម្បីរួមបញ្ចូលនូវអ្វីៗគ្រប់យ៉ាងដែលតុលាការចង់ធ្វើ ហេតុដូច្នេះហើយអំពើរិះគន់តុលាការនឹងក្លាយទៅរឿងព្រហ្មទណ្ឌ។ ក្រោមការបកស្រាយបែបនេះ បេសកជនពិសេសរបស់អង្គការសហប្រជាជាតិ លោក

| | | | |
|---|---|---|---|
| | | | ស្វ៊ីរីយ៉ា ស្វ៊ីបេឌី អាចនឹងខុសច្បាប់ ប្រសិនបើគាត់នៅបន្តរិៈគន់តុលាការរបស់ព្រះរាជាណាចក្រកម្ពុជា។ |
| **បទប្តឹងបរិហារដោយភូតកុហកដល់អាជ្ញាធរតុលាការ (មាត្រា៥២៥)** | | | |
| **ធាតុផ្សំ** | **ជាប់ពន្ធនាគារ** | **ពិន័យជាប្រាក់** | **សំគាល់/ការដាក់ទណ្ឌកម្មបន្ថែម** |
| ១) អំពើដែលប្តឹងបរិហារដោយភូតកុហក<br>២) ដល់អាជ្ញាធរតុលាការ ឬអាជ្ញាធររដ្ឋបាល | ពី ១ខែ ដល់ ៦ខែ | ពី ១០ម៉ឺនរៀល ដល់ ១លានរៀល | ការដាក់ទណ្ឌកម្មបន្ថែម: ដូចគ្នានឹងមាត្រា ៥២២ អង្គការលីកាដូមានការព្រួយបារម្ភថា ខចែងនេះនឹងត្រូវបានប្រើប្រាស់ដាក់ទណ្ឌកម្មលើអ្នកដែលលួចខ្សឹបប្រាប់ អំពីអ្នកប្រព្រឹត្តអំពើពុករលួយ ឬ ដាក់ពាក្យបណ្តឹងព្រហ្មទណ្ឌប្រឆាំងអ្នកមានអំណាច ឬចោទប្រកាន់នគរបាល |

ពីបទប្រព្រឹត្តអំពើទារុណកម្មក្នុងអំឡុងពេលសួរចម្លើយ។ ដោយសារតែអំពើពុករលួយនៅតែរីករាលដាលនៅក្នុងប្រព័ន្ធតុលាការកម្ពុជានៅឡើយ។ អំពើប្រព្រឹត្តទាំងនេះសំដែងឲ្យឃើញពីការប្ដឹងបុគ្គលណាមួយឲ្យមានការយកមកកាត់ទោសតាមតែអាចធ្វើទៅបាន៕

http://www.licadho-cambodia.org